
វិជ្ជាប្រាំបីប្រការ
VIJJA PRAMBEI PRAKAR
INSTITUT BOUDDHIQUE
ភ្នំពេញ
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
ព.ស. ២៥៤៥ គ.ស. ២០០១

# វិជ្ជាឆ្នាំបីប្រការ

ឧកញ៉ា **បុណ្ណចន្ទ្រ មន្តល**
ប្រែនិងរៀបរៀង

**ភ្នំពេញ**
ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ
គ.ស. ២០០១

# អារម្ភកថា

សៀវភៅវិជ្ជា ៨ ប្រការ ដែលនឹងកើតឡើង ដោយមានមួយថ្ងៃ ខ្ញុំបានទៅសិក្សាសួរធម៌លោកគ្រូព្រះឧត្តមមុនី អុម-ស៊ូរអធិបតីរងក្រុមជំនុំប្រែព្រះត្រៃបិដក អំពីរឿងវិបស្សនាធុរៈ លោកក៏បានពន្យល់ខ្ញុំរួចហើយ លោកមានពុទ្ធដីកាថា សៀវភៅវិជ្ជា ៨ ប្រការ ដែលហ្លួងវិចិត្រវាទការជាតិសៀមបានតែងនោះ ជាសៀវភៅមានប្រយោជន៍ច្រើនក្នុងពួកវិបស្សានាធុរៈ បើបានប្រែមកជាខ្មែរ ក៏ជាការល្អ នឹងបានជាសៀវភៅជួយគាំទ្រាំវិជ្ជាសមាធិក្នុងផ្លូវវិបស្សនា។ លុះខ្ញុំត្រឡប់មកផ្ទះវិញ បានពិនិត្យមើលសៀវភៅនោះ ទៅ ឃើញមានសេចក្តីអធិប្បាយពន្យល់ពីវិធីវិជ្ជា ៨ ប្រការឲ្យកើតមានឡើង ក្នុងសៀវភៅនោះមាននាំរឿងហេតុដែលកើតមានឡើងក្នុងប្រទេសឯទៀតៗ ហើយត្រូវគ្នានឹងវិជ្ជា ៨ ប្រការនេះ មកបំភ្លឺឲ្យឃើញពិតប្រាកដថែមទៀត។ វិជ្ជា ៨ ប្រការនេះជាសេចក្តីប្រដៅដល់អ្នករៀនកម្មដ្ឋាន កុំឲ្យប្រព្រឹត្តអាក្រក់ដោយចិត្តទុច្ចរិត គឺកុំឲ្យអួតថាខ្លួនមានបុណ្យមានឫទ្ធិ ធ្វើឲ្យមនុស្សជឿទាំងនាំបំបះបំបោរឲ្យកើតចលាចល ដូចដែលធ្លាប់មានក្នុងប្រទេសយើងរឿងៗមកហើយនោះបានឡើយ ព្រោះវិជ្ជានេះសម្រាប់តែមនុស្សសុចរិតប្រព្រឹត្តរកតែផ្លូវស្ងប់ ផ្លូវព្រះនិព្វាននោះទើបសម។ តាមដោយពិនិត្យឃើញរបៀបដែលតែងសៀវភៅវិជ្ជា ៨ ប្រការនេះ លុះតែមនុស្សអ្នកមានព្យាយាមណាស់ ហើយចេះបាលីនឹងភាសាឯទៀតច្រើន ឧស្សាហ៍មើលសៀវភៅនឹងដំណឹងតាមកាសែតដែលមានក្នុងភាសានោះៗទើបតែងបាន។ ម្យ៉ាងទៀត ឯការប្រែភាសាក្នុងផ្ទៃសៀវភៅនេះ ខ្ញុំបានប្រែរៀបរៀងតាមច្បាប់ដើម តែបើត្រង់កន្លែងណាដែលមានសេចក្តីសារដដែលៗនោះខ្ញុំមានកាត់ចេញខ្លះហើយសម្រួល សេចក្តីឲ្យស្រួលស្តាប់ទៅវិញ ។

លុះខ្ញុំបានពិនិត្យរួចហើយ ក៏ទៅពិតលោកគ្រូព្រះឧត្តមមុនី ថានឹង

ទទួលប្រែល្បងមើល ព្រោះក្នុងសៀវភៅនោះនឹងមានសេចក្តីហាមឃាត់ ថាមិនឲ្យប្រែជាភាសាអ្វីៗក៏ទេដែរ។ ខ្ញុំបានសូមឲ្យលោកជួយផ្ទៀងផ្ទាត់ ដម្រែដម្រង់សេចក្តីប្រែព្រមទាំងបាឡី លោកក៏ទទួលជួយហើយលោក បានឲ្យភិក្ខុសង្ឃជួយសរសេរជាថ្មី ថែមទាំងដាក់ឲ្យព្រះមហាថែម នឹងអ្នក អាចារ្យសេនជាក្រុមជំនុំព្រះត្រៃបិដកជួយផ្ទៀតផ្ទាត់ម្តងទៀត រួចហើយខ្ញុំ ក៏បានជូនសៀវភៅនេះ ឲ្យដាក់ទៅជាសម្បត្តិរបស់ព្រះរាជបណ្ណាល័យ កម្ពុជា សម្រាប់បោះពុម្ពផ្សាយ ។

សូមផ្សាយកុសលដែលកើតមកអំពីការប្រែសៀវភៅនេះ ជូនដល់ លោកអ្នកតែង នឹងលោកដែលថ្កើមឲ្យខ្ញុំប្រែ ព្រមទាំងលោកសង្ឃដែល ជួយក្នុងការនេះ សូមឲ្យបានសម្រេចដល់ព្រះនិព្វាន ។ ម្យ៉ាងទៀតកាល បើខ្ញុំមិនទាន់ដល់ព្រះនិព្វាន នៅអន្ទោលជាតិទៅមកក្នុងវដ្តសង្សារនៅ ឡើយ ហើយទៅកើតក្នុងជាតិណាៗនោះ សូមឲ្យខ្ញុំបានជួបតែនឹងលោក សប្បុរស ហើយឲ្យបានចេះគ្រប់ភាសាក្នុងលោក កុំបីឃ្លាតឡើយ ។

**ឧកញ៉ា បុណ្ណចន្ទ្រមង្គល**

**ឧត្តមមន្ត្រីរ៉ៃត្រ**

†††††

†

# សេចក្តីផ្តើមរបស់អ្នករៀបរៀង

អំពីហេតុដែលជឿក្នុងការហោះហើរដើរឯអាកាសបាននោះ មកពីសេចក្តីខ្នះខ្នែងឧស្សាហ៍ព្យាយាមរបស់មនុស្សជាមូល ។ កាលមុនមួយរយឆ្នាំមកនេះ អ្នកណាមួយជឿថា មនុស្សអាចធ្វើយន្តហោះបាន? ដែលធ្វើបាននោះមកពីមនុស្សព្រមយកជីវិតប្តូរក្នុងវិធីធ្វើ ទាល់តែសម្រេចបានឲ្យឃើញប្រាកដនឹងភ្នែកយើងឥឡូវនេះ ក្នុងសម័យនេះមនុស្សព្យាយាមពិនិត្យពិគ្រោះស្វែងរកវិជ្ជាធ្វើគ្រឿងចក្របម៉ាស៊ីនអម្បាលម៉ាណ ក្នុងសម័យបុរាណគេក៏ព្យាយាមរកវិជ្ជាបង្ហាត់ដួងចិត្តដូច្នេះដែរ ដួងចិត្តមនុស្សមានឫទ្ធិអំណាចយ៉ាងណា ក្នុងសម័យនេះយើងមើលមិនឃើញ តែក្នុងសម័យពុទ្ធកាលគេចេះដឹងថាចិត្តដែលបានបង្ហាត់ទម្លាប់ហ្វឹកហ្វឺនយ៉ាងល្អជាបំផុតទៅហើយ ក៏អាចនឹងប្រើធ្វើអ្វីៗបានតាមប្រាថ្នា ដូចមានប្រាកដក្នុងគម្ពីរវិសុទ្ធិមគ្គ ដែលពោលអាងពុទ្ធវាចាថា "ម្នាលភិក្ខុទាំងឡាយតថាគតមិនយល់ឃើញធម៌ណាមួយ ដែលបុគ្គលប្រដៅទូន្មានបានដោយល្អដូចជាចិត្តនោះទេ" ។

អំពីរឿងព្រេងផ្សេងៗដែលមានទាក់ទងនឹង ព្រះពុទ្ធសាសនានោះរឿងទាំងនេះមិនត្រូវសង្ស័យឡើយ គ្រាន់តែរឿងប្រៀបប្រដូច គង់មានពិតខ្លះមិនពិតខ្លះ ព្រោះអ្នកតែងរឿងតម្រាទាំងនោះ គង់មានអ្នកតែងខ្លះលុះដោយអំណាចអគតិធម៌ ជាដង្កូវក្នុងព្រះពុទ្ធសាសនា ព្យាយមរៀបរៀងរឿងដែលមិនពិតមកដាក់ក្នុងព្រះពុទ្ធសាសនា ធ្វើឲ្យទម្ងន់ឬដម្លៃរបស់ព្រះពុទ្ធសាសនាថោកថយជាងសាសនាឯទៀត ហេតុដូច្នេះគួរយើងយកធម្មាធិដ្ឋានមកពិនិត្យមើល ដើម្បីឲ្យចូលចិត្តសេចក្តីពិតដែលជាខ្លឹមរបស់តម្រានោះៗព្រោះតម្រាទាំងនោះមានរឿងខ្លះ តោងយកសេចក្តីបុគ្គលាធិដ្ឋានខ្លះមកប្រៀបធៀបមើលផង បើយកធម្មាធិដ្ឋានតែមួយមក

ពិនិត្យកាត់តម្រាទាំងនោះអស់ មុខជាគម្ពីររបស់ព្រះពុទ្ធសាសនាមិនទ្រាំនៅយូរប៉ុន្មាន ព្រះត្រៃបិដក ៨៤.០០០ ព្រះធម្មក្ខន្ធ ដែលយើងមានចិត្តជឿថាំទុកមកនឹងសល់នៅត្រឹមតែធម្មក្ខន្ធមួយ បើនឹងនិយាយដល់ប្រស្នាដែលជាសំខាន់ដូចជារឿងឥទ្ធិបាដិហារិយ៍នេះ គួរជឿថាជារបស់មានពិតប្រាកដមែន ព្រោះសេចក្ដីយល់ឃើញរបស់ព្រះគន្ថរចនាចារ្យទាំងប៉ុន្មានត្រូវគ្នាជាច្រើន ហើយពួកពុទ្ធសាសនិកជនក៏មានសេចក្ដីជឿជាក់មកជាងពីរពាន់ឆ្នាំហើយ ។

(១) ត្រង់មនោមយិទ្ធិនោះបានពណ៌នាសេចក្ដីសំខាន់ផ្សេងៗទុកជាច្រើន ហើយបាននាំយកសេចក្ដីរបស់អ្នកប្រាជ្ញឥណ្ឌៀពីរនាក់ ម្នាក់ឈ្មោះយោគីរាមចរកៈ ម្នាក់ទៀតឈ្មោះស្វាមិភក្ត្រវិសិតៈ ដែលបានសរសេររៀបរៀងទុកក្នុងតម្រាវិជ្ជាវេទមន្តនឹងរឿងរក្សារោគដោយអំណាច ដួងចិត្តមកប្រៃដាក់ជ្រកជ្រៀតទុកត្រង់ដែលពោលអំពីមនោយិទ្ធិផង ដើម្បីប្រដាប់សតិប្បញ្ញារបស់អ្នកមើលសៀវភៅនេះ ឲ្យដឹងជាមានសេចក្ដីពិតឬមិនពិតត្រឹមណា ហើយនឹងបានដឹងថាអ្នកដែលគេជឿក្នុងលទ្ធិទាំងនេះ មានឫទ្ធិធ្វើបែបយ៉ាងណាៗ យើងគួរជឿឬមិនគួរជឿត្រឹមណា ។

(២) គោលក្នុងព្រះពុទ្ធសាសនា ដែលមានទាក់ទងនឹងវិជ្ជា៨ប្រការនេះក៏បាននាំយកមកពណ៌នាដោយល្អិតដែរ គោលទាំងនេះបានស្រង់យកមកពីគម្ពីរវិសុទ្ធិមគ្គ តែការនឹងនាំយកគោលក្នុងគម្ពីរនេះមកបរិយានោះមិនបានយកពាក្យខ្ពស់ៗមកពោលទេ បានព្យាយមរើសតែពាក្យដែលងាយៗមកពោល ទុកជាអ្នកមិនចេះភាសាបាលីឬអ្នកមិនដែលរៀនធម៌វិន័យមកក្ដី ក៏អាចមើលចូលចិត្តបាន ។

ឯគម្ពីរវិសុទ្ធិមគ្គនេះ ជាគម្ពីរយ៉ាងឯករបស់ព្រះពុទ្ធឃោសាចារ្យតែងដោយខ្លួនលោក មិនបានប្រែពីច្បាប់សង្ហាដូចគម្ពីរផ្សេងៗទេ គម្ពីរវិសុទ្ធិមគ្គនេះអ្នកប្រាជ្ញរាប់អានប្រើទាំងអ្នកកាន់ ព្រះពុទ្ធសាសនានឹងអ្នកក្រៅ

ព្រះពុទ្ធសាសនា ហើយជាគម្ពីរសម្រាប់ទុកជាគោលរបស់អ្នកសិក្សាដល់ប្រយោគទី ៨ នឹងទី ៩ នៃស្យាមប្រទេស ហេតុដូច្នេះបានជាហ៊ាននាំយកមកបរិយាក្នុងសៀវភៅនេះ ។ សេចក្ដីអធិប្បាយទាំងប៉ុន្មានដែលមានបំពេញលើសពីគម្ពីរវិសុទ្ធិមគ្គនោះ ច្រើនយកតាមសេចក្ដីរបស់អ្នកប្រាជ្ញដែលមានមកពីជាន់មុន ហើយនឹងសេចក្ដីយល់ឃើញរបស់អ្នកតែងសៀវភៅនេះខ្លះ ហេតុដូច្នេះបើអ្នកមើលទៅបានប្រទះសេចក្ដីណាប្លែកពីអធិប្បាយរបស់អដ្ឋកថាចារ្យ ដិកាចារ្យ ឬអ្នកប្រាជ្ញណាក្តី ក៏ចូរជ្រាបថាសេចក្ដីនេះជាសេចក្ដីយល់ឃើញរបស់អ្នកតែង ឯសេចក្ដីចេះដឹងនឹងការយល់ឃើញខុសពីគ្នាជាពីរផ្នែក មនុស្សយើងទុកជាចេះដឹងតិច ហើយនឹងទុកដាក់ថាជាមនុស្សនោះគ្មានយល់ឃើញអ្វីសោះក៏ថាពុំបាន ការដែលបុគ្គលសំដែងសេចក្ដីយល់ឃើញរបស់ខ្លួនដោយសុចរិតនោះ ទុកជាយល់ឃើញខុសពីសេចក្ដីរបស់អ្នកចេះដឹងក្តី មិនត្រូវតិះដៀលថាគេខ្វះសេចក្ដីគោរពដល់អ្នកនោះឡើយ ។

(៣) ហេតុដែលនាំយកគោលលទ្ធិរបស់យោគីជាច្រើនមកពោលទុកក្នុងសៀវភៅនេះ បានជ្រើសរើសតែសេចក្ដីសំខាន់ៗមកអធិប្បាយទុកជាដើម ដើម្បីឲ្យអ្នកមើលចាប់នូវគោលដ៏សំខាន់ជាដើមបានសិន រួចតទៅសាខារបស់គោលនោះនឹងបានធ្វើឲ្យចូលចិត្តសេចក្ដីមាំមួនឡើង ឯសេចក្ដីបរិយាទាំងប៉ុន្មានបានយកពីតម្រារបស់យោគីវាមចរកៈ ដែលជាច្បាប់ល្អបំផុតជាងសៀវភៅលទ្ធិយោគីឯទៀត ។

សេចក្ដីបំផុតនេះ អ្នកតែងសៀវភៅសូមអរគុណដល់អ្នកដែលយកចិត្តទុកដាក់នឹងសៀវភៅនេះ ឯការតិះដៀលឬសរសើរនោះគ្មានផលប្រយោជន៍អ្វីប្លែកពីគ្នាទេ ។

❁❁❁

# សេចក្តីផ្តើម អំពីវិជ្ជា ៨ ប្រការ

បើនឹងពិចារណា ប្រៀបធៀបប្រវត្តិរបស់លោកអ្នកបង្កើតសាសនាធំៗគួរជឿថាវិជ្ជា ៨ ប្រការនេះ អគ្គមហាបុរសដែលតាំងសាសនាទាំងប៉ុន្មានៗ សុទ្ធតែបានលុះហើយទាំងអស់ឬក៏បានលុះដោយប្រការខ្លះមិនដែលខាន មានសេចក្តីចំឡែកណាស់ថា វិជ្ជា៨យ៉ាងនេះមានអ្នកយកចិត្តទុកដាក់រៀនសូត្រ ចេះដឹងស្គាល់ប្រាកដតែក្នុងទ្វីបអាស៊ីចំណែកខាងលិចគឺពីប្រទេសឥណ្ឌៀទៅទល់ឱរុបនឹងអាហ្វ្រិគ ចំណែកឯស្រុកចិននឹងអេស៊ីប្ត៏ ដែលចំរើនបន្ទាន់ៗគ្នានោះ ឬមុនឥណ្ឌៀទៅទៀត ក៏មិនឃើញប្រាកដថា រុងរឿងដោយវិជ្ជាទាំងនេះ តាមសេចក្តីពិនិត្យដែលមិនបាច់ជជែកប្រកែកគ្នាបាននោះ គឺអ្នកតាំងបង្កើតសាសនាធំៗដូចជាសម្តេចព្រះសម្មាសម្ពុទ្ធជាម្ចាស់យើង១ ព្រះហ្សេស៊ូគ្រិស្ត១ ព្រះមហាម៉ាត់១ ទាំង៣នេះបានមកចាប់កំណើតនឹងសម្រេចបានជាសាស្តាចារ្យខ្ពង់ខ្ពស់ សុទ្ធតែនៅក្នុងទ្វីបអាស៊ីទាំងអស់ ។

វិជ្ជា ៨ ប្រការនេះ ព្រះពុទ្ធជាម្ចាស់បានលុះគ្រប់ប្រការក្នុងវេលារាត្រីក្រោមម្លប់មហាពោធិព្រឹក្សលើរតនបល្ល័ង្គជាពិតប្រាកដ ទើបមានប្រស្នាចោទសួរថា "វិជ្ជាទាំង ៨ នេះសំដៅសេចក្តីត្រឹមណា? អភិនិហាររបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់នោះមានប្រការដូចម្តេចខ្លះ" ? ប្រស្នាទាំងពីរនេះ អ្នកប្រាជ្ញដែលកាន់សាសនាព្រះពុទ្ធ នឹងអ្នកដែលមិនកាន់យល់ឃើញជា ២ផ្លូវគឺ ៖

១- សេចក្តីយល់ឃើញរបស់អ្នកដែលជឿឥទ្ធានុភាពថា មនុស្សអាចអំណាចបណ្តាលឲ្យរបស់ផ្សេងៗ ដែលមនុស្សធម្មតាមិនអាចធ្វើបាននោះឲ្យប្រែប្រួលឬកើតបានតាមចិត្ត បានជាអ្នកដែលជឿឥទ្ធិបាដិហារិយ៍ទាំងនោះក៏ជឿថា ព្រះពុទ្ធជាម្ចាស់ទ្រង់អាចធ្វើបានជាប្រាកដ ។

២- សេចក្តីយល់ឃើញរបស់អ្នកដែលជឿចំពោះរបស់ដែលបានឃើញដឹងសំគាល់ដោយអាយតនខាងក្នុងទាំង ៥ គឺ ភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត, កាយ មិនព្រមជឿហួសពីនេះ ក៏ប្រកាន់ថាឥទ្ធិបាដិហារិយ៍ផ្សេងៗជារបស់មិនពិតទេ គ្រាន់តែជាសេចក្តីប្រៀបប្រដូចប៉ុណ្ណោះ ។

ឯប្រស្នានេះជាសំខាន់ណាស់ នឹងឲ្យត្រូវទាំងសងខាងមិនបានទេ ព្រោះម្ខាងស ម្ខាងខ្មៅ គង់ខុសម្ខាងៗ បើបែរជាក្រហមវិញគង់ខុសទាំងសងខាង ប៉ុន្តែនឹងឲ្យត្រូវទាំងពីរមិនបានទេ បើនឹងឲ្យឃើញពិតជាខាងណាត្រូវខាងណាខុសសឹងមានចំណែកដោយខ្លួន គឺថាបើវិនិច្ឆ័យតាមសេចក្តីយល់ឃើញទី១ ជាពិតប្រាកដថា ព្រះពុទ្ធជាម្ចាស់របស់យើងទុកជាព្រះម្ចាស់សួគ៌ (God) មានឋានៈខ្ពស់ជាងទេពតា ឥន្ទ្រព្រហ្មទាំងឡាយដូចយ៉ាងអ្នកកាន់សាសនាផ្សេងៗ ទុកដាក់ឲ្យអ្នកតាំងបង្កើតសាសនាគេនោះជា (God) ព្រះម្ចាស់សួគ៌ដូច្នោះ។ បើប្រសិនជាវិនិច្ឆ័យជាសេចក្តីយល់ឃើញទី២ ជាត្រឹមត្រូវវិញ ព្រះពុទ្ធជាម្ចាស់ក៏គ្រាន់តែជាអ្នកចេះដឹងសីលធម៌ (Philosopher) ដូចខុងជឺដែលជាសាស្តារបស់ចិត្ត ឬអារិស្តូត្ត៏នឹងសូក្រាតដែលជាសាស្តារបស់ក្រិកប៉ុណ្ណោះមិនខ្ពង់ខ្ពស់ ប្រសើរអ្វីជាងអ្នកទាំងនេះឡើយ ។

មុននឹងវិនិច្ឆ័យរកហេតុឲ្យឃើញ គួរយើងតាំងប្រស្នាសួរខ្លួនឯងបាន ២ ឬ ៣ ខសិនគឺ ៖

ព្រះពុទ្ធជាម្ចាស់ ទ្រង់បានសិក្សាក្នុងសំណាក់លទ្ធិផ្សេងៗ ដែលមនុស្សរាប់អានមុនព្រះអង្គត្រាស់ដឹង ហើយព្រះអង្គបានធ្វើទុក្ករកិរិយាដល់៦ ឆ្នាំទើបបានសម្រេច សេចក្តីសម្រេចដែលបានមកដោយព្យាយាមយ៉ាងធំក្រៃលែងដូច្នេះ មិនមានអ្វីជាទីធ្វើឲ្យព្រះអង្គមានគុណសម្បត្តិដ៏វិសេសយ៉ាងខ្ពង់ខ្ពស់លើសមនុស្សធម្មតាទេឬអ្វី ? ។

បើព្រះអង្គមានថ្នាក់ត្រឹមអ្នកចេះសីលធម៌តែប៉ុណ្ណោះទេ ហេតុអ្វីក៏

ព្រះអង្គអាចផ្សាយសាសនារបស់ព្រះអង្គបានឆាប់រហ័សច្រើនជាងសាស-នាឯទៀតៗ ហើយស្ថិតស្ថេរអង្វែងមកជាងសាសនាឯទៀតៗ ប្រស្នានេះមានពាក្យដោះស្រាយជា ២ ប្រការគឺ៖ ១) ថាធម៌របស់ព្រះអង្គទៀងត្រង់ជាសុខុមនាំទៅកាន់សេចក្ដីចំរើន ច្រើនជាងធម៌វិន័យក្នុងសាសនាផ្សេងៗ ២) ថាកាលព្រះអង្គត្រាស់ដឹងហើយៗ បានទេសនាប្រោសព្រះបាទពិម្ពិសារ ដែលមានអំណាចដ៏ធំក្រៃលែងក្នុងស្រុកឥណ្ឌៀក្នុងគ្រានោះបានជាមនុស្សទាំងឡាយជឿកាន់តាមដោយបានអំណាចរបស់ ព្រះបាទពិម្ពិសារជាអ្នកទំនុកបម្រុង ។

ខដោះស្រាយទាំង ២ ប្រការនេះ នឹងទុកថាជាត្រូវប្រាកដក៏ពុំបាន ព្រោះមនុស្សតែងតែយល់ឃើញថា "សាសនារបស់ខ្លួនល្អ" ការជជែកពីរឿងសាសនានេះមានជាដរាបមកជាងពាន់ឆ្នាំហើយក៏គ្មានអ្នក ណាវិនិច្ឆ័យឲ្យដាច់ខាត ថាសាសនាណាល្អជាបំផុតជាងគេទេ ដែលជាប្រាកដនោះលោកដែលតាំងបង្កើតសាសនាគ្រប់រូប បានដាក់គោលចារិកបែបផែនជាសំខាន់ទុកសឹងប្រហែសៗគ្នា ផ្សេងគ្នាតែសេចក្ដី ឯរឿងសាសនានេះមិនគួរនឹងអួតអាថា "សាសនារបស់ខ្លួនវិសេសជាងសាសនាឯទៀតៗ ហើយបន្ទុះបង្អាប់សាសនាឯទៀតៗ ថាសោប្មថោកទាបជាងរបស់ខ្លួន" ឯការដែលប្រកាន់ដូច្នេះ មិនមែនចរិយារបស់អ្នកចេះឡើយ បារាំងដែលជាមនុស្សល្អមែនៗ ជាអ្នកប្រដៅសាសនាគ្រិស្ត មិនដែលឮគេតិះដៀលសាសនាព្រះពុទ្ធយើងទេ ។

ត្រង់ខទី២ ដែលថាព្រះពុទ្ធជាម្ចាស់បានអំណាចពីព្រះបាទពិម្ពិសារជាគ្រឿងជ្រោមជ្រែងធ្វើឲ្យព្រះអង្គផ្សាយសាសនាបានឆាប់រហ័សនោះជាការខុសពិត ព្រោះថាអារិស្តូត្តិ៍ជាអាចារ្យរបស់ព្រះបាទអាលេកសង់ដ្រឺមហារាដែលមានឈ្មោះក្នុងពង្សាវតារឱរុបទុកជាស្ដេចចក្រពត្តិ មានអំណាចក្នុងទ្វីបឱរុបរហូតដល់មកឥណ្ឌៀ សម្បើមជាងអំណាចព្រះបាទ

ពិម្ពិសារទៅទៀត ក៏មិនប្រាកដថាអារិស្តូត្តិ៍យកអំណាចព្រះបាទអាលេកសង់ដ្រើជាគ្រឿងផ្សាយលទ្ធិរបស់ខ្លួនបានឡើយ។

ប្រស្នាមួយខទៀត គឺរឿងអង្គុយលិមាសត្ថេរ មានសេចក្តីដំណាលមកថាជាចោរសម្លាប់មនុស្សមកហើយ ៩៩៩ នាក់ កាត់យកម្រាមដៃដោតជាចង្កោម នៅខ្វះតែម្នាក់ទៀតនឹងបានគ្រប់ជា ១.000 នាក់តាមបង្គាប់របស់អាចារ្យ តមកបានចួបប្រទះនឹងព្រះពុទ្ធ បានដេញចាប់ព្រះអង្គមិនទាន់ ព្រះអង្គមានព្រះបន្ទូលតែមួយព្រះឱស្ឋ អង្គុលិមាលចោរក៏ឈប់គិតមិនហ៊ានប្រទូស្តនឹងព្រះអង្គតទៅទៀត ត្រឡប់ជាស្តាប់ធម៌ទេសនារបស់ព្រះអង្គបានសម្រេចឧបសម្បទាជាឯហិភិក្ខុ ជាព្រះអរហន្តក្នុងព្រះពុទ្ធសាសនាមួយព្រះអង្គ។ រឿងនេះគួរគិតពិចារណាជា ២ ផ្នែកគឺ១ ព្រះពុទ្ធជាម្ចាស់ទ្រង់សង្រួមព្រះឥរិយាបថជាទីបំផុត ព្រះអង្គគង់ជាមិនបានរត់ទេចុះហេតុអ្វីក៏ព្រះអង្គុលិមាលដេញតាមមិនទាន់(១) ២ ប្រសិនបើព្រះអង្គមិនមានឥទ្ធិបាដិហារិយ៍ទេ ពាក្យដែលព្រះអង្គមានព្រះបន្ទូលតែមួយព្រះឱស្ឋអាចធ្វើឲ្យចោរចិត្តទមិឡសម្លាប់មនុស្សជាង ៩00 នាក់មកហើយឲ្យព្រមឈប់ស្តាប់ព្រះធម្មទេសនាបានឬ? ប្រសិនបើជាខ្លួនយើងវិញចូលទៅក្នុងព្រៃប្រទះនឹងចោរដែលវាបម្រុងមកសម្លាប់យើងៗនិយាយតាមព្រះពុទ្ធវចនៈនោះឲ្យចោរស្តាប់មុខជាវាមិនព្រមឈប់ស្លាប់យើងទេសនាទេ វាសម្លាប់យើងមុនទេសនាមិនខាន ។

ប្រការមួយវិញទៀត បើសន្និដ្ឋានថា ឥទ្ធិបាដិហារិយ៍បែរជាផ្លូវបុគ្គលាធិដ្ឋានមិនបានហើយៗ ថាព្រះពុទ្ធជាម្ចាស់មិនមានឥទ្ធិបាដិហារិយ៍

---

(១) អ្នកតែងសៀវភៅនេះមិនចង់ឲ្យអ្នកណាសន្និដ្ឋានថា "ពីព្រោះព្រះពុទ្ធជាម្ចាស់ទ្រង់ស្គាល់ស្នាត់ផ្លូវណាស់ ទ្រង់យាងកាត់ព្រៃគេចចៀសបត់បែនទៅបានគ្រប់ច្រក មិនឲ្យអង្គុលិមាលដេញតាមទាន់" ដូច្នេះឡើយ ព្រោះថាបើយើងស្តាប់ពាក្យសន្និដ្ឋានដូច្នេះហើយ មុខគួរឲ្យអាណោចអធម្មពន់ពេកហាក់ដូចជាព្រះពុទ្ធកំពុងទ្រង់ក្រសាលល្បែងបិទពួនជាមួយនឹងអង្គុលិមាល ។

វិសេសជាងមនុស្សសាមញ្ញទេ ក៏គួរសង្ស័យណាស់ ហេតុដូចម្ដេច ក៏អ្នកប្រាជ្ញដែលសរសេរតម្រាទុកមកជាច្រើន ពីរឿងឥទ្ធិបាដិហារិយ៍របស់ព្រះពុទ្ធជាម្ចាស់ តើអ្នកប្រាជ្ញទាំងនោះយកមកពីណា? មនុស្សយើងមានធម្មជាតិមួយជាប្រាកដដែលហៅថាមនោគតិ (Imagination) មានចួនកាលធ្វើឲ្យមនុស្សគិតរកឃើញរបស់ ដែលហួសវិស័យមនុស្សទៅបានតែថាមនោគតិមនុស្ស មានតែត្រឹមរកឃើញធ្វើរបស់ដែលបានឃើញពិតនៅក្នុងលោកខ្លះតែប៉ុណ្ណោះ នឹងមានមនោគតិក្នុងរឿងដ៏ប្រាសចាកសេចក្ដីពិតប្រាកដនោះពុំបានឡើយ ដូចជាការធ្វើយយន្តហោះឬកប៉ាល់មុជទឹក នឹងរទេះដើរក្នុងដីទាំងនេះ សឹងមានមកពីមនោគតិនីមួយៗ ហើយឥឡូវនេះក៏ក្លាយទៅជារបស់ពិតទាំងអស់ ប្រការមួយទៀត បើឥទ្ធិបាដិហារិយ៍របស់ព្រះពុទ្ធជាម្ចាស់មិនពិតទេ អ្នកប្រាជ្ញដែលតែងសាស្រ្តាតម្រាទុកមកជាច្រើនពីរឿងឥទ្ធិបាដិហារិយ៍នោះ ដល់ជាប្រាសចាកហិរិឱត្តប្បៈយកសេចក្ដីមិនពិត មកពោលកុហកបញ្ឆោតមហាជនបានដល់ម្ល៉េះឬ ? លោកអ្នកប្រាជ្ញទាំងនោះសុទ្ធតែជាអ្នកមានសីលធម៌ ចេះដឹងខ្ពង់ខ្ពស់មើលទៅលោកមិនអាចយកសេចក្ដីកុហកបញ្ឆោតមកតែងទុកទេ មានពុទ្ធភាសិត១បទថា "សច្ចំ វេ អមតា វាចា" ពាក្យពិតជាវាចាមិនស្លាប់ បើប្រសិនជាតម្រាឥទ្ធិបាដិហារិយ៍របស់ព្រះពុទ្ធមិនពិតប្រាកដទេប្រហែលជាបាត់យូរណាស់ទៅហើយ មុខជាគ្មានអ្នកមានសទ្ធាចម្លងទុកតៗមកដល់ពីរពាន់ប្លាយឆ្នាំនេះទេ សេចក្ដីនេះគួរទុកជាវាចាមិនស្លាប់គួរប្រកាន់ថាជាការពិតបានឬមិនបាន ? ។

បើប្រសិនជារិះគិតពិចារណា តាមសេចក្ដីដែលពោលមកហើយនេះ គួរទទួលស្គាល់ជាក់ថា ព្រះពុទ្ធជាម្ចាស់របស់យើង មានឥទ្ធិបាដិហារិយ៍ដ៏សក្តិសិទ្ធិខ្ពង់ខ្ពស់ជាងមនុស្សធម្មតា តែឥទ្ធិបាដិហារិយ៍ទាំងនេះ នឹងទុកដាក់ជាធម្មាធិដ្ឋានទាំងអស់ក៏ពិបាក ត្រូវទុកជាបុគ្គលាធិដ្ឋានខ្លះៗ ដែល

ថា ព្រះពុទ្ធជាម្ចាស់របស់យើងទ្រង់មានអភិនិហារិយ៍ខ្ពង់ខ្ពស់ជាងមនុស្សធម្មតានោះ តើយើងនឹងអធិប្បាយអភិនិហារិយ៍នោះដោយផ្លូវណា? សេចក្តីនេះមនុស្សយល់ឃើញជា ២ ផ្លូវគឺ ១) ថាមានរបស់អ្វីមួយ មានអំណាចខ្ពស់លើសអំណាចធម្មជាតិ (Surnaturel) ។ ២) ថារបស់នោះនៅក្នុងវង្វង់ធម្មជាតិនោះឯង គឺអំណាចដួងចិត្តដែលបានបង្ហាត់ទម្លាប់យ៉ាងល្អហើយ។ ពួកទី១ ជាពួកដែលជឿថាមានអំណាចដ៏ខ្ពស់បំផុតនៅខាងលើដែលអាចធ្វើឲ្យអ្នកណាទៅជាអ្វីក៏បាន បើអ្នកណាប្រដៅដួងចិត្តបានហើយ ក៏អាចនឹងធ្វើការជាប់តនឹងអំណាចនៅខាងលើ គឺទេវតាបានអាចសុំឫទ្ធិតេជះពីទេវតាបាន (ឥទ្ធិវិធី) អាចនឹងចរចានិយាយសួររឿងផ្សេងៗនឹងអ្នកសក្តិសិទ្ធិនៅខាងលើបាន (ទិព្វសោត) អធិប្បាយមកនេះទុកជាខុសទាំងស្រុងក៏ពុំបាន គួរជឿខ្លះដែរ ។ ប៉ុន្តែគួរជ្រះថ្លាក្នុងពួកទី២ ដែលថាឫទ្ធិតេជះរបស់ព្រះពុទ្ធឬព្រះសាវក នឹងអ្នកណាដែលអាចធ្វើបានសឹងនៅក្នុងវង្វង់នៃធម្មជាតិទាំងអស់ពោលគឺដោយអំណាចដួងចិត្ត ដែលបានហាត់ហ្វឹកហ្វឺនទម្លាប់ហើយ មិនមែនជារបស់លើសធម្មជាតិ ឬហួសវិស័យមនុស្សទេ ព្រោះធម្មជាតិមានវង់ទូលាយត្រឹមណា វិស័យមនុស្សមានលក្ខណៈកំណត់ត្រឹមណានោះ យើងចេះដឹងមិនទាន់ធួនល្មមដល់ទីនោះឡើយ ហេតុនេះមុនយើងនឹងវិនិច្ឆ័យ គួររិះគិតជាមុនសិនថា "របស់នេះរបស់នោះជារបស់លើសធម្មជាតិវិស័យ ឬហួសវិស័យមនុស្សនឹងធ្វើបាន" ដូច្នេះកុំអាលប្រញាប់វិនិច្ឆ័យរហ័សពេក បើវិនិច្ឆ័យចាប់ណាស់ទៅបីដូចជាមនុស្សខ្វាក់ស្ទាបដំរី បើស្ទាបពានទៅលើកន្ទុយនឹងថាដំរីនោះមានខ្លួនដូចសត្វពស់ ។

ប្រស្នាផ្សេងៗដែលបានពណ៌នាមកខាងដើមនេះ ជាមូលហេតុនៃការគិតសរសេរវិជ្ជា ៨ ប្រការតាមគំនិតគិតឃើញ អ្នកតែងរឿងនេះជឿថាព្រះពុទ្ធជាម្ចាស់របស់យើង មានឥទ្ធាភិនិហារ្យលើសលប់មនុស្សធម្មតា

មែន ហើយព្រះអង្គអាចធ្វើការអ្វីៗដែលមនុស្សធម្មតាមិនអាចធ្វើបានទាំងអស់ផង។ ឯឥទ្ធិបាដិហារ្យដែលទ្រង់បានទាំងអម្បាលនេះក៏ជាផលនៃអំណាចដួងចិត្តរបស់ព្រះអង្គ ដូចមានសេចក្តីពិសោធក្នុងសៀវភៅនេះស្រាប់ ដើម្បីឲ្យអ្នកមើលងាយចូលចិត្ត នោះបានញែកវិជ្ជាទាំង ៨ ចេញហើយនាំយកនូវកងធម៌ទៀតៗដែលមានទាក់ទងគ្នា មករួបរួមទុកជាមួយគ្នា ដើម្បីឲ្យអ្នកមើលបានដឹងថា វិជ្ជាទាំង ៨ ប្រការនេះជាធម៌ដ៏សំខាន់របស់ព្រះពុទ្ធជាម្ចាស់គ្របដណ្តប់លើធម៌ទៀតជាច្រើនមួយវិញទៀត ការរៀនវិជ្ជា ៨ ប្រការនេះនឹងជួយឲ្យបានចូលចិត្តភ្លឺដល់ធម៌ឯទៀតៗ ជាច្រើនផង ។

**សាខារបស់វិជ្ជាទាំង៨នោះដូចមានខាងក្រោយនេះ ៖**

១- **វិបស្សនាញាណ** ញាណដែលរាប់បញ្ចូលក្នុងវិបស្សនា

២- **មនោមយិទ្ធិ** ឫទ្ធិតាមផ្លូវបាន

៣- **ឥទ្ធិវិធិ** សំដែងឫទ្ធិបាន

៤- **ទិព្វសោត** ត្រចៀកទិព្វ

៥- **ចេតោបរិយញ្ញាណ** ចេះកំណត់ចិត្តអ្នកដទៃ

៦- **បុព្វេនិវាសានុស្សតិញ្ញាណ** រឭកជាតិបាន

៧- **ទិព្វចក្ខុ** ភ្នែកទិព្វ

៨- **អាសវក្ខយញ្ញាណ** ចេះធ្វើឲ្យអស់អាសវៈ។

**វិជ្ជា ៨ នេះផ្ទុយនឹងអវិជ្ជា ៨ គឺ÷**

១- មិនស្គាល់ទុក្ខ

២- មិនស្គាល់ហេតុដែលជាទីកើតនៃទុក្ខ

៣- មិនស្គាល់សេចក្តីរលត់ទុក្ខ

៤- មិនស្គាល់ផ្លូវដែលជាឧបាយរលត់ទុក្ខ

៥- មិនស្គាល់ហេតុក្នុងអតីត

៦- មិនស្គាល់ហេតុក្នុងអនាគត

៧- មិនស្គាល់ហេតុទាំងក្នុងអតីតទាំងក្នុងអនាគត

៨- មិនស្គាល់បដិច្ចសមប្បាទ គឺមិនចេះកំណត់សភាវៈនីមួយៗដែលជាហេតុនឹងផលជាប់ទាក់ទងគ្នាទៅមក ដូចខ្សែច្រវាក់ដែលទាក់ជាប់គ្នានោះឯង ។

អវិជ្ជាត្រង់ខ ១, ២, ៣, ៤ នឹង៨ ផ្ទុយនឹងអាសវក្ខយញ្ញាណត្រង់ខ ៥, ៦, នឹង ៧ ផ្ទុយនឹងទិព្វចក្ខុ ។

វិជ្ជាទាំង ៨ នេះគ្របដណ្តប់ធម៌ទៀតៗត្រង់ខណាខ្លះ ?

បើពោលយ៉ាងទូលាយគឺគ្របទុកនូវធម៌ ៣ កងគឺ ៖

## ក- គ្របវិជ្ជា ៣ គឺ៖

១- **បុព្វេនិវាសានុស្សតិញ្ញាណ** ចេះដឹងរឭកជាតិបាន

២-**ចុក្ខូបបាតញ្ញាណ** ចេះដឹងកំណត់ច្យុតនឹងបដិសន្ធិនៃសត្វ

៣-**អាសវក្ខយញ្ញាណ** ប្រាជ្ញាកំណត់ដឹងនូវធម៌ជាទីអស់ទៅនៃអាសវៈ ។

## ខ- គ្របអភិញ្ញា ៦ គឺ៖

១-**ឥទ្ធិវិធិ** សំដែងឫទ្ធិបាន

២-**ទិព្វសោត** ត្រចៀកទិព្វ

៣-**ចេតោបរិយញ្ញាណ** ចេះស្គាល់កំណត់ចិត្តអ្នកដទៃ

៤-**បុព្វេនិវាសានុស្សតិ** រឭកជាតិបាន

៥-**ទិព្វចក្ខុ** ភ្នែកទិព្វ

៦-**អាសវក្ខយញ្ញាណ** ប្រាជ្ញាកំណត់ដឹងនូវធម៌ជាទីអស់ទៅនៃអាសវៈ ។

# គ-គ្របដណ្តប់ទសពលញ្ញាណ ៣ គឺ៖

១- **បុព្វេនិវាសានុស្សតិញ្ញាណ** ប្រាជ្ញាកំណត់រឭកជាតិកន្លងមកហើយបាន

២-**ចុតូបជាតិញ្ញាណ** ប្រាជ្ញាកំណត់ដឹងច្យុតនឹងបដិសន្ធិរបស់សត្វទាំងឡាយ ដែលកើតមកផ្សេងៗពីគ្នាដោយផលកម្ម

៣-**អាសវក្ខយញ្ញាណ** ប្រាជ្ញាកំណត់ដឹងនូវធម៌ជាទីអស់ទៅនៃអាសវៈ ។

បើពោលឲ្យល្អិតញែកសាខារបស់វិជ្ជា ៨ ចេញហើយ ធម៌ពួកនេះនៅគ្របធម៌ពួកឯទៀតៗទុកជាច្រើនពួកគឺ ៖

១-**វិបស្សនាញាណ** ក្នុងពួកវិជ្ជា គ្របវិបស្សនាញាណ ៩

២-**ឥទ្ធិវិធិ** គ្របឥទ្ធិបាដិហារិយៈ

៣-**ទិព្វចក្ខុ** គ្របញាណ ៣ គឺ ១-អតិតង្សញ្ញាណ ញាណក្នុងចំណែកអតីត ២-អនាគតង្សញ្ញាណ ញាណក្នុងចំណែកអនាគត ៣-បច្ចុប្បន្នង្សញ្ញាណ ញាណក្នុងចំណែកបច្ចុប្បន្ន ។

៤-អាសវក្ខយញ្ញាណ គ្របធម៌ ៤ ពួកគឺ ៖

**ក-គ្របអាសវៈ ៣ គឺ៖**

១-**កាមាសវ** អាសវៈជាហេតុចង់បាន

២-**ភវាសវ** អាសវៈជាហេតុចង់ទៅកើតជានេះជានោះ

៣-**អវិជ្ជាសវ** អាសវៈគឺសេចក្តីល្ងង់ខ្លៅ។

**ខ-គ្របអរិយសច្ច ៤ ៖**

១-**ទុក្ខ** សេចក្តីមិនសប្បាយ

២-**សមុទយ** ហេតុឲ្យកើតទុក្ខ

៣-**និរោធ** សេចក្តីរលត់ទុក្ខ

៤-**មគ្គ** សេចក្តីប្រតិបត្តិឲ្យដល់ទីរលត់ទុក្ខ។

**គ-គ្រប់កិច្ចក្នុងអរិយសច្ច ៤ ៖**

១-**បរិញ្ញា** កំណត់ដឹងទុក្ខសច្ច

២-**បហាន** លះសមុទយសច្ច

៣-**សច្ឆិករណ** ធ្វើឲ្យភ្លឺច្បាស់នូវនិរោធសច្ច

៤-**ភាវនា** ធ្វើមគ្គសច្ចឲ្យកើត។

ឃ-គ្រប់អវិជ្ជា ៤ ៖

១-មិនស្គាល់ក្នុងទុក្ខ

២-មិនស្គាល់ក្នុងទុក្ខសមុទយ

៣-មិនស្គាល់ក្នុងទុក្ខនិរោធ

៤-មិនស្គាល់ក្នុងទុក្ខនិរោធគាមិនីបដិបទា។

ហេតុដែលអាងយកលទ្ធិយោគីមកពោលទុកច្រើនអន្លើក្នុងសៀវភៅនេះហើយបាននាំយកគោលចារិកព្រះពុទ្ធសាសនា ក្នុងរឿងវិជ្ជា ៨ ប្រការមកបរិយាទុកផង ដើម្បីចេះដឹងស្គាល់ខសំខាន់ៗរបស់លទ្ធិយោគី ឯកសិណនឹងឈាននឹងស្នេះទុកសិន នឹងនាំគោលទាំង ៣ ប្រការនេះមកអធិប្បាយដោយខ្លីៗដូចមានតទៅនេះ កាលណាបើអ្នកមើលខំសិក្សាដោយច្បាស់លាស់តាំងពីដើមរហូតដល់ចុងហើយនឹងធ្វើឲ្យចូល ចិត្តសេចក្តីត្រង់ញែកសេចក្តីអធិប្បាយអំពីវិជ្ជា ៨ ប្រការដោយងាយគ្រប់ៗខឡើងបាន។

**ក-គោលចារិករបស់យោគី**

លទ្ធិរបស់យោគីនោះ ប្រកាន់ថាមនុស្សយើងមានភាគធំដែលចែកចេញបានជា ៧ ភាគគឺ ៖

៧-វិញ្ញាណ

៦-ដួងចិត្ត

៥-បញ្ញា

៤-សញ្ញា

៣-ប្រាណ

២-ចេតភូត (ព្រលឹង)

១-កាយ។

បាយជារៀបរៀងតាមលំដាប ពីលេខ ៧ ចុះទៅលេខ១ នេះដើម្បីឲ្យឃើញថា វិញ្ញាណជាធម្មជាតិខ្ពស់បំផុត ឯកាយជាធម្មជាតិទាបបំផុត។

## ១-កាយ

កាយជារបស់គ្រោតគ្រាតហើយមើលឃើញច្បាស់ជាងភាគសំខាន់ឯទៀតៗរបស់មនុស្ស ជាភាគរួមធាតុផ្សេងៗ ដែលផ្គុំឡើងជារូបរាងមានប្រាណជាគ្រឿងទំនុកបម្រុងឲ្យផ្គុំគ្នារស់នៅបាន បើប្រាណចេញចាកកាយកាលណា ធាតុទាំងឡាយក៏រលាយញែកពីគ្នាចេញអស់ កាយក៏ជារបស់គ្មានតម្លៃ កាលណោះហើយដែលយើងហៅថា "ស្លាប់" ដោយហេតុនេះទើបកើតគំនិតគិតឃើញថាសេចក្តីស្លាប់មានផលចំពោះ កាយមួយយ៉ាងមិនបានប៉ះពាល់ទៅដល់ភាគសំខាន់ៗទាំង៦នោះឡើយសេចក្តី ស្លាប់មិនមានអ្វីសំខាន់ ក្រៅពិផ្លាស់ប្តូរលំនៅនៃសភាពទាំង៦ ប្រការខាងដើមនោះទេ ប្រៀបដូចជាផ្ទះដែលយើងបាននៅមកជាយូរអង្វែងហើយ ផ្ទះនោះចាស់បាក់បែកយើងរុះចោលទៅសង់ឡើងជាថ្មីទៀតប៉ុណ្ណោះឯង ។

## ២-ចេតភូត

ចេតភូតគេក៏ប្រកាន់ថាជាកាយមួយដែរ សឹងមានលក្ខណៈល្អិតជាងកាយធម្មា ព្រោះតាមប្រក្រតីយើងមើលឃើញនឹងភ្នែកពុំបានប៉ុន្តែនៅគ្រោតគ្រាតជាងធម្មជាតិទាំង ៥ ប្រការខាងលើនោះទៀត ព្រោះចេតភូតនេះអាចឃើញដោយភ្នែកបានដោយកាលម្តងៗ ក្នុងសម័យបុរាណគេ

ស្គាលច្បាស់ណាស់ នឹងជាដើមកំណើតនៃការប្រកាន់និមិត្រឬប្រផ្នូល ឬកាន់ខ្មោចបិសាចឬហេតុស្វាត់កំបាំងផ្សេងៗ ។ តែបើពោលតាមលទ្ធិរបស់យោគីនោះ ចេតភូតជាភាគមួយរបស់កាយនេះឯង ហើយញែកចេញពីកាយបានដោយកាលម្តងៗ វេលាដេកលក់ ដែលញែកចេញទៅនោះ ក៏នៅមានទាក់ទងនឹងកាយ ដូចមានខ្សែចងជាប់នឹងកាយកាលណាទាញចេញទៅហើយ វេលាត្រូវការកន្ត្រាក់មកកាន់កាយវិញបាន ជួនកាលកន្ត្រាក់មករហ័សពេក ចេតភូតក៏មកប៉ះនឹងកាយជាខ្លាំងទាល់តែដឹងខ្លួនឆាប់ពេក ដូចយើងកំពុងដេកលក់យ៉ាងស្រួលសប្បាយចេតភូតចេញពីកាយទៅហើយ កំពុងដើរត្រាច់ជាសប្បាយ ទទួលមានរបស់អ្វីធ្លាក់ឬឮសន្ធឹកអ្វីជាខ្លាំងខាងខ្លួន ធ្វើឲ្យយើងភិតភ័យភ្ញាក់ឡើងដោយរហ័សរន្ធត់ញ័រក្នុងចិត្តជាខ្លាំង នេះមកពីចេតភូតរត់មកប៉ះកាយយើងយ៉ាងខ្លាំង ។

កាលណាកាយបែករលាយទៅ ដែលយើងហៅថាស្លាប់ ចេតភូតរកកាយនៅពុំទាន់បាន ក៏ត្រាច់ទៅ ជួនកាយទៅចូបមនុស្សក៏សំដែងឲ្យមនុស្សឃើញ ដែលយើងហៅថាខ្មោចលង (បិសាច) ។ កាយនឹងចេតភូតនេះអាចប្រៀបធៀបនឹងខ្លួនយើង នឹងផ្ទះរបស់យើង បីដូចយើងមានផ្ទះមួយបាននៅយូរមកហើយ ឃើញថាផ្ទះនោះគ្រាគ្រាណាស់យើងនឹងនៅតទៅទៀតពុំបាន មុខជានឹងរលំពុំខាន យើងក៏រកសង់ផ្ទះបម្រុងទុកឲ្យហើយ បើផ្ទះចាស់រលំកាលណាយើងក៏ទៅនៅផ្ទះដែលយើងសង់ថ្មីនោះមិនបាច់ដើររកផ្ទះឬទៅអាស្រ័យនៅនឹងបងប្អូនញាតិសាលោហិត នោះឡើយ បើប្រសិនជាផ្ទះយើងនៅមុនសុខៗមិនទាន់ចាស់ទ្រុឌទ្រោមទេ ហើយមានទេសកាល ជាខ្យល់ព្យុះឬភ្លើងឆេះក្តីមករំលាយផ្ទះរបស់យើងដោយមិនដឹងខ្លួន រកផ្ទះនៅគ្មាន មានតែទៅជ្រកនៅនឹងញាតិឬក៏ទ្រាំជ្រកនៅទីកន្លែងចាស់ដែលវិនាសទៅនោះសិន ទំរាំរកផ្ទះនៅបានសេចក្តីនេះប្រៀបដូចចេតភូត បើរូបកាយដែលមានជម្ងឺឈឺជាយូរ ចេតភូតដឹងថា

កាយនេះនឹងទ្រាំទ្រយូរទៅទៀតពុំបាន ក៏ស្វែងរកទីកន្លែងទុកជាមុនកាលណាកាយនេះរលាយទៅ ចេតភូតក៏ចេញពីកាយដោយស្រួលទៅនៅនឹងកាយឯទៀត ដែលរកទុកបានជាមុននោះ។ បើកាយនោះនៅសុខៗហើយទទួលមានឧប្បត្តិហេតុដូចជាស្លាប់នឹងរទេះកិន ស្លាប់ដោយគេសម្លាប់ឬស្លាប់ដោយអាការផ្សេងៗដែលឆាប់រហ័សនោះ ចេតភូតមិនទាន់ដឹងខ្លួនចេញទៅរកកាយជ្រកមិនទាន់ មិនដឹងជាទៅជ្រកឯណា ក៏ទ្រាំនៅៗទីនោះឬក៏ទៅរកញាតិដែលស្គាល់រាប់អានកាលនៅ ក្នុងកាយមិនទាន់ស្លាប់នោះ ជួនកាលក៏ធ្វើឲ្យឃើញនឹងភ្នែកជាក់ស្តែងចំពោះអ្នកណាមួយដែលយើងហៅថា "បិសាច" ព្រោះហេតុនេះមនុស្សដែលមានជម្ងឺឈឺយូរ ស្លាប់ទៅមិនសូវឃើញ (បីសាច) ឯមនុស្សស្លាប់ក្នុងបច្ចុប្បន្នទាន់ហន់ដែលហៅថាស្លាប់តាយហោងនោះច្រើនឃើញ "បិសាច" មកយាយីរឿងៗដែលទុកដាក់ថាជាខ្មោចកាច។ បើយើងជឿកាមលទ្ធិយោគីអធិប្បាយមកនេះ មិនគួរយើងខ្លាចខ្មោចសោះព្រោះជាភាគមួយរបស់កាយយើងនេះដែរ ។

តាមសេចក្តីពន្យល់ក្នុងសៀវភៅរបស់យោគីឈ្មោះ រាមៈចរកៈ មានសេចក្តីរ៉ាប់រងតទៅថា ក្នុងវេលាយើងមានជីវិតរស់នៅ ក៏អាចប្រើចេតភូតជាប្រយោជន៍បាន បើយើងចេះទម្លាប់បានល្អហើយអាចបង្គាប់ចេតភូតរបស់យើងឲ្យទៅប្រាកដឃើញទៅទីណា ក៏បាន តែនឹងឲ្យចេះនិយាយស្តីធ្វើការអ្វីបានឬមិនបាននោះ មិនឃើញមាននិយាយក្នុងសៀវភៅនោះទេគ្រាន់តែថាអាចស៊ើបការឬឲ្យដឹងការអ្វីជាមុនបាននៅវេលាយើងដេកលក់ចេតភូតនឹងនាំពណ៌ដ៏មានមករាយការដល់យើង ឲ្យដឹងឃើញក្នុងវេលាយល់សប្តិ តែសេចក្តីយល់សប្តិរបស់មនុស្សនឹងជឿបានត្រឹមណាសំដៅសេចក្តីដូចម្តេចនោះជាបញ្ហាធំទូលាយគួរធ្វើជាសៀវភៅមួយផ្សេងទៀត។

៣-ប្រាណ គឺខ្យល់ដង្ហើមចេញចូលនឹងកំលាំងរបស់សរសៃប្រសាទ

ដែលជាគ្រឿងជួយឲ្យកាយផ្គុំគ្នាទៅបាន

៤-សញ្ញា គឺសេចក្តីដឹងក្តៅរងាសប្បាយមិនសប្បាយ ។ល។

៥-បញ្ញា គឺសេចក្តីដឹងខុសត្រូវ សេចក្តីស្រឡាញ់ ខ្លាច មេត្តា សេចក្តីរាប់អាន ខឹង លោភ ឫស្យា ទាំងនេះរួមចូលក្នុងបញ្ញាទាំងអស់

៦-ដួងចិត្ត ជាអ្នកបង្គាប់ការទូទៅក្នុងខ្លួនមនុស្ស

៧-វិញ្ញាណ ជាម្ចាស់ធម្មជាតិទាំង៦ បើធម្មជាតិទាំង៦ទៅធ្វើខុសឬត្រូវអ្វីៗវិញ្ញាណជាអ្នកទទួលទាំងអស់។

តាមលទ្ធិយោគី ដែលពោលមកជាសេចក្តីសង្ខេបនេះ មនុស្សយើងប្រៀបដូចកប៉ាល់ធំមួយ វិញ្ញាណទុកដូចជាម្ចាស់កប៉ាល់ តាមធម្មតាម្ចាស់កប៉ាល់ មិនអាចទៅដើរកប៉ាល់ដោយខ្លួនឯងបានទេ តោងរកចិនជូ (កាពីតែន) គឺដួងចិត្ត ជាអ្នកបង្គាប់ការដាច់ខាតក្នុងកប៉ាល់ បើកាពីតែនប៉ិនប៉ៅប្រសប់ចេះបើកកប៉ាល់ដឹកទំនិញឬផ្ទុកមនុស្សដំណើរបាន ដោយស្រួលនោះទើបមានចំណេញ ឯម្ចាស់កប៉ាល់ដែលប្រៀបដូចវិញ្ញាណជាអ្នកបានទទួលផលទាំងអស់ បើកាពីតែន (ដួងចិត្ត) មិនប្រសប់នាំកប៉ាល់ទៅដើរឲ្យលិចខូចខាត ម្ចាស់កប៉ាល់ (វិញ្ញាណ) ក៏ត្រូវទទួលគ្រោះថ្នាក់ទាំងអស់ ហេតុនេះបានជាថាដួងចិត្តជាសំខាន់បំផុត ព្រោះធ្វើល្អឬអាក្រក់ស្រេចនូវដួងចិត្ត ឯវិញ្ញាណគ្រាន់តែជាអ្នកទទួលផល បញ្ញានឹងសញ្ញាប្រៀបដូចគ្រឿងប្រដាប់សម្រាប់កប៉ាល់ ដូចជាផែនទីនឹងត្រីវិស័យសម្រាប់ចង្អុលទិល ប្រាណប្រៀបដូចម៉ាស៊ីនដែលធ្វើឲ្យកប៉ាល់ដើរបាន ចេតភូតប្រៀបដូចជាកែវយឹតឬវិទ្យុទោរសព្ទសម្រាប់យឹតមើលនឹងឲ្យដំណឹង ជាមុនដែលនឹងមានហេតុមកដល់ ឯកាយគឺសំបកកប៉ាល់ឬរាងកប៉ាល់នោះឯង។

ដោយហេតុនេះបានជាលទ្ធិយោគីប្រកាន់ថា ក្នុងខ្លួនមនុស្សយើងកាយជារបស់គ្រោតគ្រាតបំផុត ហើយមានសេចក្តីសំខាន់នឹងមាំមួនយ៉ាង

តិចបំផុតជាងធម្មជាតិឯទៀត អ្នកមិនដែលរិះគិតឲ្យជ្រាលជ្រៅក៏ឃើញត្រឹមតែថា មនុស្សមានតែរាងកាយជារបស់សំខាន់ទំនុកបំរុងរកតែសេចក្តីសុខឲ្យរាងកាយប៉ុណ្ណោះក៏ល្មមសមគួរហើយ បើប្រសិនជាគិតជញ្ជឹងឲ្យជ្រៅទៅកាយគ្រាន់តែជាភាគ១ ក្នុងភាគ ៧ របស់មនុស្សប៉ុណ្ណោះ នៅមាន៦ ភាគទៀត ដែលយើងត្រូវយកចិត្តទុកដាក់ទំនុកបំរុងរក្សាធ្វើឲ្យល្អឡើងនឹងបានប្រើជាប្រយោជន៍បានបើចេះប្រើ។

ឯសេចក្តីទាំងប៉ុន្មានដែលពោលមកហើយក្នុងលទ្ធិយោគីនេះ អ្នកតែងសៀវភៅថាពុំមែនជាគំនិតរបស់ខ្លួនទេ គ្រាន់តែជ្រើសរើសយកសេចក្តីក្នុងសៀវភៅរបស់យោគីមកបរិយាយទុក ដើម្បីជាវិនិច្ឆ័យរបស់លោកអ្នកមើលតទៅ ។

## ខ-គោលចារកសិណនឹងឈាន

អ្នកមើលសៀវភៅនេះគង់ឆ្ងល់ថា ហេតុអ្វីបានជាអ្នកតែងសៀវភៅចាប់ផ្តើមអធិប្បាយអំពីកសិណនឹងឈានតែម្តង មិនអធិប្បាយអំពីវិធីផ្សេងៗសិន។ ព្រោះគោលវិជ្ជារបស់ព្រះពុទ្ធសាសនាដែលនាំមកជ្រៀតទុកតាំងពីឥទ្ធិវិធីជាដើម ដែលបានសំដែងវិធីផ្សេងៗ ពីគ្នាក្នុងការដែលនឹងធ្វើឥទ្ធិវិធី ទិព្វសោត ចេតោបរិយញ្ញាណ បុព្វេនិវាសានុស្សតិញ្ញាណនឹងទិព្វចក្ខុមុននឹងធ្វើវិធីផ្សេងៗដូចលោកញែកទុកជារឿងៗនោះ តោងធ្វើកសិណនឹងឈានជាមុនដរាបទៅ គឺត្រូវធ្វើកសិណដោយអនុលោម (តាមលំដាប់) នឹងបដិលោម (ច្រាសឡើង ជាមុនសិន បានចូលឈានដោយអនុលោមបដិលោមដូចគ្នាស្រេចហើយបានត្រឡប់ទៅរកវិធីដែលលោកពោលទុកជារឿងៗ នឹងធ្វើឥទ្ធិវិធីឬទិព្វសោតឬក៏ចេតោបរិយញ្ញាណ ។ល។ ក៏បានតាមចិត្ត ពោលយ៉ាងងាយគឺតាមគោលក្នុងផ្លូវសាសនារបស់យើងនេះ កសិណនឹងឈានជាកាំជណ្តើរដំបូងដូចជាវេយ្យាករណ៍

ដែលត្រូវរៀនជាមុនប្រែគម្ពីរ បើយើងមិនទាន់ចូលចិត្តយល់ផ្លូវសិណនឹងឈានជាមុន ទៅចាប់រៀនវិជ្ជា៨ប្រការតែម្តងនោះប្រៀបដូចយើងរៀនភាសាតាងប្រទេស មិនទាន់បានរៀនវេយ្យាករណ៍ជាមុនស្រាប់តែយកសៀវភៅរឿងនីមួយៗទៅឲ្យគ្រូបង្ហាត់ប្រែតែម្តងយើងក៏នឹងមាន សេចក្តីលំបាកជាដរាប ហេតុនេះឃើញថាត្រូវចាប់ផ្តើមអធិប្បាយគោលទាំងពីរប្រការនេះសិន មុននឹងចែកវិជ្ជា៨ប្រការជាខ ៗតទៅ បើយើងចូលចិត្តក្នុងផ្លូវកសិណហើយក៏នឹងបានជួយឲ្យយើងអាចដោះស្រាយប្រស្នា ផ្សេងៗអំពីឥទ្ធិបាដិហារិយ៍របស់ព្រះពុទ្ធជាម្ចាស់ដូចមានពោលទុកក្នុង សៀវភៅពុទ្ធានុភាព(១) បានងាយស្រួលឡើងជាច្រើន។

ឯសៀវភៅទាំងឡាយ ដែលអធិប្បាយអំពីកសិណនឹងឈានដោយអ្នកប្រាជ្ញលោកតែងទុកសម្រាប់ពួកអ្នកប្រាជ្ញគ្នាលោកមើលនោះ ប្រើសុទ្ធតែពាក្យឬប្រយោគដែលសាមញ្ញជនមិនងាយចូលចិត្តបានៗ ជាពួកយើងមិនសូវយកចិត្តទុកដាក់រៀនឲ្យចូលចិត្តមក តែការដែលពោលអំពីកសីណនឹងឈានក្នុងសៀវភៅនេះ បានព្យាយាមរកពាក្យដែលងាយយល់មកដាក់ សូមអ្នកមើលសៀវភៅនេះ កុំអាលបោះបង់ចោល ចូរមើលតរៀងទៅ អាចនឹងនាំឲ្យអ្នកមើលចេះដឹងជាក់ច្បាស់។

ពាក្យដែលហៅថា កសិណ តាមសព្ទប្រែថាអ្វីក៏ពុំទាន់ប្រាកដនៅឡើយ តែតាមលក្ខណៈ គឺការធ្វើចិត្តឲ្យនឹងជាសមាធិ ដោយយករបស់អ្វីមួយមកសំឡឹងមើលជាអារម្មណ៍ជាពស្តុតាង កសិណនេះលោកចែកចេញជា១០យ៉ាង ស្រេចនូវចំណង់ចង់យកអ្វីមកជាអារម្មណ៍ក៏បានតាមចិត្ត ឯក្នុងគម្ពីរវិសុទ្ធិមគ្គ លោកពោលដល់ផលដែលនឹងបានពីការចំរើនកសិណទុកដូច្នេះ ៖

---

(១) នេះជាឈ្មោះសៀវភៅមួយរបស់អ្នកតែងវិជ្ជា៨ប្រការនេះដែរ ឯសៀវភៅនោះពោលអំពីអានុភាពរបស់ព្រះពុទ្ធជាម្ចាស់ ដែលទ្រង់ប្រតិស្ថានព្រះពុទ្ធសាសនាជាអស្ចារ្យចំឡែកណាស់ហើយមានសេចក្តីចំរើននឹងស្ថិតស្ថេរជាងសាសនាឯទៀតៗ ។

១- **បឋវីកសិណ** យកដីជាអារម្មណ៍ បើចំរើនបានសម្រេចអាចនិម្មិតខ្លួនមួយឲ្យឃើញជាច្រើនបាន និម្មិតឲ្យកើតជាផែនដីអណ្តែតនៅក្នុងអាកាសឬលើទឹក រួចទៅដើរ, ឈរ, អង្គុយ លើនោះបាន។

២- **អាបោកសិណ** យកទឹកជាអារម្មណ៍ បើចំរើនបានសម្រេច អាចធ្វើផែនដីឲ្យទៅជាទឹក រួចទៅមុជងើបបាន ធ្វើឲ្យភ្លៀង ធ្វើទីផ្សេងៗឲ្យទៅជាទឹកបាន ធ្វើឲ្យផែនដីនឹងភ្នំរញ្ជួយកក្រើកបាន។

៣- **តេជោកសិណ** យកភ្លើងជាអារម្មណ៍ បើចំរើនបានសម្រេចអាចបណ្តាលឲ្យភ្លើងឆេះឬរលត់នូវទីណាក៏បាន ឬធ្វើឲ្យមានពន្លឺភ្លឺឃើញរូបដោយទិព្វចក្ខុក៏បាន។

៤- **វាយោកសិណ** យកខ្យល់ជាអារម្មណ៍ បើចំរើនបានសម្រេចអាចបណ្តាលឲ្យខ្យល់កើតបានតាមចិត្ត។

៥- **នីលកសិណ** យកពណ៌ខៀវជាអារម្មណ៍ បើចំរើនបានសម្រេចអាចនិម្មិតរូបឲ្យខៀវឬធ្វើឲ្យងងឹតឈ្លប់ក៏បាន។

៦- **បីតកសិណ** យកពណ៌លឿងជាអារម្មណ៍ បើចំរើនបានសម្រេចអាចនិម្មិតរូបឲ្យលឿង អធិស្ឋានរបស់អ្វីៗឲ្យទៅជាមាសក៏បាន។

៧- **លោហិតកសិណ** យកពណ៌ក្រហមជាអារម្មណ៍ បើចំរើនបានសម្រេច អាចនិម្មិតរូបឲ្យក្រហមឬចង់ធ្វើពណ៌ណាៗឲ្យទៅជាក្រហមក៏បាន។

៨- **ឱទាតកសិណ** យកពណ៌សជាអារម្មណ៍ បើចំរើនបានសម្រេចអាចធ្វើពណ៌ណាៗឲ្យទៅជាពណ៌សបាន ធ្វើខ្លួនឯងមិនឲ្យងងុយដេកដាស់មនុស្សដទៃឲ្យក្រោកពីលក់ កំចាត់ងងឹតឲ្យភ្លឺ ឲ្យមានពន្លឺឃើញរូបបាន។

៩- **អាលោកកសិណ** យកពន្លឺជាអារម្មណ៍ បើចំរើនបានសម្រេច

អាចធ្វើបានដូចគ្នានឹងឱទាតកសិណ។

១០- **បរិច្ឆិន្នាកាសកសិណ** យកចន្លោះប្រហោងជាអារម្មណ៍ បើចំរើនបានសម្រេច អាចធ្វើផែនដីនឹងភ្នំឬរបស់អ្វីដែលរឹងដូចជាជញ្ជាំងកំផែងឲ្យទៅជាអាកាសរួចដើរចេញចូលបាន។

ផលនៃកសិណទាំង១០នេះ យើងនឹងជឿឬមិនជឿក៏បាន តែគួរយើងរឭកគិតមើល កាលព្រះពុទ្ធឃោសាចារ្យនិមន្តទៅស្រុកលង្កាប្រមាណចា ១៦០០ឆ្នាំថ្លាយហើយ លោកនិមន្តទៅមានបំណង់ចង់ប្រែគម្ពីរព្រះបរិយត្តិធម៌ ពីភាសាសលង្កាមកជាមគធ វេលាដែលនិមន្តទៅដល់លោកបានចូលទៅសុំអនុញ្ញាតលោកព្រះសង្ឃបាល ជាកំពូលសង្ឃក្នុងលង្កាទ្វីប សម័យនោះព្រះសង្ឃបាលមុននឹងអនុញ្ញាតឲ្យប្រែគម្ពីរលោកបាននិមន្តឲ្យព្រះពុទ្ធឃោសាចារ្យ តែងគម្ពីរមួយដើម្បីនឹងបានមើលឲ្យដឹងថា ព្រះពុទ្ធឃោសាចារ្យមានចំណេះចេះដឹងត្រឹមណា ព្រះពុទ្ធឃោ-សាចារ្យក៏បានតែងគម្ពីរវិសុទ្ធិមគ្គនេះ ប្រគេនឲ្យព្រះសង្ឃបានទតមើលៗចប់ហើយ ក៏មានចិត្តសទ្ធាជឿជាក់ជាប្រាកដថា ព្រះពុទ្ធឃោសាចារ្យមានចំណេះចេះដឹងធ្លុះធ្លាយពិតមែន ក៏ព្រមអនុញ្ញាតឲ្យប្រែព្រះបរិយត្តិធម៌ហើយបានទាំងជួយទំនុកបម្រុងទាល់តែប្រែចប់ជាស្រេច បើប្រសិនជាសេចក្តីដែលព្រះពុទ្ធឃោសាចារ្យតែងទុកក្នុងគម្ពីរវិសុទ្ធិមគ្គ ត្រង់ធ្វើកសិណនោះជាសេចក្តីមិនពិត ហេតុអ្វីបានជាព្រះសង្ឃបាល ដែលជាកំពូលសង្ឃនិយមយល់ព្រមជឿតាម សេចក្តីនេះគួរពិចារណាឲ្យដឹងឃើញមុនវិធីដែលនឹងចំរើនកសិណតទៅ។

## វិធីចំរើនកសិណ

វិធីចំរើនកសិណនេះ ព្រះពុទ្ធឃោសាចារ្យបានអធិប្បាយកសិណជាដំបូងគឺបឋវីកសិណដោយពិស្តារ រួចបានបរិយាយកសិណឯទៀតៗជាសង្ខេប ព្រោះកសិណទាំង១០នេះ មានគោលដូចគ្នា ខុសពីគ្នាបន្តិច

បន្តច។

# ១- បឋវីកសិណ

ការចំរើនបឋវីកសិណ ទាំងពីរដើមដល់ចប់នោះមាន ៦ ប្រការ

១- រៀបចំរបៀបនឹងវិធីសំឡឹងមើល

២- កើតឧគ្គហនិមិត្ត

៣- កើតបដិភាគនិមិត្ត

៤- កើតឧបចារសមាធិ

៥- កើតអប្បនាសមាធិ

៦- វិធីបម្រុងរក្សាអប្បនាសមាធិឲ្យមាំមួន ទាល់តែកើតឈាន។

## ១- របៀបរៀបចំនឹងវិធីសំឡឹង

របៀបចំរើនបឋវីកសិណនោះ ហាមមិនឲ្យយកដីព័ណ៌ខៀវ, លឿង, ក្រហម, ស ឲ្យរើសរកយកតែដីព័ណ៌អរុណ (គង់ជាព័ណ៌ក្រហ្មលាយលឿង) ក្នុងគម្ពីរវិសុទ្ធិមគ្គ ឲ្យយកដីដូចដីក្នុងទន្លេគង្គា នៅក្នុងប្រទេសឥណ្ឌៀ យើងនឹងរកឲ្យបានដីយ៉ាងនោះដូចម្តេចបាន ព្រោះនៅឆ្ងាយផុតវិស័យទៅរកមកធ្វើជាគំរូបាន ដីដែលនឹងយកមកប្រើនោះ ត្រូវរើសយកឫសស្មៅនឹងក្រួសខ្សាច់ចោលចេញឲ្យអស់ ច្របាច់ច្របល់ដីនោះឲ្យល្អរួចហើយត្រូវធ្វើជើងរងទំហំបួនជ្រុង បោះភ្ជាប់នៅទីកន្លែងក៏បាន ឬធ្វើសម្រាប់លើកបានក៏បាន រួចយកសម្ពត់ឬកំណាត់កន្ទេលក៏បាន ពាសពីលើឈើរងស្រេចហើយយកដីនោះមកលាបឲ្យល្មមកម្រាស់ឃើញសាច់ដីនៅលើនោះ រួចយកឈើគ្មានជ័រមកកៀសឲ្យរាបស្មើ ទំហំវង់មូល១ចំអាម ៤ធ្នាប់ធ្វើជើងម៉ាសម្រាប់អង្គុយ កំពស់១ចំអាម ៤ ធ្នាប់ដូចគ្នា ជើងម៉ានេះតាំងចម្ងាយពីវង់កសិណ ២ ហត្ថ ១ចំអាម ល្មមតែអង្គុយសំឡឹងមើលវង់

កសិណដោយងាយមិនឱនឬងើបឲ្យទាល់តែរួយក ឯទីកន្លែងដែលនឹងរៀបចំចំរើនកសិណនេះ ត្រូវរកទីស្ងាត់កុំឲ្យមានអ្វីមកធ្វើឲ្យកង្វល់ចិត្តបាន ក្នុងទីដែលសម្រាប់អង្គុយចំរើនកសិណនោះ ត្រូវបោសសំអាតឲ្យស្អាតរួច ងូតទឹកសំអាតខ្លួនឲ្យស្រេច សឹមទៅអង្គុយសំឡឹងកសិណ មិនឲ្យនឹកដល់ព័ណ៌ឬលក្ខណៈរូបដីនោះ ឲ្យនឹកភាវនា "បឋវី" ដីៗតែម្យ៉ាងបើកភ្នែកខ្លះ បិទភ្នែកខ្លះ ទាល់តែឧគ្គហនិមិត្តកើតឡើង តាមក្នុងគម្ពីរវិសុទ្ធិមគ្គថាត្រូវធ្វើបានមួយរយឬមួយពាន់ដង។ ទីកន្លែងសម្រាប់អង្គុយចំរើននោះ ត្រូវរៀបទុកមួយកន្លែងទៀតសម្រាប់ការ កាលណាបើបានឧគ្គហនិមិត្តកើត ហើយនឹងក្រោកទៅអង្គុយ ដូចមានពណ៌នាតទៅនេះ។

## ២- កើតឧគ្គហនិមិត្ត

ឧគ្គហនិមិត្តនោះ គឺសំគាល់ចាំមើលនិមិត្តឲ្យឃើញជាប់នឹងភ្នែក ធ្មេចភ្នែកក៏នៅឃើញវង់ដីដូចបើកភ្នែក ដូចយើងសំឡឹងមើលព្រះអាទិត្យ រួចបិទភ្នែកទៅ នៅឃើញផ្សែងភ្លឺជាប់នឹងភ្នែកបានមួយស្របក់ តែឧគ្គ-ហនិមិត្តនោះ ត្រូវរក្សាឲ្យឃើញជាប់នៅភ្នែកឲ្យបានយូរតាមយើងត្រូវការ បើបាត់ទៅកាលណា យើងត្រូវការនឹងនឹកយកមកឲ្យឃើញនៅនឹងភ្នែក យើងវិញបាន កាលណាឧគ្គហនិមិត្តកើតឡើងហើយ លោកឲ្យក្រោក ចេញពីទីនោះ ទៅអង្គុយនៅទីដែលរៀបបំរុងទុកនោះ នាំយកឧគ្គហនិមិត្ត ឲ្យជាប់នឹងភ្នែកទៅអង្គុយធ្មេចភ្នែកឲ្យឃើញដូចកាលអង្គុយនៅកន្លែង មុន កិច្ចនេះមិនមែនជារបស់ងាយទេ តាមគម្ពីរវិសុទ្ធិមគ្គប្រដៅឲ្យរកស្បែក ជើងទុក បើបានឧគ្គហនិមិត្តហើយក្រោកទៅពាក់ស្បែកជើង ដើរទៅ អង្គុយនៅទីដែលខ្លួនបំរុងទុក១កន្លែងទៀត បានជាឲ្យពាក់ស្បែកជើង ព្រោះកុំឲ្យរវល់លាងជើងនាំឲ្យខូចពេល ត្រូវចំរើនឧគ្គហនិមិត្តដូច្នេះទាល់ តែកើតបដិភាគនិមិត្ត ។

## ៣- កើតបដិភាគនិមិត្ត

បដិភាគនិមិត្តនោះ តាមគម្ពីរវិសុទ្ធិមគ្គអធិប្បាយថា ៖ ឃើញរូបដីដែលជាប់នឹងភ្នែកអណ្តែតឡើង មូលដូចដួងព្រះចន្ទដែលផុះចេញពីស្រទាប់មេឃ ឃើញច្បាស់ជាងឧគ្គហនិមិត្តទាំងមួយរយភាគ តាមសេចក្តីអធិប្បាយរបស់សម្តេចព្រះមហាសមណវជិរញ្ញាណវរោរសថា "កាលណាអ្នកចំរើនកសិណ ឈោងដល់ឧគ្គហនិមិត្តដែលបានសម្រេចហើយនោះយកមកពង្រីកឬបង្រួមបានតាមចិត្ត កាលណោះទើបទុកជាបដិភាគនិមិត្តមានកំឡាំងជាងឧគ្គហនិមិត្តជាច្រើន ។

## ៤- កើតឧបចារសមាធិ

ឧបចារសមាធិ សំដៅយកសមាធិយ៉ាងជ្រលិះៗ គឺថាបើកើតបដិភាគនិមិត្តហើយ ចិត្តដំកល់នឹងបានមួយស្របក់ៗ តែអាចនឹងប្រែប្រួលវិញដោយងាយ ហេតុដូច្នេះត្រូវតែព្យាយាម រម្ងាប់ចិត្តឲ្យចុះនៅក្នុងវង់កសិណដែលជានិមិត្តជាប់ភ្នែកនោះឲ្យនៅជាប់ជាដរាប ទាល់តែកើតអប្បនាសមាធិ។

## ៥- កើតអប្បនាសមាធិ

អប្បនាសមាធិ សំដៅយកសមាធិខ្ជាប់ខ្ជួនជាបំផុត ពោលគឺតាំងចិត្តឲ្យមាំនៅក្នុងអារម្មណ៍តែមួយបានទាំងយប់ទាំងថ្ងៃ មិនឲ្យដួងចិត្តប្រែប្រួលទៅកាន់អារម្មណ៍ផ្សេងៗឡើយ ។

## ៦- វិធីបំរុងរក្សាអប្បនាសមាធិ

បើអ្នកចំរើនកសិណ បានលុះដល់អប្បនាសមាធិហើយ ក៏ទុកជាបានដល់ទីខ្ពស់បំផុតក្នុងការចំរើនកសិណ (ត្រង់ដែលនឹងធ្វើឫទ្ធិតេជះ

យ៉ាងណានោះចូរមើលត្រង់និយាយអំពីវិជ្ជា៨ប្រការតទៅចុះ) ឯអប្បនាសមាធិជាធម្មជាតិពិបាករក្សា អ្នកដែលចំរើនបានហើយតោងព្យាយាមរក្សាឲ្យមាំមួន ដូចក្នុងគម្ពីរវិសទ្ធិមគ្គប្រៀបទុកថា ឲ្យរក្សាដូចស្ត្រីកែវរក្សាគភ៌ដែលមានស្តេចចក្រពត្តិមកបដិសន្ធិ ពោលគឺត្រូវចំរើនអប្បនាសមាធិនេះជានិច្ច ក្នុងវេលាមិនបានចំរើន ក៏ត្រូវរក្សាខ្លួនឲ្យល្អ ប្រយ័ត្នកុំឲ្យមានអ្វីខាងក្រៅមកធ្វើឲ្យចិត្តកង្វល់រួញរានាំឲ្យកើតសេចក្តីប្រមាទ ក្នុងការធ្វើសមាធិ ឲ្យសោយបាត់ទៅនោះ ការនឹងរក្សាខ្លួន ក្នុងគម្ពីរវិសុទ្ធិមគ្គអធិប្បា-យថា ៖

១- ឲ្យរកទីកន្លែងនៅជាសប្បាយ

២- រាំងកុំឲ្យពន្លឺព្រះអាទិត្យចាំងភ្នែក

៣- ចៀសវាងពីពាក្យមិនពីរោះ

៤- បរិភោគអាហារដែលមិនឲ្យទោសដល់រូបកាយ

៥- ឲ្យចេះបង្ខំចិត្តដំកល់ចិត្តនឹងលួងលោមចិត្តឲ្យស្រស់នៅស្មើជាដរាប

៦- ចៀសវាងពីមនុស្សមានលក្ខណៈចិត្តទន់រវើរវាយ រើសគប់តែមនុស្សដែលមានលក្ខណៈចិត្តរឹងមាំមួន

៧- រាំងកុំឲ្យចិត្តរហ័សឬខ្ជឹលប្រអូស។

## ២-អាបោកសិណ

ការចំរើនអាបោកសិណ គម្ពីរសុទ្ធិមគ្គពោលថា បើមនុស្សមានបុណ្យកុសលជាប់មកពីជាតិមុន នឹងយកទឹកអ្វីៗ មកធ្វើជាកសិណក៏បាន ឬគ្រាន់តែឃើញទឹកនៅក្នុងស្រះ ក្នុងអណ្តូងឬនៅក្នុងទន្លេ ក៏កើតនិមិត្តបានរំពេច បើមនុស្សទើបហាត់ថ្មី មិនឲ្យយកទឹកដែលមានព័ណ៌ ខៀវលឿង ក្រហម ស មកធ្វើជាកសិណឡើយ គួរយកទឹកភ្លៀង ដែលធ្លាក់

មិនទាន់ដល់ដី ឬទឹកដែលថ្លាបរិសុទ្ធមិនល្អក់ដាក់ក្នុងបាត្រឬផើងឲ្យពេញល្មមស្មើមាត់ រួចអង្គុយសំឡឹងភាវនាធ្វើតាមរបៀបដូចមានក្នុងបឋវីកសិណ ឧគ្គហនិមិត្តសំរាប់អាបោកសិណនេះឲ្យឃើញទឹករញ្ជួយរលកញាប់ញ័រ ឯបដិភាគនិមិត្តត្រឡប់ឃើញជាទឹកនឹងថ្កល់មិនរញ្ជួយញាប់ញ័រឡើយ តពីនេះទៅត្រូវធ្វើឲ្យដូចពោលមកហើយក្នុងបឋវីកសិណ ។

## ៣- តេជោកសិណ

លោកអធិប្បាយថា អ្នកដែលមានបុណ្យកុសលហើយគ្រាន់តែឃើញអណ្តាតភ្លើងចង្កៀងចង្ក្រានឬភ្លើងឆេះព្រៃ ក៏អាចកើតនិមិត្តបានអ្នកដែលទើបរៀនចំរើន លោកឲ្យយកឈើមានខ្លឹមមកពុះ ជាចំរៀកហាលឲ្យស្ងួតផ្គុំបង្កាត់ឲ្យឆេះឲ្យមានអណ្តាតភ្លើងរួចហើយ យកកំណាត់កន្ទេលឬស្បែកឬក៏សំពត់មកចោះកណ្តាលជាប្រហោងប្រមាណ ១ ចំអាម ៤ធ្នាប់ធ្វើរបៀបដូចបឋវីកសិណ ស្រេចហើយអង្គុយសំឡឹងភាវនាទាល់តែឧគ្គហនិមិត្តកើតឃើញអណ្តាតភ្លើងកំពុងញាប់ញ័រ ឯបដិភាគនិមិត្តធ្មេចភ្នែកឃើញអណ្តាតភ្លើងនៅនឹងថ្កល់មិនញាប់ញ័រ លោកប្រៀបប្រដូចឃើញកំណាត់សំពត់ក្រហមដាក់នៅកណ្តាលអាកាស តពីនេះធ្វើឲ្យដូចបឋវីកសិណ ។

## ៤-វាយោកសិណ

ការចំរើនយកខ្យល់ជាអារម្មណ៍ លោកបញ្ញត្តទុក២យ៉ាង ម្យ៉ាងយកខ្យល់ដែលបក់មកប៉ះកាយ ម្យ៉ាងទៀតឃើញខ្យល់ដែលបកត្រូវស្លឹកឈើល្វិចៗ ឧគ្គហនិមិត្តកើតឡើងឃើញខ្យល់ញាប់ញ័រ ដូចចំហាយបាយពុះទើបដាក់ពីចង្ក្រាន ឯបដិភាគនិមិត្ត ឃើញនៅនឹងថ្កល់មិនញាប់ញ័រ។

## ៥- និលកសិណ

លោកអធិប្បាយថា នឹងយកផ្កាលំចង់ខៀវ ឬផ្កាអញ្ចាន់ ឬក៏សំពត់ព័ណ៌ខៀវមកពាសពីលើមាត់ប្រអប់ឬវត្ថុអ្វីមួយដូចជាស្គរក៏បាន ឧគ្គហនិមិត្តកើតឡើងឃើញទងព្រមនឹងផ្កា ឬរបស់អ្វីៗ ដែលយកមកប្រើជាកសិណនោះផង ឯបដិភាគនិមិត្តមិនឃើញអ្វីក្រៅពីពណ៌ខៀវនោះឡើយ ឃើញច្បាស់តែពណ៌ខៀវម្យ៉ាង ។

## ៦- បីតកសិណ

## ៧- លោហិតកសិណ

## ៨- ឱិបាតកសិណ

ទាំង៣ នេះមានន័យដូចគ្នានឹងនីលកសិណ គ្រាន់តែផ្លាស់ពណ៌ជាលឿង ក្រហម ស វិញប៉ុណ្ណោះ ។

## ៩- អាលោកកសិណ

លោកបញ្ញត្តថា យកពន្លឺតាមចន្លោះជញ្ជាំង បង្អួច ឬដុតភ្លើងរួចចោះប្រហោងយកពន្លឺភ្លើងដែលឆ្លុះមកជាប់នៅទីណាៗជាអារម្មណ៍ក៏បាន ឧគ្គហនិមិត្តកើតឡើង ឃើញពន្លឺនឹងរបស់ផ្សេងៗ ដែលជាប់នៅទីនោះ ឯបដិភាគនិមិត្ត ឃើញចំពោះតែពន្លឺប៉ុណ្ណោះ ។

## ១០- បរិច្ឆិន្នាកាសកសិណ

កសិណនេះ មើលទៅពិបាកជាងកសិណឯទៀត លោកបញ្ញត្តថាឲ្យយកចន្លោះវាលណាមួយ ដូចជាចន្លោះបង្អួច ទ្វារ ជញ្ជាំង ឲ្យនឹកតែត្រឹមចន្លោះប៉ុណ្ណោះ មិនឲ្យគិតនឹកដល់ពន្លឺឬខ្យល់ឲ្យសោះ ឧគ្គហនិមិត្តកើតឡើង ឃើញចន្លោះព្រមនឹងក្របបង្អួច ទ្វារ ឬជញ្ជាំង ឯបដិភាគនិមិត្ត ឃើញតែចន្លោះវាលមួយមុខ មិនឃើញរបស់អ្វីជាប់ជាមួយផងឡើយ ។

## ២-ឈាន

កាលណាចិត្តលុះអប្បនាសមាធិហើយ សេចក្តីសំរើបក្នុងកាមគុណ នឹងអកុសលចិត្តទាំងឡាយក៏អស់ទៅ ពោលគឺអស់សេចក្តីខ្វល់ខ្វាយក្នុងកាមតណ្ហា ហើយមិនមានចិត្តប្រទូសរ៉ាយនឹងអ្នកណា ចិត្តស្ងប់ស្ងាត់បាន ទើបហៅថាបានឈាន ឈាននេះចែកជាពីរប្រភេទ គឺ ៖

ក- រូបជ្ឈាន (ឈានមានរូប) ចែកជា ៤ គឺ :

១- **បឋមជ្ឈាន** ឈានទី ១

២- **ទុតិយជ្ឈាន** ឈានទី ២

៣- **តតិយជ្ឈាន** ឈានទី ៣

៤- **ចតុត្ថជ្ឈាន** ឈានទី ៤

ខ- អរូបជ្ឈាន (ឈានគ្មានរូប) ចែកជា ៤ ដូចគ្នាគឺ:

១- អាកាសានញ្ចាយតនជ្ឈាន ពិចារណាឃើញបដិភាគនិមិត្ត របស់កសិណទាំងនោះ ទាល់តែឃើញអាកាសទទេគ្មានអ្វីសោះ

២- វិញ្ញានញ្ចាយតនជ្ឈាន យកវិញ្ញាណជាអារម្មណ៍

៣- អាកិញ្ចញ្ញាយតនជ្ឈាន គ្មានអ្វីជាអារម្មណ៍ឡើយ

៤- នេវសញ្ញានាសញ្ញាយតនជ្ឈាន គ្មានអាម្មណ៍អ្វីឡើង បុគ្គលដែលលុះដល់ទីនេះ នឹងថាដឹងខ្លួន ឬថាមិនដឹងខ្លួនក៏ពុំបាន ។

អ្នកដែលបានឃើញឈ្មោះឈានទាំង ៨ នេះហើយ គង់មានចិត្តធុញថប់មួយរំពេច ដោយឃើញថាជារបស់ពិបាកចូលចិត្ត ហេតុដូច្នេះ សូមអ្នកមើលកុំអាលលះបង់នូវសេចក្តីឧស្សាហ៍ ចូរទុកចិត្តថាសៀវភៅវិជ្ជា៨ ប្រការនេះនឹងចុះសុទ្ធតែសេចក្តីធ្វើឲ្យអ្នកមើល បានយល់ចូលចិត្ត មិនយកសេចក្តីដែលមិនយល់មកចុះទុកក្នុងទីនេះឡើយ ។

### ក- អធិប្បាយពីរូបជ្ឈាន

មុនដែលយើងនឹងពិចារណាដល់រូបជ្ឈាន យើងត្រូវឲ្យយល់ចូលចិត្ត

ពីចិត្តរបស់មនុស្សសិន ព្រោះចិត្តមនុស្សតែងតែមានធម្មជាតិច្រើនយ៉ាងទាំងល្អទាំងអាក្រក់ច្របល់គ្នា ដូចជាពាក្យបុរាណថា កិលេសមួយពាន់ប្រាំរយ តណ្ហាមួយរយប្រាំបី តែយើងមិនបាច់យកចំនួននោះមកចែកអធិប្បាយឡើយ ទុកជូនលោកអ្នកអ្នកប្រាជ្ញជាន់ខ្ពស់លោកពណ៌នាចុះ សម្រាប់ពួកយើងត្រូវការយកតែសេចក្តី ដែលចូលចិត្តយល់ដ៏ល្មមសមគួរ យើងញែកតែត្រឹម១០ទាំងកិលេសនឹងតណ្ហា រួមនឹងធម្មជាតិដែលល្អផងក្នុង១០ ប្រការនេះ យើងយកមករៀបជាជួរទុក ល្អ១ពួក អាក្រក់១ពួក ដូច្នេះ ។

| **ពួកល្អ** | **ពួកអាក្រក់** |
|---|---|
| ១- សមាធិ | ៦- កាមច្ឆន្ទ |
| ២- បីតិ | ៧- ព្យាបាទ |
| ៣- វិតក្ក | ៨- ថីនមិទ្ធ |
| ៤- សុខ | ៩- ឧទ្ធច្ចកុក្កុច្ច |
| ៥- វិចារ | ១០- វិចិកិច្ឆា ។ |

ធម៌ទាំងនេះជាលក្ខណៈរបស់ចិត្តមនុស្សធម្មតា ឯដួងចិត្តមនុស្សយើងមានសមាធិតាំងមាំមួនខ្លះ តែកាលណាបើចិត្តយើងកើតសេចក្តីស្រឡាញ់ខ្វល់នូវរបស់អ្វីមួយ កាមច្ឆន្ទកើតឡើងវេលានោះសមាធិក៏ខូចចិត្តក៏អណ្តែតអណ្តូងមួយរំពេច ។ តាមប្រក្រតី ចិត្តយើងមាន បីតិ រីករាយ តែកាលណាបើចិត្តនឹកដល់របស់ដែលគេធ្វើឲ្យទាស់ចិត្តយើង បីតិក៏រលាយក្លាយទៅជាព្យាបាទវិញ។ យើងមានចិត្តសម្រាប់នឹកគិតដល់របស់អ្វីៗមួយ ហៅថា វិតក្ក តែមានកាលយើងចោលមិននឹកនា ព្រោះចិត្តយើងរួញដោយងងុយដេក ថីនមិទ្ធក៏កើតឡើង។ ធម្មជាតិសាងយើងមកឲ្យមានសេចក្តីសុខ យើងត្រូវការសេចក្តីសុខគ្រប់គ្នា តែមានកាលចិត្តយើងរាយមាយជា ឧទ្ធច្ច រំខានចិត្តជាកុក្កុច្ច មកកាត់សេចក្តីសុខចេញ។ យើងមាន

សតិបញ្ញាសម្រាប់ត្រិះរិះ (វិចារ) រកផ្លូវដែលជាប្រយោជន៍របស់យើង តែកាលណាបើកើតសេចក្តីសង្ស័យ (វិចិកិច្ឆា) មិនដាច់ស្រេចទៅផ្លូវណា ត្រិះរិះគិតអ្វីក៏មិនសម្រេច ។

កាលណាយើងចូលចិត្តយល់សេចក្តីទាំងនេះល្អហើយ ការដែលនឹងចូលចិត្តយល់ខាងឈានក៏ងាយឡើងជាអនេកគឺ :

១- អ្នកដែលបានសម្រេចបឋមជ្ឈាន (ឈានទី១) អាចកាត់បំបាត់សេចក្តីអាក្រក់ទាំង ៥ប្រការនោះចេញបាន នៅសល់តែពួកល្អទាំង ៥គឺ: សមាធិ, បីតិ, វិតក្ក, សុខ, វិចារ ។

២- ក្នុងធម្មជាតិល្អទាំង ៥ ប្រការនេះ វិតក្កនឹងវិចារ ក៏ជារបស់គ្រោតគ្រាតចាហេតុនាំធ្វើឲ្យចិត្តវិលវល់បាន ត្រូវព្យាយាមរំលត់វិតក្កនឹងវិចារចេញ ឲ្យនៅសល់តែសមាធិ បីតិ នឹងសុខ ធ្វើបានសម្រេចដូច្នេះហៅថាបានលុះទុតិយជ្ឈាន (ឈានទី២) ។

៣- យ៉ាងណាក៏ដោយ បីតិសេចក្តីពេញចិត្តនោះ ក៏នៅជាធម្មជាតិមិនតាន់ប្រាកដនៅឡើយ ខ្លាចក្រែងនាំយកធម្មជាតិអាក្រក់ចូលមកជាថ្មីទៀត ហេតុនេះត្រូវតែព្យាយាមលះបង់ចោលបីតិមួយនេះចេញទៀតឲ្យសល់នៅតែសមាធិនឹងសុខ អ្នកដែលធ្វើបានសម្រេចក្នុងថ្នាក់នេះឈ្មោះថាបានលុះតតិយជ្ឈាន (ឈានទី៣) ។

៤- ទុកជាដល់ថ្នាក់នេះហើយ សេចក្តីសុខក៏នៅជារបស់គ្រោតគ្រាតទៀត ព្រោះថាបើសុខនៅមាន ទុក្ខក៏គង់មានមកមួយថ្ងៃមិនខានព្រោះថាទុក្ខនឹងសុខជាគូនឹងគ្នា បានជាត្រូវលះចោលសេចក្តីសុខចេញទៀត ឲ្យនៅតែសមាធិនឹងឧបេក្ខាគឺនៅព្រងើយមិនរវល់ដល់អ្វីទាំងអស់នៅមានដួងចិត្តតែមួយដំកល់នឹង ហៅថា "ឯកគ្គតា" នេះចាត់ថាបានលុះចតុត្ថជ្ឈាន (ឈានទី៤) ។

តាមន័យនេះឃើញថា ពាក្យដែលហៅថា ឈាននោះ ទុកជាធ្វើ

ពីបាកយ៉ាងណាក្តី ការដែលចូលចិត្តលក្ខណៈរបស់ឈានហើយ មិនពិបាកដូចយើងគិតខ្លាចមកនោះទេ ព្រោះសេចក្តីអធិប្បាយទាំងប៉ុន្មាននឹងជួយឲ្យអ្នកមើលចូលចិត្តលក្ខណៈរបស់រូបជ្ឈាន ដោយមិនពិបាកឡើយ នឹងរៀបជារបៀបលក្ខណៈឈានទាំង៤នេះឲ្យច្បាស់ ដើម្បីឲ្យអ្នកមើលមានគតិរំឭកថា ឈាននោះ គឺដួងចិត្តជាថ្នាក់ៗ ទាល់តែសល់នៅបណ្តូលដែលជារបស់ល្អបំផុតនោះឯង។

### ចិត្តមនុស្សធម្មតា

| | |
|---|---|
| ១- សមាធិ...... | ៦- កាមច្ឆន្ទ |
| ២-បីតិ...... | ៧- ព្យាបាទ |
| ៣- វិតក្ក...... | ៨- ថីនមិទ្ធ |
| ៤- សុខ...... | ៩- ឧទ្ធច្ចកុក្កុច្ច |
| ៥- វិចារ...... | ១០- វិចិកិច្ឆា ។ |

### ចិត្តអ្នកលុះបឋមជ្ឈាន

| | |
|---|---|
| ១- សមាធិ...... | ៦- ...... |
| ២-បីតិ...... | ៧- ...... |
| ៣- វិតក្ក...... | ៨- ...... |
| ៤- សុខ...... | ៩- ...... |
| ៥- វិចារ...... | ១០- ...... ។ |

### ចិត្តអ្នកលុះទុតិយជ្ឈាន

| | |
|---|---|
| ១- សមាធិ...... | ៦- ...... |
| ២-បីតិ...... | ៧- ...... |

៣- ........ ៨- ......

៤- សុខ...... ៩- ......

៥- ........ ១០- ...... ។

## ចិត្តអ្នកលុះតតិយជ្ឈាន

១- សមាធិ..... ៦- ......

២-........ ៧- ......

៣- ........ ៨- ......

៤- សុខ...... ៩- ......

៥- ........ ១០- ...... ។

## ចិត្តអ្នកលុះចតុត្ថជ្ឈាន

១- សមាធិ..... ៦- ......

២-........ ៧- ......

៣- ........ ៨- ......

៤- ......... ៩- ......

៥- ........ ១០- ...... ។

## ខ- អធិប្បាយពីអរូបជ្ឈាន

ឈានទាំង៤ដែលពោលមកខាងដើមនោះ ហៅថារូបជ្ឈាន ព្រោះអាស្រ័យនូវវត្ថុដែលមានរូប គឺកសិណជាគ្រឿងជួយ បើអ្នកធ្វើធ្លាប់ចំរើនឈានទាំង ៤ ទាល់តែថ្នឹកវេលាណា បើត្រូវការធ្វើនឹងធ្វើបានសម្រេចមួយរំពេច ត្រូវហាត់ចំរើនរបស់ដែលពិបាកនឹងល្អិតតឡើងទៅទៀត គឺលើកកសិណចោលចេញ ចូលឈានមិនបាច់ប្រើកសិណតទោបាន ហៅថា

អរូបជ្ឈានៗមាន៤ ប្រការគឺ :

១- យកអាកាសជាអារម្មណ៍ គឺជញ្ជឹងនឹកថា អាកាសៗជាធម្មជាតមិនមានអ្វីជាទីបំផុត កុំឲ្យនឹកដល់បដិភាគនិមិត្ត នឹងរូបជាអារម្មណ៍ឡើយ ហៅថា **អាកាសានញ្ចាយតនជ្ឈាន** ។

២- ឈប់លើកការជញ្ជឹងដល់អាកាសចេញ ត្រូវជញ្ជឹងដល់វិញ្ញាណតែមួយមុខថា វិញ្ញាណៗជាធម្មជាតគ្មានទីបំផុត ហៅថា**វិញ្ញាន-ញ្ចាយតបជ្ឈាន** ។

៣- ឈប់លើកការជញ្ជឹងដល់វិញ្ញាណចេញ កុំនឹកដល់អ្វីឲ្យសោះ ធ្វើដួងចិត្តដំកល់ឲ្យនឹង កុំឲ្យមានអ្វីមកប៉ះពាល់ ហៅថា **អាកញ្ចញ្ញា-យតនជ្ឈាន** ។

៤- កាលណាដួងចិត្ត តម្កល់នឹងនៅក្នុងឈានយ៉ាងល្អិតបំផុតដូច្នេះ ហើយបុគ្គលដែលចម្រើនឈាននោះ ក៏បាននៅក្នុងភាវៈដែលរាប់ចូលជាវិសេសមួយ ពោលគឺមានសេចក្តីដឹងខ្លួនយ៉ាងតិចបំផុត ហាក់ដូចជាមិនដឹងខ្លួនសោះឡើយ។ អ្នកណាទៅវាយដំដូចម្តេចក៏មិនដឹងខ្លួនដែរតែជីវិតគង់មាននៅឡើយ ឈានក្នុងទីជាន់ខ្ពស់បំផុតនេះហៅថា **នេវសញ្ញានាសញ្ញាយតនជ្ឈាន** គឺថានឹងមានសញ្ញា (conscient) ក៏ថាមិនបានឬនឹងថាគ្មានសញ្ញា (inconscient) ក៏មិនមែន សូមអ្នកដែលមើលសៀវភៅនេះគួរយល់ថា វិធីផ្សេងៗតាំងពីកសិណទៅដល់ឈាននោះសុទ្ធតែជាវិធីហ្វឹកហ្វឺនដួងចិត្តជាថ្នាក់ៗតទៅ អ្នកដែលហ្វឹកហ្វឺនចិត្តដូច្នេះហើយ ដួងចិត្តតែងតែមានអំណាចជាទីបំផុត នឹងប្រើអធិដ្ឋានធ្វើអ្វីៗក៏បាន ដូចមានពណ៌នាតទៅ ក្នុងចំណែកវិជ្ជា៨ប្រការ វេលាណាមិនត្រូវការប្រើអំណាចដួងចិត្ត ក៏ជាមនុស្សធម្មតា តែបើត្រូវការប្រើក៏ចូលឈានមួយរំពេចបានមិនថាថ្នាក់ណា ហេតុនេះបានជារាប់ថាមានគ្រឿងប្រដាប់យ៉ាងប្រសើរ

សម្រាប់ធ្វើការដែលមនុស្សធម្មតាធ្វើពុំបាន ព្រោះហេតុនេះបានជាថា កសិណនឹងឈាន ជាកាំជណ្តើរដំបូងរបស់វិជ្ជា ៨ប្រការ ។

សេចក្តីបរិយាយពីលទ្ធិយោគីនឹងកសិណហើយនិងឈាន ដូចមានមកហើយនោះក៏ល្មមសមគួរហើយ តពីនេះនឹងបានបរិយាយចំណែកវិជ្ជា ៨ប្រការជាខ១សម្រាប់ប្រដាប់សតិបញ្ញាបារមីរបស់អ្នកមើលតទៅ ។

# វិជ្ជាប្រការទី១

## វិបស្សនាញាណ

វិបស្សនាញាណ មានចំណែកចែកចេញជា៩យ៉ាងគឺ:

១- **ឧទយព្វយានុបស្សនាញាណ** ប្រាជ្ញារំពឹងឃើញសេចក្តីកើតនឹងរលត់នៃសង្ខារ

២- **ភង្គានុបស្សនាញាណ** ប្រាជ្ញារំពឹងឃើញសេចក្តីរលត់នៃសង្ខារ

៣- **ភយតុបដ្ឋានញាណ** ប្រាជ្ញារំពឹងឃើញសង្ខារថាគួរឲ្យខ្លាច

៤- **អាទីនវានុបស្សនាញាណ** ប្រាជ្ញារំពឹងឃើញទោសនៃសង្ខារ

៥- **និព្វិទានុបស្សនាញាណ** ប្រាជ្ញារំពឹងឃើញនូវសង្ខារថាគួរនឿយណាយជិនឆ្អន់

៦- **មុញ្ចិតុកម្យតាញាណ** ប្រាជ្ញារំពឹងដោយមានប្រាថ្នានឹងចង់ចេញឲ្យផុតទៅ

៧- **បដិសង្ខានុបស្សនាញាណ** ប្រាជ្ញារំពឹងគិតរកផ្លូវរកឧបាយ

៨- **សង្ខារុបេក្ខាញាណ** ប្រាជ្ញារំពឹងដោយសេចក្តីព្រងើយកន្តើយក្នុងសង្ខារ

៩- **សច្ចានុលោមិកញ្ញាណ** ប្រាជ្ញាប្រព្រឹត្តទៅដោយសមគួរដល់ការកំណត់ដឹងនូវអរិយសច្ច ។

តាមសេចក្តីអធិប្បាយ របស់សម្តេចព្រះមហាសមណវជិរញ្ញាណវរោរស ទ្រង់ធ្វើអត្ថាធិប្បាយទុកថា ញាណទី១រំពឹងឃើញសេចក្តីកើតនឹងសេចក្តីរលត់នៃសង្ខារ។ ញាណទី២លើកលែងរំពឹងដល់សេចក្តីកើត រំពឹងយកជាអារម្មណ៍ចំពោះតែសេចក្តីរលត់នៃសង្ខារនោះវិញ។ ញាណទី៣រំពឹងឃើញសង្ខារនោះមានសេចក្តីរលត់ជាប្រាកដ គួរឲ្យខ្លាច ដូចខ្លាចសត្វសាហាវមានសីហៈជាដើម។ ញាណទី៤រំពឹងឃើញទោសនៃសង្ខារនោះដូចជាផ្ទះដែលភ្លើងឆេះហើយ ។ ញាណទី៥រំពឹងដល់សង្ខារដែលនាំឲ្យមានទោសក៏នឿយណាយជិនឆ្អន់។ ញាណទី៦ រំពឹងចង់ចេញចាកពីសង្ខារ ដែលបាននឿយណាយហើយនោះ ដូចជាសត្វត្រូវអន្ទាក់ចង់តែឲ្យរួចចេញពីអន្ទាក់ ។ ញាណទី៧ រំពឹងដោយពិចារណាត្រិះរិះរកផ្លូវចេញឲ្យផុតពីសង្ខារដូចជាសត្វដែលហៅថាសមុទ្រសកុណីចុះលេងក្នុងសមុទ្រ ។ ញាណទី៨ រំពឹងដោយសេចក្តីព្រងើយកន្តើយក្នុងសង្ខារ ដូចជាបុរសដែលមិនអើពើនឹងភរិយាដែលបានលែងគ្នាហើយនោះ ។ ញាណទី៩ រំពឹងទៅដោយខណៈនៃចិត្តដែលឈ្មោះថាអនុលោមកើតឡើង ក្នុងលំដាប់មនោទ្វារាវជ្ជនៈ កាត់នូវភវង្គដែលកើតឡើងក្នុងខណៈដែលអរិយមគ្គនឹងកើតជាទីបំផុតនៃសង្ខារុបេក្ខាញាណ ។

សេចក្តីអធិប្បាយរបស់សម្តេចព្រះមហាសមណអស់តែប៉ុណ្ណេះ។

បើយើងពិចារណាមើលឲ្យល្អ នឹងឃើញថាធម៌ទាំងឡាយរបស់ព្រះពុទ្ធជាម្ចាស់គ្រប់ខ ក្រៅពីធម៌ឯទៀតដែលគួរសរសើរមកហើយនោះនៅមានធម៌ដែលគួរសរសើរជាទីបំផុត គឺវិជ្ជា៨ ប្រការនេះ គួរសរសើរណាស់ព្រោះរៀបរៀងជាលំដាប់ទុកល្អណាស់ គឺមានវិបស្សនាញាណជាខាង

ដើម ហើយមានអាសវក្ខយញ្ញាណជាទីបំផុត ញាណទាំង២នេះបើត្រិះរិះគិតឲ្យល្អិតទៅឃើញថាញាណទាំង២នេះហើយ វិជ្ជាទាំង៦ប្រការនេះមិនប្រព្រឹត្តទៅតាមធម៌បានឡើយ ត្រឡប់ជាគ្រឿងប្រដាប់ សម្រាប់ធ្វើការទុច្ចរិតទៅវិញ ។

អ្នកមើលគង់យល់ថា ការតែងសៀវភៅនេះ រៀបរៀងក្នុងពួកផ្លូវបុគ្គលាធិដ្ឋាន ពោលគឺនឹងពិសោធឲ្យឃើញថា ព្រះពុទ្ធជាម្ចាស់មានឫទ្ធិពិតមែន សម្តែងបាដិហារិយ៍បានក្រៃលែងជាងមនុស្សធម្មតា ទ្រង់មានទិព្វសោត ទ្រង់រឭកជាតិបានហើយ ទ្រង់មានទិព្វចក្ខុឃើញធ្លុះផែនដី នឹងទីកំបាំងពិតមែន សាវករបស់ព្រះអង្គដែលលុះវិជ្ជាទាំង៨ នេះក៏អាចធ្វើបានដូចគ្នាជាពិត រួមសេចក្តីថាមនុស្សយើងបើបានហ្វឹកហ្វឺនប្រដៅចិត្ត (developer) តាមគោលវិជ្ជា៨ ប្រការនេះហើយបើមានឫទ្ធិតែជះយ៉ាងតិច ក៏អាចមើលធ្លុះកំផែងបានឬក៏ឮសំឡេងពីឆ្ងាយលើសវិស័យត្រចៀកមនុស្សធម្មតាដែលនឹងឮបាននោះ (មិនបាច់ប្រើទោរសព្ទ) ។

គ្រានេះនឹងកើតមានពាក្យស៊កសៀតមកថា បើមនុស្សយើងអាចធ្វើបានដល់ទីនេះហើយ ហេតុអ្វីមនុស្សក្នុងលោកក៏ទៅយកចិត្តទុកដាក់រៀនវិជ្ជាផ្សេងៗទៅវិញ មិនរៀនវិជ្ជាទាំង៨ ប្រការនេះឲ្យសម្រេចទៅនឹងបានទិព្វចក្ខុមើលល្បែងលេងស៊ីសងជាប្រាក់ យកឈ្នះឲ្យបានប្រាក់មកធ្វើជាសេដ្ឋី បើមានប៉ូលិសឬសង់ដាមមកចាប់ ក៏សម្តែងឫទ្ធិហោះឬមុជជ្រែកដីទៅ ឬទៅស្រុកមូណាកូរ លេងល្បែងនៅទីមង់តេកាឡូរឲ្យឈ្នះ កើបយកប្រាក់ទាំងលានទាំងកោដិមកធ្វើជាមហាសេដ្ឋី ពួកបារាំងដែលមិនជឿក្នុងវិជ្ជានេះ ក៏សួរថាដូចជាប្រទេសឥណ្ឌា មានហោគីពាសពេញនៅតាមភ្នំហិមាល័យ សុទ្ធតែអួតខ្លួនថាធ្វើយ៉ាងនោះយ៉ាងនេះបាន ហេតុអ្វីក៏មិនធ្វើឲ្យស្រុកឥណ្ឌារួចពីអំណាចអង់គ្លេសទៅជាឯករាជ្យជាមហាប្រទេសជា ធំក្នុងលោកទៅ។ ពាក្យស៊កសៀតឯទៀតៗ ក្រៅពីនេះនៅមានជាច្រើន តែ

យើងអាចតបដោះស្រាយដោយងាយ គឺថាមនោយិទ្ធិ ឬឥទ្ធិវិធី ឬទិព្វសោត នឹងធម៌ប្រការទៀតដែលមានក្នុងវិជ្ជាទាំង៨ នេះ បើមិនទាន់សម្រេចវិជ្ជាដំបូងគឺវិបស្សនាញាណទេ ក៏ពុំអាចចម្រើនឲ្យវិជ្ជាទាំងនេះកើតបានឡើយ ។

យើងចូរសង្កេតម្យ៉ាងទៀត ថាធម៌របស់ព្រះពុទ្ធជាម្ចាស់គ្រប់ខប្រៀបដូចដាវដែលមុត អាចយកទៅប្រើការក្នុងផ្លូវល្អឬផ្លូវខូចកាចក៏បាន តែថាធម៌របស់ព្រះពុទ្ធជាម្ចាស់ មិនបានសម្រាប់ទុកឲ្យប្រើក្នុងផ្លូវខុសទេ បានជាមានល័ក្ខខ័ណ្ឌបង្ការទុក ដូចជាវិជ្ជា៨ ប្រការនេះ មនុស្សដែលនឹងចម្រើនបាន ចំពោះតែមនុស្សដែលមានប្រាជ្ញា រំពឹងឃើញសេចក្ដីកើតសេចក្ដីរលត់ ឃើញសង្ខារគួរឲ្យខ្លាច ឃើញទោសជិនឆ្អន់ចង់តែចៀសចេញឲ្យផុតពីសង្ខារ ពិចារណារកផ្លូវនឹងធ្វើព្រងើយកន្ដើយ ក្នុងទីបំផុតមានប្រាជ្ញាកំណត់ដឹងអរិយសច្ច អ្នកដែលមានប្រាជ្ញាដូចពោលមកនេះជាអ្នកមានចិត្តប្រាថ្នាតិចឆ្ងាយពីកាមតណ្ហា ប្រាកដជាមិនប្រើឥទ្ធិវិធីឬទិព្វសោត ទិព្វចក្ខុ ក្នុងផ្លូវស្វែងរកប្រយោជន៍របស់ខ្លួន ហើយធ្វើឲ្យខូចខាតអន្តរាយរបស់អ្នកដទៃនោះឡើយ ហេតុដូច្នេះមនុស្សយើងនឹងរៀនឥទ្ធិវិធីទិព្វសោត ទិព្វចក្ខុ ឲ្យសម្រេចបាន ដើម្បីយកទៅប្រើក្នុងការរកលាភដូចមានពោលមកនេះ ពុំអាចចម្រើនបានឡើយ ព្រោះមនុស្សដែលមានសេចក្ដីគិតដូច្នោះ ហៅថាប្រាសចាកវិបស្សនាញាណដែលជាគ្រឿងឧបករណ៍របស់វិជ្ជាឯទៀត ។

ដូចជារាជការក្នុងស្រុក មិនអនុញ្ញាតឲ្យអ្នកណាមានកាំភ្លើងឥតច្បាប់ លុះតែឈ្មោះនោះមានលក្ខណ៍ ជាមនុស្សមានកេរ្តិ៍ឈ្មោះល្អពិតមិនបានយកទៅប្រើខុសច្បាប់ ទើបរាជការអនុញ្ញាតឲ្យច្បាប់កាន់កាំភ្លើងបាន យ៉ាងដូចម្ដេចមិញ ខាងធម៌ក៏ដូចគ្នា ព្រះពុទ្ធជាម្ចាស់ទ្រង់មិនអនុញ្ញាតឲ្យអ្នកណាមានឥទ្ធិវិធី ទិព្វសោតឬទិព្វចក្ខុបាន ព្រោះក្រែងយកវិជ្ជាដ៏ប្រសើរ

នេះ ទៅប្រើក្នុងផ្លូវដែលធ្វើឲ្យគេខូចប្រយោជន៍ លុះតែមនុស្សនោះមានវិបស្សនាញាណជាមុន បានចម្រើនវិជ្ជាទាំងនេះបានព្រោះវិបស្សនាញាណប្រដូចនឹងកេរ្តិ៍ឈ្មោះដែលល្អពិតជាមិនយកទៅប្រើក្នុងការដែលធ្វើឲ្យអន្តរាយដល់អ្នកទាំងពួង ។

រួចសេចក្តីថា ការរៀនវិជ្ជា៨ ប្រការនេះ នឹងសម្រេចបាន

១- លុះតែជឿជាក់ថា មិននាំយកទៅប្រើក្នុងផ្លូវខុស មុននឹងឲ្យជឿនេះត្រូវធ្វើឲ្យបានសម្រេចវិបស្សនាញាណសិន។

២- ត្រូវមានចិត្តប្រាថ្នាឲ្យបានលុះអាសវក្ខយញ្ញាណជាទីបំផុតពោលគឺត្រូវធ្វើចិត្តរបស់ខ្លួនឲ្យផុតចាកគ្រឿងសៅហ្មងទាំងឡាយ ហេតុនេះហើយបានជាថាធម៌ពួកនេះ ត្រូវឲ្យមានវិបស្សនាញាណជាដំបូង នឹងអាសវក្ខយញ្ញាណជាបរិយោសាននោះទុកជាត្រូវណាស់ ។

## គ្រានេះមានបញ្ហា ២ ប្រការគឺ

១- ពួកអសុរ ដែលមានចិត្តបាបអាក្រក់ ហេតុអ្វីក៏ហោះបាន?

២- បើចាំឲ្យសម្រេចវិបស្សនាញាណជាមុន បានធ្វើវិជ្ជាឯទៀតបាននោះធម៌ពួកនេះនឹងមិនជាប្រយោជន៍អ្វី ដល់មនុស្សសម័យនេះឡើយ ព្រោះក្នុងសម័យនេះរកអ្នកដែលបានសម្រេចវិបស្សនាញាណនោះពិបាកណាស់ ។

## សូមតបបញ្ហា ២ ខនេះដូច្នេះ

ខ១- ពីរឿងអសុរហោះបាននោះមិនខុសពីសត្វស្លាបហើរទេក្នុងរឿងនេះព្រះពុទ្ធឃោសាចារ្យ ដែលជាអ្នករចនាគម្ពីរវិសុទ្ធិមគ្គ កាលលោកតែងគម្ពីរក៏បានរឭកដល់បញ្ហានេះដែរ បានជាលោកចារិកទុកថាការហោះនោះមិនមែនតែបានឥទ្ធិវិធីក្នុងវិជ្ជា ៨ ប្រការបានហោះបាននោះទេ នៅ

មានផ្លូវធ្វើឲ្យហោះបានទៀត ពោលគឺឫទ្ធិដែលកើតដោយផលកម្ម ដូចជាសត្វស្លាបឬយក្សដែលជាពួកអសុរ ឬឫទ្ធិដែលកើតដោយវិជ្ជាការ ដូចជាក្នុងសម័យនេះប្រៀបនឹងយន្តហោះ ឯអសុរហោះបាននោះព្រះពុទ្ធឃោសាចារ្យ ពោលថាជាអំណាចនៃកម្ម ។

ខ២- នោះយើងត្រូវយកវិជ្ជា ៨ ប្រការនេះ ប្រដូចនូវគ្រឿងយន្តដែលប្រើប្រេងអេស្សង់អ្នកដែលមានគ្រឿងបែបនេះ បើគ្មានប្រេងអេស្សង់នឹងយកប្រេងកាតប្រើក៏បានតែម៉ាស៊ីនដើរមិនរហ័សឆាប់ដូចប្រេង អេស្សង់ប្រើប្រសិនជាយកទឹកទៅប្រើវិញម៉ាស៊ីននោះក៏ដើរពុំបានឡើយ ឬបើមានខ្សាច់លាយជាច្រើនផង ក៏រឹតតែនាំឲ្យខូចម៉ាស៊ីនថែមទៀត វិបស្សនាញាណប្រៀបដូចអេស្សង់ សម្រាប់ប្រើចំពោះតែគ្រឿងយន្តគឺវិជ្ជា ៨ប្រការនេះអ្នកដែលមានវិបស្សនាញាណ ប្រាកដនោះ ដូចមានប្រេងអេស្សង់ទើបអាចធ្វើវិជ្ជា ៨ ប្រការដែលប្រៀបដូចគ្រឿងយន្តឲ្យដើរបានយ៉ាងស្រួលជាទីបំផុត បើប្រសិនជារកប្រេងអេស្សង់មិនបាន ឬមិនចេះប្រើយកប្រេងកាតមកប្រើជំនួសគ្រឿងយន្តក៏គង់ដើរបានខ្លះ ដូចជាអ្នកដែលមិនចេះស្គាល់វិបស្សនាញាណ ឬមិនអាចប្រើវិបស្សនាញាណបាន នឹងយកធម៌ឯទៀតដែលមានកម្លាំងតិចជាង ដូចជាមេត្តា ករុណា ឬធម៌ណាដែលជាកុសល ក៏អាចនឹងធ្វើវិជ្ជា ៨ ប្រការនេះឲ្យសម្រេចបានខ្លះដែរ តែមិនអាចធ្វើឲ្យបានដូចវិបស្សនាញាណទេ ។

វិជ្ជា៨ ប្រការជាធម៌ដែលបែកជាមែកជាធាង ចេញមកពិអភិញ្ញា អភិញ្ញានោះ តាមគម្ពីររបស់ព្រះពុទ្ធឃោសាចារ្យថាមាន៥ គឺ **ឥទ្ធិវិធិ** សម្តែងឫទ្ធិបាន **ទិព្វសោត** ត្រចៀកទិព្វ **ចេតោបរិយញ្ញាណ** ដឹងចិត្តអ្នកដទៃ **បុព្វេនិវាសានុស្សតិញ្ញាណ** រឭកជាតិបាន **ទិព្វចក្ខុ** ភ្នែកទិព្វ បើតាមព្រះនិពន្ធរបស់សម្តេចមហាសមណៈ ថាមាន៦គឺបញ្ចូល **អាសវក្ខយញ្ញាណ** ចេះធ្វើអាសវៈឲ្យអស់ទៅ តាមសេចក្តីក្នុងព្រះនិពន្ធព្រះបឋមសម្ពោធិ

កថារបស់សម្តេចព្រះបរមានុជិតជិនោរស មានសេចក្តីធ្វើឲ្យចូលចិត្តថា អភិញ្ញាទាំងនេះកាលក្នុងសម័យមុនព្រះពុទ្ធជាម្ចាស់ ក៏មានអ្នកបានសម្រេចខ្លះហើយ ដូចជាតាបសទាំងឡាយក្នុងគ្រានោះក៏អាចហោះហើរដើរលើអាកាសបាន តែនឹងធ្វើឲ្យបានល្អស្មើនឹងព្រះពុទ្ធជាម្ចាស់នោះគ្មានទុកជាធ្វើប្រការឯទៀតបាន ក៏គងនៅជាប់ត្រឹមប្រការ៦ គឺ អាសវក្ខយញ្ញា-ណ គិតធ្វើទៅពុំរួច បានជាគិតថាការដែលនឹងធ្វើអាសវៈឲ្យអស់ទៅជាប្រាកដនោះ ត្រូវធ្វើរាងកាយឲ្យលំបាក គឺយកភ្លើងមកឆ្អើរកាយ អត់អាហារទាល់តែស្លាប់ លទ្ធិអត្តកិលមថានុយោគ ក៏កើតមានឡើងដោយប្រការដូច្នេះ ដល់មកសម័យព្រះពុទ្ធជាម្ចាស់ ទ្រង់បានរកឃើញវិបស្សនាញាណ ដែលជាកូនសោដ៏សំខាន់ ហើយបានទាំងមនោមយិទ្ធិមកមួយទៀត ទើបបង្កើតជាវិជ្ជា៨ ប្រការឡើង ធ្វើឲ្យអភិញ្ញាផ្សេងៗ មានទម្ងន់ជាច្រើនថែមទៀត ពួកតាបសដែលចម្រើនអភិញ្ញា ក្នុងសម័យមុនព្រះពុទ្ធជាម្ចាស់ ក៏មានតាំងចិត្តបដិបត្តិតាមគោលវិបស្សនាញាណមកហើយដែរ តែរកឲ្យឃើញជាប្រាកដនោះពុំបាន ក៏ដូចជាគ្រឿងម៉ាស៊ីនប្រើនឹងប្រេងកាតតែងតែមានសេចក្តីពិបាក ឬក៏សម្រេចបានយ៉ាងជ្រលិះៗ ។

តាមលទ្ធិរបស់យោគី គេគ្មានគោលជាប្រាកដ ដូចវិបស្សនាញាណរបស់យើងទេ តែគេក៏មានរបៀបច្បាប់ដ៏សំខាន់ជាដើមថា ការរៀនវិជ្ជារកអំណាចសម្រាប់ខ្លួនដូច្នេះតោងមានសេចក្តីចំណង់ដោយ ស្មោះត្រង់ហើយត្រូវទុកចិត្តឲ្យប្រាកដ ថាមិនយកវិជ្ជាទាំងនេះទៅប្រើក្នុងផ្លូវខុសក្នុងសៀវភៅរបស់យោគីភមៈចរកៈពោលថា ទុកជាមនុស្សធម្មតា ក៏អាចលុះវិជ្ជាផ្សេងៗទាំងនេះបាន តែថានឹងលុះបាននោះទាល់តែចិត្តរបស់មនុស្សនោះខ្ពស់ហួសធម្មជាតិទាបទៅហើយ ហើយមានច្បាប់របស់ធម្ម-ជាតិខមួយថា "បើយើងមិនត្រូវការប្រើអំណាច ជាប្រយោជន៍ផ្ទាល់ខ្លួនរបស់យើងទេ ទើបអំណាចនោះនឹងកើតឡើងដល់យើង ហេតុនេះបានជា

គេប្រដៅថា ការរៀនវិជ្ជាទាំងនេះ ក្នុងថ្នាក់ដំបូងឲ្យមានសេចក្តីទុកចិត្តថា បើយើងបានរៀនសម្រេចហើយ នឹងប្រើវិជ្ជាទាំងនេះជាប្រយោជន៍ដល់មនុស្សដូចគ្នា ប្រយោជន៍ដែលយើងនឹងធ្វើឲ្យមនុស្សម្នាក់នោះ ក៏ត្រូវគិតមើលថាប្រយោជន៍នោះនឹងធ្វើឲ្យក្តៅក្រហាយ ដល់មនុស្សឯទៀតដែរឬទេ។

ឯវិបស្សនាញាណនេះ បើអ្នកណាមិនសិក្សាដោយចិត្តជាកុសលធម៌ទេ ពិតជាពុំអាចធ្វើវិជ្ជាផ្សេងៗ ឲ្យសម្រេចបានឡើយ បើរៀនដោយចិត្តមិនបរិសុទ្ធគិតយកទៅប្រើការជាប្រយោជន៍របស់ខ្លួនតែមួយ ហើយនឹងធ្វើឲ្យខូចប្រយោជន៍របស់ទ្រព្យអ្នកដទៃ ដូចជាប្រើសម្រាប់បំបាត់ប្រវ័ញ្ចលួចទ្រព្យឬធ្វើទុក្ខគេដោយប្រការផ្សេង ដូចមានពោលមកនេះ ក៏នឹងបានតែផល ២ ប្រការគឺ ១- រៀនវិជ្ជានេះមិនសម្រេច។ ២- នឹងមានទោសដល់ខ្លួនផង ដូចជាមនុស្សដែលរៀនធ្វើស្នេហ៍ អំពើនឹងគុណសៃផ្សេងៗនោះ ពុំឃើញប្រាកដថាធ្វើអ្វីឲ្យបានសម្រេចជាពិតនោះឡើយឬក៏នឹងបានទទួលនូវសេចក្តីចម្រើន សេចក្តីសុខអ្វីក៏ទេ អំពីការធ្វើស្នេហ៍ធ្វើមេមត់ ធ្វើគុណសៃផ្សេងៗ នេះបារាំងក៏មានចេះដឹងជាច្រើន អ្នកដែលរកស៊ីតាមផ្លូវនេះក៏មាន តែមនុស្សអស់នេះបើមិនត្រូវគេសម្លាប់ក៏ទៅជាឆ្កួតលេលាទៅឯងៗ ព្រោះធម្មជាតិក៏តែងតែមានច្បាប់ដូចរាជការក្នុងស្រុកដែរ ហើយមានច្បាប់របស់ធម្មជាតិធ្វើទោសធ្ងន់ជាងច្បាប់សម្រាប់ស្រុកទៀត ។

សេចក្តីបរិយាយមកទាំងនេះ នឹងសម្តែងឲ្យលោកអ្នកមើលស្គាល់យល់ច្បាស់លាស់ថា វិបស្សនាញាណ កាលដើមលោកគិតថា មិនបាច់មានក៏បានដែរនោះពុំត្រូវទេ ធម៌នេះពិតជាត្រូវការប្រើក្នុងពួកវិជ្ជា៨ ប្រការជាប្រាកដណាស់ ព្រោះវិបស្សនាញាណ ជាកូនសោដ៏សំខាន់ដែលនឹងធ្វើឲ្យយើងចូលចិត្តលក្ខណៈរបស់វិជ្ជាទាំង៨ ហើយជាឧបករណ៍ជួយឲ្យ

សម្រេចវិជ្ជាផ្សេងៗទាំងអស់នោះផង ។

## វិជ្ជាប្រការទី ២

យើងបានដឹងសេចក្ដីអធិប្បាយមកច្រើនហើយថា ចិត្តមនុស្សមានអំណាចលើកាយទាំងមូល ពោលគឺរូបកាយនឹងកម្រើកបាន ដោយប្រការដូចម្ដេច ឬមនុស្សយើងនឹងប្រព្រឹត្តល្អ ឬអាក្រក់យ៉ាងណា ក៏សម្រេចនូវដួងចិត្តទាំងអស់ ព្រោះចិត្តមានអំណាចបង្គាប់អាយតនៈខាងក្នុងគ្រប់យ៉ាង ពាក្យនេះជាពាក្យប្រដៅ ដែលយើងបានទទួលរៀនធម៌ពីថ្នាក់ដំបូង តែគ្រានេះយើងល្បងពិចារណាថា ក្រៅពីការកម្រើកតាមប្រក្រតីហើយ តើចិត្តយើងអាចធ្វើអ្វីបានខ្លះ តាមពុទ្ធភាសិតដែលថា "**មនោសេដ្ឋា មនោមយា**" នោះតើសំដៅសេចក្ដីត្រឹមណា ?

តាមវិធីអធ្យាត្មវិទ្យារបស់បារាំង គេថាមានធម្មជាតិម្យ៉ាង ហៅថា ស៊ុបកុងស៊ីយ៉ង្ស៍ (subconscience) នឹងមិនឃើញថាត្រូវនឹងពាក្យអ្វីក្នុងសាសនាយើង ទើបសូមប្រែជាបណ្ដោះអាសន្ន ទុកសិនថា "អាយតនៈខាងក្រោម" ដែលបារាំងអធិប្បាយថា មនុស្សយើងប្រៀបដូចដកុំទឹកកកអណ្ដែតក្នុងទឹកសមុទ្រ យើងមើលឃើញតែត្រឹមភាគខាងលើទឹក ឯភាគនៅខាងក្រោមទឹកដែល យើងមើលពុំឃើញនោះ នៅមានទៀតជាច្រើនភាគជាងភាគដែលនៅលើទឹក មនុស្សក៏ដូចគ្នា យើងឃើញមនុស្សថាធ្វើការអ្វីៗអាចធ្វើបានតែត្រឹមណោះ ដែលជាប្រាកដនោះ នៅធ្វើបានច្រើនជាអនេកទៀត ឧទាហរណ៍ដែលនឹងនាំមកពិសោធក្នុងខនេះនៅមានច្រើន ដូចដែលបានឮនិយាយតៗមកថា វេលាដែលមានភ្លើងឆេះផ្ទះនោះ មនុស្សម្នាក់លើកទូដែកដាក់ប្រាក់ដែលធ្ងន់ណាស់រួច ដល់ភ្លើងរលត់វិញនឹងលើកតែម្នាក់ឯងពុំរួច តោងតែហៅគេឯងឱ្យជួយទើបបានរួចកិច្ចការខ្លះយើងគិតថាហួសវិស័យនឹងធ្វើបាន តែបើមានអំណាចអ្វីមកបង្គាប់ឱ្យ

យើងធ្វើ យើងក៏ធ្វើបានសម្រេច មនុស្សដែលដើរក្នុងព្រៃអស់កម្លាំងណាស់ពុំអាចនឹងដើរតទៅទៀតបាន តែបើឃើញខ្លាឬសត្វសាហាវវាដើរមកចំមុខ ក៏អាចរត់បានឆ្ងាយតទៅទៀត ។ មានរឿងក្នុងសៀវភៅអ្នកប្រាជ្ញបារាំង គួរជឿថាគេជាអ្នកប្រាជ្ញ គេមិនកុហកទេ ពោលថាមានរោងល្ខោនសត្វមួយកន្លែង ទ្រុងដែលដាក់សិង្ហធ្លាយ សិង្ហក៏វារត់ចេញទៅ ដើរប៉េលប៉ាលទៅតាមថ្នល់ រួចវាក៏ចូលទៅក្នុងផ្ទះផ្សេងៗ ហើយបានចូលទៅក្នុងផ្ទះមួយមានមនុស្សខ្វិនពីកំណើតម្នាក់ដើរពុំរួច លុះឃើញសិង្ហមក ក៏ក្រោករត់បានដូចមនុស្សជា ដល់សិង្ហចេញទៅវិញក៏ត្រឡប់ខ្វិនដូចដែល រឿងនេះបារាំងអធិប្បាយថា ព្រោះអាយតនខាងក្រម "ស៊ុបកុងស៊ីយ៉ង្ស៍" ដែលជ្រកពួននៅក្នុងខ្លួនមនុស្សនោះ ឡើងមកធ្វើប្រយោជន៍ឲ្យក្នុងវេលាកំពុងត្រូវការជាប្រាកដ តែសេចក្តីត្រូវការនេះ លុះតែខ្លាំងលើសលុបជាងការទាំងពួង លើសពីមនុស្សដែលត្រូវការជាធម្មតា បានជាបារាំងយកហេតុនេះទុកជាគោលប្រដៅថា បើចង់ធ្វើឲ្យសម្រេចការអ្វីមួយៗ ត្រូវយកចិត្តទុកដាក់ក្នុងការដែលត្រូវការនោះឲ្យខ្លាំងជាបំផុត ពួកជាតិអង់គ្លេសតាំងជាសុភាសិតថា "បើមានសេចក្តីត្រូវការត្រង់ណា គង់មានផ្លូវចន្លោះត្រង់នោះ" ។

យើងគង់តែប្រទះឃើញ អ្នកដែលបានសិក្សាដូចយើង ប្រឡងក៏បានដូចយើង ចំណេះចេះដឹងក៏ស្មើនឹងយើង តែគេធ្វើការបានល្អជាងយើង របស់អ្វីដែលយើងធ្វើសម្រេចក្នុង ៣ ម៉ោង គេធ្វើតែ ១ម៉ោងសម្រេច ចួនកាលសម្រេចបានល្អជាងយើងដែលធ្វើទាំង ៣ម៉ោងនោះផង ហើយរបស់អ្វីដែលធ្វើមិនកើតសោះ តែគេធ្វើសម្រេចបានយ៉ាងអស្ចារ្យ មនុស្សបែបនេះហើយដែលគេចេះនាំយកអាយតនខាងក្រោមឡើង មកជួយបាន បារាំងយកចិត្តទុកដាក់ជាបំផុតក្នុងការប្រដៅវិជ្ជាបណ្តុះគំនិតរបស់មនុស្ស ។

ឧទាហរណ៍ផ្សេងៗ ដែលបានបរិយាយមកខាងដើមនេះ ក៏គឺមនោ-មយិទ្ធិរបស់យើងនេះឯង មិនមែនយ៉ាងឯទៀតឡើយ ពាក្យថាមនោមយិទ្ធិនោះ ឃើញថាត្រង់នឹកភាសាដែលបារាំងហៅថា (volonte) តាមវិធីអធ្យាត្មវិទ្យាឃើញថា វូឡុងតេ ជាសំខាន់បំផុត ដែលនឹងបណ្តុះចិត្តឲ្យមានអំណាច គឺហាត់ឲ្យចេះយកអាយតនខាងក្រោមឡើងមកប្រើបានខ្លះ វិធីបណ្តុះចិត្តបែបយ៉ាងណានោះ បារាំងគេបានជ្រើសរើសទុកយ៉ាងពិស្តារលើសពីសេចក្តីដែលពោលមកក្នុងសៀវភៅនេះ ។

បើយើងនឹងសិក្សា ប្រវត្តិរបស់មនុស្ស ដែលលុះដល់ឋានៈដ៏ខ្ពស់ឬមនុស្សដែលបានលុះដល់ផលគ្រប់ៗយ៉ាង ដែលត្រូវការហើយនោះនឹងឃើញថាមនុស្សទាំងនោះ មានចំណង់យ៉ាងខ្លាំងចំពោះផលនោះហើយខំធ្វើការគ្រប់ៗយ៉ាង ដើម្បីឲ្យបានសម្រេចនូវផលនោះជាប្រាកដឯមនុស្សដែលត្រូវធ្វើការឲ្យអស់តែកម្លាំង មិនបានផលសោះឡើយក្នុងមួយជីវិតរកសេចក្តីចម្រើនមិនបាន មកពីធ្វើការរាយមាយខ្លួនរបស់ខ្លួនក៏មិនដឹងជាចាប់ធ្វើការអ្វីឲ្យប្រាកដ ដូច្នេះតើមនោមយិទ្ធិនឹងកើតឡើងដូចម្តេចបាន យ៉ាងដូចជាព្រះពុទ្ធជាម្ចាស់ ទ្រង់មានលក្ខណៈ តាមហោរទាយទុកថានឹងបានត្រាស់ជាព្រះពុទ្ធ ឬនឹងបានជាស្តេចចក្រពត្តិដែលព្រះអង្គបានត្រាស់ជាព្រះពុទ្ធ ព្រោះព្រះអង្គមានព្រះទ័យបំណងចង់បានត្រាស់ជាព្រះពុទ្ធពិតប្រាកដណាស់ ព្រះអង្គមិនបោះបង់ចោលនូវព្យាយាមសោះ បានជាបានត្រាស់ជាព្រះពុទ្ធ បើប្រសិនជាព្រះអង្គរួញរា ឬព្រះអង្គមានព្រះហឫទ័យចង់បានសម្រេចទាំងសងខាងនោះប្រហែលជាមិនបាន សម្រេចជាអ្វីសោះឡើយ ។

បើយើងសង្កេតមើលឲ្យល្អ នឹងឃើញមានមនុស្សខ្លះដែលយកចិត្តព្យាយាមក្នុងការដែលមានប្រាថ្នាជាពិតប្រាកដនោះ ឃើញថាបានសម្រេចដូចប្រាថ្នាមែន របស់ដែលគិតថាមិនបាន ត្រឡប់ជាបានវិញនេះ

ហើយឲ្យឃើញថាជាគោលរបស់មនោមយិទ្ធិយ៉ាងជាន់ទាប ។

## គ្រានេះលល្បងពិចារណាឲ្យខ្ពស់ឡើងបន្តិចទៅទៀត

អ្នកប្រាជ្ញអធ្យាត្មវិទ្យារបស់បារាំង នឹងពួកយោគីក្នុងឥណ្ឌាយល់ឃើញដូចគ្នាថា គំនិតរបស់មនុស្សយើង បែកខ្ចាយចេញមកពីក្នុងខ្លួនដូចក្រសែភ្លើងអគ្គិសនី មនុស្សដែលមានសេចក្ដីគិតយ៉ាងខ្លាំង ដែលបារាំងហៅថា (home-energique) មនុស្សមាំមួនមានស្មារតីរឹងនោះក្រសែនោះឯងមានកម្លាំងខ្លាំងចេញទៅប៉ះប្រទះរបស់អ្វីៗ ក៏ជាប់នៅដែលអណ្ដែតនៅក្នុងអាកាសក៏មាន បើប្រសិនជាមនុស្សច្រើនគ្នានៅក្នុងហាងជាមួយគ្នាមានគំនិតដូចគ្នា ក្រសែនោះក៏កាន់តែខ្លាំងឡើងទៅទៀត តួយ៉ាងរឿងនេះមានច្រើន ដូចយើងទៅនៅជាមួយនឹងមនុស្សដែលមានសេចក្ដីសោកជាអាចិន្ត្រៃ ក៏នឹងធ្វើឲ្យយើងសោកក្រៀមក្រំទៅជាមួយផង បើនៅជាមួយនឹងមនុស្សដែលមានសេចក្ដីព្យាយាម យើងក៏ដឹងថាខ្លួនយើងមានសេចក្ដីប្រឹងប្រែងធ្វើការអ្វីម្យ៉ាងៗឡើង យើងចូលទៅរកអ្នកមានបណ្ដាស័ក្តិធំ យើងច្រើនតែមានសេចក្ដីរន្ធត់ ទុកជាដឹងថាលោកមិនបានធ្វើអ្វីខ្លួនទេ លោកនឹងទទួលយើងដោយស្រួលមានមេត្តាករុណាក្ដី ក៏មិនបាត់នូវសេចក្ដីរន្ធត់នោះ ក្នុងផ្ទះឬបន្ទប់ដែលមានមនុស្សធ្លាប់នៅមកមុន ហើយលះបង់ចោលចេញទៅជាយូរ គង់ចោលក្រសែគំនិតទុក កាលណាយើងចូលទៅក្នុងផ្ទះឬបន្ទប់នោះ យើងនឹងដឹងខ្លួនថាមានចិត្តសោកឬក៏សប្បាយរីករាយស្រេចនៅផ្ទះឬបន្ទប់ដែលអ្នកនៅមុននោះ មានសេចក្ដីសោកឬសប្បាយយ៉ាងណា គេប្រៀបសេចក្ដីនេះប្រដូចយើងបង្កាត់ភ្លើងទុកចោលក្នុងបន្ទប់មួយ ទុកជាភ្លើងរលត់យូរហើយបន្ទប់នោះក៏គង់ចោលចំហាយទុកដែរ អ្នកប្រាជ្ញតារាសាស្ត្រអធិប្បាយតទៅថា ដួងផ្កាយដែលយើងមើលឃើញនៅលើមេឃនោះ មានផ្កាយខ្លះបានធ្លាក់បាត់ទៅយូរៗហើយ តែពន្លឺគង់

មាននៅជាប់ទីកន្លែងឆ្ងាយនោះជាច្រើនឆ្នាំ យើងចូលទៅក្នុងផ្ទះដែលមានមនុស្សស្លាប់ថ្មីៗ ទុកជាយើងមិនដឹងជាមុនសោះ យើងគង់ដឹងថាក្នុងចិត្តយើងមានចិត្តស្លុតស្ញប់ខុសពីប្រក្រតី រឿងទាំងនេះសម្តែងឲ្យឃើញថាក្រសែងដួងចិត្តមនុស្សខ្វាយទៅគ្រប់អន្លើ បើយើងទៅប៉ះក្រសែណាយើងក៏គង់ដឹងខ្លួនតាមដំណើរនោះជាដរាប ក្រែងតែយើងមិនបានសង្កេតឲ្យល្អ ។

មានរឿងរបស់បារាំងមួយរឿងគួរឲ្យស្តាប់ ជាគ្រឿងសម្តែងឲ្យឃើញថា ក្រសែដួងចិត្តរបស់មនុស្សមានអំណាចត្រឹមណា រឿងនេះកើតក្នុងប្រទេសអាល្លឺម៉ាញ ជាយូរឆ្នាំមកហើយ ថាមានអ្នកមានម្នាក់បានជួលជាងដែកមកធ្វើការក្នុងផ្ទះខ្លួន តែដោយសេចក្តីកំណាញ់នឹងចិត្តទុច្ចរិត មិនព្រមឲ្យឈ្នួលដែលនៅសល់ជំពាក់ ជាងដែកបានទារជាច្រើនដងមិនបានដល់ក្រោយបំផុតបដិសេធថាពុំបានជំពាក់អ្វីសោះ។ ជាងដែកក៏អស់ផ្លូវនឹងទៅប្តឹងក៏ពុំកើត ព្រោះគ្មានអ្វីជាសំគាល់តាមច្បាប់ ដល់យូរបន្តិច អ្នកមាននោះកើតរោគដេកមិនលក់ រាល់តែយប់ វេលាយាម២ ពាក់កណ្តាលអធ្រាត្របានឮតែសូរដំដែកឆឹងកងរំពង ផ្ទះជាងដែកនឹងផ្ទះអ្នកមាននោះនៅឆ្ងាយពីគ្នាស្មានជា៣ គីឡូម៉ែត្រ អ្នកមាននោះកាលពីរដើមមកក៏ពុំឮដូច្នេះទេ នឹងថាត្រចៀកខ្លួនពិការក៏ទេ ហេតុអ្វីពេលមុនពាក់កណ្តាលអធ្រាត្រក៏មិនឮសូរ ទើបអញ្ជើញពេទ្យមកត្រួតរោគនោះ ចួបចួនជាប្រទះទៅលើពេទ្យចេះដឹងរឿងក្រសែដួងចិត្ត ពេទ្យនោះក៏សួរថា ដែលមានហេតុទាស់ទែងអ្វីនឹងអ្នកណាដែរឬទេ? អ្នកមាននោះក៏រឭកឃើញ ប្រាប់ពេទ្យថា មានទាស់នឹងជាងដែកម្នាក់នៅចម្ងាយពីផ្ទះខ្លួនទៅស្មាន៣ គីឡូម៉ែត្រ ពេទ្យបានដឹងហើយ ដល់យប់ពាក់កណ្តាលអធ្រាត្រ ក៏ទៅផ្ទះជាងដែកនោះ ប្រទះឃើញជាងដែកកំពុងដំដែករងនឹងញញួរ ជាចង្វាក់ៗ នឹងបានដំដែកធ្វើការអ្វីក៏ទេ ពេទ្យក៏ចូលទៅសួរថាហេតុអ្វី ក៏បានជាធ្វើដូច្នេះ

ជាងដែកក៏តបថា មានមនុស្សម្នាក់កោងប្រាក់ឈ្នួលរបស់ខ្ញុំ រាល់យប់វេលាម៉ោង១ កណ្តាលអធ្រាត្រខ្ញុំដំដែករងនេះ តាំងចិត្តឲ្យឮដល់ទៅអ្នកនោះដើម្បីកុំឲ្យដេកបាន ទាល់តែអ្នកនោះសងឈ្នួលដែលជំពាក់ខ្ញុំនោះរួចទើបខ្ញុំឈប់។ ពេទ្យបានដឹងការច្បាស់ក៏ត្រឡប់មកណែនាំឲ្យអ្នកជម្ងឺនោះសងឈ្នួលឲ្យគ្រប់ឲ្យជាងដែកតាំងពីបានសងរួចហើយមក ក៏ដេកលក់ដរាប មិនឮសូរដំដែកទៀត ។

រឿងនេះជាតួយ៉ាងមួយទៀតក្នុងក្រសែដួងចិត្ត ជាគោលប្រើសម្រាប់អធិប្បាយលក្ខណៈ របស់មនោមយិទ្ធិ ។

ក្នុងក្រសែងដួងចិត្តនេះ គេអធិប្បាយថា អាចមានជា២ ថ្នាក់ ថ្នាក់ដំបូងមនុស្សយើងបញ្ជូនក្រសែដួងចិត្ត ដូចរឿងដែលនិយាយមកនេះ ថ្នាក់ទី២ បើដួងចិត្តមានកម្លាំងខ្លាំង ដោយការហ្វឹកហ្វឺនឬដោយមានពីកំណើតមកក្រសែនោះក៏នឹងផ្សាយចេញទៅឯង មិនបាច់តាំងចិត្តបញ្ជូនទៅទេ ។

តួយ៉ាងដូចជាមនុស្សដែលមានលក្ខណៈមាំមួន ទុកជាមិនតាំងចិត្តឲ្យមនុស្សខ្លាច ក៏គង់តែមនុស្សខ្លាចដែរ ឬមនុស្សដែលមានលក្ខណៈសម្តីផ្អែមដោយធម្មជាតិមកនោះ តែងតែមានក្រសែដួងចិត្ត ស្រូបយកដួងចិត្តមនុស្សដទៃមករកខ្លួន បើអ្នកណាបានប្រទះច្រើនមានចិត្តស្រឡាញ់ទុកជាមនុស្សនោះមិនបានតាំងចិត្តឲ្យគេស្រឡាញ់ក៏ដោយ បើមនុស្សទាំងពីរនាក់នោះមកជិតគ្នា ក្រសែនឹងក្រសែក៏ទល់គ្នា ក្រសែរបស់អ្នកណាខ្លាំងជាង ក៏សង្កត់ទៅលើអ្នកដែលមានក្រសែតិច ប្រៀបដូចយើងយកគោមពណ៌ខៀវនឹងពណ៌ក្រហម ទៅដាក់នៅក្នុងទីងងឹតជាមួយគ្នា នៅទីនោះនឹងមានពន្លឺជាពណ៌ខៀវឬពណ៌ក្រហម ស្រេចនៅគោមពណ៌ណាមានពន្លឺភ្លឺខ្លាំងជាង ហេតុដូច្នេះបានជាថា បើយើងយកក្មេងដែលឧស្សាហ៍នឹងក្មេងខ្ជិលទៅឲ្យនៅជាមួយគ្នា ក៏នឹងធ្វើឲ្យក្មេងខ្ជិលនោះទៅជាឧស្សាហ៍

ទាំង២ នាក់ ឬធ្វើឲ្យខ្ចិលទាំង២ នាក់ ស្រេចនូវក្រសែគំនិតរបស់ក្មេងខាងណាខ្លាំងជាងក៏ធ្វើឲ្យក្រសែម្ខាងដែលតិច មកតាមក្រសែគំនិតរបស់ខ្លួន ។

សម្តេចព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់មានមនោមយិទ្ធិខ្លាំងណាស់ ក្រសែគំនិតរបស់ព្រះអង្គពេញទៅដោយធម៌ព្រហ្មវិហារ ហើយមានព្រះហរទ័យស្រឡាញ់ប្រព្រឹត្តតែក្នុងសេចក្តីល្អ ព្រោះហេតុនេះឯង បើមនុស្សណាដែលបានចូលមកជិតព្រះអង្គហើយ ទុកជាមានចិត្តតាចយ៉ាងណាណាស់ក៏អាចត្រូវក្រសែដ៏ល្អរបស់ព្រះអង្គ សង្កត់ឲ្យត្រឡប់ទៅជាល្អវិញបានដោយមនោមយិទ្ធិនេះ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ទូន្មានមនុស្សដែលទាបថោកបំផុតឲ្យត្រឡប់ជាមនុស្សល្អបំផុតបានយ៉ាងអស្ចារ្យ បានជាទ្រង់ព្រះនាមថា "អនុត្តរោ បុរិសទម្មសារថិ" ខនេះហើយដែលយើងដោះស្រាយប្រស្នាក្នុងរឿង ព្រះអង្គុលិមាលបានសម្រេច ។

សេចក្តីដែលពោលមកនេះ ជាគោលនៃមនោមយិទ្ធិយ៉ាងខ្ពង់បន្តិចគ្រានេះ យើងល្បងពិចារណាឲ្យខ្ពស់ឡើងទៅទៀត ពោលគឺក្នុងធម្មវិភាគបរិច្ឆេទទី ២ ថា មនោយិទ្ធិនោះមាននិទ្ទេសថា និម្មិតកាយក្រៅពីកាយនេះបានប្រដូចហូតដាវចេញពីស្រោម សម្តេចព្រះមហាសមណក្រុមជិរញាណវរោរស ទ្រង់ប្រៀបប្រដូចនឹងមនុស្សដែលគិតធ្វើរបស់ផ្សេងៗ បានសម្រេច យើងល្បងមកស្រាវជ្រាវរកមើល បើមិនគិតប្រៀបដូច្នេះតើមនុស្សយើងនឹងអាចនិម្មិតកាយក្រៅពីកាយនេះ ប្រដូចហូតដាវចេញពីស្រោម បានពិតឬទេ សេចក្តីនេះព្រះគន្ថរចនាចារ្យរបស់យើងបានបរិយាយរឿងនេះទុកប្រការដូចម្តេចខ្លះនោះពុំដឹង ហេតុនេះបានជាសាទៅរកពាក្យរបស់អ្នកប្រាជ្ញខាងផ្លូវអធ្យាត្មវិទ្យារបស់បារាំង នឹងលទ្ធិរបស់យោគីក្នុងតណ្ឌៀវិញ ។

អ្នកប្រាជ្ញនឹងយោគីទាំងនោះ ប្រកាន់ថាកាយរបស់មនុស្សយើងមានកាយ២ គឺ Corps physique ១ និង Corps astral ១ ឯ Corps

physique បាននឹងរាងកាយ ដែលប្រកបឡើងដោយធាតុទាំង ៤ ដែលយើងឃើញនេះ ត្រង់ Corp astral នោះ គេអធិប្បាយទុកប្រហែលនឹងចេតភូតរបស់យើង ហេតុដូច្នេះសូមប្រែពាក្យនេះថា ចេតភូត ដូចបានពោលមកក្នុងសេចក្ដីដើម ត្រង់អធិប្បយាគោលចារិកលទ្ធិយោគីនោះហើយ ។

តាមធម្មតា ចេតភូតចេញពីខ្លួនមនុស្សវេលាកំពុងដេកលក់ ឬក្នុងវេលាដែលចិត្តមនុស្សកំពុងតាំងសមាធិយ៉ាងមាំមួន ដែលថាចេតភូតចេញពីខ្លួនកំពុងដេកលក់នោះចូលចិត្តងាយ គឺគេអធិប្បាយថា របស់អ្វីផ្សេងៗដែលខ្លួនឃើញក្នុងយល់សប្តិនោះ សុទ្ធតែចេតភូតបានប្រទះឃើញទាំងអស់ បារាំងដែលយកចិត្តទុកដាក់ក្នុងវិជ្ជានេះ ហើយនឹងពួកយោគីទាំងឡាយ បានព្យាយាមស្រាវជ្រាវរកផ្លូវដែលនឹងបង្គាប់ចេតភូតឲ្យទៅក្នុងទីឯទៀតៗ បានតាមចិត្តចំណង វិធីបង្គាប់នឹងធ្វើយ៉ាងណានោះគេធ្វើគោលចារិកសឹងឃើញបានជាក់ច្បាស់ថា គេនាំយកទៅពីព្រះពុទ្ធជាម្ចាស់ដ៏ប្រាកដ គោលចារិកដែលគេធ្វើទុកនោះមាន ៣ ប្រការគឺ :

១ Volonie ដែលត្រូវគ្នានឹងមនោមយិទ្ធិរបស់យើង

២ Vision ដែលត្រូវគ្នានឹងឧគ្គហនិមិត្ររបស់យើង

៣ Concentration ដែលត្រូវគ្នានឹងសមាធិ ។

ក្នុងសៀវភៅរបស់នាយ អែនដ្រើវឡែង ជាតិអង់គ្លេស ដែលជាអ្នកស្រាវជ្រាវរកសេចក្ដីពិតក្នុងវិជ្ជានេះ ពោលទុកមួយខជាឧទាហរណ៍យ៉ាងល្អពីការដកកាយ ដូចមានសេចក្ដីប្រែទុកតទៅនេះ ។

នាងមារីជាភរិយាសង់កូហ្វ មានជម្ងឺឈឺរោគរបេងរីងរៃជាខ្លាំង ទៅនៅរក្សាខ្លួនឯផ្ទះរក្សាជម្ងឺ ចម្ងាយពីផ្ទះប្រហែលជាង ១៤ គីឡូម៉ែត្រ មុននឹងអនិច្ចកម្ម មានមួយថ្ងៃស្រ្តីនោះមានចិត្តប្រាថ្នាយ៉ាងខ្លាំង ចង់ឃើញកូនរបស់ខ្លួនពីរនាក់ដែលនៅផ្ទះ តែពេទ្យមិនព្រមឲ្យជួប ព្រោះជម្ងឺស្រ្តីនោះ

អាចឆ្លងទៅកូនបាន ដល់វេលាម៉ោង២ ជាងពាក់កណ្ដាលអធ្រាត្រក្នុងយប់នោះ ស្ត្រីនោះមានអាការដូចមនុស្សស្លាប់ មាត់ហា ភ្នែកបើកបាត់ដង្ហើមចេញចូល។ ពេទ្យដែលនៅប្រចាំការ ក៏ពុំអាចដឹងច្បាស់ថាជាស្ត្រីនោះស្លាប់ហើយឬនៅឡើយ ។ លុះព្រឹកឡើងស្ត្រីនោះដឹងខ្លួនដូចជាមនុស្សទើបភ្ញាក់ពីដេក ក៏ប្រាប់ម្ដាយខ្លួនថា "យប់មិញទៅនៅនឹងកូនទើបមក" ស្ត្រីនោះក៏ស្លាប់ក្នុងវេលាព្រឹកនោះទៅ ។

ចំណែកខាងផ្ទះស្ត្រីដែលកូននៅនោះ វេលាម៉ោង ២ ជាងពាក់កណ្ដាលអធ្រាត្រក្នុងយប់ដែលស្ត្រីនោះភ្លឹក ស្ត្រីដែលជាអ្នករក្សាថែទាំងកូននៅផ្ទះនោះភ្ញាក់ឡើង ក្រឡេកទៅឯគ្រែកូនក្មេងដេកនោះ ឃើញម្ដាយក្មេងនោះឈរនៅជិតគ្រែក្មេងដេក ភ្នែករវិលវល់ មាត់គិតចង់និយាយតែមិននិយាយថាអ្វី ខ្លួនក៏ស្រែសួរថា អ្នកណាមកឈរនៅនោះ ក៏ពុំឆ្លើយតបមកវិញ ក៏ក្រោកចុះពីគ្រែដើរទៅជិតឃើញម្ដាយក្មេងនោះ ដើរចេញពីគ្រែទៅតាមទ្វារ ស្ត្រីដែលរក្សាក្មេងនោះក៏ស្រែកឡោឡើងអ្នកផ្ទះជិតខាងក៏ផ្អើលមកសួរ ស្ត្រីនោះនិយាយប្រាប់មកដំណើរ អ្នកផ្ទះជិតខាងថាស្ត្រីនោះយល់សប្តិមមើរមើរវាយទេ តែស្ត្រីចិញ្ចឹមក្មេងនោះប្រកាន់ម៉ឺងម៉ាត់ថា មិនមែនយល់សប្តិទេ គឺឃើញនឹងភ្នែកប្រាកដ ។

អ្នកប្រាជ្ញដែលពោលរឿងនេះ សន្និដ្ឋានថាប្រាកដជាចេតភូតរបស់ស្ត្រីនោះ ដែលជិតនឹងស្លាប់នោះគឺ ១មានប្រាថ្នាចង់ឃើញកូនខ្លាំងពេកជាហេតុឲ្យកើតមនោមយិទ្ធិ ២ ឃើញរូបកូនជាប់នៅនឹងភ្នែកដែលជាឧគ្គហនិមិត្ត ៣ មានសមាធិជាខ្លាំងបំផុតទាល់តែប្រាកដដូចមនុស្សស្លាប់ សេចក្ដីទាំងនេះចូលក្នុងគោល ៣ ប្រការ ដែលបានពោលមកខាងដើម។

ចំណែកខាងផ្លូវព្រះពុទ្ធសាសនារបស់យើង ដែលពោលអំពីការដកកាយនេះ បានអធិប្បាយតាមគម្ពីរវិសុទ្ធិមគ្គ ទុកនៅក្នុងចំពួកឥទ្ធិវិធីព្រោះជាពួកឫទ្ធិដូចគ្នា បានជាពោលទុកក្នុងចំពួកនោះឃើញថានឹងចូលចិត្ត

ងាយជាង ។

មានបញ្ហាសល់មួយខទៀតថា ការដែលនឹងធ្វើឲ្យក្រសែដួងចិត្ត របស់យើងមានកម្លាំងខ្លាំងឡើងនោះ តើយើងនឹងគិតធ្វើដោយវិធីណា?

អ្នកតែងសៀវភៅនេះ ថាខ្លួនពុំបានហាត់ឲ្យបានចេះដឹងអ្វីក្នុងផ្លូវ ក្រសែដួងចិត្តនោះទេឡើយ ដែលតែងជារឿងទុកនេះ ក៏ដោយសារបាន ឃើញក្នុងសៀវភៅឯទៀតៗ ហើយនឹងបានរៀនធ្វើល្បងឲ្យឃើញផល មកនោះក៏ទេ ។

ឯក្រសែងដួងចិត្ត ដែលនឹងធ្វើឲ្យមានកម្លាំងខ្លាំងនោះ ក្នុងថ្នាក់ ដម្បូងតោងសំគាល់ទុកថា មនុស្សគ្រប់រូបតែងតែមានក្រសែងដួងចិត្តមាន កម្លាំងម្យ៉ាងៗតែកម្លាំងក្រសែដួងចិត្តនោះ ខ្លះក៏គួរប្រាថ្នាយកទុក ខ្លះក៏មិន គួរយកទុក បើយើងចែកយ៉ាងសង្ខេប ក្រសែចិត្តមានពីរចំពូកគឺ ចំពូក១ ដែលស្រូបចូលមក ចំពូក ២ ដែលច្រានចេញទៅ ទាំងពីរចំពូកនេះមាន ទាំងល្អមានទាំងអាក្រក់ ច្របល់គ្នា បើយើងចែកឲ្យល្អិតចេញទៅទៀត ដូច្នេះ :

ក- ចំពូកស្រូបយកមកយ៉ាងល្អ គឺ ក្រសែដែលទាញយកដួងចិត្ត របស់មនុស្សមកឲ្យស្រឡាញ់ខ្លួន មនុស្សដែលមានក្រសែចិត្តបែបនេះអ្នក ណាឃើញក៏នឹងទប់ទល់ចិត្ត កុំឲ្យស្រឡាញ់នោះពុំបានឡើយ ទុកជា មនុស្សនោះ រូបឆោមមិនល្អស្អាតក្តី ឬមិនបានសម្តែងគុណអ្វីដ៏ល្អ ឲ្យ ឃើញប្រាកដក្តី ក៏នៅតែមានចិត្តស្រឡាញ់ ។

ខ- ចំពូកស្រូបយកមកដែលមិនគួរគប្បីប្រាថ្នាទុក គឺក្រសែចិត្តដែល ទាញយកចិត្តរបស់មនុស្សដូចគ្នា តនឹងបានយកមកឲ្យស្រឡាញ់ឬក៏មក ឲ្យស្អប់ក៏ទេ ទាញយកមកធ្វើឲ្យតែរំខានខ្លួនឯង មនុស្សដែលមានក្រសែ ចិត្តបែបនេះ ច្រើនមានមនុស្សចូលចិត្តជួបនិយាយជាមួយ តែនឹងនិយាយ ដោយពាក្យល្អក៏ទេ ជួបចង់តែចំអកចំអន់ជន្លជន្លេញ ឲ្យតែរំខាន ជួនកាល

ហែងថែមទៀត ក្នុងសាលាបង្រៀនយើងគង់ដែលប្រទះឃើញរឿយៗ មានកូនសិស្សខ្លះ ប្រព្រឹត្តខ្លួនរម្យទមមិនទាស់ទែងនឹងអ្នកណា ជួនកាលមិនចូលចិត្តគប់សមាគមនឹងអ្នកណា គ្មានអញនកណាស្អប់ គ្មានអ្នកណាស្រឡាញ់ តែមានមនុស្សចូលចិត្តជន្លជន្លេញលេងឲ្យតែរំខាន ខ្លួនងយើងបើបានប្រទះមនុស្សបែបនេះក៏មានចិត្តចង់កំហែងធ្វើឲ្យយំលេង អ្នកដែលជន្លនឹងបានដឹងខ្លួនថាមកពីហេតុអ្វី បានជាចូលចិត្តជន្លមនុស្សនោះ ឯមនុស្សដែលត្រូវគេជន្លជន្លេញទៀត ក៏មិនដឹងខ្លួនថាហេតុអ្វីក៏គេចូលចិត្តជន្លខ្លួន បើយើងដឹងស្គាល់លក្ខណៈរបស់ក្រសែដួងចិត្តដូច្នេះហើយ យើងនឹងអស់សង្ស័យហើយនឹងចូលចិត្តថាមនុស្សបែបនេះមានក្រសែចិត្តដែលស្រូបទាញយកដួងចិត្តមនុស្សមក ដើម្បីធ្វើឲ្យរំខានតែខ្លួនឯង ក្រសែដួងចិត្តបែបនេះ មិនមានចំពោះតែក្មេងៗទេ សឹងមាននៅលើបុគ្គលដែលមានអាយុច្រើនៗផង ហេតុដូច្នេះបានជាមានមនុស្សខ្លះចាស់ជិតតែនឹងស្លាប់ហើយក៏នៅមានមនុស្សចូលចិត្តជន្លលេងដែរ ។

គ- ចំពូកដែលប្រានក្រសែចិត្តចេញទៅយ៉ាងល្អនោះ គឺដួងចិត្តដែលមានអំណាចអ្នកណាចូលមកជិត តែងតែមានចិត្តកោតខ្លាច ជួនកាលមិនសូវមានមនុស្សហ៊ានចូលជិតផង ព្រោះសេចក្តីខ្លាចមិនមែនមកអំពីស្អប់ទេ អ្នកដែលមានអំណាចវាសនា តែងតែមានក្រសែចិត្តបែបនេះជាច្រើនក្នុងខ្លួន មនុស្សបែបនេះ ទុកជាយើងដឹងច្បាស់ថា គេមិនប្រើអំណាចធ្វើឲ្យយើងខ្លាចទេ ក៏គង់នៅមានចិត្តកោតខ្លាច ទុកជាគេស្រឡា-ញ់រាប់អានយើងយ៉ាងណាក្តី ក៏នៅតែមិនហ៊ានចូលទៅជិតដែរ ។

ង- ចំពូកដែលប្រានក្រសែចិត្តចេញទៅ ដែលមិនគួរប្រាថ្នានោះ គឺក្រសែដួងចិត្តដែលមិនអាចចូលទៅវេញផ្លុងជាមួយនឹងក្រសែចិត្ត របស់អ្នកដទៃ មនុស្សដែលមានក្រសែចិត្តបែបនេះទុកជាមិនបានធ្វើអ្វីឲ្យអ្នកណាស្អប់ ក៏គ្មានអ្នកណាចូលចិត្ត ក្រសែចិត្តយ៉ាងនេះច្រើនមានមនុស្ស

ស្អប់តាំងពីបានឃើញមុខជាដម្បូង ។

ច- ក្រសែដួងចិត្តដែលរាប់ថាល្អជាទីបំផុត ហើយគួរប្រាថ្នាយ៉ាងបំផុតនោះគឺក្រសែចិត្តបែប ក និង គ ផ្សំចូលគ្នាជាក្រសែចិត្តធ្វើឲ្យមនុស្សស្រឡាញ់ហើយកោតខ្លាចផង បានហៅថាក្រសែចិត្តដ៏ល្អ ដួងចិត្តទាំងនេះកើតមកពីហេតុអ្វីបានជាធ្វើឲ្យមនុស្សមានក្រសែចិត្តខុសពីគ្នាដូច្នេះ ? ដំណើរដួងចិត្តនេះត្រូវយើងសំគាល់ទុកថា ដួងចិត្តប្រៀបដូចជាដួងភ្លើងពណ៌សបរិសុទ្ធក្រសែដួងចិត្ត ប្រៀបដូចពន្លឺភ្លើងដែលឆ្លុះពន្លឺនោះជាពណ៌អ្វី មានពន្លឺខ្លាំងអម្បាលម៉ានស្រេចតែនឹងយើងយកកញ្ចក់ពណ៌ណាឆ្លុះកញ្ចក់ដែលសម្រាប់ឆ្លុះភ្លើងនោះ គឺដួងចិត្តរបស់យើងមានដូច្នេះ។ ដើមដម្បូងយើងមានកញ្ចក់ពីរផ្ទាំងសម្រាប់នឹងធ្វើឲ្យក្រសែចិត្តទន់ឬខ្លាំង តាមត្រូវការ កញ្ចក់ទាំងពីរផ្ទាំងនេះគឺ ១ សេចក្តពព្យាយាម សម្រាប់ជួយឲ្យក្រសែចិត្តខ្លាំង ២ សេចក្តីរួញរាធ្វើឲ្យក្រសែចិត្តទន់ កញ្ចក់ទាំងពីរនេះនឹងធ្វើឲ្យក្រសែចិត្តខ្លាំង ឬធ្វើឲ្យទន់ក៏បានទាំងពីរផ្លូវ គឺផ្លូវល្អនឹងផ្លូវអាក្រក់មនុស្សដែលមានព្យាយាម បើជាព្យាយាមខាងផ្លូវល្អក៏ល្អណាស់ បើព្យាយាមខាងផ្លូវអាក្រក់ក៏អាក្រក់ណាស់ មនុស្សដែលមានសេចក្តីរួញរាបើនឹងធ្វើល្អក៏មិនល្អណាស់ បើទុកជាធ្វើអាក្រក់ក៏មិនខ្លាំងលើសលុប ។

ទាំងពីរផ្ទាំងនេះជាកញ្ចក់ជាន់ដើម ។

ឯកញ្ចក់ដែលនឹងផ្លាស់ប្តូរពណ៌ ក្រសែរបស់ដួងចិត្តឲ្យទៅជា៥យ៉ាងតាំងពី ក ដល់ ច ដូចបានពោលមកខាងដើមនោះ មាន៦ផ្ទាំងដែលរៀបទុកជាគូគ្នាដូចមានតទៅនេះ :

គូទី១ - សេចក្តីមេត្តា - សេចក្តីឫស្យា

គូទី២ - សេចក្តីក្លាហាន - សេចក្តីខ្លាច

គូទី៣ - សេចក្តីរឹងប៉ឹង - សេចក្តីទន់ ។

សេចក្តីមេត្តា ជាកញ្ចក់ឆ្លុះឲ្យកើតផលក្នុង ខ ក ពោលគឺមនុស្ស

ដែលមានសេចក្តីមេត្តា ជាប់ជាប្រក្រតី តែងតែមានមនុស្សទាំងឡាយស្រឡាញ់មិនថាផ្លូវព្រះពុទ្ធសាសនាឬអធ្យាត្មវិទ្យាឬលទ្ធិណាៗ ក៏មានគោលសំខាន់ដូចគ្នាថា បើយើងចង់ឲ្យគេស្រឡាញ់យើងត្រូវយើងស្រឡាញ់គេមុន អំពីផ្លូវ "មេត្តា" ដែលមនុស្សជាច្រើនចូលចិត្តប្រើគាថាក្រមួន ប្រេងឬរបស់អ្វីផ្សេងៗនោះសុទ្ធតែជារបស់បញ្ឆោតមនុស្សលោក គោលដែលជាប្រាកដនឹងធ្វើឲ្យសម្រេចផលបានពិតនោះគឺថា "យើងត្រូវតាំងចិត្តឲ្យមាំ ឲ្យមានមេត្តាដល់បុគ្គលដែលយើងត្រូវការឲ្យគេមេត្តាយើងនោះ" នេះជាគោលដ៏ពិតប្រាកដរបស់ "ផ្លូវមេត្តា" ក្នុងផ្លូវព្រះសាសនារបស់យើង ប្រកាន់ថាធ្វើបុណ្យហើយត្រូវផ្សាយមេត្តាឲ្យទៅមនុស្សរាល់គ្នាទុកជាមនុស្សដែលជាសត្រូវរបស់ខ្លួនក៏ដោយ តាមផ្លូវសាសនាគ្រិស្តគេក៏មានគោលដូច្នេះដែរ គេមានពាក្យប្រដៅរបស់គេមួយខ គួរយើងស្តាប់សេចក្តីថា "ចូរអ្នកស្រឡាញ់មនុស្សដែលគេស្រឡាញ់អ្នក សេចក្តីពិតក៏មិនជាការប្លែកអ្វីទេ អ្នកណាៗក៏ធ្វើបាន តែមកចំឡែកនឹងពិបាកធ្វើឲ្យបានជាផលល្អបំផុតនោះ គឺត្រូវស្រឡាញ់រាប់អានមនុស្សដែលគេស្អប់អ្នកផង" សេចក្តីនេះជាផលរបស់មេត្តា ដែលយើងអាចរកបានក្នុងខ្លួនយើងមិនបាច់រត់រកអាចារ្យណាប្រដៅឡើយ ។

សេចក្តីខ្លាចនឹងចិត្តទន់ ជាកញ្ចក់ឆ្លុះឲ្យកើតផលក្នុងខ ខ. ដូចដែលយើងឃើញថាមនុស្សត្រូវជន្លជន្លេញជាប្រក្រតីនោះ ព្រោះមនុស្សនោះមានលក្ខណៈជាមនុស្សខ្លាចហើយចិត្តទន់ ។

សេចក្តីក្លាហានជាមនុស្សចិត្តរឹងប៉ឹងជាកញ្ចក់ឆ្លុះឲ្យកើតផលក្នុង ខ គ. សេចក្តីឫស្យា ជាកញ្ចក់ឆ្លុះឲ្យកើតផើលក្នុងខ ង.

សូមលោកអ្នកមើលសៀវភៅនេះសង្កេតល្បងមើល មនុស្សដែលគ្មានអ្នកណា ចូលចិត្តហើយត្រូវគេស្អប់ជាច្រើននោះ តើមកពីហេតុអ្វី គង់ឃើញថាមនុស្សបែបនេះក្នុងចិត្តច្រើនមានសេចក្តីឫស្យាជាប្រក្រតី ជា

មនុស្សមិនចង់ឲ្យអ្នកណាបានថ្កុំថ្កើងជាងខ្លួន ទុកជាមនុស្សនោះលាក់បំបិទបំបាំងចិត្តរបស់ខ្លួនអម្បាលម៉ានក៏មិនសម្រេច ព្រោះក្រសែដួងចិត្តឫស្យានោះខ្លាំងជាងក្រសែចិត្តឯទៀត អ្នកដែលមានក្រសែចិត្តយ៉ាងនេះតែងតែត្រូវគេស្អប់តាំងពីបានឃើញមុខជាដម្បូង កិរិយាវាចាផ្សេងៗ យើងអាចលាក់បាំងបានខ្លះ តែក្រសែដួងចិត្តនេះនឹងលាក់បាំងទុកពុំបានឡើយ។

ក្នុងគុណសម្បត្តិទាំងមូលដែលជាទីបំផុតនោះ គឺសេចក្តីមេត្តា ក្លាហាន មាំមួន ទាំង៣ប្រការនេះផ្សំគ្នាឡើងកើតជាផលក្នុង ខ ច. ដែលជាក្រសែយ៉ាងល្អគួរប្រាថ្នា បើយកសេចក្តីព្យាយាមបញ្ចូលថែមទៀតក៏នឹងជួយឲ្យក្រសែដួងចិត្តកាន់តែមានកម្លាំងខ្លាំងឡើង ជាការប្រសើរណាស់។

កាលណាយើងពិចារណាមកដល់ត្រឹមនេះហើយ ក៏នឹងពិចារណាតទៅដល់បញ្ហាដែលថាធ្វើដូចម្តេច នឹងបានក្រសែដួងចិត្តរបស់យើងមានកម្លាំងខ្លាំង ច្រើនឡើងដោយងាយតទៅទៀត រឿងនេះគេបានសរសេរជាគោលដូច្នេះ :

១. ព្យាយាមលះបង់ចោលកញ្ចក់ដែលមិនល្អទាំង៤ផ្ទាំងចេញ គឺសេចក្តីរួញរា សេចក្តីឫស្យា សេចក្តីខ្លាចនឹងចិត្តទន់ចេញឲ្យអស់ ទុកនៅតែ៤ផ្ទាំង គឺសេចក្តីព្យាយាម សេចក្តីមេត្តា សេចក្តីក្លាហាននឹងសេចក្តីរឹងប៉ឹង ។

២. វេលានិយាយនឹងអ្នកណា ឲ្យសំឡឹងមើលភ្នែកអ្នកនោះ ឬអ្នកដែលស្គាល់យើងនិយាយដរាបណា ភ្នែកយើងមិនទាន់រឹងល្មមនឹងសំឡឹងភ្នែកគេត្រង់បានទេ នឹងធ្វើឲ្យក្រសែងដួងចិត្តរបស់យើងឲ្យបានខ្លាំងមាំមួនពុំបានឡើយ ។

៣. ណែនាំខ្លួនឯង (Auto-suggestion) នោះរឿងនេះជាបញ្ហាធំបំផុតក្នុងផ្លូវអធ្យាត្មវិទ្យា ហើយជាវិធីដែលអ្នកប្រាជ្ញក្នុងសម័យនេះ យល់

ឃើញព្រមគ្នាថា ជាកាំជណ្ដើរដ៏ពិតប្រាកដសម្រាប់នឹងឲ្យបុគ្គលឈានឡើងទៅកាន់សេចក្ដីសម្រេចបាន រឿងនេះអ្នកតែងសៀវភៅនេះ បានបរិយាយអំពីការហ្វឹកហ្វឺនខ្លួនឯង ទុកក្នុងសៀវភៅបង្ហាត់ម៉ុនស្នង (ខួរក្បាល) ដែលបានបោះពុម្ពលើកទី២ នោះហើយក្នុងសៀវភៅនេះគ្រាន់តែពោលយ៉ាងខ្លីៗ ពីការហ្វឹកហ្វឺនខ្លួនឯង ដែលមានគោលទុកថា ឲ្យយើងនឹកឬនិយាយខ្លួនឯង ថាយើងជានេះជានោះតាមដែលយើងត្រូវការ ក្នុងការបណ្ដុះកម្លាំងដួងចិត្ត ក៏ត្រូវនឹកឬនិយាយ (ម្នាក់ឯង) ថាដួងចិត្តរបស់យើងមានកម្លាំង ការនឹកឬនិយាយដូច្នេះជាឧបករណ៍ដ៏សំខាន់ដែលនឹងធ្វើក្រសែដួងចិត្តឲ្យមានកម្លាំងឡើង នឹងនាំឲ្យបានសេចក្ដីសម្រេចដល់ការទាំងពួងផង ។

សេចក្ដីដែលពោលមកហើយនេះ នឹងជួយឲ្យលោកអ្នកមើលយល់នឹងជ្រាប វិធីបណ្ដុះក្រសែដួងចិត្ត បើចូលចិត្តយល់ឃើញតាមវិធីទាំងនេះ នឹងធ្វើល្បងមើលខ្លះក៏គួរ ព្រោះមានតែផ្លូវល្អ គ្មានផ្លូវឲ្យអន្តរាយឡើយ ។

តអំពីនេះ នឹងនាំយកសេចក្ដីអធិប្បាយរបស់យោគីពីការរក្សារោគដោយអំណាចដួងចិត្ត មកទុកក្នុងទីនេះ ដើម្បីឲ្យលោកអ្នកមើលក្រេបកនឹងសេចក្ដីត្រិះរិះរបស់ខ្លួនក៏នឹងឃើញថា ក្នុងសម័យណាៗប្រទេសណាក្ដីតែងតែមានមនុស្សចេះដឹងប្រើវិធីរក្សារោគដោយអំណាចដួងចិត្តជាដរាប តែគេប្រកាន់ថាជាអំណាចស្ងាត់កំបាំង Pouvoir occulte សម្រាប់ខ្លួនមនុស្សដែលបានមកពីព្រះឬទេវតាអង្គណាក៏ដោយ ដែលជាប្រាកដនោះពួកដែលបានមកពីព្រះឬទេវតាអង្គណាក៏ដោយ ដែលជាប្រាកដនោះ ពួកដែលមានវិជ្ជាបែបនេះ គង់មានខ្លះដឹងថាមិនមែនណាមកពីណាទេ គឺអំណាចមកពីដួងចិត្ត របស់ខ្លួនដែលនិយាយថាបានអំណាចមកពីព្រះឬមកពីអ្វីៗនោះ ដើម្បីឲ្យមនុស្សជឿច្រើនឡើងព្រោះសេចក្ដីជឿជាឧបករ-ណ៍ដ៏សំខាន់របស់វិជ្ជានេះ តែគោលដែលពិតប្រាកដនោះដូចមានពោល

ទៅ ។

លោកអ្នកមើលសៀវភៅនេះ ក៏បានឃើញថា លទ្ធិរបស់យោគី ដែលគេប្រកាន់ថា មនុស្សយើងមានចំណែកធំ បែងចេញជា ៧ ភាគក្នុង ៧ភាគនេះ ភាគដែលត្រូវការជាពិតប្រាកដ សម្រាប់នឹងធ្វើឲ្យមនុស្ស ទ្រទ្រង់កាយនៅបានក្នុងលោកគឺ "ប្រាណ" កាលណាប្រាណអស់ទៅ ហើយ កាយក៏បែកធ្លាយ ដែលយើងហៅថាស្លាប់ ហេតុនេះបានជាគេ ប្រកាន់ថាមនុស្សដែលឈឺ ព្រោះប្រាណរបស់មនុស្សនោះ ធ្វើការមិនគ្រប់ គ្រាន់ដោយមានទាស់ឬមានកម្លាំងតិច ប្រាណជាធម្មជាតិមួយដែលនឹង ផ្ទេរចេញពីគ្នាបាន ឬយកទៅជួយគ្នាបាន ដូចពេទ្យសម័យនេះស្រូបយក ឈាមពីមនុស្សដែលមានកម្លាំងមាំមួន បញ្ចូលទៅខ្លួនមនុស្សជម្ងឺ ជួយឲ្យ មានកម្លាំងច្រើនឡើង ត្រង់ការរក្សារោគដោយដួងចិត្តនោះគេយកប្រាណគឺ កម្លាំងសរសៃប្រសាទ នឹងកម្លាំងខ្យល់ដង្ហើមចេញចូលទៅជួយ ជាជំនួស ឈាមបញ្ចូលទៅជួយនោះវិញ វិធីបែបនេះមានច្រើនប្រការគឺ :

១- ផ្ទេរប្រាណចាកខ្លួនពេទ្យ ចូលត្រង់ទៅមនុស្សជម្ងឺតែម្តង វិធីនេះ ធ្វើបានពីរយ៉ាង ម្យ៉ាងប្រើ "ផ្លុំ" ដែលនឹងបញ្ចូលខ្យល់ដកដង្ហើមព្រមទាំង កម្លាំងប្រាណឲ្យផ្សាយចូលទៅ ជ្រួតជ្រាបត្រង់កន្លែងដែលឈឺនោះ ម្យ៉ាង ទៀតប្រើម្រាមដៃដៃស្ទាប ដោយប្រកាន់ថាប្រាណឬក្រសៃដួងចិត្តនោះ ផ្សាយចេញតាមចុងម្រាមដៃរបស់មនុស្សជាច្រើន ហេតុនេះឯងបានជា ធម្មជាតិធ្វើឲ្យមនុស្សគ្រប់ជាតិគ្រប់ភាសា ចេះដឹងប្រើម្រាមដៃចង្អុលក្នុង វេលានិយាយការអ្វីៗ ឲ្យមនុស្សស្តាប់ បើជាការសំខាន់ ដែលនឹងបង្គាប់ឲ្យ មនុស្សជឿ ដូចជាអ្នកមានអំណាចលើអ្នកដែលនៅក្រោមបង្គាប់នោះ កាលណាបង្គាប់ការជាមាំមួន ច្រើនប្រើម្រាមដៃចង្អុលទៅអ្នកទទួលបង្គាប់ ជាដរាប ពោលគឺក្រៅពីបង្គាប់ដោយសម្តីហើយ ថែមបង្គាប់ដោយក្រសៃ ដួងចិត្តទៀត មនុស្សដែលមិនស្គាល់ក្រសៃដួងចិត្តសោះ ក៏អាចធ្វើបាន

ដែរ ព្រោះជាកំណើតរបស់ធម្មជាតិ ។

២- មានវិធីម្យ៉ាងទៀត សម្រាប់មនុស្សរក្សាជម្ងឺ ដែលមិនអាចទៅដល់ខ្លួនមនុស្សជម្ងឺឬប៉ះពាល់ដល់ខ្លួនមនុស្សជម្ងឺនោះ គឺផ្ទេរប្រាណចូលទៅរបស់អ្វីមួយ រួចបានផ្ទេរពីរបស់នោះចូលទៅខ្លួនមនុស្សជម្ងឺ របស់ដែលនឹងទទួលប្រាណទុកនោះមានច្រើនយ៉ាង ដែលល្អបំផុតគឺទឹក ការផ្ទេរប្រាណឲ្យចូលទៅក្នុងទឹកនោះ នឹងប្រើដៃត្រាំទឹក ឬផ្លុំឲ្យខ្យល់ដកដង្ហើមចូលទៅក្នុងទឹកក៏បាន រួចយកទឹកនោះទៅស្រោចមនុស្សជម្ងឺ វិធីនេះគឺវិធីធ្វើទឹកមន្តដែលយើងដឹងស្គាល់គ្រប់គ្នា ។

៣- សម្រាប់អ្នកដែលមានកម្លាំង ដួងចិត្តខ្លាំងណាស់នោះ មិនបាច់ផ្ទេរប្រាណដូច្នេះទេ គេអាចប្រើកម្លាំងដួងចិត្ត បង្គាប់ប្រាណឲ្យចេញទៅទីឆ្ងាយៗ ចូលទៅក្នុងខ្លួនមនុស្សជម្ងឺបាន ។ ដែលនឹងធ្វើឲ្យសម្រេចតាមវិធីនេះ អ្នករក្សាជម្ងឺនឹងមនុស្សជម្ងឺត្រូវប្រតិបត្តិតាមរបៀប គឺប្រការ១ អ្នករក្សាត្រូវតាំងចិត្តឲ្យមាំបង្គាប់ប្រាណរបស់ខ្លួន ឲ្យចេញពីខ្លួនចូលទៅខ្លួនមនុស្សជម្ងឺ។ ប្រការ២ ត្រូវឲ្យមានមនោគតិ មើលឲ្យឃើញថា មនុស្សជម្ងឺនោះនឹងសះជាចាករោគ ដោយកម្លាំងដួងចិត្តរបស់ខ្លួនជាប្រាកដ។ ខាងមនុស្សជម្ងឺវិញ ប្រការ១ ត្រូវមានសេចក្តីជឿជាប្រាកដថា ខ្លួននឹងជាដោយការរក្សាបែបនេះ ប្រការ២ ត្រូវឲ្យនឹកថា ខ្លួនអញនឹងជារោគដោយគ្រូនេះជាប្រាកដ បែបនេះហើយដែលជាការរក្សារោគដោយអំណាចដួងចិត្ត។

សេចក្តីនេះគ្រាន់តែកាត់ស្រង់យកមកប្រែទុកជូនលោកអ្នកមើលសៀវភៅនេះស្តាប់អំពីការរក្សារោគបែបនេះល្អត្រឹមណានោះ ទុកជូនលោកអ្នកមើលវិនិច្ឆ័យចុះ ទុកជាដូចម្តេចក្តី បើយើងដឹងយល់គោលនេះប្រាកដហើយ យើងក៏មិនវង្វេងជឿមនុស្សដែលមានឧបាយកលនាំយកវិជ្ជាអំណាចដួងចិត្តមកប្រើ ជាគ្រឿងប្រដាប់សម្រាប់បញ្ឆោតមនុស្សនោះទេ ។

# វិជ្ជាប្រការទី ៣

ឥទ្ធិវិធិ

រឿងឥទ្ធិវិធិនេះ តាមក្នុងសៀវភៅធម្មវិភាគ បរិច្ឆេទទី២ ពោលជានិទ្ទេសទុកថា "សម្តែងឫទ្ធិបានផ្សេងៗគឺមនុស្សម្នាក់និម្មិតឲ្យឃើញមានជាមនុស្សច្រើននាក់ក៏បាន មនុស្សច្រើននាក់ត្រឡប់ធ្វើឲ្យនៅតែម្នាក់វិញក៏បាន បំបាំងខ្លួនចេញចូលតាមវត្ថុអ្វីៗ ដែលខាំងរាំង ដូចជាជញ្ជាំងកំផែងឬភ្នំក៏បាន ជ្រែកដីទៅផុះក្នុងទីណាៗក៏បាន ដើរលើទឹកក៏បាន ហោះហើរដើរអង្គុយលើអាកាសក៏បាន យកដៃទៅស្ទាបព្រះចន្ទ្រនឹងព្រះអាទិត្យក៏បាន ប្រើអំណាចកាយទៅដល់ព្រហ្មលោកក៏បាន ។

សម្តេចព្រះមហាសមណ ក្រុមវជ្ជីរញ្ញាណវរោរស បានប្រទានព្រះតម្រិះទុកថា "តាមនិទ្ទេសមើលទៅ ជារបស់ហួសធម្មតាមនុស្ស តែនៅមានកិច្ចការរបស់មនុស្សយកមកប្រៀបប្រដូចបានច្រើនយ៉ាង គឺមនុស្សម្នាក់ធ្វើឲ្យឃើញមានជាច្រើននាក់ ប្រដូចនឹងមនុស្សម្នាក់ធ្វើការបានច្រើនមុខប្រៀបដូចជាព្រះរាជាមួយព្រះអង្គគ្រងអាណាចក្រជាច្រើន មនុស្សច្រើនឲ្យឃើញតែម្នាក់នោះ ប្រៀបនឹងការរួមសាមគ្គីរបស់ឯកជនជាមួយគណៈដូចយ៉ាងព្រះសង្ឃ បំបាំងនឹងជ្រែកដី ប្រៀបនឹងការជីកឧម្មង្គ ដើរលើទឹកប្រៀបនឹងមនុស្សទៅប្រទេសត្រជាក់ដើរលើទឹកកក ហោះប្រៀបនឹងអាកាសយាន ស្ទាបព្រះអាទិត្យនឹងព្រះចន្ទ្រដោយដៃបាន ប្រៀបដូចការស្គាល់ដំណើរព្រះចន្ទ្រនឹងព្រះអាទិត្យរហូតដល់ចេះទំនាយទាយ ចន្ទ្រគ្រាសសូរ្យគ្រាសបាន ប្រើអំណាចដោយកាយទៅដល់ព្រហ្មលោកបាននោះ ប្រៀបដូចការចេះទំនាយទាយផ្កាយនពគ្រោះនឹងស្ថានរបស់ផ្កាយឫក្សបាន" តាមសេចក្តីប្រៀបនេះ មើលទៅសម្តេចព្រះមហាសមណៈទ្រង់មិនជឿឥទ្ធិវិធិសោះក៏ទេ តាមដែលបរិយាយទុកក្នុងនិទ្ទេសនោះ ឃើញថាទ្រង់គង់ជឿខ្លះឬក៏ជឿទាំងអស់ តែទ្រង់ជាប្រមុខពុទ្ធមាមកៈក្នុងប្រទេស

ស្យាម ក្នុងសម័យដែលទ្រង់គង់ព្រះជន្មនៅឡើយ បើនឹងមានព្រះបន្ទូលការអ្វីចេញទៅ ទ្រង់ប្រយ័ត្នមិនពោលពីរបស់អ្វីដែលពិបាកពិសោធបាននោះទេ ដើម្បីបង្ការមិនឲ្យមាន សេចក្តីចំអកពីមនុស្សទាំងឡាយនោះផង ប្រការមួយទៀត ទ្រង់ឃើញថាក្នុងសម័យនេះ ការសិក្សាធម៌របស់ព្រះពុទ្ធជាម្ចាស់សំដៅទៅតែក្នុងផ្លូវគន្ថធុរៈជាច្រើន ត្រង់ផ្លូវវិបស្សនាធុរៈ មានអ្នកសិក្សាតិច បានជាទ្រង់រកពាក្យ អធិប្បាយឲ្យចូលចិត្តងាយ សៀវភៅទ្រង់តែងទុក ក៏ជាបែបសម្រាប់រៀនថ្នាក់ដើមៗបើប្រសិនចាទ្រង់មិនប្រៀបប្រដូចខ្លះអ្នកដែលចាប់រៀនធម៌ដំបូងនឹងរួញរាឃើញថាការសិក្សា ផ្លូវព្រះពុទ្ធសាសនាជារបស់ពិបាកលើសវិស័យមនុស្ស ហេតុនេះគួរឃើញគួរយល់ថាការប្រៀបប្រដូចនោះ ជាការបង្ហំមិនមែនថាទ្រង់មិនជឿឥទ្ធិវិធិដូចជាអធិប្បាយរបស់ទ្រង់ ទុកក្នុងនិទ្ទេសនោះទេ ។

សៀវភៅនេះ មិនជាគោលសម្រាបឲ្យអ្នករៀនសូត្រគ្រប់គ្នាធ្វើតាមទេ គ្រាន់តែជាសេចក្តីយល់ឃើញ របស់បុគ្គលពោលតាមគំនិតដែលគិតឃើញ ដោយមិនខ្លាចក្រែងសេចក្តីចំអកចំអន់ បើលោកអ្នកឯណាយល់ឃើញថានៅមានសេចក្តីតក់ភ្លាត់ជាច្រើនឬខុសទាំងអស់ក្តី ក៏ចូរតែងសេចក្តីជាសៀវភៅមួយ ក្នុងរឿងដូចគ្នានេះ មកពិឃាតលបលាងសេចក្តីយល់ឃើញរបស់សៀវភៅនេះឲ្យរលំរលាយទៅ ប្រៀបដូចគេកាប់ក្របែ-លដើមចេកដោយដាវមុតដូច្នោះចុះ ។

តាមសេចក្តីយល់ ឃើញថា ឥទ្ធិវិធិ មានសេចក្តីប៉ុនប៉ងត្រង់តាមនិទ្ទេសគ្រប់ប្រការមិនចាំបាច់គិតប្រៀបធៀបទេ ព្រោះឥទ្ធិវិធិជារបស់ខ្ពស់លើសវិស័យមនុស្សសាមញ្ញជាប្រាកដ បើប្រកាន់ថាចិនដែលដើរលើទឹកកកក្នុងរោងធ្វើទឹកកកបាន ឬជាតិសាសន៍អេស្គិមូ ដើរលើទឹកកករកចាប់ឆ្មាទឹក នឹងពួកលាវស៊ីឈ្នួលជីកឧមង្គ ធ្វើផ្លូវរទេះភ្លើងទាំងនោះ ទុកជាពួកអ្នកបានសម្រេចឥទ្ធិវិធិពិតមែនហើយ ក៏គួរអាណិតអាសូរវិជ្ជា ៨ ប្រការ

ពេកណាស់ មកធ្លាក់ចុះដល់ថ្នាក់ទាបបំផុតហួសពេកនេះ មើលទៅសម្តេចព្រះមហាសមណៈប្រាកដជាទ្រង់មិនប្រកាន់ជឿដូច្នោះទេ ដែលទ្រង់ប្រៀបទុកដូចបានពោលមកហើយនោះ គ្រាន់តែជាសេចក្តីប្រដូចប៉ុណ្ណោះ ។

តទីវិធិនេះ មានលក្ខណៈជិតមនោមយិទ្ធិជាច្រើន បើនឹងហៅថាមនោមយិទ្ធិក៏មានកម្លាំងក៏បាន ការនឹងអធិប្បាយវិជ្ជានេះ ត្រូវចែកអធិប្បាយជា ៣ថ្នាក់ដូចបានអធិប្បាយមកហើយក្នុងមនោមយិទ្ធិ គឺថ្នាក់ទាប ថ្នាក់កណ្តាល នឹងថ្នាក់ខ្ពស់បំផុត ។

ថ្នាក់ទាបយើងគង់ដែលបានឃើញជាច្រើន មនុស្សខ្លះធ្វើការបានប្លែកម្យ៉ាងៗ ឬដែលយើងហៅថាលេងកល លោកអ្នកមើលសៀវភៅនេះគង់ញញឹមចំអកចំអន់ថា មិនគួរនាំយករឿងលេងកល ជារបស់លេងតាមផ្លូវមកចុះទុកក្នុងសៀវភៅដែលពោលពីធម៌ដ៏ប្រសើរ របស់ព្រះពុទ្ធជាម្ចាស់សោះ ហេតុដែលយកមកចុះទុកនេះគ្រាន់តែសំគាល់ដល់កម្លាំងដួងចិត្តរបស់បុគ្គល មិនបានសំគាល់ដល់ការដែលលេងបញ្ឆោតភ្នែកមនុស្សយ៉ាងដែលចាប់បានងាយៗនោះទេ ល្បែងលេងកលនេះបានឃើញមកជាច្រើន ច្រើននិយាយគ្នាថា លេងត្រង់នេះជាការបញ្ឆោត ត្រង់នោះជាការបំបាំងភ្នែក ហាក់ដូចជាថាខ្លួនដឹងត្រឹមនេះក៏ល្មមស្គាល់បានហើយដែលជាពិតប្រាកដនោះមិនទាន់ស្គាល់ល្មមគ្រប់គ្រាន់ទេ នៅមានខដែលគួរឲ្យដឹងស្គាល់តទៅទៀត គឺថាការដែលគេលេងបញ្ឆោតបំបាំងភ្នែកនោះតើគេធ្វើដោយវិធីណា ?

ការបំបាំងភ្នែកនេះ បានស្រាវជ្រាវរកសេចក្តីអធិប្បាយ ប្រទះឃើញក្នុងសៀវភៅរបស់ពួកឥណ្ឌា ឈ្មោះស្វាមីបន្ទជាសី តែងទុកជាគោលដ៏សំខាន់ថាគំនិតរបស់មនុស្សយើងនោះ អាចធ្វើឲ្យកើតជារូបរាងឡើងបានលុះតែកាលណាគំនិតនោះខ្លាំងណាស់ ហើយត្រូវបញ្ជូនគំនិតនោះឲ្យ

ក្លាយច្បាស់ជារូបមាននៅទីកន្លែងដែលនឹងធ្វើឲ្យគេឃើញនោះបានគំនិតដែលធ្វើឲ្យមានជារូបរាងនេះ ភាសាបារាំងហៅថា (Forme de la pensee) មនុស្សដែលលេងកលដោយអំណាចដួងចិត្តរបស់ខ្លួនជាពិតប្រាកដនោះ គឺធ្វើគំនិតឲ្យមានជារូបរាងឡើង ដោយវិធីបែបជាមួយនឹងមនោមយិទ្ធិ ដែលបានអធិប្បាយមកហើយ ពោលគឺ(១) ឧគ្គហនិមិត្ត (vision) ព្យាយាមសំគាល់ចាំរបស់ ដែលត្រូវការនឹងធ្វើឲ្យកើតមានឡើងនោះទាល់តែជាប់នៅនឹងភ្នែក (២) មនោមយិទ្ធិ គឺឲ្យមានសេចក្តីប្រាថ្នាយ៉ាងខ្លាំង ចង់ឲ្យរបស់នោះកើតមានឡើង (៣) ឲ្យមានសមាធិបែបយ៉ាងដែលនឹងធ្វើនោះ គឺបើមានដបមួយទទេស្អាតហើយនឹងធ្វើឲ្យមនុស្សឃើញមានជាផ្កាកុឡាបនៅក្នុងដបនោះ(១) ត្រូវចាំរូបរាងលក្ខណៈផ្កាកុឡាឲ្យជាប់នៅនឹងភ្នែកដែលជាឧគ្គហនិមិត្ត របស់នេះមិនមែនធ្វើដោយងាយបាននោះទេ តោងហាត់ធ្វើយូរឆ្នាំ ដូចជាអង្គុយសំឡឹងកសិណ ដែលបានពោលមកហើយនោះ ការដែលពិបាកធ្វើនោះគឺមកពីភ្នែកមនុស្សយើង តាមធម្មតាអាចឆ្លុះយករូបដែលបានឃើញមកជាប់នៅនឹងភ្នែកបានត្រឹមតែកន្លះវិនាទី បានជាការរៀនឧគ្គហនិមិត្តហើយព្យាយាមធ្វើឲ្យរូបជាប់នៅនឹងភ្នែក ឲ្យបានយូរតាមត្រូវការនោះជារបស់ពិបាកធ្វើណាស់ (២)តោងមានសេចក្តីប្រាថ្នាយ៉ាងខ្លាំង ដែលនឹងឆ្លុះបញ្ជូនរូបផ្កាកុឡាបឲ្យទៅមាននៅក្នុងដបនោះ (៣) តោងមានសមាធិដំកល់ឲ្យនឹងនៅក្នុងផ្កាកុឡាបនោះតែម្យ៉ាង ។

តាមគោលដែលមានមកនេះ បើលោកជឿឬមិនជឿក៏តាមចិត្តចុះតែមនុស្សដែលគេជឿ គេនាំយកវិធីនោះមកប្រើ ក្នុងការធ្វើរបស់ផ្សេងៗបានសម្រេច ដូចជាគ្រឿងថតរូប ភាពយន្ត (កុនស្រមោល) នឹងគ្រឿងបញ្ជូនស្រមោលរូបតាមវិទ្យុ សុទ្ធតែយកដម្រាប់តាមវិធីនេះ គ្រាន់តែប្រើវត្ថុជំនួសមនុស្សប៉ុណ្ណោះ គ្រឿងថតរូបមានកញ្ចក់យ៉ាងក្រាស់ភ្ជាប់មុខបំពង់

គ្រឿងថត ប្រៀបដូចភ្នែកមនុស្ស សម្រាប់ឆ្លុះយករូបនៅមុខគ្រឿងចូលទៅជាប់ហ្វីល្ម គឺវត្ថុដែលមានថ្នាំភ្ជាប់សម្រាប់ទទួលស្រមោលរូបទុកប្រៀបដូចដួងចិត្តរបស់មនុស្ស ដូចមានពោលមកហើយ ថាភ្នែកមនុស្សអាចឆ្លុះយករូបដែលឃើញមកភ្ជាប់ទុកនៅនឹងភ្នែកបានកន្លះវិនាទី ព្រោះគេបានប្រទះវិធីមួយនេះហើយ បានជាគេគិតធ្វើភាពយន្តឲ្យសម្រេចបានគឺផ្លាស់រូបរាល់កន្លះវិនាទី ឲ្យមនុស្សមើលឃើញរូប កម្រើកដៃជើងដើរទៅមកបាន តែបើយើងទៅពិនិត្យ ពិចារណាមើលរូបរាងក្នុងហ្វីល្មឲ្យច្បាស់ប្រាកដហើយ ក៏នឹងឃើញរូបទាំងនោះផ្សេងៗពីគ្នា ជារយៈៗរាប់ពាន់ហ្មឺនរូប ។

ភាពយន្តក្ដី ឬគ្រឿងឆ្លុះរូបក្ដី សុទ្ធតែគិតបង្កើតតាមគោល ៣ ប្រការនេះជាពិត គឺឧគ្គហនិមិត្តបង្កើតឡើងដូចជារូបភ្ជាប់នៅហ្វីល្មឬកញ្ចក់ដែលមានរូបជាប់នៅនោះ មនោមយិទ្ធិ ដូចគ្រឿងឆ្លុះរូបទៅឃើញនូវសំពត់រនាំង សមាធិដូចតាំងដំកល់គ្រឿងឆ្លុះឲ្យនឹងមិនឲ្យងាកងោកបាន ដើម្បីឲ្យឃើញរូបច្បាស់ឯគ្រឿងឆ្លុះរូបតាមវិទ្យុនោះ ក៏យកតាមគោលនេះដូចគ្នាគ្រាន់តែធ្វើគ្រឿងទាំង ៣ នោះឲ្យខ្លាំងឡើង ។

គ្រានេះយើងនឹងស្គាល់ឬសគល់ថា ការលេងកលឧបាយផ្សេងៗដែលគួរឲ្យឆ្ងល់នោះបង្កើតពីភ្នែកនឹងដួងចិត្តរបស់មនុស្សនោះឯង ពីព្រោះរូបទាំងនោះគ្រាន់តែជាស្រមោល មិនមែនខ្លួនប្រាកដនោះទេ បានជាឃើញតែក្នុងវេលាកំពុងដួងចិត្តមានអំណាចបង្គាប់ ឲ្យមានជារូបឡើងឲ្យមនុស្សឃើញបានមួយស្របក់ បានជាថតរូបមិនជាប់ បារាំងដែលបានឃើញពួកយោគី ធ្វើរបស់អ្វីៗ ឲ្យកើតបានក្នុងវេលាមួយរំពេចនោះគេបានព្យាយាមថតយករូបទុក តែដល់លាងហ្វីល្មទៅ មិនឃើញមានរូបជាប់នៅនឹងហ្វីល្មសោះ ។

សេចក្ដីដែលពោលមកនេះ ជាឥទ្ធិវិធិយ៉ាងទាប តទៅនេះយើងនឹង

ល្បងពិចារណាដល់យ៉ាងកណ្តាល ។

មានពាក្យអធិប្បាយរបស់ព្រះយោគីប្រការមួយថា ដួងចិត្តរបស់យើងអាចសាងអវយវៈឲ្យយើងបានមួយបែបទៀត ដែលក្នុងភាសាបារាំងហៅថា ប្រាអ៊ាស្ត្រូស៍ (Bras astraux) បើប្រែតាមតួអក្សរថា "ដៃដែលជាប់តនឹងដួងផ្កាយ" គេអធិប្បាយថា យើងអាចប្រើដៃបែបនេះ ទៅធ្វើការយ៉ាងណាៗបានតាមត្រូវការ ដោយខ្លួនយើងមិនបាច់កម្រើកពីទីកន្លែង ដៃបែបនេះនឹងចង់ឲ្យមានកម្លាំងប៉ុន្មានៗ ក៏សម្រេចបានតាមចិត្តអ្នកដែលមានអំណាចប្រើដៃបែបនេះ អាចធ្វើឲ្យកម្រើករបស់ដែលមានទម្ងន់ធ្ងន់លើសកម្លាំងមនុស្ស ឲ្យឃ្លាតចេញពីទីកន្លែង មិនបាច់ពាល់ដោយដៃក៏បាន ហើយនឹងធ្វើការផ្សេងៗបានច្រើនជាអនេកតទៅទៀតសេចក្តីនេះត្រូវនឹងនិទ្ទេស ក្នុងឥទ្ធិវិធិរបស់យើងថា "ពាលអង្អែលព្រះអាទិត្យនឹងព្រះចន្ទ្រដោយដៃបាន" ។

ប្រាអ៊ាស្ត្រូស៍ ឬដៃដែលជាប់តនឹងដួងផ្កាយនេះជាសេចក្តីប្រាថ្នាយ៉ាងខ្ពស់បំផុត របស់ពួកយោគីក្នុងឥណ្ឌៀ ចង់ធ្វើឲ្យកើតមានឡើង បានជានាំគ្នាទៅព្យាយាមធ្វើ អត់បាយក្រហាយទឹក នៅតាមភ្នំហិមាល័យរាប់ជាឆ្នាំៗ ខ្លះក៏រហូតអស់មួយជីវិតក៏មាន តាមដែលបានឃើញកាសែតអង់គ្លេសនិយាយរៀបរាប់ ពីពួកយោគីដែលទៅប្រកាសព្រះពុទ្ធសាសនាក្នុងស្រុកបារាំងនោះ យោគីដែលជាមេគណ បានអធិប្បាយបំភ្លឺសេចក្តីឲ្យអ្នកតែកាសែតថា ផលដែលពួកយោគីត្រូវការលុះនោះ គឺត្រូវការឲ្យមានឫទ្ធិរំកិលភ្នំ នឹងបង្គាប់ធាតុទាំង៤បាន (គឺសំដៅសេចក្តីថានឹងធ្វើឲ្យភ្លៀងធ្លាក់ចុះមកឬឲ្យថ្ងៃរះបានតាមសេចក្តីត្រូវការ) តាំងពីនោះមកដល់ឥឡូវនេះគ្មានយោគីណាធ្វើបាន ទូកជាដូចម្តេច ក៏គង់នាំគ្នាព្យាយាមតរៀងមកដោយជឿជាក់ថា ព្រះពុទ្ធជាម្ចាស់ព្រះអង្គធ្វើបានសម្រេចជាប្រាកដ ។

វិធីធ្វើឲ្យកើតដៃបែបនេះ តាមគំនិតរបស់ពួកយោគីនោះឃើញថា

មិនហួសពីគោលទាំង៣ ដែលពោលមកនោះទេ គ្រាន់តែថែមមនោគតិឡើងមួយទៀត ដើម្បីជួយឲ្យមនោមយិទ្ធិមានកំលាំងខ្លាំងឡើង ឬក៏សម្រាប់ជួយឲ្យមានចិត្តជឿខ្ជាប់ខ្ជួននូវការសម្រេចរបស់ខ្លួនព្រោះ មនុស្សយើងនឹងធ្វើការអ្វី បើមិនជឿថាការនោះនឹងសម្រេចបានទេក៏គ្មានផ្លូវសម្រេចបានឡើយ ដែលពោលមកនេះជាយ៉ាងកណ្តាល គ្រានេះនឹងពិចារណាដល់ថ្នាក់ខ្ពស់បំផុត។

ឥទ្ធិវិធិយ៉ាងខ្ពស់បំផុតនោះ តាមសេចក្តីអធិប្បាយដែលបានប្រទះមកគឺការប្រើ (១) ចេតភូតដែលពោលមកហើយក្នុងមនោមយិទ្ធិ (២) សេចក្តីគិតបង្កើតជារូបរាង (៣) ដៃដែលជាប់តនឹងផ្កាយ ទាំង៣ ប្រការនេះរួមគ្នាជាមួយ ពោលគឺប្រើខទី១ ជាខ្លួនរបស់យើង ប្រើខទី២ ជាគ្រឿងបញ្ជូនខ្លួនយើងឲ្យទៅប្រាកដឃើញនៅទីណាៗបាន ប្រើខទី៣ ជាកម្លាំងធ្វើការគ្រប់យ៉ាងបានតាមចិត្ត តែរូបខ្លួនដែលជាអ្នកធ្វើនោះនៅៗទីកន្លែងដដែល មិនបានកម្រើតខ្លួនទៅណាឡើយ អ្នកដែលបំបាំង ជ្រែកដី ដើរលើទឹក ហោះហើរដើរលើអាកាសនោះ គឺចេតភូតទាំងអស់ ដែលមានបញ្ហាថា ហេតុអ្វីបានជាព្រះអង្គុលិមាលរត់តាមព្រះពុទ្ធជាម្ចាស់មិនទាន់? យើងអាចដោះស្រាយបានដោយងាយ ថាបានជាព្រះអង្គុលិមាលរត់តាមមិនទាន់ ព្រោះមិនមែនរូបព្រះពុទ្ធដ៏ប្រាកដ គ្រាន់តែចេតភូតរបស់ព្រះអង្គដែលព្រះអង្គធ្វើឲ្យកើតឡើងដោយឥទ្ធិវិធិយ៉ាងខ្ពស់បំផុតត្រង់ ព្រះរូបព្រះអង្គដ៏ពិតមែននោះមិនចាំបាច់ស្តេចទៅក្នុងទីកន្លែងនោះក៏បាន ។

កាលណារៀបរាប់ពណ៌នាមកដល់មនោមយិទ្ធិនឹងឥទ្ធិវិធិ ទាំងនេះហើយ ច្រើនមានមនុស្សចូលចិត្តគិតថាបែបយ៉ាងហិប្ន៉ូទិស្ម៍(Hypnotisme) វិធីសណ្តំដួងចិត្ត តាមសេចក្តីពិតប្រាកដនោះខុសគ្នាច្រើនពាក្យដែលហៅថា ហិប្ន៉ូទិស្ម៍ មកពីភាសាក្រិក (Hypnose) ប្រែថាលក់ វិជ្ជាបែបនេះ ជាវិជ្ជាធ្វើឲ្យមនុស្សដេកលក់ ឬសតិអណ្តែតដោយមិនធ្មេចភ្នែក បែបដែល

ហៅថា (Hypnotisme en etat de veille) វិជ្ជានេះមនុស្សយើងរៀនមកអំពីសត្វតិរច្ឆាន ដូចជាសត្វពស់ដែលមានអំណាចសង្កត់សត្វផ្សេងៗឲ្យតក់ស្លុតជាអាហាររបស់វា បានជាមានពាក្យហៅម្យ៉ាងទៀតថា (Magnetisme animal) គ្រឿងស្រូបរបស់សត្វតិរច្ឆានបែបនេះយើងនឹងឃើញថា ខុសនឹងមនោមយិទ្ធិនឹងឥទ្ធិវិធិជាច្រើន ព្រោះវិជ្ជា២ ប្រការនេះព្រះពុទ្ធជាម្ចាស់មិនបានរៀនពីសត្វតិរច្ឆានទេ ប្រការមួយទៀត ហិប្ន៉ូទិស្ម៍ប្រើបានទាំងផ្លូវល្អនឹងផ្លូវអាក្រក់ ឮល្បីថាមានមនុស្សជាច្រើននាំយកទៅប្រើក្នុងផ្លូវដ៏លាមកអាក្រក់ ដូចជាប្រើជាគ្រឿងបង្គាប់ឲ្យស្ត្រីសុខចិត្ត ឲ្យព្រមរួមប្រវេណីជាដើម ឯមនោមយិទ្ធិនឹងឥទ្ធិវិធិនោះ នឹងនាំយកទៅប្រើក្នុងផ្លូវលាមកអនាចារពុំបានឡើយ តែអ្នកណាមានសេចក្តីប្រាថ្នាយកទៅប្រើដូចពោលមកនេះនឹងបណ្តុះវិជ្ជា២ ប្រការដោយគ្មានវិបស្សនាញាណពុំបានឡើយ ការដែលមានមនុស្សខ្លះពោលថា ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រើហិប្ន៉ូទិស្ម៍នោះ ជាសេចក្តីយល់ខុសខ្លាំងណាស់ ហើយជាការមើលងាយព្រះពុទ្ធជាម្ចាស់ដោយមិនរិះគិត ។

គោលផ្សេងៗដែលបានបរិយាយមកនេះ ជាគំនិតរបស់បារាំងនឹងយោគី ឯចំណែកគោលក្នុងគម្ពីរព្រះពុទ្ធសាសនា តាមដែលព្រះពុទ្ធឃោសាចារ្យ បរិយាយទុកនោះដូចមានសេចក្តីតទៅនេះ :

ក្នុងថ្នាក់ដម្បូង តោងធ្វើកសិណ៨ ពីបឋវីកសីណដល់ឱទាតកសិណ មិនបាច់ប្រើអាលោកកសិណ នឹងបរិច្ឆិន្នាកាសកសិណនោះទេប្រើតែឈាន ៨ ដោយអនុលោម (តាមលំដាប់) នឹងបដិលោម (ច្រាសឡើង) ដោយអាការ១៤ យ៉ាងដូចមានតទៅនេះ :

១- ធ្វើរៀងតាមលំដាប់កសិណ គឺតាំងពិបឋវីកសិណ អាបោកសិណ រៀងរាបតទៅដល់ ឱទាតកសិណ បានមួយរយមួយពាន់ផង។

២- ធ្វើកសិណច្រាសឡើង ពីឱទាតកសិណ លោហិតកសិណទល់

ដល់បឋវីកសិណ ធ្វើបែបនេះឲ្យបានច្រើនគ្រាដូចគ្នា។

៣- ធ្វើតាមលំដាប់កសិណ រៀងទៅទាល់តែអស់ រួចធ្វើច្រាសឡើងវិញឲ្យទាល់តែដល់ដើមវិញ ។

៤- ចូលរូបជ្ឈាន ពីបឋមជ្ឈានដល់ចតុត្ថជ្ឈាន រួចចូលអរូបជ្ឈានពីវិញ្ញាណញ្ចាយតនជ្ឈាន តាមលំដាប់ទាល់តែដល់នេវសញ្ញានាសញ្ញា-យតនជ្ឈាន ឲ្យបានច្រើនគ្រា ។

៥- ចូលឈានច្រាសឡើង ពីនេវសញ្ញានាសញ្ញាយតនជ្ឈាន ទៅដល់បឋមជ្ឈាន ។

៦- ចូលឈានតាមលំដាប់រួចហើយ ចូលច្រាសឡើងវិញ ផ្លាស់ប្តូរបែបនេះជាដរាបទៅ ។

៧- ធ្វើរៀងតាមលំដាប់កសិណ តែរម្លងលំដាប់ឈាន គឺចូលបឋវី-កសិណរួចហើយ ចូលបឋមជ្ឈាន១ រួចហើយ ត្រឡប់ចូលបឋវីកសិណវិញ រួចចូលតតិយជ្ឈាន (រម្លងទុតិយជ្ឈាន) រួចហើយ ផ្លាស់ពីបឋវីកកសី-ណទៅចូលអាបោកសិណរួចហើយ ចូលឈានរម្លងតាមលំដាប់ថ្នាក់ឈាន នឹងផ្លាស់កសិណឲ្យរៀងគ្នាដរាបតទៅ ទាល់តែគ្រប់៨ ។

៨- ធ្វើរៀងតាមលំដាប់ឈាន តែរម្លងលំដាប់កសិណ គឺចូលបឋ-មជ្ឈានហើយ ចូលបឋវីកសិណ រួចត្រឡប់ទៅចូលបឋមជ្ឈានវិញរួចចូលតេជោកសិណ (រម្លងអាបោកសិណ) ធ្វើតាមលំដាប់នេះរួចហើយផ្លាស់ពីបឋមជ្ឈាន ទៅចូលទុតិយជ្ឈាន រួចចូលកសិណរម្លងតាមលំដាប់ថ្នាក់កសិណ នឹងផ្លាស់ឈានឲ្យរៀងគ្នាទាល់តែគ្រប់ទាំង ៨ ។

៩- រម្លងទាំងឈាននឹងកសិណ ពោលគឺចូលបឋមជ្ឈាននឹងបឋវី-កសិណហើយ ចូលតតិយជ្ឈាននឹងតេជោកសិណ ធ្វើដូច្នេះជាដរាបតទៅ ។

១០- រួមអង្គ សំដៅសេចក្តីថា ចូលបឋមជ្ឈាននឹងបឋវីកសិណចូល

ទុតិយជ្ឈាននឹងបឋវីកសិណ ចូលតតិយជ្ឈាននឹងបឋវីកសិណ ធ្វើតាមលំដាប់នេះតទៅទាល់តែអស់ ។

១១- រួមអារម្មណ៍ សំដៅសេចក្តីថា ចូលបឋមជ្ឈានហើយ ចូលបឋ-វីកសិណ រួចវិលទៅចូលបឋមជ្ឈានវិញ រួចចូលតេជោកសិណ ធ្វើយ៉ាងនេះទាល់តែអស់កសិណ ហើយសឹមផ្លាស់ឈានថ្មី ។

១២- រួមអង្គនឹងអារម្មណ៍ សំដៅសេចក្តីថា ចូលឈាននឹងជ្រែកកសិណជាលំដាប់ទៅ ពោលគឺបឋមជ្ឈាននឹងបឋវីកសិណ រួចចូលទុតិយ-ជ្ឈាននឹងអាបោកសិណ រួចចូលតតិយជ្ឈាននឹងតេជោកសិណ ។ល។

១៣- កំណត់អង្គ គឺមិនបានចូលឈាន គ្រាន់តែកំណត់ថាឈានណា មានអង្គប៉ុន្មាន ដូចជាបឋមជ្ឈាន មានអង្គ៥ ទុតិយជ្ឈានមានអង្គ៣ (ដូចមានរបៀបបញ្ជីទុកក្នុងទំព័រ ៣៨) ។

១៤- កំណត់អារម្មណ៍ គឺមិនបានចូលកសិណ គ្រាន់តែរំឭកដល់កសិណថាមានរបស់នោះៗ ជាអារម្មណ៍ ដូចបឋវីកសិណ មានដីជាអារម្ម-ណ៍ អាបោកសិណ មានទឹកជាអារម្មណ៍ ។ល។

តាមវិធីដែលពណ៌នាមកតាំងពីទី១ ដល់ទី១៤នេះ គ្រាន់តែមើលក៏ដឹងខ្លួនថានឿយហត់ទៅហើយ បើប្រសិនជាធ្វើពិតមែន នឹងលំបាកយ៉ាងណាក៏ពុំដឹង ប្រសិនជាឥទ្ធិវិធិជារបស់ធ្វើបានដោយងាយពិតមែនហើយ តែពួកយើងគ្មានអ្នកឯណាដើរតាមផ្លូវថ្នល់ទេ មុខជានាំគ្នាហោះអស់ហើយ ។ បើធ្វើបានសម្រេចតាមវិធីដូចបញ្ញត្តិទុកទាំង ១៤ ប្រការនេះហើយដួងចិត្តនឹងទន់ភ្លន់គួរដល់ការងារ ជាដួងចិត្តបរិសុទ្ធផូរផង់ល្អមាំមួនប្រាសចាកគ្រឿងសៅហ្មង ជាចិត្តគួរដល់អភិនីហារដែលអាចសម្តែងឫទ្ធិបានតាមវិធីរបស់លោកដែលពន្យល់ទុកមក ដូចមានតទៅនេះ :

១- បើត្រូវការបំបាំងខ្លួន ដើរចេញចូលទៅមកតាមជញ្ជាំង កំពែងឬទីកន្លែងដែលមានអ្វីខាខាំងរាំងរាផ្សេងៗនោះ លោកឲ្យចូលអាកាសកសិ-

ណស្រេចហើយរំពឹងដល់ជញ្ជាំងឬកំពែងនោះ រួចអធិដ្ឋានថា របស់ទាំងនោះចូរក្លាយទៅជាអាកាស ជញ្ជាំងឬកំពែងនោះក៏នឹងទៅជាចន្លោះមួយរំពេច បើប្រសិនជានៅទាស់ ត្រូវអធិដ្ឋានជាថ្មីឡើងវិញ ។

២- បើត្រូវការជ្រែកដី ឲ្យចូលអាបោកសិណ រួចអធិដ្ឋានឲ្យដីត្រឡប់ទៅជាទឹក ។

៣- បើនឹងដើរលើទឹក ឲ្យចូលបឋវីកសិណ អធិដ្ឋានឲ្យទឹកទៅជាដី។

៤- បើនឹងហោះហើរដើរលើអាកាស ឲ្យចូលបឋវីកសិណ អធិដ្ឋនាឲ្យអាកាសទៅជាដី ។

៥- អំពីការលូកស្ទាបព្រះអាទិត្យព្រះចន្ទ្រនោះ តាមក្នុងគម្ពីរវិសុទ្ធិមគ្គ ក៏ឲ្យអធិដ្ឋានដូចគ្នា កាលណាអធិដ្ឋានហើយ ព្រះចន្ទ្រព្រះអាទិត្យក៏នឹងធ្លាក់ចុះមកដូចជាផ្លែត្នោតជ្រុះពីធ្លាយមកនៅក្នុងដៃ តែដួងព្រះចន្ទ្រព្រះអាទិត្យពិតនោះនៅទីកន្លែងដើមដដែល ឯដួងព្រះចន្ទ្រព្រះអាទិត្យដែលមកឃើញនៅដៃនោះ គឺរូបនិម្មិត មិនមែនដួងព្រះចន្ទ្រព្រះអាទិត្យមែនៗនោះទេ ។

តាមសេចក្ដីនេះឃើញថា ឥទ្ធិវិធិគ្រប់យ៉ាង សម្រេចដោយការអធិដ្ឋាន ក្នុងការដែលនិម្មិតមនុស្សម្នាក់ឲ្យឃើញមានជាមនុស្សច្រើនឬនិម្មិតមនុស្សច្រើនឲ្យឃើញមានតែម្នាក់វិញឬក៏ការដកហូតកាយដូចជា ដកដាវចេញពីស្រោម ដូចបានពោលមកហើយក្នុងមនោមយិទ្ធិនោះ ក៏សម្រេចដោយការអធិដ្ឋានទាំងអស់ ។

# វិជ្ជាប្រការទី ៤

## ទិព្វសោត

ក្នុងសៀវភៅធម្មវិភាគបរិច្ឆេទទី២ ពោលជានិទ្ទេសពីទិព្វសោតទុកថាមានត្រចៀកទិព្វលើសមនុស្សសាមញ្ញ ស្តាប់សំឡេងបាន២ យ៉ាងគឺ សំឡេងទិព្វនឹងសំឡេងមនុស្ស នៅឆ្ងាយឬជិតបាន សម្រេចព្រះមហាសមណក្រុមវជីរញ្ញាណវរោរស ទ្រង់ប្រៀបទុកថា មានការប្រដូចនូវមនុស្សនឹងវត្ថុ សន្និដ្ឋានយ៉ាងមនុស្សដែលបានទទួលពាក្យប្រាប់ ស្តាប់សំឡេងអំពីចម្ងាយបាន ធៀបដូចឮដំណឹងពីស្រុកឆ្ងាយដែលហៅថាត្រ-ចៀកវែ ឥឡូវមានទោរសព្ទជាគ្រឿងធៀបផង ។

ឯទិព្វសោតនេះ គ្មានសេចក្តីអ្វីនឹងពោលឲ្យច្រើនណាស់ទេ ព្រោះមិនបានប្រទះពាក្យអធិប្បាយដ៏ពេញចិត្តពិតៗនោះសោះ ដែលបានប្រទះខ្លះ ក៏ឃើញមានអធិប្បាយតែផ្លូវអំណាចខាងលើ គឺថាអ្នកដែលបានទិព្វ-សោតនោះ ដោយបានព្យាយាមបំពេញកិច្ច ទាល់តែអាចស្តាប់ព្រះឱង្ការនឹងសន្ទនាជាមួយព្រះម្ចាស់សួគ៌បាន ពាក្យអធិប្បាយនេះខ្ញុំមិនស្រឡាញ់សោះ ប្រការមួយទៀត គោលរឿងនេះ ប្រហែលនឹងរឿងទិព្វចក្ខុដែលនឹងមានអធិប្បាយទុកដោយពិស្តារតទៅនេះ រឿងទិព្វសោតនេះ ដោយឃើញថាត្រចៀកជាផាតមួយ របស់អាយតនៈខាងក្នុង បានជាពោលអំពីអាយត-នៈនោះផង ដើម្បីជាប្រយោជន៍ ២ ប្រការគឺ :

១- នឹងនាំយកបញ្ហាដែលនឹងពោលតទៅនេះ ឡើងកាន់សេចក្តីពិចារណារបស់លោកអ្នកធម៌ ។

២- នឹងដើម្បីជាពាក្យអធិប្បាយអំពីទិព្វសោតនេះផង ។

ឯទិព្វសោតនេះ មានមនុស្សជាច្រើនក្នុងលោកនេះ មិនអាចហ៊ានប្រើគំនិតព្យាយាមស្រាវជ្រាវរក ឲ្យឃើញសេចក្តីពិតដោយខ្លួនឯងសោះ ច្រើនតែចុះចិត្តជឿតាមលទ្ធិម្យ៉ាងៗ ដែលមានអ្នកប្រដៅលំអៀងដោយ

អគតិ បានជាសេចក្តីជឿតាមលទ្ធិម្យ៉ាង ដែលមានអ្នកប្រដៅលំអៀងដោយអគតិ បានជាសេចក្តីជឿតាមនោះក៏ច្រើនខុសប្រាសចាកពីផ្លូវល្អបើមនុស្សដែលត្រិះរិះរកហេតុផលដោយខ្លួនឯង ឲ្យឃើញពិតប្រាកដរួចសិមចុះចិត្តជឿ ប្រតិបត្តិតាមសមគួរដែលខ្លួនឃើញនោះ ទើបឈ្មោះថាមានដំណើរតាមផ្លូវត្រង់ ហើយជាប្រយោជន៍ដល់ជាតិមនុស្សផង យើងគង់ដែលបានដឹងឃើញក្នុងពង្សាវតារលោកថា ក្នុងស្រុកប្រទេសណាៗឬគណៈណា ដែលកាន់តែចម្រើនឡើងនោះ ក៏មកពីមានមនុស្សត្រិះរិះរកហេតុ មិនមែនដោយមានមនុស្សជឿរវើរវាយផ្តេសផ្តាសតាមលទ្ធិផ្សេងៗដោយប្រាសចាកសេចក្តីពិនិត្យពិគ្រោះនោះទេ ។

អំពីសេចក្តីសន្តោស ជារបស់គួរមាន បើអ្នកណាមានហើយ ក៏ទុកដូចមានទ្រព្យដ៏ប្រសើរដូចពុទ្ធភាសិតថា "សន្តុដ្ឋី បរមំ ធនំ" មិនចាំបាច់កកេះកកាយដោយអំណាចតណ្ហា ដែលនឹងដឹកនាំឲ្យធ្វើការទុច្ចរិតបាននោះទេសេចក្តីសន្តោសនេះ សំដៅតែត្រឹមត្រូវសម្បត្តិឬជោគលាភផ្សេងៗមិនបានសំដៅដល់សេចក្តីចេះដឹងទេ ព្រោះចំណេះចេះដឹងជារបស់ដែលយើងគួរស្វែងរកឲ្យខ្ពស់ៗឡើងតទៅ មិនគួរចូលចិត្តនៅត្រឹមចំណេះដែលចេះប៉ុណ្ណោះនោះទេ បើយើងមិនគិតស្រាវជ្រាវរកចំណេះតទៅទៀត រួចថែមទាំងមិនត្រិះរិះគិតរកហេតុផលរបស់ខ្លួនឯងខ្លះផងហើយ លោកក៏មិនបានផ្លាស់សភាព ពីព្រៃមកជារមណីយស្ថាន បែបយ៉ាងដែលយើងឃើញក្នុងឥឡូវនេះឡើយ ដូចមានពាក្យរបស់នាយគ្រេនវិលក្លៃសែរ ជាតិអាមេរិកាន់ ដែលជាអ្នកមានវោហារយ៉ាងឯក សរសេរទុកក្នុងសៀវភៅ "វិធីបណ្តុះកម្លាំងចិត្ត"(១) ថា ការដែលយើងសិក្សាវិជ្ជាដើម្បីជាផ្លូវអាចនាំឲ្យយើងប្រើគំនិតរបស់យើងឲ្យផុះមានឡើងតទៅទៀត មិនបានយកគំនិត

---

(១) សៀវភៅ How to bild Mental Power របស់ Grenvill Kleiser។

របស់អ្នកដទៃ មកផ្ទុកនៅក្នុងខួរក្បាលយើងតែម្យ៉ាងនោះទេ ។

ការដែលប្រារព្ធមកដោយវែងនេះ ដើម្បីជាការដោះខ្លួនទុកជាមុន ក្រែងមានពាក្យនិទ្ទាថា ជាមនុស្សឥតគ្រូដោយហេតុដែលនឹងពណ៌នាដល់រឿងអាយតនៈតទៅនោះ ។

យើងធ្លាប់ទទួលពាក្យប្រដៅមកថា អាយតនៈក្នុងរបស់យើងមាន៦ យ៉ាងគឺភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយនឹងចិត្ត ហើយយើងធ្លាប់ទទួលពាក្យអធិប្បាយតទៅថា ចិត្តនឹងដឹងអ្វីមុនក្រៅពីភ្នែក ត្រចៀក ច្រមុះ អណ្តានឹងកាយរាយការឲ្យជ្រាបនោះពុំបានឡើយ តែយើងចេះដឹងត្រឹមនេះយើងគួរល្មមពេញចិត្តហើយឬនៅ ?

គួរយើងល្បងស្រាវជ្រាវរក ក្រៅអំពីអាយតនៈទាំង៦ ដែលចេញឈ្មោះមកហើយនោះ តើនៅមានអាយតនៈអ្វីតទៅទៀតខ្លះ ដែលនឹងអាចនាំចិត្តឲ្យជ្រាបបាននោះ ?

អំពីការដែលនឹងពិចារណាដល់ខទាំងនេះ យើងល្បងគិតកកាយរកហេតុតាំងពីដើមឈើ សត្វតិរិច្ឆាន ដល់មនុស្ស អ្នកដែលធ្លាប់សង្កេតគង់ដែលឃើញដើមឈើតូចៗ ដែលដុះជិតដើមឈើធំ ឬជិតវត្ថុអ្វីមួយច្រើនងាកចេញពីដើមឈើធំៗ ឬវត្ថុទាំងនោះ មិនលូតលាស់ទល់នឹងដើមឈើធំៗ ឬវត្ថុដែលដុះនៅក្រោមនោះឡើយ ចាតិលតាវល្លិផ្សេងៗ ដែលដុះវារឡើងតាមកំពែងត្រួយវាច្រើនបោះពួយដម្រង់ទៅទីណាដែលមាន កន្លែងតោង រួចកាន់តែលូតតទៅទាល់តែតោងបាន ដើមឈើនឹងលតាវល្លិទាំងនោះគ្មានភ្នែកទេ ហេតុអ្វីក៏បានជាអាចងាកចៀសវាងពីដើមឈើធំ ហើយត្រួយវាបោះពួយដម្រង់ទៅរកទីសម្រាប់តោងនោះបាន ?

សត្វតិរច្ឆានខ្លះ ដូចជាឆ្កែឬសេះ យើងរាប់អានថាជាសត្វមានច្រមុះត្រចៀកភ្នែកវៃ អាចឮសំឡេងនឹងស្រង់ក្លិនបានពីឆម្ងាយ ឬមើលឃើញពីចម្ងាយបាន ឆ្កែដែលព្រាត់វង្វេងម្ចាស់វានៅតាមផ្លូវ ក្នុងចំណោមមនុស្សដើរទៅមកជាច្រើន វាអាចតាមរកម្ចាស់វាដែលនៅឆ្ងាយឃើញ មកពីហេតុស្គាល់ក្លិន មុនដែលនឹងជឿសម្ដីនេះ យើងគួរតាំងបញ្ហាក្នុងចិត្ត បានមួយខថាក្លិននេះជារបស់ធុំប្រាសខ្យល់ពុំបាន ហេតុអ្វីឆ្កែតាមរកម្ចាស់វាដែលនៅលើខ្យល់ឃើញ ?

រឿងដែលសត្វដឹងនេះ មានក្នុងពង្សាវតារក្រុងរោម ថាកាលក្នុងសម័យបុរាណអានពពៃថាជាសត្វប្រសើរ ព្រោះមានសម័យមួយក្នុងវេលាយប់សត្រូវរបស់ពួករោម៉ង់ លើកទ័ពជិតមកក្រុងរោម ដោយអ្នកស្រុកក្នុងក្រុងរោមមិនបានដឹង អ្នកចាំយាមនៅលើប៉មបន្ទាយក៏មើលមិនឃើញ តែក្នុងវេលានោះមានពពៃមួយហ្វូង វាស្រែកកញ្ជ្រោលឡើងខុសពីប្រក្រតីមនុស្សនៅក្នុងបន្ទាយទាំងប៉ុន្មាន ក៏បានដឹងផ្អើលភ្ញើកឡើង រៀបខ្លួនចាំតទល់រក្សាក្រុងរោម ឲ្យរួចពីសត្រូវបានៗជាពួករោមម៉ង់ឆ្ងល់ណាស់ថា ក្នុងវេលាដែលពពៃស្រែកឡើងនោះ សត្រូវនៅឆ្ងាយណាស់ តែសន្ធឹកជើងដើរក៏មិនឮផង ហើយនៅក្រោមខ្យល់មិនអាចនឹងស្រង់ក្លិនបានទេ ហេតុអ្វីបានជាពពៃមានអាការដឹងខុសពីប្រក្រតីយ៉ាងនេះ បានជាពួករោមម៉ង់នាំគ្នាជឿថា សត្វពពៃជាសត្វដែលព្រះម្ចាស់សួគ៌ឲ្យមកកើត សម្រាប់ជួយការពារក្រុងរោម សេចក្ដីនេះតើយើងគួរវិនិច្ឆ័យយ៉ាងណា? សេចក្ដីដឹងបែបនេះ ដែលខ្ពស់ជាងសត្វតទៅទៀត គឺមនុស្សព្រៃ (ព្នង) ក្នុងស្រុកអាហ្វ្រិកបានដំណឹងថាពួកនេះដឹងខ្លួនរហ័សបំផុត ក្នុងវេលាដែលមានខ្លាឬសិង្ហ កំពុងដើរមកក្នុងទីដែលខ្លួននៅ បារាំងដែលទៅបរបាញ់សត្វក្នុងស្រុកអាហ្វ្រិក តោងតែមានមនុស្សបែបនេះទៅជាមួយដរាប តើមកពីហេតុអ្វីបានជាមនុស្សទាំងនោះដឹង តាមហេតុដែលបណ្ដាលឲ្យដឹងមុន

នេះ យើងរាល់គ្នាគង់ដែលបានឮពីកូនក្មេងនិយាយអ្វីផ្សេងៗប្លែកពីប្រក្រ-តី ដែលយើងហៅថា ចៃដន់ ប្រាប់ហេតុដោយក្មេងនោះនឹងបានដឹងឮ ឃើញមកពីទីណាក៏ទេ ជួនកាលក៏ត្រូវតាមសម្ដីដែលវានិយាយនោះ តែ គ្មានអ្នកណាចាប់ភ្លឹក យកចិត្តទុកដាក់ថានឹងមានហេតុនោះក៏ទេ មនុស្ស ចាស់ក៏មានជាដរាបដែរ ដែលជាចៃដន់ក្នុងចិត្ត ដូចមានគេមកខ្សឹបប្រាប់ ជួនកាលក៏ត្រូវតាមដែលខ្លួនឮខ្សឹបនោះ តែរឿងចៃដន់ឬប្រផ្នូលទាំងនេះ ច្រើនតែមិនយកចិត្តទុកដាក់ជឿ ស្រាវជ្រាវរកហេតុ យកមកពិគ្រោះ ពិចារណារកឲ្យឃើញសេចក្ដីពិត ច្រើនទុកឲ្យកន្លងហួសទៅ សមអ្នក សម័យថ្មីឥឡូវនេះក៏កាន់តែណាស់ឡើងទៀតសុទ្ធតែថាមិនគួរ ទៅ ប្រកាន់តាមចៃដន់ ឬប្រផ្នូលដែលជាការឆ្កួតព្រើលនោះទេ តែកាលណា មានហេតុពិតត្រូវតាមនិមិត្រនោះហើយ ទើបនឹកឃើញដល់បុព្វហេតុ និមិត្រដែលបង្កើតឲ្យដឹងមុនកើតហេតុនោះ ដូចជាហេតុដែលមនុស្សត្រូវ គេសម្លាប់ឬសម្លាប់ខ្លួនឯងក្នុងផ្ទះណាមួយ មនុស្សដែលនៅក្នុងផ្ទះនោះ សឹងគ្រប់គ្នានិយាយថា មុនកើតហេតុ បានឃើញបុព្វនិមិត្រឬចៃដន់យ៉ាង នេះយ៉ាងនោះ ខ្លះក៏ថាបានយល់សប្តិឃើញយ៉ាងនេះយ៉ាងនោះ។ល។ តាមដែលមនុស្សទាំងនោះនិយាយ គង់មានមនុស្សខ្លះបានឃើញបានឮអ្វី ម្យ៉ាងៗ ឲ្យជាបុព្វហេតុ មុននឹងកើតហេតុជាប្រាកដតែមិនយកចិត្តទុកដាក់ ចោលឲ្យកន្លងហួសទៅ មិនប្រកាន់ជឿថាជាការសំខាន់ដល់មានហេតុ ឡើង ទើបរឮកឃើញ ។

បើយើងយកហេតុ ដែលមានពោលមកខាងលើនេះ មកត្រិះរិះគិត មើលឲ្យល្អិតហើយ ក៏នឹងសន្និដ្ឋានបានពីរផ្លូវគឺ :

១. យើងមានអាយតនមួយឬក៏ច្រើននឹងហៅថាអ្វីក៏ពុំដឹង ធ្វើនាទី-រាយការឲ្យចិត្ត នៅឱកាសដែលភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយនឹង រាយការឲ្យចិត្តពុំបាននោះ ។

២. អាយតនខាងក្នុងទាំង៥របស់យើង មានគ្រាខ្លះអាចរាយការឲ្យលើសជាងប្រក្រតី ។

លោកអ្នកមើលគង់គិតថា សេចក្តីដឹង២ ផ្លូវនេះបើជាពិតដោយផ្លូវណាមួយ ហេតុដូចម្តេចចែដន់ទាំងនោះ មិនបណ្តាលឲ្យឃើញត្រូវប្រាកដជាដរាបទៅ ទបថា បានជាមានខុសជាច្រើន ព្រោះរបស់ដែលធ្វើឲ្យយើងមានចៃដន់ឬប្រាប់បុព្វហេតុឲ្យយើងដឹងនោះ នៅឆ្ងាយហួស ដូចជាការដែលនិយាយដោយទោរសព្ទ រម្លងស្រុកឬប្រទេសឆ្ងាយតែងតែមានធ្វើឲ្យចូលចិត្តខុសគ្នាជារឿយៗ មិនបាច់ពោលដល់ចៃដន់ដែលគ្មានអ្វីជាទីតាំងនោះទេ គ្រាន់តែយើងឮអ្វីៗ នៅជិតត្រចៀកយើងក៏នៅមានខុសជាដរាបដែរ ។

ឯខសន្និដ្ឋាន តាមផ្លូវទាំងពីរនេះ នឹងវិន្និច្ឆ័យ ផ្លូវណាជាត្រូវក៏មិនទាន់បាន ព្រោះពួកយោគីក្នុងឥណ្ឌៀ ច្រើនជឿតាមផ្លូវទី១ ដោយថ្លែងសេចក្តីយល់ឃើញថា មនុស្សមានអាយតនច្រើនជាង ៦ ហើយនៅមានជំនឿតទៅទៀតថា បើក្នុងលោកដទៃៗ ដូចជាលោកព្រះអង្គារជាដើមមានមនុស្សនៅហើយ មនុស្សទាំងនោះអាចមានអាយតនៈទាំង ៨-៩ឬ ១០ ក៏បាន ដោយជំនឿនេះបានជាលទ្ធិរបស់យោគី វិលទៅរកផ្លូវដែលនឹងបណ្តុះអាយតនៈមួយជាថ្មី ឲ្យកើតមានឡើងក្នុងខ្លួនដូចជាបណ្តុះដៃឲ្យជាប់នឹងផ្កាយ (Bras astral) នឹងប្រើកាយឲ្យជាប់តនឹងផ្កាយ (corps astral) ដែលបានពោលមកហើយក្នុងមនោមយិទ្ធិនឹងឥទ្ធិវិធិ តាមឧទាហរណ៍ដែលបានពោលមកហើយនោះគេឲ្យឈ្មោះថា សេចក្តីដឹងខ្លួនដែលជាប់តនឹងដួងផ្កាយ (perception astral) ដែលឲ្យឈ្មោះថា "ជាប់តនឹងដួងផ្កាយ" នេះ ក៏ព្រោះមិនទាន់ដឹងជានឹងឲ្យហៅថាឈ្មោះអ្វីនោះឯងត្រង់វិធីដែលគេនឹងបណ្តុះឲ្យកើតឡើងបានយ៉ាងណានោះ គេអធិប្បាយ

ទុកយ៉ាងពិស្តារ បើនឹងប្រែយកមកចុះក្នុងសៀវភៅនេះផង ឃើញថាគ្មានឱកាសនឹងបញ្ចប់បាន បានជាមិននាំយកមកចុះផ្សាយ ។

តាមមើលទៅបារាំង ប្រហែលងាកទៅក្នុងផ្លូវទីពីរ គឺថាយើងគ្មានអាយតនអ្វីថែមទៀតទេ មានតែអាយតនខាងក្នុង ៥គឺភ្នែក ត្រចៀក ច្រមុះ អណ្តាតនឹងកាយ របស់យើងនេះ បើហាត់ឲ្យល្អហើយក៏អាចទទួលអាយតនខាងក្រៅទាំង៥គឺៈ រូប សំឡេង ក្លិន រសនឹងផោដ្ឋព្វ ពីផ្លូវឆ្ងាយលើសពីប្រក្រតីបាន ដោយជំនឿនេះហើយ បានជាបារាំងនាំគ្នាតែងសៀវភៅជាច្រើន និយាយពីវិធីហាត់ធ្វើឲ្យភ្នែកវៃ ត្រចៀកវៃ ច្រមុះចាំក្លិនបាន ។ល។

ជំនឿទាំងពីរយ៉ាងនេះ យ៉ាងទី១ដែលជាសេចក្តីជឿរបស់ពួកយោគីថា មនុស្សយើងអាចមានអាយតនច្រើនជាង៦នោះ ក៏មិនទាន់ឃើញមានពាក្យអធិប្បាយ ឲ្យបានក្បោះក្បាយ គួរឲ្យជឿប្រាកដនោះសោះនៅតែក្នុងពិគ្រោះពិចារណាតទៅទៀត អំពីផ្លូវទីពីរ ដែលជាជំនឿរបស់បារាំងនោះល្មមស្តាប់បាន ព្រោះថាអវយវៈគ្រប់យ៉ាងរបស់យើងនោះបើហាត់ហើយក៏អាចប្រើការបានយ៉ាងល្អដរាប ឯត្រចៀកនេះ ក៏នៅត្រូវការទម្លាប់ឲ្យធ្លាប់ បើមិនដូច្នោះទេ យើងនឹងញែកខ្សែសំឡេងចេញពុំបាន អ្នកដែលមិនចេះភាសាក្លឹង្គគិតថាភាសាក្លឹង្គនិយាយមានសំឡេងខ្យល់ "រ" ទាំងអស់ តែបើបានស្តាប់ទាល់តែធ្លាប់ត្រចៀកទៅហើយ ក៏នឹងញែកអក្សរតាមសំឡេងចេញបាន បើយើងឲ្យបារាំងដែលទើបមកពីស្រុកឱ្យបមកស្តាប់ទេសនាមហាជាតក៏ គេនឹងថាឮតែសំឡេងមួយទាំងអស់គ្មានសំឡេងខ្ពស់ទាប តែពួកយើងធ្លាប់ស្តាប់នោះដឹងថាមានសំឡេងខ្ពស់ទាប ពិរោះមិនពិរោះ អ្នកដែលធ្លាប់ស្តាប់ញឹកញយ ក៏កាន់តែចេះដឹងញែកសំឡេងឲ្យច្បាស់ឡើងជាដរាប ទាល់តែអាចមានពាក្យសរសើរឬបន្តុះថាចេះទេស្នពិរោះឬមិនពិរោះបាន ឯការស្តាប់ភ្លេងបារាំងដ៏ដូចគ្នា ភ្លេងយ៉ាងឯកនៅអូប៉េរ៉ាក្នុងក្រុង

បារាំងសែស បើយើងទៅដល់ដម្បូងហើយចូលទៅស្តាប់ គង់ឮភ្លឹងនោះដូចក្មេងគោះអ្វីលេងជាល្បែង តែបើបានស្តាបញយៗចាប់ដើមតាំងពីភ្លេងជាន់ទាបដែលលេងតាមរោងល្ខោនតូចៗទៅរួចទៅស្តាប់ភ្លេងអូប៉េរ៉ា ទើបដឹងថាភ្លេងដែលគេលេងនោះពិរោះយ៉ាងប្រសើរពិតប្រាកដមែន មិនមែនដូចយើងឮថាដូចកូនក្មេងគោះជាល្បែងនោះទេ ហេតុនេះបានជាអ្នកស្រុកបែលស៊ិកដែលជាអ្នកមាន ស្វ៊ិជិះរទេះភ្លើងពិក្រុងប្រ៊ុកសែល ទាំងថ្ងៃត្រង់មកស្តាប់ភ្លេងអូប៉េរ៉ានៅក្រុងបារីស ដល់ពាក់កណ្តាលអធ្រាត្រទើបត្រឡប់ទៅស្រុកវិញ ។

ចំណែកអ្នកប្រាជ្ញខាងតូរ្យតន្ត្រី គេយល់ចូលចិត្តជ្រៅជ្រះជាងអ្នកស្តាប់ ក្នុងវេលាកំពុងលេងភ្លេង គេគ្រាន់តែស្តាប់ពីចម្ងាយ មិនឃើញរូបអ្នកលេងភ្លេងផង គេអាចទាយប្រាប់ថាក្នុងភ្លេងវង់នោះ មានចំនួនមនុស្សអ្នកលេងប៉ុណ្ណោះនាក់មានគ្រឿងបែបណា ខ្លះគេដឹងទាំងអស់ គ្រូភ្លេងដែលគេស្ទាត់ គេអាចចង្អុលមនុស្សអ្នកលេងដែលកូតឬផ្លុំខុសតែបន្តិចបន្តួច ក្នុងពេលកំពុងតែលេងនោះបានមួយរំពេច ។

ការដែលនាំយករឿងតូរ្យតន្ត្រី មកពោលក្នុងធម៌នេះ គ្រាន់តែជាឧទាហរណ៍ ឲ្យឃើញពិតថា ត្រចៀកមនុស្ស បើព្យាយាមហាត់ហ្វឹកហ្វឺនឲ្យល្អហើយ ក៏គង់ស្តាប់បានខ្លះ ព្រោះរូបកាយរបស់មនុស្ស ដែលធម្មជាតិកសាងមកនោះ ជារបស់អស្ចារ្យលើសលុប ជាងរបស់ដែលមនុស្សបង្កើតនោះទៀត ទូរសព្ទមានខ្សែក្តី ឥតខ្សែក្តី ដែលយើងចូលចិត្តថាជារបស់ប្រសើរ ប្រើនិយាយដឹងសម្តីគ្នាបាន ដោយរហ័សឆាប់មិនខូចពេលដើរទៅរកគ្នានោះ ប្រាកដជាយកបែបតាមអាយតនៈរាងកាយរបស់មនុស្ស មកគិតប្រដិតសាងគ្រឿងទូរសព្ទនេះឡើង យើងគង់ដឹងថា សំឡេងផ្សេងៗអណ្តែតតាមអាកាសមកប៉ះនឹងគ្រឿងទទួលដែលនៅក្នុងត្រចៀក យើងបានជាដឹងសេចក្តី បានជាគេយកបែបនេះមកគិតធ្វើជាគ្រឿងទូរសព្ទ

គ្រាន់តែបន្ថែមឲ្យមានកម្លាំងខ្លាងឡើង វិទ្យុទូរសព្ទដែលបញ្ជូនសំឡេងទៅឆ្ងាយរម្លងទ្វីបបាន ក៏ព្រោះមានកម្លាំងខ្លាំងជាបំផុត បើប្រសិនជាយើងមានវិធីហាត់ ឲ្យត្រចៀកយើងមានកម្លាំងខ្លាំងតើយើងនឹងស្តាប់សំឡេងពីចម្ងាយមិនបានដែរឬអ្វី មនុស្សភ្នែកខ្វាក់ហេតុអ្វីបានជាត្រចៀកវៃខុសពីប្រក្រតី ព្រោះហេតុមកពីដឹងខ្លួនថាត្រូវតែប្រើត្រចៀកជំនួសភ្នែក បានជាព្យាយាហាត់ទម្លាប់ឲ្យត្រចៀកវៃឡើងរបស់អ្វីក៏ដោយ សុទ្ធតែមកពីព្យាយាមហាត់ទម្លាប់ឲ្យស្ទាត់ទាំងអស់ ។

តាមក្នុងផ្លូវព្រះពុទ្ធសាសនាដ៏ប្រាកដនោះ ក៏ឲ្យបង្ហាត់ត្រចៀកឲ្យល្អឡើងដែរ តែត្រូវធ្វើដួងចិត្តឲ្យផូរផង់ជ្រះថ្លាជាមុនសិន តាមក្នុងគម្ពីរវិសុទ្ធិមគ្គថា ត្រូវចូលឈានជាមុន ប្រហែលជាសំដៅដល់គ្រប់ៗឈានព្រោះមិនឃើញប្រាប់ឲ្យច្បាស់ថាឈានណា កាលណាចេញពីឈានហើយក្នុងជានដម្បូង ឲ្យនឹកដល់សំឡេងខ្លាំងៗជាមុន ដូចជាសំឡេងរគាំង ស្គរឬស័ង្ខ រួចហើយនឹងដល់សំឡេងដែលល្អិតតទៅ ទាល់ដល់ទីបំផុតឲ្យនឹកដល់ទិព្វសោតៗក៏នឹងកើតឡើង បើត្រូវការចង់ស្តាប់សំឡេងអ្វីៗក៏ឲ្យកំណត់ក្នុងចិត្ត រឭកនឹកដល់ទីកន្លែងដែលត្រូវការនឹងស្តាប់នោះ ទុកជាមានសូរអ្វីទ្រហឹងអឺងអាប់ ក៏គង់នៅឮសំឡេងដែលត្រូវការជាដរាបបាន ។

# វិជ្ជាប្រការទី ៥

## ចេតោបរិយញ្ញាណ

ចេតោបរិយញ្ញាណនោះ មាននិទ្ទេសពោលទុកក្នុងធម្មវិភាគបរិច្ឆេទទី២ថា កំណត់ដោយចិត្តរបស់ខ្លួនឯងរួចហើយ ដឹងចិត្តរបស់បុគ្គលដទៃថាបរិសុទ្ធឬសៅហ្មងយ៉ាងណា សម្រេចព្រះមហាសមណក្រុមវជិរញ្ញាណវរោរស ទ្រង់ប្រៀបប្រដូចការទាយចិត្តនឹងកំណត់ស្គាល់ដឹងអធ្យាស្រ័យរបស់មនុស្ស ។

តាមក្នុងនិទ្ទេសក្តី ក្នុងអត្ថាធិប្បាយរបស់សម្រេចព្រះមហាសមណក្តី ចេតោបរិយញ្ញាណ មើលទៅមិនជារបស់ហួសវិស័យមនុស្សទេ អ្នករៀនធម៌ជាច្រើនគង់មើលឃើញថាជារបស់ងាយព្រោះ ដោយអាស្រ័យបដិភាណរបស់ខ្លួន សង្កេតឫកពានឹងពាក្យនិយាយរបស់មនុស្ស ក៏អាចស្គាល់ដឹងចិត្តមិនបានច្រើនក៏តិច ឬដោយយើងដឹងនិស្ស័យចិត្តថ្លើមនឹងសេចក្តីប្រព្រឹត្តិរបស់បុគ្គលនោះអំពីតមកយ៉ាងណាក៏អាចទំនាយ ទាយបានថាបុគ្គលនោះ ក្នុងការឥឡូវនេះកំពុងគិតអ្វី ឬនឹងដឹងថាកំពុងគិតអ្វីតទៅមុខទៀត ក៏ទាយត្រូវទាំងអស់ ។

តាមក្នុងអធ្យាត្មវិទ្យារបស់បារាំងក្តី លទ្ធិរបស់យោគីឥណ្ឌៀក្តីចេតោ-បរិយញ្ញាណ ដែលត្រូវនឹងពាក្យថា (Lecture de la pensee) ក្តីក៏គេប្រកាន់ថាជារបស់ងាយដូចគ្នាដែរ ហើយជាដើមនៃវិជ្ជាដ៏ជ្រាលជ្រៅទាំងឡាយជាវិជ្ជាខាងដើមរបស់ទិព្វចក្ខុ បើពោលតាមគោលរបស់គេហើយមនុស្សយើងនឹងធ្វើទិព្វចក្ខុឲ្យកើតឡើងបានលុះ តែធ្វើចេតោបរិយញ្ញាឲ្យកើតឡើងជាមុនសិន ។

ឯវិជ្ជាមួយនេះ អ្នកប្រាជ្ញបារាំងនឹងឥណ្ឌៀ គេចែកជាពីរប្រការគឺ ប្រភេទទី១ អាចដឹងគំនិតរបស់អ្នកដទៃ (Lecture de la pansee) ប្រភេទទី២ អាចធ្វើឲ្យអ្នកដទៃដឹងគំនិតរបស់អ្នក (Transmission de la pensee) ប្រភេទទី១ ត្រូវនឹងចេតោបរិយញ្ញារបស់យើង ត្រង់ប្រភេទទី២ មិនដឹងជាត្រូវនឹងអ្វី ក្នុងព្រះពុទ្ធសាសនា មើលទៅប្រហែលជាគ្មាននៅក្នុងវង់វិជ្ជា៨ ប្រការនោះទេ តែទុកជាដូចម្តេចក្តី ក៏មិនជាការឥតប្រយោជ-ន៍ទេបានជានាំយកទាំងពីរបែបមកពណ៌នាទុកដើម្បី បំភ្លឺឲ្យចូលចិត្តក្នុងចេតោបរិយញ្ញាឲ្យបានល្អឡើង ។

សេចក្តីនេះបានបរិយាយមក ក្នុង "មនោមយិទ្ធិ" ថាចិត្តឬគំនិតរបស់មនុស្ស តែងតែមានក្រសែផ្សាយចេញពីខ្លួន អណ្តែតត្រសែតទៅតាម

អាកាសធាតុ មានខ្លះក៏ជាប់នៅក្នុងទីផ្សេងៗ ហេតុនេះឯងបានជាថាបើប្រសិនជាមានចិត្តមួយទៀតជាគ្រឿងទទួលក្រសែនេះ ក៏អាចនឹងដឹងនូវគំនិតរបស់គ្នាទៅវិញទៅមកបាន ដូចជាវិទ្យុទោរសព្ទ សឹងមានគ្រឿងសម្រាប់បញ្ជូនសំឡេង តែសំឡេងដែលបែកចេញទៅតាមអាកាសនោះគ្មានអ្នកណាឮទេ លុះតែកាលណាសំឡេងនោះមកប៉ះពាល់គ្រឿងដែលទទួលគ្នា ទើបឮសំឡេងមួយរំពេច ទោរសព្ទដែលមានខ្សែក៏ដូចគ្នាដែរ តាមដែលយើងគិតថា សំឡេងរត់ទៅមកតាមខ្សែលួស តែបើយើងយកខ្សែលួសមកដាក់ផ្ទាប់ត្រចៀកយើងៗ ក៏មិនបានឮអ្វីសោះឡើយព្រោះសំឡេងដែលរត់តាមខ្សែលួសនោះ គ្មានគ្រឿងទទួលបានជាមិនឮកាលណាមានគ្រឿងភ្ជាប់នឹងខ្សែលួសសម្រាប់ទទួល សំឡេងក៏រត់មកប៉ះគ្រឿងនោះបានទើបឮសូរសំឡេងឡើង ហេតុនេះឯង បានជាអ្នកប្រាជ្ញបារាំងនឹងឥណ្ឌៀ ចែកវិជ្ជានេះជា២ ប្រភេទ គឺអាចធ្វើឲ្យមនុស្សឯទៀតដឹងគំនិតរបស់ខ្លួនដែលជាគ្រឿងបញ្ជូន នឹងចេតោបរិយញ្ញាជាគ្រឿងទទួល ហេតុដែលបានជានាំយកវិធីបង្ហាត់ចេតោបរិយញ្ញារបស់បារាំងនឹងរបស់យោគី មកបរិយាយទុកនេះ ដើម្បីជាគ្រឿងប្រដាបសតិបញ្ញាឲ្យអ្នករៀនធម៌របស់យើង ប្រៀបធៀបមើលនឹងវិធីដែលមាននៅក្នុងតម្រាព្រះពុទ្ធសាសនា ។

ឯវិធីបង្ហាត់វិជ្ជាប្រភេទនេះ តាមក្នុងសៀវភៅរបស់យោគី អធិប្បាយថា ក្នុងជាន់ដម្បូង ត្រូវមានគ្នាពីរនាក់ តោងរកអ្នកដែលមានចិត្តជឿក្នុងវិជ្ជានេះ ហើយឲ្យអ្នកនោះមានចិត្តប្រាថ្នា ចង់ចេះវិជ្ជានេះ ពិតប្រាកដមែនបើរកបានហើយ ឲ្យម្នាក់ជាអ្នកហាត់បញ្ជូន ម្នាក់ជាអ្នកហាត់ទទួលផ្លាស់ប្តូរគ្នា អ្នកហាត់ទទួលត្រូវយកសំពត់ចងបិទភ្នែក ឲ្យមានខ្មៅដៃមួយនឹងក្រដាសសម្រាប់កត់ ឯអ្នកបញ្ជូនត្រូវយកដៃខ្ទប់ថ្ងាសអ្នកទទួល ឲ្យមានខ្មៅដៃនឹងក្រដាសសម្រាប់កត់ដូចគ្នា ស្រេចហើយត្រូវសញ្ញាយលព្រមគ្នា

ថាវិធីដែលត្រូវធ្វើ គឺចាប់ធ្វើពីលេខណាមួយក្នុងរវាងពីមួយដល់៥ អ្នកបញ្ជូនត្រូវការឲ្យអ្នកទទួលសរសេរលេខណា ត្រូវតាំងចិត្តជាសមាធិដំកល់ឲ្យនឹងនឹកដល់លេខដែលខ្លួននឹងឲ្យទទួលសរសេរនោះ ខាងចំណែកអ្នកទទួលក៏ត្រូវដំកល់ចិត្តជាសមាធិឲ្យនឹងដូចគ្នា នឹកតែក្នុងរវាងលេខ១ ដល់លេខ៥រួចសរសេរតែ១លេខក្នុងក្រដាសរបស់ខ្លួន តាមតែចិត្តដែលគិតឃើញថាអ្នកបញ្ជូនត្រូវការលេខណា ក្នុងថ្ងៃដម្បូងគេឲ្យធ្វើបាន២០ដង គឺសរសេរលេខឲ្យបាន២០ ដងរួចស្រាយសំពត់ពីភ្នែកអ្នកទទួលចេញ យកក្រដាសទាំងពីរសន្លឹកមកផ្ទៀបគ្នាមើល ឃើញមានខុសប៉ុន្មាន ត្រូវប៉ុន្មានកត់ទុកដល់ស្អែកឡើងធ្វើដូច្នោះទៀត គេឲ្យធ្វើតែរាល់ថ្ងៃទាល់តែលេខទាំង៥ តួត្រូវគ្នាទាំងអស់ឬក៏នៅមានខុសខ្លះតែយ៉ាងតិចបំផុត តាមតម្រាពោលថាបើអ្នកទាំង២ មានសមាធិមាំស្មើគ្នាហើយ លេខដែលកត់នោះក៏កាន់តែខុសតិចៗទៅជារាល់ថ្ងៃ ទាល់តែត្រូវគ្នាគ្រប់លេខ រួចបានបន្ថែមចំនួនលេខឲ្យច្រើនឡើងពី១ ដល់ ១០ រហូតដល់ពាន់ នេះចាត់ជាថ្នាក់ទី១ត្រឹមតែក្នុងថ្នាក់ទី១ ដល់ ១០ រហូតដល់ពាន់ នេះចាត់ជាថ្នាក់ទី១ត្រឹមតែក្នុងថ្នាក់ទី១នេះ អាចអស់វេលា ហាត់រាប់ខែ ក្នុងថ្នាក់ទី២វិធីហាត់មានទំនងដូចគ្នាដែរ តែឲ្យប្រើអក្សរជំនួសលេខ ជាន់ដម្បូងឲ្យព្រមព្រៀងគ្នា ធ្វើពីអក្សរតិ រួចបន្ថែមតទៅជាដរាបទាល់តែអស់ស្រៈនឹងព្យញ្ជនៈរួចបានផ្សំគ្នាជាពាក្យឡើង បើធ្វើបានទាំងពីរថ្នាក់នេះហើយឲ្យចោលការដែលយកដៃខ្ទប់ថ្ងាសចេញ គ្រាន់តែយកដៃឆ្វេងចាប់គ្នាទុក រួចហើយដូចយ៉ាងពោលមកនោះ នេះជាថ្នាកទី៣ ដល់ថ្នាក់ទី៤ មិនបាច់ពាល់ដល់អវយវៈរាងកាយឡើយ គ្រាន់តែឲ្យជាប់តនឹងវត្ថុអ្វីមួយ ដូចជាសំពត់ឬខ្សែអម្បោះវិធីធ្វើតាមបែបក្នុងថ្នាក់ទី១ នឹងទី ២ ។

តាមបែបដែលបានពណ៌នាមកហើយនេះ ជាវិធីតាមបែបទោរសព្ទ ឬទោរលេខដែលមានខ្សែ បើមានសេចក្ដីព្យាយាមហាត់ហ្វឹកហ្វឺនជាថ្នាក់ៗ

បានល្អឡើងជាដរាភតទៅហើយ តពីនេះទៅទៀត ត្រូវហាត់តាមបែបទោរសព្ទគ្មានខ្សែ គឺមិនឲ្យរាងកាយប៉ះពាល់គ្នាដោយវត្ថុអ្វីឡើយ ដូចមានពោលតទៅនេះ គឺថ្នាក់ទី៥ឲ្យនៅក្នុងបន្ទប់ជាមួយគ្នា មិនបាច់ចងភ្នែកអង្គុយឃ្លាតពីគ្នា ឲ្យអ្នកបញ្ជូននឹកក្នុងចិត្តត្រង់ពាក្យណាមួយឲ្យអ្នកទទួលសរសេរ បើឃើញថាសរសេរត្រូវតាមសេចក្តីនឹករបស់អ្នកបញ្ជូនត្រឹមត្រូវច្រើនជាបំផុតហើយ ក៏ឲ្យខិតចេញពីទីកន្លែង ឲ្យឃ្លាតបន្តិចៗម្តងរួចទៅអង្គុយនៅបន្ទប់មួយដោយខ្លួនពីគ្នា ធ្វើបានហើយត្រូវទៅអង្គុយផ្ទះដោយខ្លួន ចេះតែឃ្លាតចេញពីគ្នាឲ្យបានឆ្ងាយដារាបទៅ ។

វិធីផ្សេងៗ ដែលពណ៌នាមកនេះ នឹងឲ្យបានសម្រេចត្រឹមណានោះពុំបានដឹងទេ ព្រោះមិនដែលហាត់ធ្វើ តែបានប្រទះតម្រាជាច្រើន មានអធិប្បាយដូចៗគ្នាថា មនុស្សយើងអាចធ្វើឲ្យសម្រេចបានលើសពីសេចក្តីដែលយើងស្មាននោះទៀត តែតោមានសេចក្តីព្យាយាមហាត់ធ្វើរៀងរាបតាមថ្នាក់តាមជាន់ កុំរម្លងចោលថ្នាក់ទី១ ទៅធ្វើថ្នាក់ទី២ តែម្តងនោះពុំបានទេ ហើយត្រូវហាត់ធ្វើក្នុងថ្នាក់មួយៗឲ្យបានល្អសិន ក្នុងវិធីនេះដែលសំខាន់បំផុត គឺសមាធិ (Concentration) បើដួងចិត្តមិនដំកល់នឹងជាសមាធិទេ នឹងធ្វើឲ្យសម្រេចពុំបានឡើយ ។

វិធីនេះបើយើងចូលចិត្តជឿតាម ដែលមានពណ៌នាមកនោះហើយៗបានបង្ហាត់ហ្វឹកហ្វឺន តាមសេចក្តីអធិប្បាយរបស់គេ ក៏នឹងឲ្យយើងបានសម្រេចគ្រប់បែបដែលយើងត្រូវការ ហើយក៏អាចទាយចិត្តមនុស្សដទៃបាន ឬធ្វើឲ្យមនុស្សដទៃដឹងគំនិតរបស់យើងបាន អ្នកតែងសៀវភៅពីវិជ្ជានេះពោលថា បើអ្នកដែលហាត់ធ្វើមិនសម្រេចមានចិត្តធុញថប់ថយសេចក្តីព្យាយាមគិតបោះបង់ចោលលែងធ្វើតទៅទៀត ក៏ស្រាប់តែសម្រេ-ចឡើង១ រំពេចក៏មាន គេប្រកាន់ថា មានមនុស្សខ្លះធ្វើបានសម្រេចអាចឲ្យដំណឹងជាប់តនឹងមនុស្សនៅផ្សេងប្រទេសពីគ្នាបាន បើពិតប្រាកដ

ដូច្នោះមែនហើយ គួរមានប្រយោជន៍ច្រើនណាស់ ព្រោះសម្រាប់ប្រើក្នុងវេលាមានការក្រីក្រ ដូចជាចោរចាប់យកខ្លួនទៅលាក់ទុកក៏អាចឲ្យដំណឹងទៅគ្នាបាន កាលឆ្នាំកន្លងមកហើយ មានសាស្រ្តាចារ្យស្រុកអូទ្រីស៍ម្នាក់ចូលមកសំដែងវិជ្ជានេះ នៅក្រុងស្យាម នៅទីកន្លែងក្រុមតំរួត (ប៉ូលិស) ដើម្បីឲ្យឃើញថា វិជ្ជានេះមានប្រយោជន៍ត្រឹមណា ក្នុងការស៊ើបរកពួកចោរកំណាចនោះ ។

វិធីដែលពណ៌នាមកនេះ ជាវិជ្ជាបឋមដម្បូង សឹងមើលទៅអ្នកណាក៏អាចហាត់ធ្វើបាន តែតាមបំណងរបស់ចេតោបរិញ្ញាណក្នុងវិជ្ជា៨ប្រការដ៏ពិតប្រាកដនោះ ជាវិជ្ជាខ្ពស់ជាងនេះទៅទៀត ពោលគឺដួងចិត្តរបស់អ្នកមានញាណបែបនេះ ប្រៀបដូចគ្រឿងទទួលដ៏មានកម្លាំងច្រើនអាចទទួលក្រសែគំនិតរបស់មនុស្សណាមួយមកឲ្យដឹងបានទាំងអស់ ទុកជាមនុស្សនោះព្យាយាមលាក់គំនិតរបស់ខ្លួនទុកដូចម្តេចក្តី ក៏យើងអាចដឹងនូវគំនិតនោះដែរ ដូចជាគ្រឿងវិទ្យុដែលមានកម្លាំងខ្លាំង អាចស្តាត់ទទួលដំណឹងផ្សេងៗ ដែលបញ្ជូនមកតាមផ្លូវវិទ្យុដូចគ្នាបាន ដោយមិនចំពោះថាដំណឹងនោះ គេជូនទៅដល់តែគ្រឿងរបស់គេនោះទេ ដូចយើងបានដឹងឮកាលក្នុងគ្រាមហាសង្គ្រាមរួមមកហើយនោះ ថាកងទ័ពម្ខាងអាចប្រើវិទ្យុទោ-សព្ទ លួចស្តាត់ទទួលដំណឹងរបស់ពួកម្ខាងទៀតបានជាដរាប បើយើងឃើញថា ការធ្វើចិត្តរបស់ឲ្យបានជាគ្រឿងសម្រាប់ទទួលក្រសែគំនិតរបស់មនុស្សបានហើយៗ ការនេះត្រឹមតែមនុស្សសាមញ្ញជនក៏អាចហាត់ធ្វើបានដែរ ចុះហេតុអ្វីក៏ព្រះពុទ្ធជាម្ចាស់របស់យើងធ្វើមិនបាន តាមក្នុងពុទ្ធប្រវត្តិ ឬអនុពុទ្ធប្រវត្តិ ដែលយើងបានរៀនមកហើយនោះនឹងឃើញថាព្រះពុទ្ធជាម្ចាស់របស់យើង ព្រះអង្គប្រើចេតោបរិញ្ញាណជាដម្បូង ក្នុងកាលដែលទ្រង់ទូន្មានសាវកឲ្យបានលុះមគ្គផល បានជាថាការដែលនឹងប្រដៅ

ទូន្មានមនុស្ស ដោយមិនដឹងគំនិតរបស់គេនោះជាការពិបាកនឹងប្រដៅទូន្មាននាស់ ។

តាមក្នុងគម្ពីរវិសុទ្ធិមគ្គ ត្រង់ដែលនិយាយអំពីចេតោបរិយញ្ញាណ ដែលព្រះពុទ្ធឃោសាចារ្យបានសំដែងទុកនោះ ឃើញផ្សេងពីរបស់យោគី នឹងរបស់អ្នកប្រាជ្ញអធ្យាត្មវិទ្យា ដែលបានពោលមកខាងដើមនោះជាច្រើន គឺព្រះពុទ្ធឃោសាចារ្យ ត្រូវការឲ្យចេះដឹងស្គាល់ដួងចិត្តមនុស្សដទៃតែត្រឹមសេចក្តីទោមនស្សឬសោមនស្ស ផូរផង់ឬល្អក់ឬក៏ជាឧបេក្ខា មិនត្រូវការឲ្យដឹងស្គាល់ដល់ចិត្តមនុស្សនោះទេ ហើយលោកបានពោលថាគោលទុកថាត្រូវសម្រេចទិព្វចក្ខុជាមុនសិន មុននឹងបានសម្រេចចេតោបរិយញ្ញាណនេះ ព្រោះត្រូវអាស្រ័យភ្នែកទិព្វឲ្យមើលធ្លុះឃើញព័ណ៌បេះដូងរបស់មនុស្សតើមានពណ៌យ៉ាងណា ពោលគឺថាបើចិត្តសោមនស្ស បេះដូងក្រហមដូចផ្លែជ្រៃទុំ បើចិត្តទោមនស្ស បេះដូងខ្មៅ បើចិត្តជាឧបេក្ខាបេះ-ដូងថ្លាដូចប្រេងល្ង ឃើញខុសពីគោលរបស់យោគី ដែលថាចេតោបរិយ-ញ្ញាណ ជាថ្នាក់ដម្បូងរបស់ទិព្វចក្ខុ សេចក្តីនេះសូមលោកអ្នកមើលវិនិច្ឆ័យចុះ ។

# វិជ្ជាប្រការទី ៦

## បុព្វេនិវាសានុស្សតិញ្ញាណ

តាមធម្មវិភាគ បរិច្ឆេទទី២ ពោលជានិទ្ទេសទុកថា រឭកជាតិដែលកន្លងមកហើយបាន តាំងពីជាតិ១ ជាតិ២ រហូតដល់ទៅច្រើនៗកល្បដឹងថាក្នុងកាលជាតិនោះៗមានឈ្មោះគោត្រត្រកូលយ៉ាងនោះ មានសម្បុរពណ៌ មានអាហារបែបនោះៗ បានសោយសុខឬសោយទុក្ខមានអាយុប៉ុន្មានៗក៏ដឹង ច្យុតពីជាតិនោះមក កើតក្នុងជាតិណាខ្លះ បានធ្វើជាអ្វីៗរួចបានមកកើតក្នុងជាតិនេះ រឿងនេះសម្រេចព្រះមហាសមណទ្រង់ប្រៀប

ប្រដូចនឹងការដឹងចាំពង្សាវតារបស់ខ្លួន ហើយទ្រង់ប្រារព្ធតទៅទៀតថា សេចក្តីរឭកជាតិបាន ដូចមានសំដែងមកនោះ ចាត់ជាអង្គនៃព្រះសម្មាសម្ពោធិញាណ បានដោយបែបយ៉ាងណា គួរពិចារណាមើលថា បើរឭកជាតិបានដូច្នោះតើ នឹងបាត់ភ្ញាក់ផ្អើលនូវសេចក្តីវិលកើតវិលស្លាប់ ដែលជាគតិនៃធម្មតានាំឲ្យកើតជាអនត្តានុបស្សនាញាណដោយឯកឯង ដូច្នេះនេះក៏គួរឲ្យឆ្ងល់ដែរ ព្រោះញាណនេះលោកពោលថាកំចាត់នូវមោហៈ ដែលកំបាំងក្នុងខន្ធសន្តាន ឲ្យឃើញថាជាអនត្តានុបស្សនាញាណ ដ៏សមជាអង្គនៃព្រះសម្មាសម្ពោធិញាណ ។

បុព្វេនិវាសានុស្សតិញ្ញាណនេះ ជាបញ្ហាដែលអ្នកចេះធម៌បានជជែកគ្នាមកជាច្រើន មិនមែនតែសាសនារបស់យើងនេះទេ សាសនាឯទៀតក៏ដូចគ្នា គឺពួកដែលប្រកាន់ថា វិញ្ញាណជាធម្មជាតិមិនចេះរលត់សូន្យ (Spiritualiste) នោះក៏ប្រកាន់តាមនិទ្ទេស ដែលពោលមកហើយនោះ ចំណែកខាងពួកដែលប្រកាន់ថា វិញ្ញាណជាធម្មជាតិរលត់ទៅជាមួយនឹងខ្លួនវេលាស្លាប់ទៅនោះ ក៏ថាគ្មានអ្វីលើសពីភ្នែកឃើញ ត្រចៀកឮ ហិតក្លិនដោយច្រមុះ ដឹងឱជារសដោយអណ្តាត សម្ផស្សដឹងដោយកាយនោះទេ (Materialiste) ពួកនេះហើយដែលប្រៀបធៀបនឹងការដែលរឭកឃើញកាលពីក្មេង ពីកម្លោះនឹងកាលពីខែឆ្នាំណាៗ បានធ្វើអ្វីខ្លះ បានសេចក្តីសុខសេចក្តីទុក្ខសេចក្តីចម្រើននឹងមិនចម្រើន ដោយមានហេតុផលជាប់តគ្នាយ៉ាងណាៗ នេះឯងកើតជាបញ្ហាដ៏គួរគិត តើខាងណាខុសខាងណាត្រូវ ។

មុននឹងដោះស្រាយបញ្ហានេះនៅមានខមួយទៀតជាបញ្ហា សំខាន់ណាស់ ហើយជាបណ្តូលរបស់សាសនាគ្រប់សាសនាដែលបានជជែកគ្នាមករាប់ទាំងពាន់ៗឆ្នាំហើយក៏មិនសម្រេច សព្វថ្ងៃនៅមានមនុស្សព្យាយាមស្រាវជ្រាវរកហេតុ ឲ្យបានឃើញពិតប្រាកដត្រឹមត្រូវនោះណាស់ក៏ពុំទាន់

ប្រទះឃើញពាក្យតបឆ្លើយណាមួយ ដែលនឹងមិនឲ្យអ្នកណាហ៊ានជជែកទៀតបានអំពីប្រស្នាខនេះថា "មនុស្សយើងស្លាប់ហើយកកកើតវិញឬទេ" បើប្រសិនជាវិនិច្ឆ័យថា មនុស្សស្លាប់ហើយសូន្យនោះមិនបាច់សង្ស័យទេ ត្រូវតែគិតប្រៀបធៀបឲ្យឃើញថាបុព្វនិវាសានុស្សតិញ្ញាណមាន ទំនងដូចម្តេច? បើវិនិច្ឆ័យថា មនុស្សស្លាប់ហើយកើតវិញទៀតនេះ ក៏នឹងមានបញ្ហាតទៅថា គួរគិតរកអ្វីប្រៀបប្រដូចឬនឹងអធិប្បាយទៅតាមនិទ្ទេស ។

ឯកំណើតកើតរបស់មនុស្សនោះ បារាំងក៏មានសេចក្តីយល់ឃើញប្លែកគ្នាជាពីរពួក គឺចំណែកពួកដែលប្រកាន់ជឿតាមផ្លូវសាសនាថាព្រះម្ចាស់សួគ៌សាងមនុស្សប្រុស១ស្រី១ ឲ្យជាគូនៅរួមជាមួយគ្នា បង្កើតជាពូជៗតមកទាលតែផ្សាយទូទៅក្នុងលោក ដូចមាននៅក្នុងបច្ចុប្បន្ននេះ ចំណែកខាងពួកអ្នកប្រាជ្ញវិទ្យាសាស្ត្រឃើញថា មនុស្សយើងកើតឯងដោយធម្មជាតិ គឺដើមឈើកើតមុនបានសត្វកើតពីដើមឈើ រួចកាន់តែចម្រើនឡើងក្លាយទៅជាស្វា ត្រង់នេះឯង ដែលធ្វើឲ្យពួកលោកសង្ឃបារាំងក្នុងស្រុកអាមេរិក នាំគ្នាប្តឹងតុលាការសុំឲ្យហាមឃាត់ កុំឲ្យប្រដៅកូនសិស្សក្នុងសាលារៀនថាមនុស្សកើតមកពីស្វាឬពីសត្វផ្សេងៗ ព្រោះថាបើប្រដៅដូច្នេះហើយ ក្នុងមួយរយឆ្នាំទៅមុខគ្មានមនុស្សជឿព្រះជាម្ចាស់ក្នុងសាសនាគ្រិស្តនោះឡើង ។

អំពីសេចក្តីយល់ឃើញរបស់មនុស្សទាំងឡាយ អំពីកំណើតកើតរបស់មនុស្សនោះ យើងល្មមយកមកសរុបជាបីពួកដូច្នេះ ។

ពួកទី១- យល់ឃើញថាមនុស្សយើងកើតមកឯងៗ ដោយបានវិញ្ញាណមកថ្មី មិនមែនវិញ្ញាណជាប់មកពីជាតិណាៗទេ តែកាលណាស្លាប់វិញ្ញាណក៏រលត់ ។ ផលនៃជំនឿនេះ គឺថាមនុស្សនឹងបានទទួលផលល្អឬអាក្រក់ដោយប្រការដូចម្តេចៗ ក៏ទទួលតែក្នុងលោកនេះប៉ុណ្ណោះ ដល់ស្លាប់ទៅហើយ ក៏ជាអហោសិកម្ម ។

ពួកទី២- យល់ឃើញថាមនុស្សកើតមកតោងអាស្រ័យវិញ្ញាណដែលមានមកពីមុនហើយនោះទាំងអស់ កាលណាស្លាប់វិញ្ញាណមិនរលត់ អរង់ចាំទាល់តែប្រទះកាយសម្រាប់កើតជាថ្មីទៀត ។

ពួកទី៣- យល់ឃើញជាកណ្តាលថា មនុស្សកើតថ្មីវិញ្ញាណក៏ថ្មី ដោយមិនបានយកវិញ្ញាណរបស់មនុស្សស្លាប់មកបញ្ចូលក៏មាន មនុស្សដែលកើតមក ដោយវិញ្ញាណចាស់ក៏មាន មនុស្សដែលស្លាប់ហើយដោយវិញ្ញាណរលត់ទៅក៏មាន មិនរលត់ក៏មាន ។

តាមសេចកក្តីយល់ឃើញ ពួកទី១ ជាសេចក្តីយល់ឃើញរបស់អ្នកប្រាជ្ញវិទ្យាសាស្ត្រដោយពិត ដែលជាពួកអ្នកអធិប្បាយថា មនុស្សកើតមកពីសត្វស្វានោះឯង សេចក្តីយល់ឃើញរបស់ពួកនេះយើងអាចតាំងប្រស្នាជជែកបានច្រើនខគឺ :

១- បើមនុស្សយើង បានវិញ្ញាណថ្មីជាដរាបទៅ ដោយមិនជាប់មកពីជាតិណាៗទេ វិញ្ញាណនោះក៏នឹងដូចគ្នាទាំងអស់ តែហេតុអ្វីក៏មនុស្សយើង មិនដូចគ្នាទាំងអស់ ដូចម្តេចបានជាមានល្ងង់មានឈ្លាស មានឧស្សាហ៍ មានខ្ជិល មានចិត្តត្រង់មិនត្រង់សុចរិតមិនសុចរិត ដែលជាហេតុឲ្យផ្ទុយគ្នាខុសគ្នាជាដរាប ដូចជាកូនដែលកើតពីមាតាបិតាជាមួយគ្នា មួយល្អជាបំផុត មួយទៀត អាក្រក់បំផុតក៏មាន មិនដូចគ្នានឹងដើមឈើ ដូចជាដើមកុឡាប ដែលមានផ្កាច្រើន ទុកជាខុសគ្នាដោយផ្កាធំតូចក៏គង់ក្លិនមិនខុសគ្នា ដោយផ្កាមួយក្រអូប ផ្កាមួយស្អុយ ក៏ទេដែរ ប្រសិនបើមានពាក្យដោះស្រាយថា ព្រោះវិញ្ញាណដែលបានមកនោះផ្សេងពីគ្នា យើងអាចមានពាក្យសួរតទៅថា អ្វីជាហេតុធ្វើឲ្យផ្សេងពីគ្នា ក្នុងសាសនាឬលទ្ធិណាៗក្តីតែងតែមានគោលដូចគ្នាថា ផលនឹងមានបានលុះតែមានហេតុ ។

២- មនុស្សដែលបានរៀនសូត្រដូចគ្នា ធ្វើការដូចគ្នា ចិត្តហ៊ានដូចគ្នា តែម្នាក់បានល្អ ម្នាក់មិនបានចម្រើនល្អ ដូចជាមនុស្សដែលចិត្តត្រង់ឧស្សា-

ហ៍ធ្វើការដោយសុចរិតអស់មួយជីវិត តែមិនបានសេចក្ដីសុខ ឬឲ្យបានជាអ្នកមានសម្បត្តិទ្រព្យក៏ទេ ឯមនុស្សខ្លះដែលឆបោករាស្ត្រ ប៉ាំងព្រះរាជទ្រព្យ បៀតបៀនមនុស្សដទៃ ធ្វើឲ្យមនុស្សក្ដៅក្រហាយជានិច្ចនោះ ត្រឡប់ជាមានសេចក្ដីចម្រើន មានអំណាចវាសនា មានមនុស្សទាំងពួងញញើតខ្លាចក៏មាន

៣- បើយល់ឃើញពិតប្រាកដថា មនុស្សស្លាប់ទៅហើយវិញ្ញាណក៏រលត់ទៅជាមួយដែរ មិនមានបាបបុណ្យគុណទោសអ្វីជាប់ទៅលោកខាងមុខទេ ដូច្នេះនេះមនុស្សនោះក៏នឹងគិតថា ចាំបាច់ខ្វល់ខ្វាយប្រព្រឹត្តធ្វើឲ្យបានសេចក្ដីល្អទុកធ្វើអ្វី គ្រាន់តែរក្សាខ្លួនចិញ្ចឹមជីវិតឲ្យរួចទំរាំរលត់ទៅក៏បានហើយ ។

ប្រការមួយវិញទៀត បើមនុស្សនោះ មានអំណាចធ្វើអ្វីបានតាមចិត្តក៏នឹងប្រព្រឹត្តដោយផ្លូវត្រង់ខ្លះ វៀចខ្លះ រកផលប្រយោជន៍ឲ្យខាងតែបានទុកជាមានពាក្យនិន្ទាថាអ្វីក៏ដោយ ស្លាប់ទៅហើយអ្នកណាចង់និយាយថាដូចម្ដេចៗ ក៏ថាទៅចុះ សុំឲ្យតែមានទ្រព្យចាយសប្បាយចិត្តក្នុងមួយជាតិក៏បានហើយ ។

បើគិតដល់បញ្ហាទាំង៣ ខ ដែលមានមកនោះ ក៏នឹងធ្វើឲ្យអ្នករៀនធម៌ អាចតាំងជាបញ្ហាបានច្រើនខតទៅទៀត ។ តាមសេចក្ដីយល់ឃើញក្នុងពួកទី១នោះ មិនខុសតែម្យ៉ាងទេ នៅមានសេចក្ដីខុសទៅទៀតថាបើជឿតាមសេចក្ដីនោះហើយ ក៏នឹងនាំឲ្យមនុស្សប្រាសចាកសីលធម៌ដែលល្អនោះផង ។ អ្នកដែលបានរៀនធម៌គង់ដឹងថា ជាការពិបាកណាស់ដែលនឹងអធិប្បាយឲ្យមនុស្សក្នុងបច្ចុប្បន្ននេះ យល់មើលឃើញផលដែលបានទទួលដោយការសុចរិតគ្រៅអំពីមនុស្សដែលប្រព្រឹត្តរកស៊ីដោយខុស ផ្លូវធម៌នោះ មួយទៀត ការដែលនឹងសម្ដែងពន្យល់ឲ្យមនុស្សមើលឃើញផលក្នុងការរក្សា សីលថានឹងបានផលក្នុងបច្ចុប្បន្នយ៉ាងណានោះ ក៏ពិបា-

លពន្យល់ណាស់ដែរ ព្រោះក្នុងលោកនេះ មានមនុស្សដែលប្រព្រឹត្ត អាក្រក់ច្រើនជាងមនុស្សប្រព្រឹត្តល្អ មនុស្សបែបនេះ មានតាំងពីលោក កើតឡើងរហូតមកដល់ឥឡូវនេះ ក៏មិនឃើញមានអ្វីទោសឲ្យបានគ្រប់ មនុស្សដែលនៅតែមានមនុស្សប្រព្រឹត្តអាក្រក់នោះ មានអាយុយឺនវែង មានឱកាសរស់នៅបៀតបៀនមនុស្សផងគ្នាឲ្យបានយូរតទៅទៀត ត្រង់ មនុស្សល្អច្រើនស្លាប់ឆាប់ ប្រហែលដូចពាក្យថា ទីវិមានក្នុងស្ថានសួគ៌ ត្រូវ ការយកខ្លួនឲ្យទៅនៅឆាប់នោះទេដឹង?

វិធីដែលយើងប្រដៅធម៌គ្នា ក្នុងជំនាន់ថ្មីនេះ យើងអធិប្បាយថា មនុស្សធ្វើបាបអាក្រក់លាមកយ៉ាងណា ទុកជាគ្មានអ្នកណាដឹងឃើញគ្មាន អ្នកណាធ្វើទោសបាន ក៏គង់នៅមានសេចក្តីក្រហល់ក្រហាយក្នុងចិត្តរបស់ ខ្លួនដែរ បែបនេះក៏មានច្រើន តែក៏គង់នៅមានចន្លោះជាច្រើនទៀតដែរ ព្រោះមនុស្សដែលធ្វើបាបជាប្រក្រតីទាល់តែថ្នឹកហើយ ត្រឡប់ជាមាន សេចក្តីពេញចិត្ត ក្នុងការដែលខ្លួនមានឱកាសធ្វើបាបនោះៗ មនុស្សដែល រកស៊ីចិញ្ចឹមជីវិត ដោយផ្លូវកោងកាចក៏មានចិត្តត្រេកអរ យល់ឃើញថាខ្លួន ឆ្លាតចេះកោងគេបានសម្រេចដូចប្រាថ្នារបស់ខ្លួន មនុស្សដែលប្រព្រឹត្ត បៀតបៀន ធ្វើឲ្យមនុស្សផងគ្នាក្តៅក្រហាយដោយមិនយុត្តិធម៌ច្រើនមាន ចិត្តអំណរ យល់ឃើញថាខ្លួនមានជ័យជំនះក្នុងការដែលធ្វើបានសម្រេច ដូចគំនិតរបស់ខ្លួន។ មនុស្សដូចបានពណ៌នាមកនេះ មាននៅក្នុងលោក ជាច្រើន ។

អ្នកប្រាជ្ញទាំងឡាយ បានយល់ឃើញដូចគ្នាថា ដំណើរធម្មជាតិក៏ តែងតែមានច្បាប់ដូចរាជការក្នុងស្រុកដែលហៅថា (Loi de la nature) ដូចមានពណ៌នាក្នុងវិជ្ជាប្រការទី១ រួចមកហើយ ។ បើធម្មជាតិសាង មនុស្សឡើងហើយ ធម្មជាតិក៏ត្រូវធ្វើទោសមនុស្សដែលប្រព្រឹត្តខុសហើយ ក៏ត្រូវឲ្យបំណាច់រង្វាន់មនុស្សដែលប្រព្រឹត្តល្អ ហេតុនេះយើងគួរជឿថា

មនុស្សដែលប្រព្រឹត្តល្អឬអាក្រក់ បើប្រសិនជាមិនបានទទួលផលក្នុងជាតិនេះ ក៏គង់តែនឹងបានទទួលទៅក្នុងជាតិមុខ គិតបានដូច្នេះក៏នឹងធ្វើឲ្យមនុស្សដែលមានចិត្តអាក្រក់ទប់ចិត្តបានខ្លះ មុននឹងទៅធ្វើកំដៅឲ្យមនុស្សដទៃ ហើយនឹងធ្វើឲ្យមនុស្សដែលប្រកបដោយសេចក្ដីសុចរិតល្អមិនបានទទួលផលល្អក្នុងលោកនេះ ត្រឡប់ទទួលនូវផលអាក្រក់វិញនោះ នឹងមើលឃើញក្នុងលោកនេះ ប្រាសចាកសេចក្ដីយុត្តិធម៌ ហើយក៏នឹងលះបង់ចោលនូវសេចក្ដីតូចចិត្តចេញបានខ្លះ ដោយមានចិត្តគិតទៅទទួលផលល្អក្នុងលោកខាងមុខ មនុស្សដែលកើតមកបានសេចក្ដីសុខ ក៏នឹងបានប្រព្រឹត្តឲ្យល្អតទៅ ដើម្បីឲ្យបានទទួលសេចក្ដីសុខក្នុងលោកខាងមុខតទៅទៀត។ មនុស្សដែលកើតមកបានសេចក្ដីទុក្ខក៏នឹងបានគិតឃើញថាពីព្រោះប្រព្រឹត្តមិនល្អមកពីជាតិមុន ក៏នឹងបានព្យាយាម ប្រព្រឹត្តឲ្យល្អក្នុងជាតិនេះតទៅ នឹងបានទទួលផលល្អក្នុងជាតិមុខ។ ហេតុនេះបានជាការដែលប្រដៅថា មនុស្សស្លាប់ហើយវិញ្ញាណរលត់គ្មានអ្វីមកកើតទៀតនោះជាការមិនគួរប្រដៅសោះ បើប្រដៅតាមបែបនោះហើយ ក៏នឹងនាំឲ្យមនុស្សប្រព្រឹត្តអាក្រក់ខុសពីធម៌ល្អ ហើយនឹងនាំឲ្យមានគំនិតធ្វើការអាក្រក់ឲ្យក្ដៅក្រហាយដល់មនុស្សគ្នាឯងផង ដោយមិនកោតខ្លាចអាជ្ញាក្នុងលោកនេះធ្វើទស ព្រោះនឹងគិតថាក្នុងវេលាដែលធ្វើអាក្រក់នោះ គ្មានអ្នកណាឃើញ ឬក៏មានអាងអ្វីម្យ៉ាងៗថាខ្លួនមិនត្រូវទោសទេក៏នឹងប្រព្រឹត្តតទៅ មិនគិតខ្លាចមានទោសទៅក្នុងលោកខាងមុខពីព្រោះយល់ឃើញថាស្លាប់ហើយវិញ្ញាណរលត់ទៅជាមួយផង ។

សេចក្ដីយល់ឃើញពួកទី២មានហេតុផលសមច្រើនជាងពួកទី១ តែនៅមានពាក្យជជែកថា បើមនុស្សយើងតោងអាស្រ័យវិញ្ញាណចាស់ទាំងនោះមកកើតជាមួយ តើវិញ្ញាណចាស់នោះមកពីណា កាលដម្បូងបង្អស់តាមព្រះគន្ថរចនាចារ្យក្នុងសាសនារបស់យើង សម្ដែងទុកថាអាយុរបស់

លោកមានច្រើនកោដិឆ្នាំ (ខាងអ្នកប្រាជ្ញពង្សាវតារកឃើញតាមសាវតា ឃើញមានតែត្រឹមប្រាំពាន់ឆ្នាំជាយ៉ាងច្រើន) ទុកជាយូរយ៉ាងណាក៏ដោយ ក៏គង់នៅមានបញ្ហាថា វិញ្ញាណដើមបង្អស់នោះតើមកពីណា ? បើមនុស្ស យើងទាំងអស់គ្នាប្រកាន់ថា ធ្លាប់កើតមកហើយ ក៏ពិបាកថាដែលកើតថ្មី វិញ្ញាណក៏ថ្មី គង់មានខ្លះ ។

តាមសេចក្តីយល់ទាំង៣ពួក បើគិតទៅឃើញថា ពួកទី៣ នោះត្រូវណាស់ យើងអាចយកសេចក្តីយល់ឃើញរបស់អ្នកប្រាជ្ញវិទ្យាសាស្ត្រនឹងអ្នកប្រាជ្ញខាងផ្លូវសាសនា មកប្រកបគ្នាគង់ឃើញមិនខុសដល់ទៅផ្ទុយគ្នាបាននោះទេ ពោលក្នុងជាន់ដំបូង មនុស្សអាចកើតពីដើមឈើជាមុន តែមិនបានកើតជាមនុស្សក្នុងវេលានោះទេ តោងកើតជាសត្វមុនចាប់ដើមដំបូងកើតជាសត្វដែលល្ងង់សិន រួចបានកើតជាសត្វរៀងរាបដរាប ទាល់តែដល់សត្វដែលឆ្លាតដូចជាស្វា រួចហើយបានក្លាយមកជាមនុស្ស ហេតុនេះបានជាក្នុងផ្លូវសាសនារបស់យើងរាប់មនុស្សទុកជាសត្វ១ពួក ដ៏ប្រសើរខ្ពង់ខ្ពស់ជាងសត្វទាំងពួង។ កាលណាក្លាយមកជាមនុស្សហើយ ក៏អាចមានកូនចៅកើតជាមនុស្សតមក ដោយបានវិញ្ញាណមកថ្មីឯវិញ្ញាណដែលបានកតើមកជាមួយនឹងរូបកាយនៅក្នុងលោកនេះហើយ ក៏ត្រូវតែទទួលខុសត្រូវ ក្នុងការដែលកាយប្រព្រឹត្ត បើកាយទៅប្រព្រឹត្តអាក្រក់ហើយមិនបានទទួលទោសក្នុងលោកនេះ វិញ្ញាណក៏នឹងត្រូវទៅទទួលទោសក្នុងកាយខាងមុខ វិញ្ញាណនឹងរត់រលត់មុន ដោយមិនទាន់បានទទួលទោសដែលកាយធ្វើ ដូចជាលួចវាយក្បាលគេបែកហើយរត់បាត់មិនឲ្យចាប់បាននោះ ធម្មជាតិគង់តែមិនព្រមឲ្យរត់រួចបាននោះទេ ។ បានជាថាហេតុដែលប្រកាន់ថាវិញ្ញាណរលត់ទៅជាមួយខ្លួនស្លាប់នោះ មិនគួរស្តាប់យកមកជាគតិសោះឡើយ គ្រាន់តែមនុស្សទោសដែលត្រូវប្រហារជីវិតម្តេចគេទំនុកបំរុងរវាំងរក្សាមិនឲ្យវាស្លាប់មុនប្រហារជីវិត ។ វិញ្ញាណ

របស់មនុស្សក៏ដូចគ្នា បើធ្វើខុសអ្វីទុកក្នុងលោកនេះនឹងរត់រលត់ទៅនោះពុំបាន ត្រូវតែចាំទទួលទោសកំហុសរបស់ខ្លួនឲ្យអស់សិន បើចង់រលត់ក៏រលត់ទៅបាន ឯការដែលរលត់នោះឯង យើងហៅថា និព្វាន ។

តាមសាសនារបស់យើង ពោលថានឹងលុះដល់និព្វាននោះជារបស់ពិបាកណាស់ តោងសាងបារមីច្រើនពាន់ជាតិ កសាងបារមីនេះគឺជាការដោះខ្លួនពីទោសដែលខ្លួនប្រព្រឹត្តខុសមកនោះ ហើយនឹងដោះបំណុលក្នុងលោកដែលខ្លួនបានអាស្រ័យមកនោះផង បើបានធ្វើការដោះខ្លួនរួចពីទោសនឹងដោះបំណុលរបស់លោករួចបានហើយ ចង់នៅតទៅឬចង់រលត់នោះមានគតិ២ ផ្លូវ មួយបើចង់នៅតទៅ ក៏ទៅកើតក្នុងសុគតិដែលហៅថាស្ថានសួគ៌ មួយវិញទៀត បើមិនទុកចិត្ត ខ្លាចក្រែងនៅទៅហើយប្រព្រឹត្តអាក្រក់ធ្វើបាបក៏នឹងនាំឲ្យមានទោសទុក្ខ ត្រូវចាំដោះពៀរវេរាតទៅទៀតឬក៏មានសេចក្ដីនឿយណាយ ជិនឆ្អន់នឹងកំណើតដែលវិលកើតវិលស្លាប់នោះ ក៏មានតែរលត់សូន្យទៅ ដែលហៅថាចូលព្រះនិព្វាន ។

មនុស្សដែលកើតមកក្នុងលោកជាមួយគ្នា ត្រូវប្រកាន់ដូចជាបានចូលហ៊ុនជាមួយគ្នា ហើយនៅក្រោមច្បាប់របស់ធម្មជាតិ ដូចជាអ្នកចូលហ៊ុនធ្វើជំនួញ ដែលត្រូវនៅក្នុងបង្គាប់ច្បាប់សម្រាប់ស្រុក ដែលខ្លួនអាស្រ័យផែនដីនៅនោះ ព្រោះខ្លួនបានផលប្រយោជន៍ ជាគ្រឿងចិញ្ចឹមជីវិតប្រៀបប្រដូចនូវប្រាក់ចំណេញ នឹងការប្រាក់ដែលចូលហ៊ុនបានមកទាំងប៉ុន្មាននោះ ត្រូវតែកាត់សងបំណុលដែលហ៊ុនចំពាក់ឲ្យរួចសិន អ្នកចូលហ៊ុនមិនព្រមកាត់សងបំណុលនឹងការបង់ខាត ដែលហ៊ុនធ្វើនោះទេគិតតែចូលហ៊ុនហើយ ទារយកតែចំណេញនោះ ច្បាប់ក្នុងស្រុកក៏គង់តែមិនយល់ព្រមឲ្យធ្វើដូច្នោះបានឡើយ ។

រួមសេចក្ដី ដែលពោលមកនេះ គួរតែជឿថា មនុស្សស្លាប់ហើយត្រូវតែមកកើតជាថ្មីទៀត ទាល់តែសងបំណុលដែលចំពាក់ក្នុងលោកឲ្យអស់ដែល

ហៅថាបំណុលនោះ គឺសំដៅដល់កំហុសរបស់ខ្លួន ដែលបានប្រព្រឹត្តបទអាក្រក់មកពីជាតិមុនៗដែលថាសងបំណុលនោះ គឺត្រូវប្រព្រឹត្តសេចក្តីល្អដោះសេចក្តីអាក្រក់របស់ធម្មជាតិ ដែលខ្លួនបានប្រព្រឹត្តមកហើយនោះ ។ មនុស្សដែលកើតមកហើយនៅស្ងៀម មិនបានប្រព្រឹត្តធ្វើនូវការល្អឬការអាក្រក់សោះ ក៏នឹងទៅនិព្វានពុំបានដែរ ព្រោះនៅមានជាប់បំណុលរបស់ធម្មជាតិ ដូចជាកំណើតមនុស្សធ្វើសេចក្តីលំបាកដល់មនុស្សពួកខ្លះដូចមាតាជាដើម តោងតែសងគុណលោកឲ្យរួចស្រេច ទើបចូលទៅនិព្វានបាន។ ហេតុដូច្នេះបានជាការដែលនឹងទៅនិព្វានបាននោះលុះ តែធ្វើសេចក្តីល្អឲ្យច្រើនណាស់ ដូចដែលហៅថាសន្សំបារមីមករាប់ហ្មឺនសែនជាតិនោះ តាមន័យដែលអធិប្បាយមកនេះ ។

បើលោកអ្នកមើល មានសេចក្តីយល់ឃើញថា មនុស្សស្លាប់ហើយកើតទៀតនោះ បញ្ហាក៏នឹងមានតទៅថា បុព្វេនិវាសានុស្សតិញ្ញាណនោះតើនឹងសំដៅតែត្រឹមជាតិនេះតែមួយ ឬក៏សំដៅដល់ទៅជាតិដែលកន្លងមកហើយនោះផង ។

បើសំដៅតែត្រឹមក្នុងជាតិនេះ ក៏តោងអធិប្បាយថាតាំងពីដឹងសេចក្តីមក ទល់ឥឡូវនេះ អាចដឹងចាំបានថាកាលក្នុងអាយុបានប៉ុណ្ណោះៗបានធ្វើការឬបានប្រទះហេតុយ៉ាងនោះៗ ដែរឬទេ រឿងនេះមិនជាពិបាកទេបើមនុស្សយើងគ្រប់គ្នាគ្មានសតិវិបល្លាសហើយ ក៏អាចចាំហេតុការណ៍ដែលខ្លួនបានប្រទះមកហើយនោះបាន ។ បើយើងយកសេចក្តីចាំ ក្នុងជាតិនេះថា ជាបុព្វេនិវាសានុស្សតិញ្ញាណហើយ ក៏នឹងធ្វើឲ្យកិត្តិគុណ របស់ព្រះពុទ្ធជាម្ចាស់ ថោកថយទាបពេកណាស់ ។ ព្រោះថាព្រះពុទ្ធជាម្ចាស់ដែលនឹងបានលុះញាណ១ នេះ តោងធ្វើទុក្ករកិរិយាដល់ទៅ ៦ឆ្នាំហាក់ដូចជាព្រះអង្គល្ងង់ ជាងសាមញ្ញជន ព្រោះការធ្វើបានដោយងាយមិនបាច់ព្យាយាមក៏ធ្វើបានដែរ ព្រះអង្គទៅព្យាយាមធ្វើជាយូរឆ្នាំ ឲ្យអស់តែកម្លាំងឥតអំពើ។

ហេតុនេះគួរឲ្យជឿថា បុព្វេនិវាសានុស្សតិញ្ញាណនោះ ពិតប្រាកដជានឹករឭកឃើញដល់ជាតិ ដែលកន្លងមកហើយបាន មិនមែននឹកឃើញតែក្នុងជាតិនេះទេ ។

ឯបុព្វេនិវាសានុស្សតិញ្ញាណនេះ ពុំដែលប្រទសេចក្ដីអធិប្បាយរបស់បារាំងឬរបស់យោគីណាមួយក្នុងតណ្ហៀ ថាជាអ្វីឲ្យប្រាកដនោះឡើយ តាមសេចក្ដីដែលយល់ឃើញ គឺបាននូវការនាំយករបស់ធ្លាប់ដឹងឃើញចំណាំចាំបានមកហើយនោះ ចូលមកកាន់ដួងចិត្តជាថ្មីវិញបាន ដូចក្នុងភាសាបារាំងហៅថា (Facult de la memoire) ប្រៀបដូចយើងធ្លាប់នៅក្នុងស្រុក ស្គាល់ច្រកល្ហកទាំងប៉ុន្មាន ហើយចេញចោលស្រុកទៅបាន ៣០ឆ្នាំ បានត្រឡប់វិលមកស្រុកវិញ ក៏នឹងរកផ្លូវដែលយើងធ្លាប់ដើរពីមុននោះពុំឃើញឡើយ ព្រោះចេញចោលទៅយូរឆ្នាំ ស្រុកប្រទេសដែលយើងធ្លាប់នៅពីដើមនោះ រាជការផ្លាស់បែបផែនរៀបចំជាថ្មី ឬមួយក៏សំគាល់សេចក្ដីចំណាំរបស់ខ្លួនមិនប្រាកដក៏មាន ម្យ៉ាងទៀត យើងធ្លាប់រៀនមកថា មនុស្សយើងស្លាប់ហើយវិញ្ញាណចេញទៅរេរង់នៅក្នុងទីណាមួយរាប់ហ្មឺនៗឆ្នាំ ទើបបានមកកើតជាថ្មីទៀត ហេតុនេះបានជាចាំអ្វីមិនបាន ព្រោះក្នុងលោកបានផ្លាស់ប្ដូរទៅជាច្រើន វិញ្ញាណក៏ភ្លេចអស់។ យើងមកល្បងគិតមើលទៀតថា បើមនុស្សស្លាប់ហើយមកកើតមួយរំពេចវិញ តែមនុស្សនោះមុននឹងស្លាប់មានស្មារតីល្អចាំសេចក្ដីបាន ប្រហែលជារឭកជាតិបានខ្លះឬទេ រឿងនេះយើងគង់ដែលបានឮ លោកចាស់ៗនិយាយដំណាលមកជាច្រើន ថាមានក្មេងខ្លះកើតមកដល់ធំដឹងសេចក្ដី ក៏និយាយប្រាប់ថាខ្លួនធ្លាប់កើតមកហើយបានចាំរបស់ទ្រព្យនោះៗប្រាប់ដំណើររបស់ទាំងនោះក៏ត្រូវទៀត តែរឿងនេះមានតិចណាស់ បានជាបណ្ដោយឲ្យថាជារឿងមិនពិត ហើយមិនយកចិត្តទុកដាក់តមក។ មានរឿងគេនិយាយថា មានស្ត្រីម្នាក់មានប្ដី កាលប្ដីនឹងដាច់ខ្យល់ស្លាប់ បានយកកំបោរលាបកជើងសំ

គាល់ ដើម្បីចងដឹងថាមកកើតវិញឬទេ ដល់ស្ត្រីនោះមានប្តីថ្មីកូនដម្បូងកើតមកឃើញមានប៉ានផ្ទៅនៅកជើង ជាស្នាមកំបោរដែលគូសសំគាល់ ដល់កូននោះធំឡើងដឹងសេចក្តីមិនព្រមហៅស្ត្រីនោះថាម្តាយ ការដែលក្មេងមានប៉ានផ្ទៅនៅកជើងនោះព្រោះម្តាយមានចេតសិករព្វកជា រឿយៗដល់ស្នាមកំបោរដែលខ្លួនគូសនៅកជើងរបស់ប្តី ឯក្មេងដែលហៅម្តាយថាជាប្រពន្ធវិញនោះប្រហែលជាមានអ្នកណា ទៅបញ្ចោះឲ្យហៅ។ ការដឹងជាតិនេះ មានកាសែតដេលីមេក្នុងក្រុងទេព ចុះដំណឹងតាមខ្សែលួសថាមានរឿងប្លែកកើតឡើងក្នុងស្រុកឥណ្ឌៀ គឺក្មេងស្ត្រីម្នាក់អាយុបាន៣ឆ្នាំប្រាប់អាពុកថាជាកំណើតទីពីរដែលខ្លួនមកកើតក្នុងលោកនេះកាល មុនកើតនៅទីនោះៗ ឪពុកក៏មិនយកចិត្តទុកដាក់ គិតថាបុត្រីខ្លួននិយាយទៅតាមភាសាក្មេង តែកូននោះនៅតែនិយាយជាដរាប ហើយរំអុកឲ្យឪពុកវានាំទៅទី ដែលខ្លួនបានកើតមុននោះ ទាល់តែក្មេងនោះអាយុ៧ឆ្នាំ ឪពុកឃើញវានិយាយញយៗខុសនឹងប្រក្រតី ក៏នាំកូននោះទៅតាមពាក្យវាថាទីកន្លែងភូមិដែលវាកើតមុននោះ ដេកផ្លូវមួយយប់បានដល់ ទៅដល់ភូមិនោះហើយវាប្រាប់ផ្លូវឲ្យទៅទីកន្លែងផ្ទះដែលវាកើត នឹងប្រាប់ឈ្មោះមនុស្សដែលនៅក្នុងទីនោះត្រូវ រួចវាក៏ទៅរកបុរសពីរនាក់ថាជាកូនរបស់វា ដល់វេលាឪពុកវានឹងនាំត្រឡប់វិលមកស្រុកវិញ វាយំមិនព្រមវិលវិញ ទាល់តែបង្ខំបានវាមករឿងនេះក៏ជាហេតុនាំឲ្យយើងគួរស្រាវជ្រាវ រកសេចក្តីពិតឲ្យឃើញថាមកពីហេតុដូចម្តេច(១)? កាលដែលព្រះពុទ្ធជាម្ចាស់របស់យើងទ្រង់អាចរំឭកជាតិបាននោះ មានសេចក្តីសន្និដ្ឋានបានពីរប្រការ គឺកាលក្នុងវេលាព្រះអង្គបានសម្រេចព្រះសម្មាសម្ពោធិញ្ញាណហើយនោះ ព្រះអង្គមានព្រះហឫទ័យផូរផង់ដូចជាព្រះចន្ទ្រក្នុងថ្ងៃពេលបូណ៌មី ប្រការមួយទៀតមុនព្រះអង្គនឹងបានត្រាស់ជាព្រះពុទ្ធនោះ ក្នុងជាតិនីមួយៗដែលព្រះអង្គកំពុងសាងបារមី ព្រះអង្គប្រតិបត្តិធ្វើតែសេចក្តី

ល្អមកជាច្រើនជាតិ  គ្មានអ្វីនឹងធ្វើព្រះទ័យឲ្យល្អក់សៅហ្មងបានក្នុងវេលាដែលព្រះអង្គរលត់ចិត្ត ពីជាតិមួយទៅជាតិមួយជាថ្មីនោះ មុនដែលព្រះអង្គបានត្រាស់ជាព្រះពុទ្ធ ។

សេចក្តីនេះនឹងអធិប្បាយតាមអត្តនោមតិថា  ធម្មតាមនុស្សយើងបើចាំអ្វីបាន ឬបានឃើញអ្វីមួយផងហើយដល់កន្លងយូរទៅ ក៏អាចភ្លេចទៅវិញបាន  បើនឹងព្យាយាមរំឭកនឹកចង់ឲ្យឃើញមកវិញនោះជារបស់ពិបាក តែមានថ្ងៃណាឬវេលាណាមួយ  ចិត្តយើងថ្លាផូរផង់គ្មានអ្វីមកធ្វើឲ្យរំខានចិត្តសោះនោះ  ក៏អាចនឹងឃើញឯងៗដោយមិនបានព្យាយាមនឹករផង  ឬមនុស្សដែលកំពុងព្យាយាមធ្វើការនីមួយៗ  ចង់ឲ្យបានសម្រេចម្យ៉ាងៗតែ

------------------------------------------------------------------------------------

(១) កាលខ្ញុំនៅធ្វើជាចៅហ្វាយស្រុកកៀនស្វាយ មានស្ត្រីឈ្មោះនាងជូជាប្រពន្ធឈ្មោះផ្លូនៅចុងស្ពានកំពង់ទួល ខណ្ឌកណ្តាលស្ទឹង កើតកូនមកភ្លោះប្រុសទាំង២ មួយមិនដឹងជាតិ កូនមួយទៀតដឹងជាតិ  ឪពុកម្តាយឲ្យឈ្មោះរួច  ចៅរួចអាយុបាន  ៦ខួបលេងនៅមុខផ្ទះបៀតចិញ្ចើមថ្នល់ស្រាប់តែឃើញនាងភេមនឹងឈ្មោះនេត  មកពីស្រុកភ្នំស្រួច  ដើរមកដល់មុខផ្ទះ ចៅរួចៗស្រែកប្រាប់ឪពុកម្តាយថា ឪពុកម្តាយខ្ញុំមកហើយ ឪពុកម្តាយក៏ឆ្ងល់បានសួរចៅរួចៗថាកាលជាតិមុនខ្ញុំឈ្មោះអិមប្រពន្ធឈ្មោះណប់  នៅឃុំព្រៃកប្បស្សីកៀនស្វាយ  ទៅសួរឪពុកម្តាយនៅភ្នំស្រួចទទួលឈឺស្លាប់  ខ្លួនខ្ញុំដើរមកគ្នា២នាក់  ដល់មកចុងស្ពានកំពង់ទួលទទួលភ្លៀងធំខ្ញុំក៏នាំគ្នាចូលទៅសុំផ្ទះនាងជូនៅ  ឪពុកម្តាយបានដឹងដោយចៅរួចប្រាប់ដូច្នោះ  ក៏នាំចៅរួចមកឃុំព្រៃកប្បស្សីស្រុកកៀនស្វាយ ចៅរួចចង្អុលឈ្មោះនាងលាប់ថាជាប្រពន្ធរបស់ខ្លួនហើយស្គាល់ឈ្មោះបងប្អូនខាងប្រពន្ធសឹងគ្រប់ឈ្មោះ  ឯរបស់ទ្រព្យរបស់ចៅរួចៗក៏ស្គាល់ ដល់អាយុពេញបួសជាសាមណេរ  ឪពុកម្តាយចង់ឲ្យបួសនៅវត្តកោះក្របី  ចៅរួចមិនព្រមរត់ទៅបួសជាសាមណេរនៅវត្តពោធិល្បំ  កណ្តាលស្ទឹង  រឿងនេះខ្ញុំបានយកខ្លួនក្មេងនោះតាំងពីអាយុ  ៨ខួបមកសួរបញ្ជាក់ហើយបានសួរបងប្អូនខាងនាងលាប់ក៏ទទួលថាពិតមែន (ន័យលក្ខណៈរបស់អ្នកប្រែ) ។

កាលកំពុងធ្វើនោះ ពុំទាន់គិតឃើញដល់ការរបស់ខ្លួនធ្វើបានយ៉ាងណាខ្លះហើយនោះទេ  លុះតែការដែលធ្វើនោះសម្រេចហើយបានមើលទៅឃើញ

ពេញចិត្ត ដោយផលនៃខ្លួនព្យាយាម ដួងចិត្តនោះក៏ថ្លារឭកនឹកឃើញចាំនូវការផ្សេងៗទាំងប៉ុន្មាន ដែលខ្លួនបានធ្វើមកហើយនោះដូចជាអ្នករៀនវិជ្ជាផ្សេងៗ ដែលទើបប្រឡងបានសម្រេចថ្មីៗនឹងចាំនូវវិជ្ជាបានច្រើនលើសជាងកាលកំពុងប្រឡងឬមុននឹងចូលប្រឡង។ ព្រះពុទ្ធជាម្ចាស់របស់យើង ក៏គង់ដូច្នេះដែរ សេចក្តីសម្រេចរបស់ព្រះអង្គធ្វើឲ្យព្រះអង្គពេញព្រះទ័យក្នុងសន្តិសុខ ជាងសេចក្តីសម្រេចពីការអ្វីៗទាំងអស់ ក៏អាស្រ័យនូវព្រះទ័យជ្រះថ្លាផូរផង់ ប្រាសចាកកិលេសនោះឯងបានជាសេចក្តីចាំទាងប៉ុន្មានៗ ត្រឡប់មកកាន់ព្រះអង្គ បានវិញ ។

មនុស្សយើងនឹងភ្លេចរបស់ដែលធ្លាប់បានប្រទះឃើញ ឬចាំបានមកហើយ ច្រើនមកពីចិត្តមិនទៀង ដួងចិត្តល្អក់សៅហ្មងក្នុងវេលាកំពុងធ្វើការ។ ឯមនុស្សដែលគ្មានហេតុអ្វី មកធ្វើឲ្យខ្វល់ក្នុងដួងចិត្តបាននោះមានសេចក្តីចាំបានជាច្រើនបំផុត ។ មកពីហេតុនេះបានជាក្នុងផ្លូវសាសនារបស់យើង ប្រកាន់ខ្ជាប់ឲ្យប្រដៅមនុស្សជិតស្លាប់ ឲ្យមានស្មារតីព្យាយាមរឭកនឹកតែពីសេចក្តីល្អផ្សេងៗ ដែលខ្លួនបានធ្វើនោះសម្រាប់ធ្វើឲ្យវិញ្ញាណរឭកជាប់ទៅជាមួយ ក្នុងលោកខាងមុខ មនុស្សដែលគ្មានសេចក្តីល្អសម្រាប់នឹងនឹករឭក ឬមនុស្សដែលមានចិត្តបាបអាក្រក់ប្រព្រឹត្តធ្វើតែសេចក្តីក្តៅក្រហាយ ឲ្យមនុស្សទាំងពួងក្តៅក្រហាយនិច្ចនោះក៏មិនអាចនឹករឭកដល់ សេចក្តីល្អរបស់ខ្លួនបានឡើយ បានជាមនុស្សដែលធ្លាប់ប្រព្រឹត្តសេចក្តីទុច្ចរិត វេលានឹងស្លាប់ពុំបានស្លាប់ដោយសេចក្តីសុខទេ។

ព្រះពុទ្ធជាម្ចាស់ កាលកំពុងសាងព្រះបារមី ក្នុងជាតិក្រោយៗមកនោះ ព្រះអង្គបានប្រព្រឹត្តធ្វើតែសេចក្តីល្អដរាបមក មិនដែលឃើញមានក្នុងគម្ពីរថា ព្រះអង្គធ្វើឲ្យអ្នកណា បានក្តៅក្រហាយនោះឡើយ ហេតុនេះឯង បានជាវេលាដែលព្រះអង្គនឹងលះលោកមួយទៅ សាងសន្សំព្រះបារមីក្នុងលោកឯទៀតនោះ ព្រះអង្គតែងតែមានសតិផូរផង់ គ្មានអ្វីប៉ះពាល់ធ្វើ

ឲ្យខ្វល់ក្នុងព្រះទ័យបាន បានជាព្រះអង្គមានសេចក្តីចាំមាំមួនបានដោយងាយ ហេតុនេះបានជាថា មិនគួរទៅសង្ស័យ ក្នុងខដែលថាព្រះពុទ្ធជាម្ចាស់មិនអាចរំឭកជាតិជាច្រើនបាននោះសោះ គួរតែជឿថាព្រះអង្គរំឭកជាតិបានជាពិតប្រាកដណាស់ ។

តាមសេចក្តីអធិប្បាយ របស់ព្រះពុទ្ធឃោសាចារ្យថា បុព្វេនិវាសានុស្សតិញ្ញាណ លោកសំដៅដល់សេចក្តីរឭកជាតិដ៏កន្លងមកជាច្រើនជាតិមុននឹងមកកើតក្នុងជាតិនេះ ។ ឯវិធីដែលលោកអធិប្បាយទុកនោះគួរឲ្យជ្រះថ្លា ព្រោះជាការបង្ហាត់សេចក្តីចាំថយក្រោយជាជាន់ៗ តទៅ ។ លោកអធិប្បាយទុកថា ក្នុងជាន់ដម្បូង ត្រូវចូលឈាន៤ ដោយលំដាប់កាលណាចេញពីឈានទាំង៤ ហើយ ឲ្យរំឭកនឹកដល់ការដែលបានធ្វើមកហើយនោះ នឹកថយក្រោយទៅទាល់តែដល់ការដែលបានធ្វើក្នុងវេលាព្រឹកព្រហ៊ាម រួចនឹកទៅការផ្សេងៗដែលបានធ្វើក្នុងមជ្ឈិមយាម ក្នុងមជ្ឈិមយាម រហូតទៅដល់ ២ ថ្ងៃ ៤ ថ្ងៃ ១០ ថ្ងៃ រួចដល់១ ខែ ១ឆ្នាំ ១០ឆ្នាំ ២០ ឆ្នាំ ទាល់តែដល់វេលាកើត បើជាប់ត្រង់ណា ត្រូវចូលឈានឡើងវិញ (ដើម្បីធ្វើឲ្យចិត្តថ្លាផូរផង់សម្រាប់ឲ្យរំឭកចាំបាន) រួចនឹករឭកតៗទៅ ទាល់តែដល់ភពដែលកន្លងមកហើយ ។

†††

††

†

# វិជ្ជាប្រការទី ៧

## ទិព្វចក្ខុ

ទិព្វចក្ខុនេះជាវិជ្ជាធំបំផុត ហើយជាទីសំគាល់ដ៏សំខាន់ក្នុងសៀវភៅនេះ បានជារៀបរាប់ឲ្យពិស្តារជាងវិជ្ជាឯទៀតបន្តិច។

តាមធម្មវិភាគបរិច្ឆេទទី២ ពោលជានិទ្ទេសទុកក្នុងពួកវិជ្ជាទី ៣ឲ្យឈ្មោះថាចុតូបបាតញ្ញាណ គឺមានចក្ខុទិព្វបរិសុទ្ធលើសចក្ខុមនុស្សសាមញ្ញ មើលឃើញពពួកសត្វកំពុងចុតិ កំពុងកើត ជាសត្វថោកទាបឧត្តមមានពណ៌សម្បុរស្រស់ មិនស្រស់ នឹងបានសេចក្តីសុខឬទុក្ខក៏ដឹងបាន ហើយដឹងឃើញច្បាស់នូវពួកទាំងនោះអន្ទោលទៅតាមកម្ម។ សម្តេចព្រះមហាសមណៈ ទ្រង់ប្រៀបប្រដូចនូវការដឹងសាវតារបស់មនុស្សដទៃ រួចទ្រង់អធិប្បាយតទៅថា "ដែលប្រារព្ធដល់សត្វវិលកើតវិលស្លាប់នោះ ដូចគ្នានឹងបុព្វេនិវាសានុស្សតិញ្ញាណ ប្រារព្ធខ្លួនតាមនិទ្ទេស ថែមប្រារព្ធនូវគតិនៃសត្វទាំងនោះផង មើលទៅសម្តែងនោះមិនមែនតែត្រឹមវិលកើតវិលស្លាប់ដែលជាគតិធម្មតានោះទេ សេចក្តីថាប្រព្រឹត្តទៅដោយអំណាចកម្មក៏ជាគតិនៃធម្មតាដូចគ្នាដែរ។ ញាណនេះលោកពោលថា កំចាត់មោហៈដែលកំបាំងកម្មស្សកតា នឹងពោលថាកំចាត់នូវមោហៈ ដែលជាហេតុជឿប្រកាន់ដោយគ្មានហេតុ ដូចជាសីលព្វតបរាមាសនឹងមិច្ឆាទិដ្ឋិក៏បាន ចាត់ជាអង្គនៃព្រះសម្មាសម្ពោធិញាណក៏គួរដែរ ។

បណ្តាអវយវៈទាំងអស់ ភ្នែកជារបស់សំខាន់ជាងអវយវៈទៀត គឺប្រើបានជាប្រយោជន៍ច្រើនជាងអវយវៈដែលមាននៅក្នុងកាយ យើងហើយជារបស់សំរាប់សម្តែងឲ្យឃើញនិស្ស័យ ចិត្តថ្លើមនឹងសេចក្តីប្រព្រឹត្តរបស់មនុស្សជាគ្រឿងដៃដ៏ប្រសើរ ដែលមនុស្សត្រូវការប្រើបាន មិនត្រឹម

តែកិច្ចការដែប្រចាំថ្ងៃនោះទេ ជាគ្រឿងជួយឲ្យសម្រេចសេចក្តីបំណងក្នុងការផ្សេងៗ បានច្រើនយ៉ាងទៀត ។

យើងដឹងថាភ្នែករបស់យើងរាល់គ្នាមាន៣ ពណ៌ៗ សនៅជុំវិញខាងក្រៅរួចពណ៌ ស្ករ ឬពណ៌ស្ទើរខ្មៅ ភ្នែកបាវាំងជាពណ៌ ស្ករខ្ចី ឬពណ៌ផ្ទៃមេឃក៏ថាបាន ដែលជាប្រយោជន៍ហើយជាសំខាន់បំផុត គឺចុចខ្មៅនៅកណ្តាលប្រស្រីភ្នែកដែលយើងហៅថាភ្នែក ឯត្រង់ជុំវិញនោះទុកជាត្រូវរបួសដល់ចេញឈាមក៏មិនខ្វាក់ បើត្រូវរបួសបន្តិចបន្តួចត្រង់កែវភ្នែកហើយក៏អាចខ្វាក់បាន បានជាធម្មជាតិបង្កើតឲ្យមានរោមភ្នែកមកជាមួយសម្រាប់ការពារវេលាមានអ្វីមកប៉ះពាល់ នឹងប៉ះរោមភ្នែកជាមុនភ្នែក៏នឹងប៉ប្រិចឲ្យរួចពីត្រូវរបួសបាន ក៏ដោយសាររោមភ្នែកជួយការពារដែលថាភ្នែកជាប្រយោជន៍របស់រាងកាយជាច្រើនបំផុតនោះ ពីព្រោះភ្នែកជាគ្រឿងសម្រាប់មើល រកចំណេះចេះដឹងទាំងពួងមកការពារខ្លួនបានមនុស្សថ្លង់នៅមានគ្រោះល្អជាងមនុស្សខ្វាកជាច្រើន ឧបមាដូចមនុស្សភ្នែកខ្វាក់ពីកំណើត មិនស្គាល់រូបរាងមុខមាត់មាតាបិតាបង្កើតនោះដូចម្តេចសោះគ្រាន់តែដឹងសណ្ឋានដូចជាដឹងនូវសណ្ឋាន គោ ក្របី ដំរី សេះ ដោយមានមនុស្សពន្យល់ឲ្យស្តាប់ ព្រោះគ្មានអ្នកប្រាជ្ញណាមួយក្នុងលោកចេះដឹងអធិប្បាយឲ្យមនុស្សខ្វាក់ភ្នែកពីកំណើត ស្គាល់លក្ខណៈពណ៌ទាំងនោះបាន ហេតុដូច្នេះមនុស្សខ្វាក់នោះក៏នឹងចូលចិត្តថា សម្បុរពណ៌ក៏ដូចជារូបសត្វទាំងនោះដែរ ឬមួយវិញទៀត គ្រាន់តែដឹងថាភ្លើងជារបស់ក្តៅ ដីជារបស់រឹង ទឹកជារបស់ជ្រាយ តែនឹងស្គាល់រូបសម្បុររបស់ធាតុទាំងនោះជាយ៉ាងណាពុំបានឡើង ហេតុនេះឯងបានជាថាមនុស្សខ្វាក់ពីកំណើត ទុកជាមនុស្សមានគ្រោះធ្ងន់ជាបំផុត ព្រោះខាតផ្លូវចេះដឹងក្នុងលោកនេះពាក់កណ្តាល ឬក៏ច្រើនជាងពាក់កណ្តាលក៏មាន។

ដែលថាភ្នែកជាគ្រឿងសម្តែងឲ្យស្គាល់ឃើញនិស្ស័យ ចិត្តថ្លើមនឹងសេចក្តីប្រព្រឹត្តនឹងលក្ខណៈផ្សេងៗរបស់មនុស្សនោះ គឺថាបើយើងសង្កេតមើលឲ្យល្អហើយ នឹងឃើញថាភ្នែកមនុស្សម្នាក់ៗខុសគ្នាជាច្រើន ដែលជាសំខាន់បំផុតគឺចុចកណ្តាលដែលហៅថាកែវភ្នែក មនុស្សឆ្លាតច្រើនមានកែវភ្នែកធំ មនុស្សល្ងង់កែវភ្នែកច្រើនតូច មនុស្សដែលអាចពង្រីកកែវភ្នែកឲ្យធំ ឬក៏ឲ្យតូចបាននោះ ជាអ្នកមានលក្ខណៈអត់ធ្មត់មាំមួន ជាមនុស្សមានសេចក្តីព្យាយាមឧស្សាហ៍មិនញញើតខ្លាចសេចក្តីលំបាក ហើយមិនខ្លាចក្រែងអ្នកណា អាចប្រើមនោមយិទ្ធិយ៉ាងទាប ឬយ៉ាងកណ្តាល ជាគ្រឿងបង្គាប់មនុស្សដែលនៅក្នុងអំណាច ឲ្យជឿស្តាប់បានដោយងាយ។ មនុស្សដែលមិនហ៊ានមើលភ្នែកគេត្រង់ៗ កំពុងនិយាយនោះ ជាមនុស្សមាននិស្ស័យទន់ ខ្លាច ធ្វើអ្វីមិនប្រាកដ បើមិនដូច្នោះទេ ក៏ជាមនុស្សស្លូតតែចិត្តវៀច គង់មានសេចក្តីខុសអ្វីជាប់នឹងខ្លួន ។

ហេតុនេះ បានជាបារាំងគេប្រកាន់យ៉ាងមាំមួន ថាកាលណាចាប់ដៃគ្នាឬធ្វើសេចក្តីគោរពគ្នាទៅវិញទៅមក ត្រូវតែមើលភ្នែកគ្នាដរាប បើមិនធ្វើដូច្នេះទេ គេប្រកាន់ថាជាកិរិយាថោកទាបបំផុត ។ វេលានិយាយនឹងអ្នកមានបណ្តាស័ក្តិធំ ឬស្តាប់លោកនិយាយត្រូវមើលភ្នែកលោក បើដាក់ភ្នែកសញ្ចប់សញ្ចឹងមើលខាងក្រោម មិនសំឡឹងមើលមាត់លោកនិយាយឬក៏មើលទៅឯទៀត ក៏ចាត់ជាអគារវៈ មិនជាទីគោរព។ បើជាទាហានគេមានច្បាប់បង្គាប់ទុកជាស្រេចថា ក្នុងវេលាធ្វើការគោរពត្រូវមើលភ្នែកអ្នកធំជាងខ្លួន អ្នកណាដែលក្រឡេកមើលណេះមើលណោះ ទុកជាមនុស្សមិនបរិសុទ្ធ គង់មានអ្វីម្យ៉ាងៗដែលប្រព្រឹត្តមិនល្អលាក់ទុកក្នុងខ្លួនព្រោះហេតុនេះឯងបានជាគ្រឿងសម្តែងឲ្យឃើញពិរុទ្ធរបស់មនុស្ស ដែលធ្វើខុសទទួលទោសជារឿយៗ ។ កាលណាយើងចូលទៅរកលោកអ្នកមានបណ្តាស័ក្តិធំៗ យើងគង់ឃើញភ្នែកលោកសំឡឹងមើលត្រង់មកភ្នែកយើង

យើងត្រូវឲ្យដឹងថាដែលលោកសំឡឹងមកយើងនោះ លោកមិនសំឡឹងមើលដោយឥតប្រយោជន៍ទេ លោកព្យាយាមមើលនិស្ស័យចិត្តថ្លើមនឹងសេចក្ដីចំណង់របស់យើងក្នុងវេលានោះផង ។ ព្រោះហេតុនេះឯង បានជាក្នុងវេលាកំពុងនិយាយការអ្វីៗនឹងលោក លោកអាចស្កាត់និយាយប្រាប់ឲ្យត្រូវនឹងចិត្តយើង ដែលយើងបំរុងនឹងនិយាយតទៅទៀតនោះ មកតែពីភ្នែកយើង ជាគ្រឿងសម្ដែងឲ្យលោកឃើញពីសេចក្ដីនិយាយល្អអាក្រក់ពិតមិនពិតល្ងង់ខ្លៅឆ្លាតមិនឆ្លាត យ៉ាងណាៗបាន ។ សេចក្ដីខុសត្រូវអាចលាក់ទុកក្នុងចិត្តដោយវិធីផ្សេងៗ បាន តែភ្នែកនោះនឹងនាំយកសេចក្ដីដែលលាក់ទុកនោះមកបង្ហាញឲ្យគេដឹង ។ ដូច្នេះបានជាមនុស្សបរិសុទ្ធប្រាសចាកមន្ទិលក្នុងខ្លួន មិនរន្ធត់ញាប់ញ័រខ្លាច ក្នុងការដែលនឹងសំឡឹងមើលភ្នែកមនុស្សដោយត្រង់នោះសោះ ។

តាមសេចក្ដីអធិប្បាយ ក្នុងមនោមយិទ្ធិ ដែលមានមកហើយខាងដើមនោះ ថាក្រសែគំនិតរបស់មនុស្ស ផ្សាយចេញចាកមនុស្សទៅបានច្រើនផ្លូវ បានជាអ្នកប្រាជ្ញក្នុងវិជ្ជានេះប្រកាន់ដូចគ្នាថា ក្រសែទាំងនោះចេញតាមភ្នែកជាច្រើនបំផុត បានជាមនុស្សយើងប្រើភ្នែកជាដៃគូដ៏សំខាន់ក្នុងការផ្សាយមនោមយិទ្ធិរបស់ខ្លួន តាមដែលបានសង្កេតមើលក្នុងទីប្រជុំធំៗ ដែលនានាប្រទេសក្នុងលោក បញ្ជូនមន្ត្រីទៅនិយាយការជំនួសនោះ ឃើញបណ្ដាលោកដែលមានកេរ្តិ៍ឈ្មោះជាមន្ត្រីឆ្លាតបំផុតក្នុងលោក វេលានិយាយក្នុងទីប្រជុំ ភ្នែកលោកមិនមើលទៅទីណាឡើយសំឡឹងមើលទៅតែអ្នកស្ដាប់ដូចជាគេខ្វេះយកនូវដួងចិត្តរបស់អ្នកស្ដាប់មកញាំញី បង្គាប់ឲ្យជឿតាមដែលលោកនិយាយនោះឯពួកដែលគ្មានឈ្មោះ ល្បីល្បាញខាងនិយាយការអ្វីឲ្យល្អជាវិសេសនោះ វេលានិយាយច្រើនងើយមើលពិតានមើលសំបុត្រឬមើលបាតដៃរបស់ខ្លួន សម្ដីរបស់ពួកនេះទុកជានិយាយឆ្លាតបំផុត ក៏គ្មានទម្ងន់ល្មមធ្វើឲ្យមនុស្សជឿបានជាច្រើនដែរ បើ

យើងព្យាយាមសង្កេតមើលភ្នែករបស់លោកដែលមានអំណាចវាសនា នឹងឃើញចុចកណ្ដាលប្រស្រីភ្នែករបស់លោក ធ្វើឲ្យធំឬតូចបាន តាមហេតុការណ៍ដែលនិយាយនោះ បើក្នុងវេលានិយាយសប្បាយរីករាយនឹងគ្នា លោកទើបឃើញចុចក្នុងលោកតូច តែដល់និយាយការឬមានបង្គាប់យ៉ាងណាៗនឹងឃើញចុចនោះរីកធំឡើង បើកំពុងខឹងផងទៀត ចុចនោះក៏កាន់តែរីកធំបំផុតទៅទៀត ទាល់តែពណ៌កែវភ្នែកអមជុំវិញនោះតិចទៅ។ ពួកស្នាក្ដីដែលល្បីឈ្មោះក្នុងអឺរ៉ុប ដែលមានរង្វង់ភ្នែកកណ្ដាលពណ៌ផ្ទៃមេឃមកពីកណើតនោះ ដល់វេលានិយាយអធិប្បាយរឿងក្ដីសំខាន់ៗ នឹងឃើញកែវភ្នែកខ្មៅទាំងអស់ពណ៌ផ្ទៃមេឃដែលនៅជុំវិញនោះក៏បាត់ ទៅនៅសល់តែពណ៌ខ្មៅកណ្ដាលនឹងជុំវិញ។ ហេតុទាំងនេះមកពីមានសេចក្ដីប្រាថ្នាខ្លាំង ក្រសែមនោមយិទ្ធិនោះផ្សាយចេញមកតាមភ្នែកយ៉ាងខ្លាំង ក្រសែមនោមយិទ្ធិនោះផ្សាយចេញមកតាមភ្នែគយ៉ាងខ្លាំងបំផុត ដោយនិយាយអធិប្បាយសេចក្ដី ចង់ឲ្យតុលាការជឿថាក្ដីរបស់ខ្លួនមានល័ក្ខខ័ណ្ឌល្អជាងគូក្ដីម្ខាង អ្នកដែលដំណាងការនគរ វេលាដែលត្រូវការនិយាយឲ្យពួកសមាជិក ក្នុងរដ្ឋសភាទាំងអស់ ឲ្យយល់ឃើញព្រមតាមសេចក្ដីគិតរបស់ខ្លួននោះ ត្រូវប្រើអណ្ដាតរបស់ខ្លួនជាដាវយ៉ាងមុត កាប់ឆ្កាសេចក្ដីយល់របស់អ្នកម្ខាង ឲ្យរលំដួលព្រមយល់តាមខ្លួននិយាយ ដែលជាការប្រយោជន៍ ហើយឲ្យមានប្រៀបដល់ប្រទេសរបស់ខ្លួនផងនោះក្ដី ។ អ្នកដែលគ្រប់គ្រងមនុស្សច្រើន ដូចជាមេកម្មករដែលព្យាយាមបញ្ចុះបញ្ចូលឲ្យមនុស្សធ្វើការដ៏មានចំនួនរាប់ពាន់ កំពុងបោះបង់ចោលការទៅនោះ ឲ្យត្រឡប់ចូលមកធ្វើការវិញក្ដី ពួកទាំងនេះបានប្រើភ្នែក ជាគ្រឿងដៃដ៏ប្រសើរក្រៃលែងជាងសស្ត្រាវុធទៀត តាមដែលពុទ្ធនិយាយថា មនុស្សដែលប្រទះនឹងខ្លាទាល់ច្រករករត់ទៅណាពុំបាន បានសំឡឹងមើលភ្នែកវាមិន

បំប្រិចភ្នែកអាចធ្វើឲ្យចៀសចេញ មិនហ៊ានធ្វើអ្វីបាននោះ គួរជឿថាមានប្រាកដមែន ។

តាមដែលពណ៌នាមកនេះគឺពោលអំពីលក្ខណៈនឹងគុណប្រយោជន៍របស់ភ្នែកមនុស្សប្រក្រតី មិនទាន់ចូលក្នុងគោលទិព្វចក្ខុទេ តាមដោយពិតនោះ រឿងនេះគួរពណ៌នាទុកក្នុងមនោមយិទ្ធិ ច្រើនជាងពោលទុកក្នុងទីនោះ ឥឡូវនេះនឹងបានបរិយាយដល់លក្ខណៈភ្នែកទិព្វ ដែលបាននាមហៅថា "ទិព្វចក្ខុ" ជាវត្ថុសំខាន់ក្នុងសៀវភៅនេះតទៅ ។

ទិព្វចក្ខុនេះត្រូវនឹងបារាំងហៅថា (Clairvoyance) តែបារាំងរួមយកញាណទាំង ៣ គឺអតីតំសញ្ញាណ ញាណក្នុងចំណែកអតីត អនាគតំសញ្ញាណ ញាណក្នុងអនាគតនឹងបច្ចុប្បន្នំសញ្ញាណ ញាណក្នុងបច្ចុប្បន្នទាំង៣ប្រការនេះនៅក្នុងចំណោមទិព្វចក្ខុ បើតាមនិទ្ទេសរបស់យើងមើលទៅសំដៅដល់ការ ឃើញកន្លងហួសចក្ខុរបស់មនុស្សធម្មតា ដូចដែលមានពោលមករាងដើម ថាមើលធ្លុះដី។ល។ (Clairvoyance) បើយើងយកមកប្រៀបគ្នាហើយ ក៏នឹងចុះតាមគន្លងជាមួយបាន គឺថាបើអាចមើលឃើញ សត្វកំពុងចុតិបានហើយ មិនគួរសង្ស័យនឹងការដែលថាអាចមើលឃើញ អតីត អនាគត បានយ៉ាងច្បាស់ល្អនោះឡើយដោយហេតុនេះបានជាថាការដែលនឹងអធិប្បាយដល់ទិព្វចក្ខុនោះ នឹងបាននាំយកគំនិតរបស់បារាំង នឹងគោលក្នុងនិទ្ទេសរបស់យើងមករួមគ្នា ឲ្យលោកអ្នកមើលវិនិច្ឆ័យប្រៀបធៀបទាំងពីរផ្លូវមើល។

វិទ្យាសម្រាប់ដឹងអតីតនឹងទំនាយនូវអនាគតបាននោះ ជារបស់បានផ្សាយមកក្នុងលោកមនុស្សបានចេះដឹងមកក្នុងលោកជាច្រើនបំផុត គឺហោរាសាស្ត្រ ពោលគឺលទ្ធិដែលប្រកាន់ថា មនុស្សយើងកើតមកនៅក្រោមអានុភាពរបស់ដួងផ្កាយទាំងឡាយ នឹងបានល្អឬអាក្រក់ដោយប្រការយ៉ងណា ក៏ស្រេចហើយតែផ្កាយជាដើមហេតុ។ មានន័យមួយទៀត

ប្រកាន់ថា មនុស្សយើងកើតមកមានបកាសិតរបស់ព្រះនៅខាងលើបំផុត ត្រាទំនាយទុកមកហើយនឹងបានល្អ អាក្រក់យ៉ាងណា តោងទៅតាមបកាសិតនោះ ។ លទ្ធិដែលពណ៌នាមកខាងដើមនោះ មានមូលជាសេចក្ដីពិតប្រាកដជាច្រើន បានជាមានអ្នករៀន ចំឡងជាតម្រាក្បួនផ្សាយចេញទៅគ្រប់ប្រទេស ព្រោះសេចក្ដីនិយមមិនទាន់សាបសូន្យ បានជាមានមកដល់ឥឡូវនេះ ។ រឿងនេះយើងល្បងពិចារណាមើលលទ្ធិនេះមានខដែលមិនស្រួល គួរឲ្យសង្ស័យនោះដោយមានបញ្ហាយ៉ាងណាខ្លះ? តាមសេចក្ដីយល់ឃើញនោះដូច្នេះគឺ :

១- មានខដែលមិនស្រួលច្រើន គឺត្រូវឲ្យបានថ្ងៃខែឆ្នាំនឹងពេលវេលាដែលកើតឲ្យត្រឹមត្រូវប្រាកដជាបំផុត ទើបគន់គូរទំនាយត្រឹមត្រូវបាន ហេតុនេះបានជាមនុស្សក្នុងលោកនេះ មួយសែននាក់មានប្រហែលមួយនាក់ ដែលអាចដឹងចាំពេលវេលាកំណើតរបស់ខ្លួនជាប្រាកដបាននោះ បើមនុស្សដែលនៅឆ្ងាយ ផុតពីសូរកាំភ្លើងបាញ់យាម ហើយគ្មានទាំងនាលិកាដែលដើរត្រឹមត្រូវទៀត ក៏មិនអាចដឹងពេលវេលាដែលខ្លួនកើតឲ្យបានត្រឹមត្រូវឡើយ បានជាអ្នកចេះវិជ្ជាហោរាសាស្រ្ត ថាការដែលទាយខុសនោះមកពីពេលវេលាកើតមិនទៀងត្រឹមត្រូវប្រាកដ(១) ។

២- គួរសង្ស័យនោះ គឺមនុស្សដែលកើតមក បានជាស្ដេចសោយរាជសម្បត្តិ ឬជាមហាសេដ្ឋី ហើយមនុស្សដែលកើតក្នុងពេលវេលាឆ្នាំ ខែ ថ្ងៃ ដូចគ្នា ឬក៏ពេលវេលានាទីប្រកិតគ្នា ល្មមនៅក្នុងពេលទំនាយជាមួយគ្នាបាន តើមនុស្សនោះនឹងបានជាស្ដេចសោយរាជ្យ ឬជាមហាសេដ្ឋីទៅទាំងអស់បានឬទេ? (២) ។

---

(១) មានគេអធិប្បាយថា អាចយករូបពណ៌សម្បុរសរបស់បុគ្គលមកជាគ្រឿងត្រួតមើលឲ្យដឹងវេលាកើតខុសឬត្រូវបាន។

៣- មនុស្សដែលមានអំណាចស័ក្តិខ្ពង់ខ្ពស់បំផុត ដែលមានឈ្មោះក្នុងពង្សាវតាររបស់លោក ដូចជា ណាប៉ូឡេអុង សេសារ អាឡេកសង្រ្គឹម មហារាជ ទាំងនេះ ដួងជតាល្អគ្រប់អង្គឬអ្វី?

៤- មនុស្សដែលដឹងថា ដួងជតារបស់ខ្លួនអាក្រក់ហើយព្យាយាមប្រព្រឹត្តតែសេចក្តីល្អ មិនធុញថប់នឹងសេចក្តីលំបាក ដូច្នេះតើនឹងមានឱកាសបានល្អខ្លះដែរឬទេ? ឬមនុស្សដែលដឹងច្បាស់ថា ដួងជតារបស់ខ្លួនល្អ តែប្រហែលខ្លួនមិនធ្វើការអ្វីសោះ ប្រព្រឹត្តជាមនុស្សពាលទៅនោះតើនឹងបានល្អដូចដួងជតានោះដែរឬទេ ?

៥- លទ្ធិដែលប្រកាន់ថា មនុស្សយើងកើតមក មានបកាសិតរបស់ព្រះខាងលើបំផុត ត្រាទំនាយទុកមកនោះ នឹងថាត្រូវឬខុសក៏តាមចុះ តែលទ្ធិបែបនេះមើលទៅមិនសូវល្អ ព្រោះនឹងនាំឲ្យមនុស្សខ្ជិលមិនចង់ធ្វើការអ្វីៗ ដោយគិតឃើញថាទុកជាធ្វើទៅក៏មិនបានជាល្អ ព្រោះដួងជតាទំនាយថាអាក្រក់ ម្យ៉ាងទៀត ហោរទាយថាល្អ ក៏នឹងថាលាភផលទាំងពួងនឹងមានមកឯងៗ មិនចាំបាច់ធ្វើការអ្វីឡើយ។ ក្នុងលោកនេះយើងគង់ប្រទះឃើញ មានមនុស្សជាច្រើនដែលខ្ជិលជាប្រក្រតីមិនធ្វើការរកស៊ីអ្វី ដើរតែបន់ស្រន់អ្នកតា នឹងរកហោរទាយឲ្យ បើឮទំនាយទាយថានឹងមានបុណ្យឬនឹងមានលោភ ក៏ត្រឡប់មកផ្ទះទ្រាំអត់ឃ្លានចាំបុណ្យនឹងលាភ មិនធ្វើការអ្វី បើឃ្លានណាស់យកទឹកវិតពោះ រង់ចាំពេលវេលាជោគលាភតាមទំនាយដែលថានឹងមានមកនោះ ចាំទៅមិនឃើញមានបានអ្វី ក៏ជេរប្រទេចផ្តាសាអ្នកតានឹងហោរថាកុហក ឬក៏នឹករេរីវាយឃើញទៅជាមាន

---

(២) មានអ្នកដែលបានមើលសៀវភៅវិជ្ជ៨ ប្រការដែលបោះពុម្ពគ្រាមុនអធិប្បាយថាថ្ងៃកំណើតតែម្យ៉ាង នឹងធ្វើឲ្យមនុស្សល្អដូចគ្នាពុំបាន តោងយកឋានផ្សេងមកប្រកបជាមួយប្រដូចនូវស្មៅដុះលើភ្នំ ទុកជាដូចម្តេច ក៏គង់ខ្ពស់ជាងដើមត្នោត ដែលដុះតាមជើងភ្នំដែរ។

មនុស្សឈ្នានីស បានជាមិនបានលាភ ក៏កើតចិត្តវិបល្លាស គិតស្វែងរកលាភដោយមិនប្រកបនឹងធម៌វិញ អកុសលក៏តាមមកដល់ឲ្យផលទៅជាអាក្រក់ខុសទំនាយ ។

តាមដែលពណ៌នាមកទាំង៥ ប្រការនេះ មិនមែនមើលងាយដោយមិនចង់ជឿលទ្ធិហោរដែលមនុស្សក្នុងលោកបានរាប់អានមកយូរ ហើយនោះទេ វិជ្ជាហោរគួរជឿណាស់ ព្រោះមានខ្លះទំនាយទាយត្រូវជាច្រើន តែតាមប្រក្រតីត្រូវលើមនុស្សយ៉ាងកណ្ដាល គឺមនុស្សដែលមានព្យាយាមធម្មតា មានសេចក្ដីប្រព្រឹត្តិល្អគួរសម គ្មានចិត្តទុច្ចរិតក្នុងខ្លួន មិនបានធ្វើសេចក្ដីល្អដ៏វិសេសអ្វីឲ្យបានច្រើនផង ទំនាយច្រើនត្រូវមនុស្សបែបនេះ ព្រោះមនុស្សយើង គង់មានឆ្នាំខែណាមួយប្រែប្រួលនិស្ស័យចិត្ត ប្រព្រឹត្តឲ្យល្អឡើង ឬក៏អាក្រក់ទៅក៏មានជាច្រើន។ បានជាបកាសិតរបស់ព្រះខាងលើបំផុតនោះ បើមានពិតប្រាកដមែន តើនឹងប្រែប្រួលបានទៅខ្លះដែរឬទេ[១] ?

វិជ្ជាដឹងអតីតទំនាយទាយទៅអនាគតនេះ ជាវិជ្ជាគួរនិយមណាស់ បើមនុស្សយើងចម្រើនក្នុងវិជ្ជាមួយនេះ ដល់ទៅប្រើការបានជាពិតប្រាកដហើយ ក៏អាចនឹងធ្វើប្រយោជន៍ឲ្យលោកបានជាច្រើនណាស់ ដោយហេតុនេះនឹងព្យាយាមអធិប្បាយតាមគោលរបស់ទិព្វចក្ខុល្បងមើល ដើម្បីបើកផ្លូវជូនលោកអ្នកមើលសៀវភៅ ត្រិះរិះគិតស្រាវជ្រាវរកតទៅ សេចក្ដីដែលនឹងអធិប្បាយនេះ មិនបានគិតសង្កត់សង្កិនវិជ្ជាហោរាស្ដ្រឬក៏នឹងគិតលើកចំទួយសេចក្ដីដែលនឹងពោលតទៅនេះ ថាខ្ពស់ខ្ពស់លើសវិជ្ជាហោរក៏ទេ គ្រាន់តែអធិប្បាយទុកជូនលោកអ្នកមើលពិនិត្យកាត់សេចក្ដីដោយខ្លួនឯងតែប៉ុណ្ណោះ ។

តាមក្នុងវិជ្ជាទិព្វចក្ខុ (Clairvoyance) របស់បារាំងនឹងយោគីគេមានគោលថា :

១) របស់អ្វីដែលមានមកពីអតីតហើយនោះ គង់មានចោលស្នាម លំអានទុកឲ្យក្នុងបច្ចុប្បន្ននេះដឹងបានជាដរាប ។

២) របស់អ្វីដែលនឹងមានមកក្នុងកាលខាងមុខ ច្រើនមានជាស្រ-មោមកឲ្យឃើញជាមុន ឬមានក្រសែមកឲ្យដឹងជាមុន ។

៣) របស់អ្វីកំពុងធ្វើ ច្រើនមានជាស្រមោលឲ្យឃើញមានការក្នុងមួយអន្លើទៀត ។

ហេតុនេះឯង បានជាមានសេចក្ដីអធិប្បាយពីគោលទាំង៣ ប្រការទុក ដូចមានតទៅ :

១- ដែលថារបស់អ្វីធ្លាប់មានពីអតីតមកហើយ គង់ចោលស្នាមទុកឲ្យក្នុងបច្ចុប្បន្នដឹងបាននោះ គឺថាមនុស្សធម្មតាគ្រប់គ្នាដែលបានប្រទះរបស់ចាស់ៗ ច្រើនមានមនោគតិ ឃើញហេតុការណ៍ដែលមានមកក្នុងគ្រានោះៗ បើទៅមើលបុរាណវត្ថុឬក្រុងចាស់ៗ ដែលចោលមកអង្វែងឆ្នាំហើយនោះ យើងគង់មានចេតសិករឭកឃើញមួយរំពេច ពីជីវិតនឹងការដែលកន្លងទៅហើយរបស់មនុស្សក្នុងសម័យនោះ អ្នកដែលគេចេះស្ទាតក្នុងវិជ្ជានេះគេគ្រាន់តែរើសយកដុំក្រួសឬដុំថ្មមួយដុំពីស្ថានបុរាណ មកក្ដាប់ទុកក្នុងដៃ ហើយអាចប្រាប់ថារបស់ទាំងនោះ មានមកហើយក្នុងសម័យនោះៗបាន ដោយក្រសែដែលជាប់នូវវត្ថុនោះមកប៉ះពាល់ដៃមនុស្សដែលចេះវិជ្ជានេះ ឲ្យមានជាសម្ពស្សដល់កាយៗអាចរាយការតទៅចិត្តឲ្យដឹងជារឿងឡើងបានមួយរំពេច ។

២- ត្រង់ថារបស់អ្វីដែលនឹងមានមកដល់អនាគត ច្រើនមានជាស្រមោលមកមុន ឬមានជាក្រសែមកឲ្យដឹងជាមុននោះ គេប្រៀបសេចក្ដីដូចជាប៉ាល់ធំៗ ដែលកំពុងបើកទៅ តែងតែមានរលកក្នុងទឹកផាត់ទៅមុនមុខកប៉ាល់ដរាប ពួកដែលរកស៊ីចាប់ត្រីក្នុងសមុទ្រតែងតែដឹងហេតុជាមុនប្រុងខ្លួនរត់ ឬប្រុងតដៃឲ្យទាន់ ក្នុងវេលាដែលមានត្រីធំមក ដោយឃើញ

រលកផាត់ខុសពីប្រក្រតី ហេតុការណ៍ទាំងឡាយក្នុងលោកនេះតែងតែមានកម្លាំងនឹងអំណាចសំខាន់ ច្រើនជាងត្រីនឹងកប៉ាល់ទាំងនោះតាមប្រក្រតីភ្នែកយើងមើលមិនឃើញថា ក្នុងអាកាសដែលស្រឡះទូលាយឆ្ងាយល្វឹងល្វើយហួសភ្នែកយើងនោះមានអ្វីនៅខ្លះ បើប្រសិនជាយើងមានភ្នែកបែបដូចជាទិព្វចក្ខុហើយ យើងក៏នឹងមើលឃើញហេតុការណ៍ឬរបស់ផ្សេងៗ ដែលអណ្ដែតហួសទៅក្នុងចក្រវាឡ ដែលមានរបស់សុទ្ធតែគួររៀនឲ្យដឹងស្គាល់ណាស់ ។

តាមគម្ពីរព្រះពុទ្ធសាសនាយើង ដែលព្រះគន្ថរចនាចារ្យលោកពោលទុក ថាទេវតាមកស្ដាប់ធម៌ទេសនា របស់ព្រះពុទ្ធជាម្ចាស់ជាច្រើនណាស់ ទាល់តែចង្អៀតណែនក្ដន់ រកកន្លែងអង្គុយស្ដាប់គ្មាន តោងនិម្មិតខ្លួនឲ្យតូចប៉ុនធូលី ប្រជៀតស្ដាប់ព្រះធម៌ទេសនា។ បើជាសេចក្ដីដែលលោកចរិកទុកមកនោះ មិនបានពោលតែត្រឹមមនោគតិទេ ហើយបានឃើញនូវទេវតាទាំងនោះ ប្រហែលឃើញដោយផលនៃវិជ្ជាទិព្វចក្ខុមួយនេះដែរឬដឹង ?

៣- ត្រង់ដែលថារបស់អ្វីកំពុងធ្វើ អាចមានជាស្រមោលឲ្យឃើញប្រាកដមួយអន្លើទៀតបាននោះ បារាំងឲ្យឈ្មោះថា (Deuxieme vue) សេចក្ដីអធិប្បាយរឿងនេះបែបដូចគ្នានឹងរឿងប្រផ្នូលចៃដន់ ដែលបានពោលមកហើយខាងដើម បានជាមិនបាច់អធិប្បាយក្នុងទីនេះតទៅទៀត ។

រឿងនេះសមាគមស្វែងរកចំណេះវិជ្ជាដួងចិត្ត (Societe des rech-Erches psychiques) ដែលតាំងនៅក្រុងឡុនដុន បានឲ្យបែបទុកពីរយ៉ាង សម្រាប់ពិសោធត្រង់ប្រការ២ នឹងប្រការ៣ ដែលយើងគួរនាំយកមកពីគ្រោះពិចារណាមើល ឲ្យឃើញសេចក្ដីពិតនោះតើមានត្រឹមណា សុំឲ្យលោកអ្នកមើលជ្រាបជាមុនថា សមាគនេះបានតាំងមកជាយូរឆ្នាំហើយ

សមាជិកនឹងកម្មការសុទ្ធតែអ្នកប្រាជ្ញដែលមានកេរ្តិ៍ឈ្មោះក្នុងលោក។ ពួកសេដ្ឋីគហបតីឃើញនូវគុណប្រយោជន៍របស់សមាគមនេះ បានជួយចេញប្រាក់ឲ្យជាច្រើន សម្រាប់ទំនុបបំរុងក្នុងការស្រាវជ្រាវរកវិជ្ជានេះដើម្បីផ្សាយក្នុងលោកនឲ្យចេះដឹងច្រើនឡើង ដោយហេតុនេះបានជាមុខងាររបស់សមាគមនេះ ត្រូវរក្សាកេរ្តិ៍ឈ្មោះ មិននាំយករឿងផ្តេសផ្តាសប្រាសចាកមូលនៃសេចក្តីពិត មកពោលបញ្ឆោតមហាជនឡើយ បែបយើងដែលគេទុកសម្រាប់ឲ្យពិសោធត្រង់ប្រការ២ នោះមានដូច្នេះថា :

ក្នុងស្រុកអង់គ្លេស៍ មានស្រ្តីម្នាក់ឈ្មោះហ៍នណាហ៍គ្រីន នៅតំបន់ឱកសហ្វរ៍តឈា ក្នុងប្រទេសអង់គ្លេស៍ មានរបរជាអ្នកស៊ីឈ្នួលបំរើនៅផ្ទះ១ មានយប់មួយដេកយល់សប្តិឃើញថា ខ្លួននៅក្នុងផ្ទះតែម្នាក់ឯងក្នុងថ្ងៃអាទិត្យវេលាយប់ បានឮសូរមនុស្សគោះទ្វារ ក៏បើកចេញទៅមើលមានចោរ ៣ - ៤ នាក់រត់ចូលមកក្នុងផ្ទះ ខ្លួនក៏បានព្យាយាមការពារៗ មិនឈ្នះក៏ត្រូវរបួសរបស់ចោរដល់សន្លប់ ហើយចោរក៏យកទ្រព្យដែលមានតម្លៃបានទៅជាច្រើន ដល់ព្រឹកឡើងក៏ទៅនិយាយប្រាប់ឲ្យផ្ទះជិតខាងស្តាប់តាមហេតុដែលខ្លួនយល់សប្តិឃើញនោះ ថាខ្លួនបានចាំលក្ខណៈមុខមាត់រូបរាងចោរទាំងនោះជាប្រាកដផង រួចពីនោះមកជាយូរថ្ងៃក៏ពុំឃើញមានហេតុអ្វី ដល់មកថ្ងៃ១ជាថ្ងៃអាទិត្យ ម្ចាស់ផ្ទះនឹងកូនឈ្នួលចេញទៅអស់នៅតែស្ត្រីនោះចាំផ្ទះតែម្នាក់ឯង វេលាពាក់កណ្តាលអធ្រាត្របានឮសូរគោះទ្វារ ស្រ្តីនោះក៏នឹងឃើញដល់សេចក្តីដែលខ្លួនយល់សប្តិនោះ ក៏មិនបើទ្វារគ្រាន់តែមើលទៅតាមបង្អួច ក៏ឃើញចោរមានចំនួននឹងលក្ខណៈរូបរាង ត្រូវនឹងសេចក្តីយល់សប្តិរបស់ខ្លួនជាទីបំផុត ក៏ស្រែកឆោឡោឡើងឲ្យអ្នកស្រុកជួយ ចោរទាំងនោះក៏រត់ទៅវិញអស់ ។

មានរឿងមួយទៀត ជារឿងល្បីល្បាញ គឺរឿងលោកស្ប៉ែនសើពិយែសេវ៉ាល់ ជាសេនាបតីក្រសួងឃ្លាំងប្រទេសអង់គ្លេស៍ ត្រូវមនុស្សលប

សម្លាប់។ មនុស្សនឹងកើតហេតុជាយូរថ្ងៃ មានមនុស្សម្នាក់ឈ្មោះសង់វិល លើយ៉ម្ស៍ ទីលំនៅៗឆ្ងាយពីក្រុងឡុនដន បានឃើញនឹងភ្នែកខ្លួនស្រស់ៗ ដល់៣ដង ដោយមិនបានយល់សប្តិ ថាឃើញមានមនុស្សពាក់អាវពណ៌ខៀវចាស់ អាវកាក់ក្នុងស ចូលទៅសម្លាប់លោកពិឃែសេវ៉ាល់ ក្នុងទីបរិវេណប្រជុំសភារាស្ត្រ ក្រុងឡុនដន។ សង់វីលលើយ៉ម្ស៍ឃើញបុព្វនិមិត្រអាក្រក់យ៉ាងនេះដល់៣ ដងជាប្លែក ដោយខ្លួននឹងមានសតិឆ្គួតវង្វេងវាយក៏ទេ គឺឃើញនឹងភ្នែកស្រស់ៗ ជាហេតុប្លែកបំផុតក្នុងលោក ក៏មានចិត្តមិនសប្បាយ ទៅប្រឹក្សានឹងមិត្រសម្លាញ់ជាច្រើនគិតចូលទៅក្រុងឡុនដន ជំរាបលោកពិឃែសេវ៉ាល់ឲ្យជ្រាប នឹងបានរវាំងខ្លួន តែពួកសម្លាញ់ទាំងនោះ ជាមនុស្សសម័យថ្មី នាំគ្នាសើចចំអកឲ្យវីលលើយ៉ម្ស៍ ថាទៅជឿតាមនិមិត្រផ្តេសផ្តាសដែលឃើញនោះធ្វើអ្វី ក៏ឃាត់មិនឲ្យវីលលើយ៉ម្ស៍ទៅជំរាបលោកសេវ៉ាល់ វីលលើយ៉ម្ស៍ក៏ខានចូលទៅក្នុងក្រុងឡុនដន។ តមកបាន៧ថ្ងៃ លោកពិឃែសេវ៉ាល់ ក៏ត្រូវមនុស្សពាក់អាវពណ៌ខៀវចាស់ អាវកាក់ស បាញ់លោកស្លាប់នៅទីបរិវេណសភារាស្ត្រក្នុងក្រុងឡុនដក ត្រូវដូចវីលើយ៉ម្ស៍បានឃើញមុនថ្ងៃកើតហេតុនោះមែន បើប្រសិនជាគ្មានពួកសម្លាញ់សម័យថ្មី ឃាត់ខាំងហើយលោកពិឃែសេវ៉ាល់ប្រហែលជាមិនស្លាប់ដោយហេតុនេះទេ ទាំងពីររឿងនេះជាបែបយ៉ាងឲ្យឃើញថា ហេតុការណ៍អ្វីដែលនឹងមានឡើង អាចមានស្រមោលមកឲ្យឃើញមុន ឯបែបយ៉ាងក្នុងប្រការទី៣ ដែលថារបស់អ្វីកំពុងធ្វើ អាចមានស្រមោលឲ្យឃើញប្រាកដនៅទីមួយទៀតបាននោះគឺមានសេចក្តីដំណាលថា កាលកន្លងមកជាង៧០ឆ្នាំ ហើយនេះ មានអ្នកប្រាជ្ញជាតិស៊ូអែតម្នាក់ឈ្មោះស្វីដេនបើរគ៍ នៅក្នុងខេត្តកោតេនបើរគ៍ក្នុងប្រទេសស៊ូអែត អ្នកប្រាជ្ញនេះមានផ្ទះមួយកន្លែងទៀត នៅក្រុងស្តុក្ខុល្ម មានមួយថ្ងៃទៅស៊ីលៀងឯផ្ទះសំឡាញ់ជាមួយនឹងគ្នា ១៥នាក់កំពុងស៊ីលៀងស្វីដេកបើរគ៍ ចេះតែក្រវល់ក្រវាយ

ក្រោចេញទៅក្រៅបន្ទប់លៀង រួចត្រឡប់ចូលមក មុខស្លក់ ស្រែកប្រាប់សំឡាញ់ទាំងនោះថា ភ្លើងកំពុងឆេះផ្ទះក្នុងក្រុងស្តុក្ខុល្ម ជិតដល់ផ្ទះរបស់ខ្លួនហើយ រួចក៏ត្រឡប់ចេញទៅក្រៅវិញ យូរបន្តិចក៏ត្រឡប់ចូលមកវិញប្រាប់ថា ភ្លើងរលត់ហើយ នៅតែផ្ទះ៣ ទៀតនឹងឆេះដល់ផ្ទះរបស់ខ្លួន មនុស្សដែលកំពុងស៊ីលៀងទាំងប៉ុន្មាន ក្នុងវេលានោះក៏ឆ្ងល់ណាស់ រឿងនេះក៏ឮខ្ចរខ្ចាយទៅមួយរំពេចថាជារឿងចំឡែក អ្នករាជការរក្សាស្រុកក៏អញ្ជើញស្វីដេនបើរគ៍ទៅពិចារណាសួរកត់តាមហេតុទុក រំលងបានពីរថ្ងៃមានដំណឹងតាមកាសែតពីក្រុងស្តុក្ខុល្ម បរិយាយពីរឿងភ្លើងឆេះដោយពិស្តារត្រូវតាមហេតុដែលស្វីដេនបើរគ៍ ឆ្លើយឲ្យការទុកនៅសាលាស្រុកគ្រប់ប្រការ ។

ការដែលនាំយករឿងទាំងនេះមកសំដែងទុកក្នុងទីនេះ មិនមែនបំណងឲ្យលោកអ្នកមើលជឿថាជាការប្រាកដនោះទេ ទុកគ្រាន់តែជាផ្លូវពិចារណារឮកដល់បែបយ៉ាង ដែលមាននៅក្នុងស្រុកយើង លោកគង់បានឃើញឬបានស្តាប់មកខ្លះ បើលោកមើលមកដល់ត្រង់នេះ លោកគង់ចង់ជ្រាបថា នឹងមើលរបស់ទាំងនោះ ដោយប្រការដូចម្តេចនោះ ដូចមានពោលតទៅ :

វិធីដែលបារាំងនឹងយោគីក្នុងតណ្ឌៀ ប្រើសំរាប់ធ្វើឲ្យកើតទិព្វចក្ខុមើលឃើញរបស់ផ្សេងៗ ក្នុងអតីតអនាគតនឹងបច្ចុប្បន្ននោះមាន ៣វិធីគឺ:

វិធីទី១ - ដោយប៉ះពាល់វត្ថុណាមួយ ដែលជាប់ទាក់ទងនឹងបុគ្គលទីស្ថាន ឬហេតុការណ៍ដែលត្រូវការនឹងជ្រាបនោះ។

វិធីទី២ - ដោយសំឡឹងមើលកែវឬពែងទឹក។

វិធីទី៣ - ដោយសណ្តំខ្លួនឲ្យលក់ បែបចូលឈានរបស់យើង។

ឯវិធីទាំង៣ នេះនឹងនាំយកវិធីទី១ នឹងទី២ មកបរិយាយទុក ដើម្បីជាគ្រឿងសម្រាប់ប្រកបសេចក្តីត្រិះរិះរបស់អ្នកដែលយកចិត្តទុក ដើម្បីវិជ្ជា

នេះខ្លះ តែត្រង់វិធីទី៣ នោះមិនបាននាំយកសេចក្ដីមកបរិយាយទុកព្រោះជាសេចក្ដីពិស្ដារណាស់ តោងធ្វើជាសៀវភៅមួយផ្សេងទៀតបានបើនឹងកាត់បំប្រួញយកតែសេចក្ដីឲ្យបានខ្លីមកចុះក្នុងសៀវភៅនេះ ខ្លាចក្រែងនាំឲ្យលោកអ្នកមើលមិនយល់សេចក្ដីច្បាស់ យកទៅធ្វើតាមនឹងនាំឲ្យអន្តរាយដល់ខ្លួន ព្រោះមានដំណឹងថា មានអ្នករៀនវិជ្ជាសណ្ដំដួងចិត្តដោយមិនយល់ច្បាស់ ហាត់ធ្វើជិតតែនឹងខ្វាក់ភ្នែកជាច្រើន សមនឹងសុភាសិតដែលថា "ចំណេះតិចច្រើនតែអន្តរាយ" ។

ឯវិធីទី១ នឹងទី២ នោះ បើទុកជាយកទៅហាត់ធ្វើតាមក៏គ្មានអន្តរាយ មានតែគុណប្រយោជន៍ ជាគ្រឿងហាត់ឲ្យចាំ ហើយមនោគតិរបស់យើងក៏នឹងល្អឡើង សមាធិទៀតក៏កាន់តែមាំមួនឡើង ព្រោះសេចក្ដីចាំ១ មនោគតិ១ សមាធិ១ ទាំង៣ប្រការនេះ ជាប្រយោជន៍សំរាប់ធ្វើការគ្រប់យ៉ាងបាន ។ ឯវិធីផ្សេងៗដែលមានអធិប្បាយមកនេះ សូមកុំឲ្យលោកអ្នកមើលគិតថា អ្នកតែងសៀវភៅនេះ បានសម្រេចវិជ្ជាទាំងនេះឡើយ វិធីទាំងប៉ុន្មានស្រង់យកតាមតែតម្រារបស់គេដែលបានប្រទះឃើញ ក៏នាំយកមករួបរួមទុកចែកគ្នាមើលតែប៉ុណ្ណោះ ។

ជាន់ដម្បូងរបស់វិធីទី១នោះ គេឲ្យចាប់ធ្វើពីរបស់ដែលងាយជាមុន គឺឲ្យយកចុតហ្មាយចាស់ៗ ដែលមានគេសរសេរមកដល់យើងជាយូរមកហើយនោះ មកក្ដាប់ទុក្នុងបាទដៃរួចព្យាយាមនឹកដល់អ្នកដែលសរសេរនោះ មានរូបរាងលក្ខណៈមុខមាត់និស្ស័យចិត្តថ្លើមដូចម្ដេចខ្លះ វិធីនេះត្រូវព្យាយាមនឹកដល់មនុស្សសរសេរ ដែលយើងស្គាល់ជិតដិតច្បាស់នោះជាមុនរួចសិននឹកដល់មនុស្សដែលយើងស្គាល់ស្រពេចស្រពិលជាក្រោយ។

ជាន់ទី២ - កាលណាដើរទៅលេងទីកន្លែងណាៗមួយ តាមខេត្តក្រៅ ដល់វិលមកវិញរើសយកដីមួយដុំ មកកាន់ក្ដាប់ទុកក្នុងបាទដៃ

ព្យាយាមរឭកនឹកដល់ទីកន្លែងនោះ ទាល់តែឃើញរូបភាពទីកន្លែងនោះជាប់នឹងភ្នែក ស្ទើរតែទៅជាឧគ្គហនិមិត្រ ។

ជាន់ទី៣ - យករបស់អ្វីមួយ ដែលជារបស់មកពីទីឯទៀត ដែលយើងមិនធ្លាប់ឃើញសោះ គ្រាន់តែដឹងរឿងខ្លះ ឧបមាដូចកន្សែងជូតមុខមួយបានមកពីស្រុកអង់គ្លេស ដែលយើងពុំស្គាល់ស្រុកនោះសោះ គ្រាន់តែដឹងតាមសៀវភៅ ឬដឹងដោយគេនិយាយឲ្យស្តាប់ គេឲ្យយកកន្សែងនោះមកកាន់ទុកនៅដៃ រួចព្យាយាមនឹកដល់ប្រទេសអង់គ្លេសនោះ ទាល់តែប្រើមនោគតិសំឡឹងមើលទៅឃើញដូចជាខ្លួននៅក្នុងស្រុកនោះ ។

ជាន់ទី៤ - យករបស់អ្វីដែលបានមកពីទីកន្លែង ដែលយើងមិនស្គាល់មិនដែលឮនិយាយសោះនោះ មកកាន់ទុករួចព្យាយាមនឹកថារបស់នេះមកពីទីកន្លែងណា។

ជាន់ទី៥ - បើអាចនឹងធ្វើបាន ល្បងរើសយករបស់ដែលគេចោលដោយយើងមិនស្គាល់រូបរាងឈ្មោះម្ចាស់របស់នោះសោះ ដូចជាកន្ទុយបារីសំបកឈើគូសឬសែតក្តី យកមកកាន់រួចព្យាយាមនឹករកម្ចាស់របស់នោះតើមាននិស្ស័យចិត្តថ្លើមយ៉ាងណា មានរបររកស៊ីធ្វើការអ្វី ក្នុងវេលានេះកំពុងធ្វើអ្វី ។ល។

តាមវិធីដូចអធិប្បាយមកនេះ នឹងឃើញថាមនោគតិជាគ្រឿងជួយយ៉ាងសំខាន់ បើយើងហាត់ហ្វឹកហ្វឺនញឹកញាប់ហើយ ក្រសែដែលជាប់នៅនឹងរបស់នោះឯង នឹងធ្វើឲ្យមនោគតិរបស់យើងដឹងឃើញច្បាស់ឡើងទាល់តែត្រូវតាមសេចក្តីដ៏ពិតប្រាកដជាបំផុតនោះ បារាំងបានប្រើវិជ្ជានេះចាប់ចោរបានខ្លះ ក្នុងករណីហេតុដែលហួសវិស័យនឹងស្គាល់ខ្លួនចោរនោះបាន ដោយរបស់ដែលចោរលួចនោះវាចោលនៅទីនីមួយៗ គេយករបស់នោះមកឲ្យអ្នកចេះស្ទាត់ក្នុងវិជ្ជានេះធ្វើល្បងមើល បើអ្នកនោះប្រាប់ចំពោះឈ្មោះណា គេហៅឈ្មោះនោះមកពិចារណាសួរ តែដោយសេចក្តីឆ្លាត

របស់អ្នកសួរយកចម្លើយផងទើបបាន ជួនកាលក៏ត្រូវដោយចោរឆ្លើយទទួលសារភាព ឬក៏ឲ្យមានជាពិរុទ្ធម្យ៉ាងៗចូលក្នុងផ្លូវច្បាប់នាំឲ្យជម្រះរកតទៅទៀតបាន ។

ក្នុងវិធីទី ២ ការដែលឲ្យសំឡឹងមើលកែវនោះ គឺអាបោកសិណរបស់យើងនេះឯង តាមបុរាណគេប្រើសំឡឹងមើលទឹក ត្រង់កែវនេះជាវិធីថ្មីដោយបារាំងទើបគិតឡើងជាន់ក្រោយ ដែលជាប្រាកដនោះ របស់អ្វីដែលឆ្លុះមើលឃើញស្រមោលបាន ក៏ប្រើបានទាំងអស់ តាមប្រទេសដែលធ្លាប់ប្រើក្នុងឥឡូវនេះ ពួកអេស៊ិប្ត៍នឹងឥណ្ឌៀនៅប្រើទឹកជាដាក់ក្នុងពែងពួកអាហ្វ្រិគប្រើមើលទឹកក្នុងអណ្តូង ពួកនូវវែលសេឡង់ប្រើមើលឈាមសត្វ ឯពួកឱរុបយល់ឃើញថាហាត់សំឡឹងមើលកែវរហ័សជាបំផុត។

វិធីហាត់គេទុកបែបដូចមានតទៅ :

១ - ឲ្យរកទីកន្លែងបន្ទប់ដែលស្ងាត់ គ្មានមនុស្សទៅធ្វើឲ្យរំខានបានក្នុងបន្ទប់នោះកុំឲ្យមានរូបភាពអ្វីៗឲ្យសោះ ហើយកុំឲ្យក្តៅស្អុះពេកកុំឲ្យមានពន្លឺខ្លាំង កុំឲ្យងងឹតពេក ពន្លឺនោះឲ្យមាននៅខាងក្រោយ កុំឲ្យមាននៅខាងមុខ ។

២ - របស់ដែលនឹងសំឡឹងមើលនោះ ជាដុំកែវឬកែវធម្មតាមានទឹកក្នុងនោះក៏បាន តែត្រូវឲ្យមានកំណាក់សំពត់ឬក្រដាសពណ៌ខ្មៅរងខាងក្រោម ។

៣ - ហាមមិនឲ្យហាត់ធ្វើក្នុងវេលាដែលទើបបរិភោគអាហាររួចត្រូវបង្អង់ឲ្យអាហាររលាយសិន ។

៤ - ឲ្យអង្គុយតាមសម្រួលដែលស្រួលបំផុត រួចហើយសំឡឹងមើលក្នុងដុំកែវឬពែងទឹកនោះ កុំមើលខាងក្រៅរបស់នោះ កុំសំឡឹងមើលឲ្យហួសកម្លាំងភ្នែក មើលតាមតែប្រក្រតីដែលយើងធ្លាប់មើល ដែលជា

សំខាន់បំផុត គឺសមាធិដម្កល់ចិត្តឲ្យនឹងនៅក្នុងដុំកែវឬក្នុងពែងទឹកនោះកុំឲ្យនឹកដល់របស់អ្វីឲ្យសោះ ។

៥ - ក្នុងគ្រាដម្បូងឲ្យអង្គុយសំឡឹងត្រឹម ១៥នាទី រួចទុកកែវឬពែងនោះក្នុងទីងងឹត កុំឲ្យមានមនុស្សទៅប៉ះពាល់ ដល់ថ្ងៃស្អែកឡើងឲ្យអង្គុយក្នុងវេលាពេលដូចថ្ងៃមុន ត្រូវថែមវេលាបាន ៥នាទីឡើងទៀត ជារាល់ថ្ងៃទាល់តែដល់ ១ម៉ោង កុំឲ្យហួសពី១ម៉ោងឡើយ។ ដែលធ្វើនេះក្នុង១០ដងដម្បូង មុខជាមិនបានឃើញអ្វីទេ បើមានអ្នកណាធ្វើហើយបានឃើញក្នុងគ្រាទីពីរ ទុកជាអ្នកនោះធ្វើបានរហ័សណាស់ហើយ ។

៦ - បើកាលណាមើលឃើញក្នុងដុំកែវឬទឹកក្នុងពែងមានជាផ្សែងពពក ហើយមានចំណុចមូលប៉ុនចុងម្ទុលជាពណ៌សរិលរលក្នុងកណ្តាលពពកនោះ ក៏ទុកជាបានសម្រេចដូចប្រាថ្នាហើយ ក្នុងវេលាដែលបានសម្រេចនោះ ត្រូវរួមកម្លាំងចិត្តទាំងអស់វិលទៅរករឿងអ្វីមួយ ដែលត្រូវការចង់ដឹងនោះ ដូចជាចង់ដឹងថាបងប្អូនមិត្រសម្លាញ់យើងដែលនៅឆ្ងាយកំពុងធ្វើអ្វីក្នុងពេលនោះ តាមធម្មតានឹងមើលឃើញមួយរំពេច រួចពីនេះតទៅអនាគតនោះ នឹងមានហេតុការណ៍ដូចម្តេចៗក៏បាន ឬនឹងមើលហេតុការណ៍អ្វីៗនឹងដឹងដោយដុំកែវនេះជាដរាប ។

វិធីហាត់ដូចបានពោលមកនេះ នឹងឲ្យសម្រេចបានអម្បាលម៉ាណនោះ ពុំអាចទទួលខុសត្រូវទេ ព្រោះមិនដែលហាត់ធ្វើ គ្រាន់តែសរសេរតាមតម្រាដែលគួរជឿ តម្រានីមួយៗមានវិធីប្រដៅខុសគ្នា តែចេញមកពីគោលដ៏សំខាន់តែមួយ គឺឲ្យមានដួងចិត្តជាសមាធិ បើលោកអ្នកមើលសៀវភៅនេះ ឃើញមានហេតុផល គួរធ្វើល្បងមើលក៏ធ្វើបាន ឥតមានសេចក្តីអន្តរាយអ្វីដល់ខ្លួនឡើយ ។

តាមសេចក្តីដែលពណ៌នាមកហើយខាងដើមនោះ ជាវិធីបង្ហាត់ចិត្តឲ្យដឹង ឃើញ តែមនុស្សយើងជួនកាលបានឃើញដោយអស្ចារ្យដូចជា

២ - ៣ រឿងដែលមានមកនោះ ។ សេចក្តីដែលបរិយាយមកនេះជាវិធីដឹងនូវអតីតនឹងទំនាយនូវអនាគតបាន គ្រានេះល្បងពិចារណាតាមនិទ្ទេសដែលពោលទុកថា ចក្ខុមើលឃើញហួសវិស័យរបស់សាមញ្ញជនតទៅ ។

ក្នុងក្រុងប៉ារីស មានស្ត្រីចាស់ម្នាក់ឈ្មោះអល្សានដឺសីវៈ គ្រាន់តែឈ្មោះក៏ដឹងថាមានជាប់ពូជមកពីក្លិង្គ មានរបរជាអ្នកទាយ ស្ត្រីនេះបានទទួលសេចក្តីរាប់អានពីសភាអ្នកប្រាជ្ញវិទ្យាសាស្ត្រក្នុងក្រុងប៉ារីសៗ បានឲ្យប្រកាសនីយប័ត្រទុកជាសំគាល់ ដោយស្ត្រីនុ៎ះឯងអាចទាយទុកកាលក្នុងមហាសង្គ្រាម យ៉ាងល្អិតពិស្តារថា មហាសង្គ្រាមនឹងសម្រេចលើកលែងច្បាំងនៅថ្ងៃនោះៗ បារាំងសែសនឹងបានស៊ីញេសញ្ញាស្លាប់សឹកជាមួយអូទ្រិស៊ីនឹងអាល្លឺម៉ង់នៅថ្ងៃនោះៗ ផលនៃការសង្គ្រាមនឹងមានជាប្រការដូចម្តេចៗនោះ ឃើញត្រូវតាមទំនាយទាយ អ្នកតែងសៀវភៅនេះបានតាំងប្រស្នាសួរស្ត្រីនេះថា មនុស្សយើងអាចមើលធ្លុះកំផែងឬជញ្ជាំងឬគ្រឿងបិទបាំងផ្សេងៗបានឬទេ? ស្ត្រីនោះរ៉ាប់រងថា មនុស្សយើងអាចធ្វើដូច្នោះបានដោយពិត សូម្បីសត្វចំពួកខ្លះ ដូចជាស្រមោចក៏មានភ្នែកមើលលឃើញធ្លុះដូចគ្នា ។ ឯភ្នែកស្រមោចមើលឃើញធ្លុះនោះ បានល្បងយកស្ករខ្ទប់ រួចទុកនៅទីកន្លែងមួយ ដែលច្រមុះស្រមោចស្រង់ក្លិនមិនបាន ក្នុងវេលាមួយម៉ោងស្ករកញ្ចប់នោះពេលសុទ្ធតែស្រមោច បានត្រួចមើលតាមផ្លូវដែលវាមក ឃើញឡើងតាមជញ្ជាំងពីក្រោមផ្ទះមករោមស្ករនោះ ដល់ព្រឹកឡើងល្បងមើលទៀត បានយកកញ្ចប់ស្ករដាក់ក្នុងពែងរួចយកទឹកចាក់ក្នុងចាកទ្រពែង ហើយចាំមើលដើមផ្ទះដែលវាមកពីមុនតើវានឹងមកទៀតឬទេ ប្រហែលមួយម៉ោង ក៏មិនឃើញវាមក ចាំមើលនៅកន្លែងទុកស្ករពីរម៉ោងទៀត ក៏មិនឃើញមានស្រមោចដល់មួយមកជិតចានស្ករនោះសោះ។

ហេតុនេះ គួរគិតបើយើងប្រកាន់ថា ស្រមោចមានច្រមុះល្អ ស្រង់ក្លិនបាន បានជាថ្ងៃដម្បូងវាមករោមស៊ីស្ករបាន ចុះដល់ថ្ងៃទី២ ដែលយកស្ករទៅបណ្តែតលើទឹកនោះ ហេតុអ្វីក៏វាមិនមករោមទៀត ក្លិនស្ករដែលបណ្តែតទឹកនោះ នឹងបាត់ក្លិនក៏ទេ គួរតែស្រង់ក្លិនតាមមករកចាននោះទៀត ហេតុអ្វីក៏មិនឃើញមកដល់មួយសោះ បានជាថាបើរឿងនោះមិនសន្និដ្ឋានថាស្រមោចមានភ្នែកអាចមើលធ្លុះទីកំបាំងផ្សេងៗ បានទេ ក៏គ្មានអ្វីនឹងអធិប្បាយតទៀតឡើយ ។

ក្នុងសម័យនេះ មានវត្ថុដែលមនុស្សសាងឡើង សម្រាប់ធ្លុះមើលក្នុងខ្លួនមនុស្សជម្ងឺ ដូចជាមនុស្សដែលត្រូវគ្រាប់កាំភ្លើង ឬកើតវណរោគ (រោគរីងរៃ) ក្នុងខ្លួន គេយកគ្រឿងនេះធ្លុះមើលឃើញ ដឹងថាមានគ្រាប់ឬដំបៅនៅទីកន្លែងត្រង់ណាៗបាន ហើយគេអាចធ្លុះថតយករូបរោគនោះមកពិនិត្យមើលបានទៀត។

ឯភ្នែករបស់មនុស្ស ដែលនឹងមើលឃើញធ្លុះបាននោះ តាមតម្រាដែលបានប្រទះមក ឃើញពោលថា ជាថ្នាក់ខ្ពស់ជាងការសណ្តំខ្លួនឯងឲ្យលក់នោះទៀត គឺតោងសណ្តំខ្លួនឯងឲ្យបានស្ទាត់សិន ក្នុងវេលាដែលលក់ដោយសណ្តំនោះ ឲ្យមើលឃើញរបស់ផ្សេងៗបាន ដូចជាយល់សប្តិតែខុសនឹងសេចក្តីយល់សប្តិ ហេតុដែលឃើញដោយសណ្តំជារបស់ពិតព្រោះអាចមើលឃើញរបស់គ្រប់យ៉ាងតាមត្រូវការបាន មិនដូចសេចក្តីយល់សប្តិ ដែលយើងបង្គាប់បានដោយពិបាកនោះទេ បើស្ទាត់ដល់ទីនេះហើយ គ្រាក្រោយមិនបាច់សណ្តំខ្លួនឲ្យលក់ទេ អាចមើលឃើញដោយភ្នែកស្រស់ៗបាន ដូចគ្នានឹងសណ្តំចិត្តមនុស្សដទៃឲ្យលក់ហើយឲ្យស្តីនិយាយឬធ្វើអ្វីបានគ្រប់យ៉ាង កាលណាចេះស្ទាត់ប្រាកដហើយដល់ក្រោយមិនបាច់សណ្តំឲ្យលក់ទេ អាចបង្គាប់មនុស្សនៅកំពុងភ្ញាក់ ឲ្យធ្វើអ្វីៗបានទាំងអស់ ។

ដែលពិតនោះ ការដែលនឹងឲ្យមានទិព្វចក្ខុបានដល់ថ្នាក់នេះ ជារបស់ពិបាកណាស់ ក្នុងសម័យនេះមិនដែលប្រទះឃើញមនុស្សណាមានទិព្វចក្ខុដល់ថ្នាក់នេះសោះ ព្រោះមនុស្សក្នុងសម័យនេះនឹងមានវិបស្សនាញាណឲ្យពេញបរិបូណ៌ពុំបាននោះឯង ឯព្រះពុទ្ធជាម្ចាស់ ឬសាវករបស់ព្រះអង្គដែលបានសម្រេចវិបស្សនាញាណពេញបរិបូណ៌ ឆ្ងាយចាកកិលេសហើយនោះ អាចមានទិព្វចក្ខុជាប្រាកដពុំសង្ស័យឡើយ ។

តាមចំណែកក្នុងគម្ពីរវិសុទ្ធិមគ្គនោះ លោកបញ្ញត្តឲ្យប្រើអាលោកកសិណជាសំខាន់ ពោលគឺឲ្យចម្រើនឲ្យកើតពន្លឺភ្លឺទំលាយនូវសេចក្តីកំបាំងនឹងរបស់រាំងរាទាំងពួងចេញ ឲ្យភ្នែកអាចមើលឃើញធ្លុះរហូតដល់សត្វកំពុងចុតិ កំពុងកើតបាន ។

ឯលទ្ធិរបស់យោគី គេក៏មានដូច្នេះដែរ គេពោលទុកថាអ្នកដែលបានលុះទិព្វចក្ខុ អាចមើលឃើញចេតភូត កំពុងរត់ឆ្វៀលឆ្វាតចុះឡើងក្នុងលោក បើតាមន័យអត្ថាធិប្បាយរបស់ព្រះពុទ្ធឃោសាចារ្យនោះ មិនឃើញប្រាកដថា ប្រើទិព្វចក្ខុជាគ្រឿងធ្វើឲ្យដឹងអតីត អនាគតបាន ដូចយ៉ាងលទ្ធិរបស់យោគីនឹងបារាំងនោះឡើយ ។

†††††

††

†

# វិជ្ជាប្រការទី ៨

អាសវក្ខយញ្ញាណ

តាមនិទ្ទេសក្នុងវិជ្ជាប្រការទី៨នេះ មានសេចក្តីក្នុងធម្មវិភាគបរិច្ឆេទទី២ ថា "ដឹងច្បាស់តាមពិតប្រាកដថា នេះជាទុក្ខ នេះជាទុក្ខសមុទយនេះជាទុក្ខនិរោធ នេះជាទុក្ខនិរោធគាមិនីបដិបទា ទាំងនេះជាអាសវៈនេះជាហេតុកើតនៃអាសវៈ នេះជាហេតុរំលត់នៃអាសវៈ នេះជាផ្លូវទៅដល់សេចក្តីរលត់អាសវៈ កាលណាចេះដឹងឃើញដូច្នេះហើយ ចិត្តក៏ផុតចាកកាមាសវៈ ភវាសវៈ អវិជ្ជាសវៈ ដឹងច្បាស់ថាជាតិអស់ហើយ ព្រហ្មចរិយៈបាននៅរួចហើយ ករណីយកិច្ចបានធ្វើសម្រេចហើយ កិច្ចការផ្សេងៗដែលនឹងត្រូវធ្វើដូច្នេះតទៅទៀតនោះគ្មានឡើយ" ។

វិជ្ជាទី៨ នេះមិនបានអធិប្បាយទៀតទេ ព្រោះថាបើនឹងអធិប្បាយតោងវិលទៅរកចតុរារិយសច្ច ដែលមានសេចក្តីអធិប្បាយយ៉ាងប្រសើរដល់២ សៀវភៅហើយនោះ គឺសៀវភៅពុទ្ធប្រវត្តិរបស់សម្តេចព្រះមហាសមណៈ នឹងសៀវភៅ "ព្រះពុទ្ធត្រាស់ដឹងអ្វី" ដែលជាព្រះរាជនិពន្ធរបស់ព្រះបាទសម្រេចព្រះរាមាធិបតីទី ៦ តែងទុកមកហើយនោះ ។

ហេតុនេះនឹងអធិប្បាយឲ្យល្អជាងសៀវភៅនោះតទៅទៀតពុំបាន ។ ប្រការមួយទៀត អរិយសច្ច៤ ជាធម៌ដែលពុទ្ធសាសនិកជនយល់ចូលចិត្តរាល់គ្នាហើយ នឹងនាំយកមកអធិប្បាយទៀតក៏ពុំគួរ ។

ដើម្បីនឹងរួបរួម ឲ្យបានចូលចិត្តលក្ខណៈរបស់វិជ្ជា៨ ប្រការនេះឲ្យច្បាស់លាស់ឡើងតទៅនោះ សូមឲ្យលោកអ្នកមើលរឭកដល់សេចក្តីដែលបានពោលមកហើយខាងដើម ព្រោះវិជ្ជា ៨ ប្រការនេះបានរៀបរៀងតាមលំដាប់ទុកត្រឹមត្រូវណាស់ គឺមានវិបស្សនាញាណជាខាងដើមនឹងអាសវក្ខយញ្ញាណជាបរិយោសាន។ ថាបើបុគ្គលណាចង់រៀនវិជ្ជា៨ប្រការឲ្យសម្រេចនោះតោងមានចិត្តត្រង់ចំពោះ គឺចង់ចេះវិជ្ជានោះ ដើម្បីចង់ធ្វើ

ឲ្យអាសវៈអស់ទៅ មិនបានចង់ធ្វើគ្រាន់តែជាគ្រឿងប្រដាប់សម្រាប់ជំនួយជួយឲ្យអាសៈកំរើកឡើងនោះឡើយ ។

កាលដែលសម្តេចព្រះមហាសមណ ទ្រង់ប្រទានអធិប្បាយទុកថា "មិនធ្វើតែត្រឹមកិច្ចចេះដឹងប៉ុណ្ណោះទេ ត្រូវយោលយកសេចក្តីដែលចេះនោះមកជាឧបការៈ ធ្វើអាសវៈឲ្យអស់ទៅជាមួយផង ទើបចាត់ជាអង្គព្រះសម្មាសម្ពោធិញាណជាគួរណាស់" សេចក្តីនេះឃើញថាជាសេចក្តីត្រឹមត្រូវ រកទីតិះដៀលថាដូចម្តេចពុំបានឡើយ ព្រោះសេចក្តីចេះដឹងរបស់មនុស្សគ្រប់គ្នានឹងរកបាន តែនឹងអាស្រ័យសេចក្តីចេះដឹងតែម្យ៉ាង ធ្វើឲ្យបានល្អនោះពុំបានឡើយ តោងយកសេចក្តីចេះនោះមកប្រើតាមផ្លូវត្រឹមត្រូវផង បើអ្នកណាយកសេចក្តីដែលចេះនោះ ទៅប្រើដើម្បីឃើញតែប្រយោជន៍របស់ខ្លួន ធ្វើឲ្យខូចប្រយោជន៍របស់អ្នកដទៃនោះ ក៏ជាបាបខ្លាំងណាស់ គង់មានមួយថ្ងៃនឹងទទួលទោស ជាពិតប្រាកដពុំខានព្រោះធម៌របស់ព្រះពុទ្ធជាម្ចាស់គ្រប់ខ ប្រដៅឲ្យមនុស្សប្រព្រឹត្តខ្លួនឲ្យល្អឲ្យមានប្រយោជន៍ដល់ខ្លួន ហើយឲ្យមានដល់អ្នកដទៃផង យើងរាល់គ្នាគង់បានដឹងថា ព្រះពុទ្ធជាម្ចាស់ ព្រះអង្គយកព្រះទ័យទុកដាក់ក្នុងសេចក្តីនេះណាស់ បានជាមានព្រះពុទ្ធវាចាដែលជាខាងក្រោយបំផុតមុនស្តេចរំលត់ខន្ធចូលកាន់ព្រះនិព្វានទុកថា "អ្នកទាំងឡាយ ចូរញ៉ាំងកិច្ចការទាំងពួងឲ្យបានជាប្រយោជន៍ដល់ខ្លួន ហើយឲ្យបានជាប្រយោជន៍ដល់អ្នកដទៃ ឲ្យបានបរិបូណ៌ដោយសេចក្តីមិនប្រមាទនេះចុះ" ព្រះពុទ្ធវាចានេះ ជាទីចាប់ចិត្តនៃយើងដែលជាពុទ្ធសាសនិកជនគ្រប់គ្នា ។

# អវសានកថា

អំពីវិជ្ជាប្រាំបីប្រការនេះ លោកអ្នកមើលក៏បានមើលហើយ តាំងពីដើមដល់ចាប់ចុង ដូច្នោះសូមលោករំឭកឡើងវិញ ដល់សេចក្ដីដែលបានមើលមកហើយទាំងប៉ុន្មាននោះ រួចស្វែងរកខវិនិច្ឆ័យរបស់លោក តើមានសេចក្ដីយល់ឃើញដូចម្ដេច សៀវភៅនេះមិនបានបំណងប៉ងចង់នាំចិត្តលោកអ្នកមើល ឲ្យជឿក្នុងឥទ្ធិបាដិហារិយ៍នោះទេ ការដែលលោកនឹងជឿឬមិនជឿក៏មិនខូចប្រយោជន៍ឬបានប្រយោជន៍អ្វី ដល់អ្នកតែងនោះឡើយ បំណងក៏ពិតប្រាកដក្នុងការតែសៀវភៅនេះ គ្រាន់តែរើសយកគំនិតរបស់លោកអ្នកប្រាជ្ញមករួបរួមទុកហើយនឹងបំពេញថែមសេចក្ដីដែលអ្នក តែងបានគិតឃើញនោះផង ទុកសម្រាប់ជាផ្លូវជូនលោកអ្នកចេះធម៌ត្រិះរិះវិនិច្ឆ័យតទៅ ។

ឯវិទ្យាការក្នុងលោកនេះ តែងតែមានច្រើនប្រភេទ អ្នកណាសិក្សាផ្លូវលោក ក៏សរសើរថាផ្លូវនោះល្អជាធម្មតារបស់លោកមិនជាខុសអ្វីតែតែថាយើងមិនគួរនឹងយកវិជ្ជាការ ប្រភេទដែលយើងសិក្សាទៅសង្កត់សង្កិនវិជ្ជាប្រភេទឯទៀតនោះឡើយ ។ ឧបមាដូចយើងរៀនផ្លូវពេទ្យយើងក៏មានអំណាចសរសើរវិជ្ជាពេទ្យរបស់យើងថាល្អវិសេស សម្រាប់ជួយជីវិតមនុស្ស តែយើងមិនគួរនិយាយថាល្អជាងច្បាប់ ដែលជាវិជ្ជាសម្រាប់សម្រេចឲ្យកាត់ក្បាលមនុស្ស ឬល្អជាងវិជ្ជាធ្វើគ្រឿងយន្តដែលជាប្រដាប់សម្រាប់ធ្វើឲ្យមនុស្សដាច់ដៃជើងនោះឡើយ។ ក្នុងសម័យនេះច្រើនសិក្សាខាងគន្ថធុរៈ យើងក៏សរសើរថាគន្ថធុរៈរបស់យើងវិសេសដូចម្ដេចក៏បានតែកុំយកទៅនិយាយសង្កត់សង្កិនវិបស្សនាធុរៈថាជារបស់មិនពិត នោះឡើយ វិជ្ជាប្រភេទនីមួយៗតែងតែមានលក្ខណៈវិធីដែលរៀននឹងគុណប្រយោជន៍ផ្សេងៗពីគ្នា នឹងយកមកប្រៀបប្រដូចគ្នាឲ្យឃើញថាប្រភេទណាល្អជាងណាពុំបានឡើយ ។

វិបស្សនាធុរៈ ជាវិជ្ជាបង្វឹកបង្វើន ដុសខាត់ពត់ដួងចិត្ត បណ្តុះសមត្ថភាពឲ្យល្អ ដូចលោកអ្នកមើល បានមើលដឹងមកហើយថា ផ្លូវព្រះពុទ្ធសាសនារបស់យើងក្តី ផ្លូវអធ្យាត្មវិទ្យារបស់បារាំងក្តី លទ្ធិរបស់យោគីក្តី មានគោលត្រូវត្រង់ដូចគ្នាថា ដួងចិត្តរបស់មនុស្សដែលហាត់ហ្វឹកហ្វឺនល្អហើយ តែងតែមានអំណាច អាចធ្វើរបស់អ្វីៗដែលយើងមើលមិនឃើញដោយភ្នែកជាប្រក្រតីបាននោះឲ្យឃើញបាន ។ ពោលចំពោះតែព្រះពុទ្ធជាម្ចាស់របស់យើង យើងចេះដឹងមិនអស់ថា ព្រះអង្គជាឯកអគ្គមហាបុរសនោះតើព្រះអង្គបានធ្វើការបង្ហាត់ព្រះអង្គយ៉ាងណាខ្លះ បានជាព្រះអង្គអាចទូន្មានមនុស្សដទៃបានយ៉ាងល្អដល់ម្ល៉េះ ហេតុនេះយើងមិនត្រូវសង្ស័យថាព្រះអង្គមិនបានបង្ហាត់ព្រះអង្គឯងឲ្យបានយ៉ាងល្អបំផុត ឲ្យមានអំណាចដ៏វិសេសលើសជាងមនុស្សសាមញ្ញនោះឡើយ ។

ការប្រែប្រួលនៃកាលសម័យ តែងតែធ្វើឲ្យបុគ្គលផ្លាស់ប្តូរចិត្តនិយមវិជ្ជាផ្សេងៗទៅជាមួយផង កាលក្នុងសម័យព្រះពុទ្ធជាម្ចាស់ សេចក្តីចេះដឹងក្នុងផ្លូវចិត្តសាស្ត្រចម្រើនឡើងដល់ទីបំផុត រួចក៏ចុះថយបន្តិចៗមកដល់សម័យឥឡូវនេះ សេចក្តីចេះដឹងខាងផ្លូវវិទ្យាសាស្ត្រក៏ចម្រើនឡើងនឹងទុកថាដល់កំរិតបំផុតហើយក៏បាន ដោយមានអាកាសយានសម្រាប់ហោះមានកប៉ាល់មុជទឹកសម្រាប់មុជចុះទៅបាតសមុទ្រយ៉ាងជ្រៅ បានមានរទេះដើរក្នុងដី មានគ្រឿងវិទ្យុទោរលេខទោរសព្ទ គ្រឿងមើលផ្កាយគ្រឿងធ្វើទឹកឲ្យកក យើងឃើញគ្រប់ចំពូកហើយ មើលទៅខាងមុខទៀតគ្មានឃើញអ្វីជាវិសេសទៅទៀតឡើយ សេចក្តីចេះដឹងក្នុងផ្លូវវិទ្យាសាស្ត្ររបស់មនុស្សចម្រើនឡើងដល់ទីបំផុតហើយ សម័យនេះអាចនឹងផ្លាស់ប្តូរវិលទៅចម្រើនខាងផ្លូវចិត្តសាស្ត្រវិញក៏បាន ដ្បិតក្នុងវេលានេះ បារាំងកំពុងយកចិត្តទុកដាក់ស្រាវជ្រាវរកវិជ្ជាទាំងនេះច្រើនគ្នា ក្នុងជីវិតយើងអាចនឹងទាន់ឃើញវិជ្ជាចិត្តសាស្ត្រចម្រើនឡើងវិញ ដោយប្លែកចំឡែកម្តង

ទៀតក៏បាន ដោយមនុស្សកំពុងបង្ហាត់វិជ្ជា ៨ ប្រការនេះ ដូចកាលក្នុងសម័យរបស់ព្រះពុទ្ធជាម្ចាស់ខ្លះក៏សឹងថាបានដែរ ។

សៀវភៅវិជ្ជា ៨ ប្រការនេះ ប្រដូចជាព្រះស្តូបតូចៗដែលសាងទុកក្នុងព្រះពុទ្ធសាសនា ដោយដុំថ្មផ្សេងៗដែលបានព្យាយមស្វែងរកមកពីទីកន្លែងទាំងបួនទិសក្នុងលោកមកផ្សំគ្នារួបរួមទុកជាដុំមួយ ទំរាំតែនឹងបានសម្រេចជាអង្គព្រះស្តូបតូចនេះ អ្នកសាងបានយកកម្លាំងព្យាយាមទ្រាំទ្រខំកសាងរាប់ជាឆ្នាំៗទើបបានសម្រេច តែកម្លាំងទាំងប៉ុន្មានដែលអស់ទៅនោះ បានអន្តរធានបាត់ទៅ ដោយដឹងប្រាកដថាសៀវភៅ "វិជ្ជា ៨ ប្រការនេះ" ជាសៀវភៅមានមហាជន ចូលចិត្តជាច្រើន ទុកជាអាមិសបូជាក៏ជាផើលមួយដែលអ្នកតែងបានទទួលមកដល់ឥឡូវនេះ ។

ក្នុងទីបំផុតរបស់សៀវភៅវិជ្ជា ៨ ប្រការនេះ អ្នកតែងបានតាំងសេចក្តីប្រាថ្នាយ៉ាងពិតប្រាកដក្នុងចិត្ត ជូនលោកអ្នកមើលនឹងលោកអ្នកដែលមិនបានមើល សូមឲ្យបានទទួលនូវសេចក្តីសុខ សេចក្តីចម្រើនគ្រប់ៗគ្នាហើយសូមអនុញ្ញាតខ្ចីយកពាក្យរបស់ ស្វាមីមុក្តីចី ជាតិតណ្ហៀអ្នកតែងសៀវភៅ មនោមយិទ្ធិ មកពោលទុកក្នុងទីនេះ បីដូចជាពាក្យរបស់អ្នកតែងសៀវភៅថា :

សូមឲ្យអ្នកដែលមានជម្ងឺឈឺចាប់ទាំងប៉ុន្មាន ឲ្យបានជាស្រឡះពីជម្ងឺទាំងនោះ ឲ្យមានរាងកាយមាំមួនបរិបូណ៌ឡើងវិញ។

សូមឲ្យមនុស្សដែលទន់គ្មានកម្លាំង ឲ្យមានកម្លាំងមាំមួនឡើង។

សូមឲ្យមនុស្សដែលក្រខ្សត់ ឲ្យបានជាអ្នកមានសម្បត្តិមាំមួនឡើង ។

សូមឲ្យមនុស្សដែលមានសេចក្តីធុញថប់ ត្រឡបជាអ្នកមានព្យាយាមឡើង ។

សូមឲ្យមនុស្សដែលមានចិត្តអាក្រក់ ត្រឡប់ជាមនុស្សចិត្តមេត្តាយ៉ាងល្អឡើង ។

សូមឲ្យមនុស្សដែលត្រូវគេស្អប់ ត្រឡប់ជាមនុស្សមានគេស្រឡាញ់រាប់អានឡើង ។
សូមឲ្យមនុស្សដែលមានចិត្តប្រឡាក់ប្រឡូក ដោយមន្ទិលផ្សេងៗលាងមន្ទិលក្នុងខ្លួន ឲ្យបានជាមនុស្សបរិសុទ្ធិឡើង ។

**អវសាន**

(កំហុសរាប់ពាន់បង្កើតបានជាភាពជោគជ័យ
ភាពជោគជ័យណាដែលមិនមានកំហុសមិនមានឡើយ។)

**ដោយ ថៃ ប៊ុនឆាយ**